18K-CA080-東埔寨文：三寶佛學問答集-字.pdf 1 2019/8/1 下午 02:08:07

As this is a Dhamma text,
we request that it be treated with respect.
If you are finished with it,
please pass it on to others or
offer it to a monastery, school or public library.
Thanks for your co-operation.
**Namo Amitabha!**

《東埔寨文：三寶佛學問答集 Triratanavinicchaya》
財團法人佛陀教育基金會 印贈
Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Website: www.budaedu.org ; overseas@budaedu.org,
**This book is for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន
Printed in Taiwan
CA080

CA080 ត្រៃរត្នវិនិច្ឆ័យ Triratanavinicchaya

# ត្រៃរត្នវិនិច្ឆ័យ

ព្រះសមុហ៍ពុទ្ធញាណ ម៉ិញ ន៉ាត្រី
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត ក្រុងភ្នំពេញ

*បានអធិប្បាយរៀបរៀង*

តាមគម្ពីរទាំងឡាយមានគម្ពីរវិសុទ្ធិមគ្គជាដើម

ភ្នំពេញ
ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ
បោះពុម្ពចែកជាធម្មទាន

ព.ស. ២៥៦៣ គ.ស. ២០១៩

# ត្រៃរត្នវិនិច្ឆ័យ


ព្រះសមុហ៍ពុទ្ធញ្ញាណ **ម៉ិញ ន៉ាត្រី**

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត ក្រុងភ្នំពេញ


*បានអធិប្បាយរៀបរៀង*

តាមគម្ពីរទាំងឡាយមានគម្ពីរវិសុទ្ធិមគ្គជាដើម


**ភ្នំពេញ**

**ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ**

**បោះពុម្ពចែកជាធម្មទាន**

**ព.ស. ២៥៦៣** **គ.ស. ២០១៩**

# កថាមុខ

ចាប់ដើមអំពីកាលដែលយើងខ្ញុំ បានសេពគប់នឹងលោកអ្នកប្រាជ្ញទាំងឡាយ ហើយបានសន្ទនាកុសលផ្សេងៗរៀងរាបមក យើងខ្ញុំមានសោមនស្សជ្រះថ្លាចំពោះគុណព្រះរត្នត្រ័យពន់ពេក ហើយឧស្សាហ៍យកសៀវភៅធម៌ទាំងឡាយមានសៀវភៅគិហិប្បដិបត្តិជាដើម មកមើលរឿយៗ លុះមើលដល់ត្រង់រតនប្បណាម ក៏នឹកក្នុកឃើញថាតាមរបៀបខ្ញុំៗនេះ មានភិក្ខុសាមណេរ ឧបាសក ឧបាសិកា ដែលចេះដឹងសម្បូណ៌កុះករទូទៅទាំងកម្ពុជរដ្ឋដែរហើយ តែពុទ្ធបរិស័ទទាំងនោះ ទោះបីចេះចាំមាត់ស្ទូត្របានស្ទាត់ជំនាញក៏កម្រមានអ្នកធ្វៀវឆ្លាស យល់អត្ថរសនៃព្រះនាមនោះៗ ដោយពិស្តារបាន ព្រោះក្នុងផ្ទៃនៃព្រះគុណមួយៗ មានសេចក្តីជ្រាលជ្រៅក្រៃពេក ។ សម័យនេះជាកាលគួរឲ្យមានច្បាប់ពិស្តារទុកជាកែវសម្រាប់ចុះពង្រីកបំភ្លឺនូវគុណព្រះរតនត្រ័យ ដែលមានអាថ៌កំបាំងជ្រាលជ្រៅឲ្យភ្លឺស្វាង មានសេចក្តីរាក់ងាយយល់ឡើង ដើម្បីទុកជាទីសប្បាយនៃពុទ្ធមាមកជនអ្នកប្រាថ្នាសេចក្តីពិស្តារ ។

ថ្ងៃមួយ ខ្ញុំបានចូលទៅសន្ទនាអំពីរឿងនេះ ជាមួយនឹងលោកអាចារ្យ ម៉ិញ ន៉ាត្រី នៅវត្តនិរោធរង្សី សូមឲ្យលោករៀបរៀងធម៌នេះឲ្យលោកក៏មានសោមនស្សរីករាយ ទទួលរៀបរៀង ដោយសេចក្តីព្យាយាមដ៏ស្វិតស្វាញ ដរាបដល់បានចប់គុណព្រះរតនត្រ័យ ដោយសេចក្តី

ពិស្តារ ល្មមសមតាមសេចក្តីប្រាថ្នា ។

លុះចប់ហើយ ខ្ញុំបានយកទៅប្រគល់ឲ្យបណ្ណាគា ប៊ុត-នាង ឲ្យចាត់ចែង បោះពុម្ពផ្សាយ បណ្ណាគារ ប៊ុត-នាង ក៏បានទទួលភារៈដោយសេចក្តីស្មោះ-សរចាត់ការដរាបដល់បានសម្រេច ។ ក្នុងទីអវសាននេះ យើងខ្ញុំស្វាមី-ភរិ-យាសូមឧទ្ទិសផលនៃធម្មទាននេះជូនដល់បុព្វការីជនទាំងឡាយ មាន មាតាបិតាជាដើម សូមឲ្យលោកបានសម្រេចនូវត្រីពិធសម្បត្តិកុំបីឃ្លាត សូមចែករំលែកកុសលរាសីនេះ ជូនដល់អស់លោក-អ្នកសប្បុរសទាំង ឡាយ ឲ្យបានសម្រេចនូវឥដ្ឋមនុញ្ញផល តាមសេចក្តីប្រាថ្នារៀងៗខ្លួន!

ឧកញ៉ា ពិភក្តិជនា ប៉ោយ-ងិន

និងអ្នកស្រីស៊ីស័ក្តិ ជាភរិយា

ហេតុដំបូងដែលនាំឲ្យកើតសៀវភៅនេះឡើង ដោយខ្ញុំត្រិះរិះឃើញថា "ទំនៀមរបស់បោរាណកបណ្ឌិត តាំងអំពីសម័យព្រេងនាយមក, ព្រះគន្ថរចនាចារ្យទាំងឡាយ ដែលស្វែងរកឃើញនូវវិជ្ជាសម្បត្តិ បានដល់នូវត្រើយនៃវិជ្ជាហើយ លោកមិនព្រងើយកន្តើយលាក់សុំទុកនូវវិជ្ជាសម្បត្តិនោះចំពោះខ្លួនម្នាក់ឯងឡើយ លោកតែងចែករំលែកដល់ជនដទៃ ដោយការសម្តែងខ្លះ ការបង្រៀនខ្លះ ការចារឹកទុកជាក្បួនខ្នាតខ្លះ ទុកជាប្រទីបសម្រាប់បំភ្លឺផ្លូវប្រតិបត្តិដល់បច្ឆិមាជនតាសត្វទៅមិនឲ្យវង្វេងវេងវោងស្រពេចស្រពិលក្នុងធម្មប្បដិបទា អាត្មាអញក៏ជាអ្នកបានរៀនសូត្រនូវពុទ្ធសាសនវិជ្ជា ចេះដឹងល្មមសមគួរតាមកាលសម័យហើយ គួរណាស់តែចារឹកក្បួនខ្នាតអ្វីមួយ ទុកជាភស្តុតាងនៃការចេះដឹង ជាសណ្តាប់នៃអ្នកប្រាជ្ញ ជាបុរាណគតិ ជាបវេណីរបស់បណ្ឌិតទាំងឡាយ" ។ ស្នាមគំនិតនេះ ចេះតែប្រាកដឡើងៗ មិនរលុបរលាយទៅវិញ ។

គាប់ចួនថ្ងៃមួយ ជាឱកាសនាំឲ្យបំណងរបស់ខ្ញុំបានសម្រេច ទទួលលោកឧកញ៉ាពិភក្តិជនា ប៉ោយ-ងិន កាលនៅជាលេខានុការ ផុតលេខក្នុងក្រសួងរស៊ីដង់ម៉ែរីនៅឡើយបានចូលមកសន្ទនានឹងខ្ញុំ ដើម្បីឲ្យជួយរៀបធម៌នេះឡើង ជាដំណើរស្របចួបទៅលើពន្លកគំនិតរបស់ខ្ញុំដែលបម្រុងលូតលាស់ស្រាប់ ខ្ញុំក៏ទទួលរៀបរៀងដោយសោមនស្សដោយវីរិយភាព

ដ៏មុតមាំ ដរាបដល់បានសម្រេច ។

ក្នុងការដែលរៀបរៀងនេះ ខ្ញុំបានស្រង់យករតនប្បណាមទាំងបាលីសម្រាយក្នុងសៀវភៅគិហិប្បដិបត្តិទុកជាគោល ដើម្បីគោរពដល់ស្នាព្រះហស្តរបស់លោកអ្នកតែងដើមផង ដើម្បីតម្រូវអធ្យាស្រ័យរបស់អ្នកអាពធ-នាផង ហើយបានយកច្បាប់ផ្សេងៗ មានគម្ពីរវិសុទ្ធិមគ្គបាលី និងមហា-ពុទ្ធគុណសម្រាយបុរាណជាដើម មកទុកជាគោលនៃសេចក្តីអធិប្បាយ ។

ក្នុងផ្ទៃសៀវភៅនេះ ខ្ញុំរៀបរៀងជារបៀបពាក្យបុច្ឆា វិសជ្ជនា និងសេចក្តីអធិប្បាយ ដើម្បីរំលាយសេចក្តីងឿងឆ្ងល់របស់សិក្ខាកាមជន ។

អាស្រ័យរបៀបធម៌ដែលមានលក្ខណៈដូច្នេះ ទើបខ្ញុំកំណត់នាមថា **ត្រៃរត្នវិនិច្ឆ័យ** "វិនិច្ឆ័យអំពីគុណព្រះត្រៃរត្ន" ។

លុះរៀបរៀងចប់ហើយ ដើម្បីនឹងការពារមិនឲ្យមានសេចក្តីភ្ញាំងភ្ញាត់ ខ្ញុំបានយកទៅប្រគេន ព្រះតេជគុណព្រះសាក្យវង្ស ហួត-តាត និងព្រះតេជគុណ ព្រះពុទ្ធវង្ស សោម ឈុន សូមឲ្យលោកពិនិត្យផ្ទៀងផ្ទាត់ឲ្យថែមទៀត ព្រះតេជគុណទាំងពីរព្រះអង្គ ក៏មេត្តាអនុគ្រោះទទួលពិនិត្យឲ្យយល់ឃើញថាត្រឹមត្រូវតាមច្បាប់នោះៗហើយ ។ ខ្ញុំមានសេចក្តីត្រេកអរជាអនេក ចំពោះព្រះតេជគុណទាំងពីរព្រះអង្គ ដែលលោកមានសេចក្តីករុណាពិនិត្យផ្ទៀងផ្ទាត់ឲ្យដរាបបានសម្រេច ។

ក្នុងទីបំផុតនៃឧបត្តិកថានេះ ខ្ញុំសូមលើកធម្មបណ្ណាការនេះជូនដល់

បុព្វការីបុគ្គល មានមាតាបិតាគ្រូអាចារ្យជាដើម សូមឲ្យលោកបានសម្រេចនូវសេចក្ដីសុខសព្វប្រការ តាមសមគួរដល់សេចក្ដីប្រាថ្នា សូមចែករំលែកនូវបុញ្ញរាសីនេះដល់អស់លោកអ្នកជាសាធុជនទាំងឡាយ ព្រមទាំងសព្វសត្វទូទៅក្នុងអនន្តចក្រវាឡ សូមឲ្យបានសម្រេចនូវឥដ្ឋវិបុលផលរាល់ៗប្រាណកុំបីឃ្លាត!

**ចិរំ ឋិប្បតុ សទ្ធម្មោ**

**សុខិតា ហោន្តុ ចាណិនោ**

សូមឲ្យព្រះសទ្ធម្ម ធម៌ឧត្ដមរុងរឿងឆ្ងាយ

សូមឲ្យសត្វទាំងឡាយ សុខសប្បាយសព្វៗកាល !

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

ថ្ងៃចន្ទ ១០ កើតខែផល្គុន ឆ្នាំមមី ចត្វាស័ក

ព.ស. ២៤៨៥ (១៥ ខែម៉ារ្ស ឆ្នាំ ១៩៤៣)

ព្រះសមុហ៍ពុទ្ធញាណ ម-ង៉ាគ្រី

បញ្ជីធម៌ ទំព័រ


គុណព្រះរត្នត្រ័យ ........................................ ៥

សរណគមន៍ ........................................ ១២

ឧបត្តិហេតុនៃសរណគមន៍ ........................................ ១២

ប្រភេទនៃសរណគមន៍ ........................................ ១៦

វិធីដាច់សរណគមន៍ ........................................ ២១

ហេតុដែលសៅហ្មងសរណគមន៍ ........................................ ២២

ធម៌ជាហេតុឲ្យសរណគមន៍ខ្ជាប់ខ្ជួន ........................................ ២៣

អានិសង្សនៃសរណគមន៍ ........................................ ២៤

**ពុទ្ធរតនវិនិច្ឆ័យ** ........................................ ២៧

ពាក្យថា ពុទ្ធៈ ........................................ ២៧

សម្បទារបស់ព្រះពុទ្ធ ........................................ ២៨

ពុទ្ធការកធម៌ ........................................ ៣១

បារមីធម៌ ១០ ........................................ ៣២

ធម្មសមោធាន ៨ ប្រការ ........................................ ៣៩

ចរិយារបស់ពោធិសត្វ ........................................ ៤១

អធ្យាស្រ័យរបស់ពោធិសត្វ ........................................ ៤២

ទុក្ករកិរិយា ........................................ ៤៣

វិនិច្ឆ័យអំពីបទនមស្ការព្រះពុទ្ធ ........................................ ៤៨

អំពីមារ ៥ យ៉ាង ........................................ ៤៩

បញ្ជីធម៌ ទំព័រ


វិនិច្ឆ័យបទ នមស្សការព្រះពុទ្ធគ្រប់ត្រៃកាល ......................................៥២

**ព្រះពុទ្ធគុណ ១០ ព្រះនាម ..........................៥៥**

វិនិច្ឆ័យបទថា អរហំ ......................................................................៥៧

អំពីទ្រង់ឆ្ងាយចាកសឹកសត្រូវ ......................................៥៨

កិលេស ១៦ យ៉ាង ......................................................៦០

វាសនា ២ យ៉ាង ..........................................................៦៦

អំពីទ្រង់បំបាក់បង់នូវសំសារចក្រ ................................៦៧

អំពីទ្រង់គួរដល់គ្រឿងបូជាដ៏វិសេស ..........................៦៨

អំពីទ្រង់មិនសម្ងំធ្វើបាបក្នុងទីកំបាំង ............................៧០

វិនិច្ឆ័យបទថា សម្មាសម្ពុទ្ធោ ............................................................៧១

វិនិច្ឆ័យបទថា វិជ្ជាចរណសម្បន្នោ ...................................................៧៨

វិជ្ជា ៣ និងវិជ្ជា ៨ ......................................................៧៩

ចរណៈ ១៥ ...............................................................៨២

វិនិច្ឆ័យបទថា សុគតោ ...................................................................៨៦

អំពីទ្រង់មានដំណើរល្អ ...............................................៨៦

អំពីទ្រង់យាងទៅកាន់ទីដ៏ល្អ .........................................៨៧

អំពីទ្រង់យាងទៅដោយប្រពៃ .......................................៨៧

អំពីទ្រង់ត្រាស់តែវាចាដែលត្រូវ ....................................៨៨

វិនិច្ឆ័យបទថា លោកវិទូ ...................................................................៩០

បញ្ជីធម៌ ទំព័រ


អំពីសង្ខារលោក ....................................................៩០
អំពីសត្វលោក .........................................................៩៣
អំពីឱកាសលោក.......................................................៩៥
វិនិច្ឆ័យបទថា អនុត្តរោ ........................................................ ៩៩
អំពីសីលគុណ ..................................................... ១០០
អំពីសមាធិគុណ .................................................. ១០១
អំពីបញ្ញាគុណ...................................................... ១០១
អំពីវិមុត្តិគុណ...................................................... ១០២
អំពីវិមុត្តិញ្ញាណទស្សនគុណ ....................................១០៣
វិនិច្ឆ័យបទថា បុរិសទម្មសារថិ ...................................................... ១០៤
វិនិច្ឆ័យបទថា សត្ថា ទេវមនុស្សានំ ..............................................១០៨
អំពីទិដ្ឋធម្មិកប្រយោជន៍ ...........................................១០៩
អំពីសម្បរាយិកប្រយោជន៍ ....................................... ១១០
អំពីបរមត្ថប្រយោជន៍ .............................................. ១១២
វិនិច្ឆ័យបទថា ពុទ្ធោ ........................................................ ១១៦
វិនិច្ឆ័យបទថា ភគវា ........................................................ ១២១
អំពីទ្រង់មានកុសលធម៌ ........................................... ១២២
អំពីទ្រង់បំបាក់បង់នូវកិលេស ...................................១២៣
អំពីទ្រង់មានជោគ .................................................. ១២៥

បញ្ជីធម៌ ទំព័រ


អំពីទ្រង់ចែកនូវធម្មរតនៈ ........................................ ១២៦

អំពីទ្រង់គប់រកនូវវិហារធម៌ចំណែកល្អ ...................... ១២៦

អំពីទ្រង់ខ្ពាក់ចោលនូវតណ្ហាក្នុងភព ..........................១២៧

វិនិច្ឆ័យបទ ប្តេជ្ញាខ្លួន .......................................................១២៩

វិនិច្ឆ័យបទ ខមាទោស ព្រះពុទ្ធ ...........................................១៣២

អានិសង្សនៃការចម្រើនពុទ្ធានុស្សតិ ...........................១៣៤

**ធម្មរតនវិនិច្ឆ័យ** ..................................១៣៧

បរិយត្តិធម៌ ......................................................................១៣៧

អត្ថរបស់បរិយត្តិធម៌ ..............................................១៣៧

ភាសិត ៤ ........................................................... ១៣៨

អធិដ្ឋាន ២ ......................................................... ១៣៩

បដិបត្តិធម៌ ...................................................................... ១៤០

សីល ............................................................... ១៤០

សមាធិ ............................................................. ១៤២

បញ្ញា ...............................................................១៤៣

វិធីចម្រើនវិបស្សនាបញ្ញា ................................ ១៤៤

បដិវេធធម៌ ...................................................................... ១៥២

មគ្គ ៤ ............................................................. ១៥២

ផល ៤ ............................................................. ១៥៤

| បញ្ជីធម៌ | | ទំព័រ |
|---|---|---|
| | អធិប្បាយអំពីមគ្គនិងផលដោយសារុប្ប .................... | ១៥៥ |
| | និញ្វាន .................................................................... | ១៥៦ |
| | ព្រះនិញ្វានមានគុណគួរប្រាថ្នា .................................... | ១៥៩ |
| វិនិច្ឆ័យបទ | នមស្សការព្រះធម៌ .................................................. | ១៦៤ |
| វិនិច្ឆ័យបទ | នមស្សការព្រះធម៌គ្រប់ត្រៃកាល................................ | ១៦៧ |
| | **ព្រះធម្មគុណ ៦ ព្រះនាម** ....................... | ១៦៩ |
| វិនិច្ឆ័យបទថា | ស្វាក្ខាតោ ភគវតា ធម្មោ ........................................ | ១៧១ |
| | បរិយត្តិធម៌ឈ្មោះ ស្វាក្ខាតោ.................................... | ១៧១ |
| | លោកុត្តរធម៌ឈ្មោះ ស្វាក្ខាតោ ................................ | ១៧៧ |
| វិនិច្ឆ័យបទថា | សន្ទិដ្ឋិកោ ............................................................ | ១៧៩ |
| វិនិច្ឆ័យបទថា | អកាលិកោ.............................................................. | ១៨២ |
| វិនិច្ឆ័យបទថា | ឯហិបស្សិកោ ........................................................ | ១៨៥ |
| វិនិច្ឆ័យបទថា | ឱបនយិកោ ............................................................ | ១៨៨ |
| វិនិច្ឆ័យបទថា | បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ........................................ | ១៩១ |
| | ព្រះធម្មគុណទាក់ទងគ្នា .......................................... | ១៩២ |
| វិនិច្ឆ័យបទ | ខមាទោសព្រះធម៌ .................................................. | ១៩៤ |
| | ផលនៃការចម្រើនធម្មានុស្សតិ .................................. | ១៩៦ |
| | សង្ឃរតនវិនិច្ឆ័យ .................................................... | ១៩៩ |
| ពាក្យថា | សង្ឃ ........................................................................ | ១៩៩ |

| បញ្ជីធម៌ | ទំព័រ |
|---|---|


សម្មតិសង្ឃ .......................................... ២០២

អរិយសង្ឃ .......................................... ២០២

សោតាបន្ន .......................................... ២០៣

សកទាគាមី .......................................... ២០៤

អនាគាមី .......................................... ២០៤

អរហន្ត .......................................... ២០៦

គុណរបស់ព្រះអរហន្ត .......................................... ២០៩

វិនិច្ឆ័យបទ នមស្សការព្រះសង្ឃ .......................................... ២១២

វិនិច្ឆ័យបទ នមស្សការព្រះសង្ឃគ្រប់ត្រៃកាល .......................................... ២១៥

ព្រះសង្ឃគុណ ៩ .......................................... ២១៨

វិនិច្ឆ័យបទថា សុប្បដិបន្នោ .......................................... ២២០

វិនិច្ឆ័យបទថា ឧជុប្បដិបន្នោ .......................................... ២២៣

កាមសុខល្លិកានុយោគ .......................................... ២២៤

អត្តកិលមថានុយោគ .......................................... ២២៥

មជ្ឈិមាបដិបទា .......................................... ២២៧

វិនិច្ឆ័យបទថា ញាយប្បដិបន្នោ .......................................... ២២៩

វិនិច្ឆ័យបទថា សាមីចិប្បដិបន្នោ .......................................... ២៣១

វិនិច្ឆ័យបទថា អាហុនេយ្យោ .......................................... ២៣៣

វិនិច្ឆ័យបទថា បាហុនេយ្យោ .......................................... ២៣៥

បញ្ជីធម៌ ទំព័រ


វិនិច្ឆ័យបទថា ទក្ខិណេយ្យោ ........ ២៣៨

អង្គរបស់ទាយក ៣ ប្រការ ........ ២៣៩

អង្គរបស់បដិគ្គាហក ៣ ប្រការ ........ ២៣៩

ទក្ខិណាវិសុទ្ធិ ៤ ប្រការ ........ ២៤២

វិនិច្ឆ័យបទថា អញ្ជលិករណីយោ ........ ២៤៤

វិនិច្ឆ័យបទថា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ........ ២៤៧

វិនិច្ឆ័យបទ ខមាទោសព្រះសង្ឃ ........ ២៥៣

អានិសង្សនៃការចម្រើនសង្ឃានុស្សតិ ........ ២៥៧

# នមត្ថុ  រតនត្តយស្ស

## “សូមនមស្សការថ្វាយបង្គំចំពោះព្រះរត្នត្រៃ”

បណ្ដាសព្វសត្វទាំងអស់ក្នុងលោក ទោះជាតិណាសាសន៍ណាក៏ដោយ សុទ្ធសឹងប្រាថ្នាសេចក្ដីសុខ សេចក្ដីចម្រើន តែងខ្ពើមទុក្ខស្រឡាញ់សុខ ខ្ពើមអាក្រក់ស្រឡាញ់ល្អ ខ្ពើមក្រស្រឡាញ់មាន ខ្ពើមស្លាប់ស្រឡាញ់រស់ ខ្ពើមទោសស្រឡាញ់គុណ តែពុំអាចនឹងឲ្យសម្រេចតាមបំណងទាំងនោះបាន ម្ល៉ោះហើយក៏ខំស្វះស្វែង រកវត្ថុជាទីពឹងពំនាក់ដែលសម្គាល់ឃើញថាមានមហានុភាព ដើម្បីឲ្យបានសម្រេចតាមបំណងនោះៗតែសព្វប្រាណ ។

ហេតុនេះហើយបានជាមនុស្សយើងមានលទ្ធិសាសនា ទំនៀមទម្លាប់ផ្សេងៗ គ្នា សូម្បីតែអ្នកដែលប្រកាន់សាសន៍តែមួយជាមួយគ្នា ក៏គង់បែកលទ្ធិផ្សេងៗ គ្នាជាច្រើននិកាយតទៅទៀត ។

អ្នកដែលស្វែងរកទីពឹងទាំងអស់នោះ ចួនកាលក៏ប្រទះទៅលើទីពឹងឯក ឧត្ដម ក្សេមក្សាន្ត មានទំនងអាចនឹងជួយបំបាត់ទុក្ខទោសគ្រោះថ្នាក់ទាំងនោះសមតាមបំណងបាន ចួនកាលក៏ពានពារទៅលើទីពឹងដែលរីងរិតតែនាំបណ្ដាលឲ្យបានទទួលទុក្ខទោសគ្រោះថ្នាក់ទៅវិញក៏មាន ។

កាលបើដូច្នេះ តើវត្ថុណាដែលជាទីពឹងចម្បងបណ្ដាច់ក្នុងលោក?-វត្ថុដែលជាទីពឹង ចម្បង បណ្ដាច់ ក្នុងលោកនោះ មានតែព្រះរត្នត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនេះហើយដែលជាអគ្គសរណគមន៍ឧត្តម បំផុតរបស់សត្វលោក រកសរណវត្ថុដទៃប្រៀបផ្ទឹមស្មើគ្មាន ព្រោះជាវត្ថុអាចធ្វើឲ្យសម្រេចបរមត្ថប្រយោជន៍ដល់សត្វបាន ។

ប្រសិនបើមានពាក្យសួរថា ក្នុងទីនេះឃើញថាត្រូវយកព្រះរត្នត្រ័យជាទីពឹងទីរឭក បើដូច្នោះមិនជាទំនាស់នឹងពាក្យថា **អត្តា ហិ អត្តនោ នាថោ** "ខ្លួនទីពឹងខ្លួន" ទៅហើយឬ?- មិនជាទំនាស់គ្នាទេ ពាក្យទាំងពីរម៉ាត់នេះមានសេចក្តីរួមគ្នាតែមួយ គឺលោកប្រដៅថាកិច្ចដែលកាន់យកព្រះរត្នត្រ័យជាទីពឹងទីរឭកក្តី កិច្ចដែលធ្វើអំពើកុសលណាមួយ មានរក្សាសីលជាដើមក្តី ត្រូវធ្វើដោយខ្លួនឯង មិនត្រូវជួលឬពឹងអ្នកដទៃឲ្យកាន់ ឬឲ្យធ្វើជំនួសខ្លួន ហើយខ្លួនឯងនៅស្ងៀមព្រងើយ លែងអើពើនឹងព្រះរត្នត្រ័យឬនឹងកុសលណាមួយសោះ ដោយអាងថា គេធ្វើហើយខ្លួនចាំបាច់ធ្វើអ្វីទៀត ហើយទន្ទឹងចាំយកសម្បត្តិសួគ៌ សម្បត្តិនិព្វានតែម្តងនោះទេ ទោះបីទន្ទឹងរង់ចាំអស់សែនអសង្ខេយ្យជាតិផង ក៏មិនបានសម្រេចដែរ ។

សូមទាញឧទាហរណ៍មកបញ្ជាក់ឲ្យឃើញថា ប្រសិនបើយើងជួលឬពឹងគេឲ្យកាន់យកព្រះរត្នត្រ័យជាទីពឹង ឬឲ្យប្រព្រឹត្តសុចរិតមានរក្សាសីល ធ្វើសមាធិជាដើមជំនួសខ្លួន តើការស្ងប់រម្ងាប់កិលេសណាមួយមានដល់យើងផងទេ? មិនមានទេ បើមិនមានដូច្នេះហើយ ម្តេចឡើយនឹងឲ្យឈ្មោះថា ធ្វើទីពឹងដើម្បីខ្លួនបាន? នឹងឲ្យឈ្មោះថា យកព្រះរត្នត្រ័យ

ជាទីពឹងពំនាក់បាន ? លុះតែកាន់យកព្រះរត្នត្រ័យជាទីពឹងឬធ្វើកុសលសុចរិតដោយចិត្តរបស់ខ្លួន ទើបឈ្មោះថា "ខ្លួនជាទីពឹងខ្លួន" ដោយពិត ។ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទាំង ៣ នេះ បានជាមាននាមថា រតនៈ ព្រោះជាគ្រឿងញុំាងសត្វឲ្យរីករាយបាន ឲ្យសម្រេចប្រយោជន៍បាន ទាំងជាវត្ថុមានតម្លៃថ្លៃថ្លាបំផុត លើសលែងរតនវត្ថុដទៃ(១) ដែលមានវិញ្ញាណនិងឥតវិញ្ញាណនៅក្នុងលោកផងទៀត ។

ព្រះរត្នត្រ័យទាំង ៣ នេះ កើតមានឡើងព្រមគ្នាតែម្តងក៏ទេ គឺព្រះធម៌កើតមុន ព្រះពុទ្ធកើតបន្ទាប់ ព្រះសង្ឃកើតក្រោយ ព្រោះថាព្រះធម៌ជាសភាពឥតរូបមាននៅជានិច្ចជាធម្មតា ដូចជាខ្យល់មាននៅពេញអាកាសសព្វកាលវេលា តែឥតមាននរណាស្គាល់ លុះត្រាតែព្រះពុទ្ធជាអ្នកប្រាជ្ញធំលើសលែងប្រាជ្ញនានាកើតឡើងក្នុងលោក ទើបទ្រង់ត្រាស់សម្តែងបង្ហាញប្រាប់សត្វឲ្យដឹងនូវព្រះធម៌ថាជាវត្ថុមានតម្លៃ លុះសត្វបានដឹងថាជាវត្ថុមានតម្លៃដូច្នោះហើយ ក៏សូមទទួលយកមករក្សាផ្ទាល់ខ្លួន តាមតម្រាប់តម្រាយព្រះពុទ្ធតាមកម្លាំងឧបនិស្ស័យរបស់ខ្លួន ។

---

(១) ពាក្យថារតនវត្ថុដទៃនេះ បានដល់រតនវត្ថុសម្រាប់ស្តេចចក្រ មាន ៧ ប្រការគឺ ចក្ករតនៈ ចក្រកែវ ១ ហត្ថិរតនៈ ដំរីកែវ ១ អស្សរតនៈ សេះកែវ ១ មណិរតនៈ កែវមណី ១ ឥត្ថីរតនៈ ស្ត្រីកែវ ១ គហបតិរតនៈ គហបតីកែវ ១ បរិនាយករតនៈ មេទ័ពកែវ ១ ។ វត្ថុទាំង ៧ ប្រការនេះ បានឈ្មោះថា រតនៈ ព្រោះអាចញុំាងព្រះទ័យរបស់ស្តេចចក្រឲ្យរីករាយ ឲ្យសម្រេចសេចក្តីប្រាថ្នាតាមនាទីរបស់ខ្លួនបាន ។

អាស្រ័យហេតុដែលកើតមានមុនក្រោយជាងគ្នាយ៉ាងនេះ ទើបបានជាព្រះរត្នត្រ័យទាំង ៣ នេះ មានធំតូចជាងគ្នាតាមលំដាប់ដែរ គឺព្រះធម៌ធំជាងព្រះពុទ្ធ តូចជាងព្រះធម៌ សមដោយបាលីថា **សទ្ធម្មោ គរុកាតព្វោ** "ព្រះពុទ្ធទ្រង់គោរពនូវព្រះធម៌" ។ ឯព្រះសង្ឃតូចជាងព្រះពុទ្ធនិងព្រះធម៌ទៅទៀត ព្រោះព្រះសង្ឃកើតអំពីព្រះពុទ្ធនិងព្រះធម៌ ។

ព្រះរត្នត្រ័យទាំង ៣ នេះ ជាបច្ច័យអាស្រ័យទាក់ទងគ្នាទៅវិញទៅមក លះបង់គ្នាពុំបាន ប្រសិនបើខ្វះណាមួយៗហើយ នឹងជាហេតុនាំឲ្យវិនាសប្រយោជន៍របស់ពួកសត្វជាអនេកពុំខាន ព្រោះថា បើខ្វះព្រះធម៌ហើយ ព្រះពុទ្ធក៏មិនមាន បើព្រះពុទ្ធមិនមានហើយ សត្វលោកនឹងស្គាល់ផ្លូវសួគ៌និព្វានដូចម្ដេចបាន? ទាំងព្រះសង្ឃសោតក៏មិនមានទៀត បើព្រះសង្ឃមិនមានហើយ នរណានឹងអាចរក្សាព្រះពុទ្ធសាសនាឲ្យគង់ទ្រង់ជរាបដល់មកសព្វថ្ងៃនេះបាន? បើគ្មានពុទ្ធសាសនាហើយ សត្វសព្វថ្ងៃនឹងប្រព្រឹត្តឲ្យត្រឹមត្រូវជាផ្លូវនៃសេចក្ដីសុខស្ងប់និងវិមុត្តិរសដូចម្ដេចបាន?

ហេតុនោះបានជាថាព្រះរត្នត្រ័យទាំង ៣ នេះតែងអាស្រ័យទាក់ទងគ្នាទៅវិញទៅមក លះបង់គ្នាពុំបាន ។

បើសម្ដែងដោយអានិសង្សនៃការបូជា[១] វិញ លោកថាបូជាព្រះ

---

(១) ពាក្យថាបូជា ប្រែថា ប្រគល់ឲ្យ ប្រគេន ថ្វាយ ប្រព្រឹត្តតាម ។ ការបូជាព្រះរត្នត្រ័យ ដែលមានញែកអានិសង្សជាប់មុខដោយឡែកដូច្នេះ គ្រាន់តែជាប្រធាននៃទេសនាទេ ព្រោះបូជាត្រឹមតែព្រះពុទ្ធប៉ុណ្ណោះ ក៏គង់ឲ្យអានិសង្សទាំង ៣ យ៉ាងបានដែរ ព្រះធម៌ព្រះសង្ឃទៀតក៏ដូចគ្នា ។

ពុទ្ធមានតេជះច្រើន បូជាព្រះធម៌មានបញ្ញាច្រើន បូជាព្រះសង្ឃមានទ្រព្យធនច្រើន ។

ប្រសិនបើមានពាក្យសួរថា ពាក្យទាំងពីរម៉ាត់ខាងដើមនិងខាងចុងល្មមស្តាប់បានហើយ ចុះពាក្យថា បូជាព្រះធម៌មានបញ្ញាច្រើននោះ តើត្រូវបូជាដូចម្តេច?

ត្រូវឆ្លើយថា : ពាក្យថាបូជាៗ ក្នុងទីនេះ បានដល់ការរៀនធម៌ដោយគោរព ដោយសេចក្តីពិនិត្យពិច័យឲ្យជាក់លាក់ត្រាតែចេះចាំប្រាកដស្ទាត់ជំនាញ ហើយប្រតិបត្តិតាម កាន់តាម ទើបឈ្មោះថាបូជាព្រះធម៌ ។

មានព្រាហ្មណ៍ម្នាក់ក្រាបទូលសួរព្រះសព្វញ្ញុពុទ្ធថា ព្រះធម៌គ្មានរូប ការបូជាព្រះធម៌ត្រូវបូជាដូចម្តេច? ព្រះបរមសាស្តាទ្រង់ត្រាស់តបថា បូជាដល់លោកអ្នកចេះដឹងធម៌ច្រើន ឬដល់អ្នកសម្តែងធម៌ ឈ្មោះថាបូជាព្រះធម៌ ។

## គុណរបស់ព្រះរត្នត្រ័យ

បើសម្តែងដោយគុណវិញ ព្រះរត្នត្រ័យទាំង ៣ នេះ មានគុណឥតបើបើនឹងថ្លឹងថ្លែងប្រៀបធៀបបាន ។ សូមលើកយកតែគុណព្រះពុទ្ធរត្នមួយមកសម្តែងល្មមជានិទស្សនៈ ដើម្បីឲ្យឃើញជាកស្តុតាងដូចសេចក្តីតទៅនេះ

ព្រះពុទ្ធមួយព្រះអង្គៗ ប្រកបដោយគុណច្រើនពន់ពេក អនេកអនន្ត ឥតឧបមា សូម្បីតែព្រះពុទ្ធដូចគ្នា ដែលបានត្រាស់ឡើងក្នុង

លោក ចាប់ដើមអំពីពេលត្រាស់ដឹងហើយ ទៅទល់នឹងពេលបរិនិព្វាន ទ្រង់សម្តែងតែគុណព្រះពុទ្ធមួយព្រះអង្គប៉ុណ្ណោះ ក៏ពុំអាចនឹងពណ៌នាឲ្យអស់បានឡើយ សមដោយពាក្យដែលព្រះពុទ្ធរក្ខិតត្ថេរប្រៀបទុកថា៖

**សហស្សសីសោបិ ចេ ចោសោ សីសេសីសេ សតំមុខា**

**មុខេមុខេ សតំជិវ្ហា ជីវិកាបេ្បា មហិទ្ធិកោ**

**ជ សក្កោតិ ច វណ្ណេតុំ ជិស្សេសំ សត្ថុនោ គុណំ**

"ប្រសិនបើមានបុរសណាមួយ មានក្បាលមួយពាន់ ក្នុងក្បាលមួយៗ មានមាត់ ១ រយៗ ក្នុងមាត់មួយៗ មានអណ្តាត ១ រយៗ មានអាយុមួយកប្ប មានឫទ្ធិច្រើន (ជាអ្នកសរសើរគុណព្រះពុទ្ធទាំងយប់ទាំងថ្ងៃ ដរាបដល់អស់អាយុប៉ុណ្ណោះ) ក៏ពុំអាចនឹងពណ៌នាគុណ ព្រះសាស្តាឲ្យអស់មិនឲ្យសេសសល់បានឡើយ" ។

ប៉ុន្តែបើប្រមូលយកតែគុណដែលជាប្រធាន នៃគុណទាំងនោះមកពណ៌នាដោយរួបរួម មានត្រឹម ៣ យ៉ាងគឺ បញ្ញាគុណ ១ វិសុទ្ធិគុណ ១ ករុណាគុណ ១ ។

**បញ្ញាគុណ** បានដល់សព្វញ្ញុតញ្ញាណ ដែលមុតដូចព្រះខ័នពេជ្ររបស់ស្តេចចក្រពត្តិអាចកាត់ពន្ធះអវិជ្ជាតណ្ហា ទ្រង់ជ្រាបច្បាស់នូវញេយ្យធម៌ទាំងពួង ទោះបីជាធម៌មានអត្ថល្អិតជ្រាលជ្រៅសុខុមគម្ភីរភាពយ៉ាងណា ក៏ទ្រង់ត្រាស់ដឹងទាំងអស់ ឥតមានទើសទាល់សល់ចំពាក់ កំបាំង

នឹងញាណញេយ្យរបស់ព្រះអង្គឡើយ ។

**វិសុទ្ធិគុណ** បានដល់ព្រះទ័យដ៏បរិសុទ្ធស្អាតផូរផង់ឥតប្រឡាក់ប្រឡូសដោយមន្ទិលគឺកិលេស[១] បាបធម៌សព្វយ៉ាង សូម្បីកិលេសល្អិតយ៉ាងណា ក៏ឥតមានសេសសល់ក្នុងព្រះទ័យព្រះអង្គឡើយ ។

**ករុណាគុណ** បានដល់សេចក្ដីប្រណីអាសូរសត្វសាធារណ៍ខំបំពេញពុទ្ធការកធម៌រាប់កប្បជាអនេកមិនអើពើនឹងសេចក្ដីទុក្ខលំបាក ដរាបដល់បានត្រាស់ដឹងហើយទៀត ក៏ទ្រង់ធ្វើពុទ្ធដំណើរទៅកាន់ស្រុកតូចធំនិគមជនបទនានាដោយឥតមានធុញទ្រាន់ ដើម្បីប្រទានធម៌ទេសនាដល់ពួកសត្វ ឥតបេះរើសមុខថាមានទ្រព្យសម្បត្តិឬឥតទ្រព្យសម្បត្តិ មានជាតិត្រកូលឧត្តុង្គឧត្តមខ្ពង់ខ្ពស់ឬថោកទាបឡើយ ។

ព្រះពុទ្ធត្រឹមតែមួយព្រះអង្គប៉ុណ្ណោះ ទ្រង់មានព្រះគុណដ៏ខ្ពង់ខ្ពស់រកទីបំផុតមិនឃើញម៉្លេះទៅហើយ ចំណង់បើរួបរួមគុណព្រះធម៌និងព្រះសង្ឃមកទៀត ព្រះគុណនោះច្រើនជាអនេកនឹងប្រៀបនឹងប្រមាណឯណាបាន? ព្រះរត្នត្រ័យទាំង ៣ នេះ ប្រកបដោយគុណអនេក អនន្ត

---

១- កិលេស ប្រែថាធម៌ជាគ្រឿងសៅហ្មងចិត្ត បើបែកតាមថ្នាក់តាមជាន់មាន ៣ ពួក គឺ កិលេសគ្រោតគ្រាតពួក ១ កិលេសកណ្ដាលពួក ១ កិលេសល្អិតពួក ១ ។ កិលេសគ្រោតគ្រាតបានដល់កាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ជាដើម ត្រូវលះបានដោយសីល ។ កិលេសកណ្ដាល បានដល់នីវរណធម៌ ៥ ត្រូវលះបង់បានដោយសមាធិ ។ កិលេសល្អិតបានដល់សញ្ញោជន ១០ ត្រូវលះបង់ដោយបញ្ញា ។

ដល់ពួកសត្វផុតប្រៀប ឧបមាថាប៉ុណ្ណេះប៉ុណ្ណោះបាន ក៏ពិតមែន តែគង់មានលក្ខណៈឲ្យសង្កេតបានថា មានតិចច្រើនជាងគ្នាជាប្រាកដ គឺព្រះពុទ្ធនិងព្រះធម៌មានគុណប្រហែលគ្នា ឯព្រះសង្ឃមានគុណតិចជាង ព្រោះថា ព្រះធម៌ដែលមានទាំងប៉ុន្មាន មកសមោធានរួបរួមនៅក្នុងហទយវត្ថុរបស់ព្រះពុទ្ធទាំងអស់ សមដូចពុទ្ធវាទដែលទ្រង់ត្រាស់សម្តែងចំពោះនឹងវក្កលិភិក្ខុថា

**យោ ខោ វក្កលិ ធម្មំ បស្សតិ សោ មំ បស្សតិ យោ មំ បស្សតិ សោ ធម្មំ បស្សតិ ។**

ម្នាលវក្កលិ អ្នកណាឃើញធម៌ អ្នកនោះឈ្មោះថាឃើញតថាគត អ្នកណាឃើញតថាគត អ្នកនោះឈ្មោះថាឃើញធម៌ ។

បានសេចក្តីថា អ្នកណាប្រតិបត្តិតាមធម៌របស់ព្រះអង្គ អ្នកនោះឈ្មោះថាប្រតិបត្តិតាមព្រះអង្គ អ្នកណាប្រតិបត្តិតាមព្រះអង្គ អ្នកនោះឈ្មោះថាប្រតិបត្តិតាមធម៌របស់ព្រះអង្គ ។

ឯព្រះសង្ឃបានជាមានគុណតិចជាង ព្រោះទ្រទ្រង់នូវគុណធម៌ដោយអន្ទើៗ មិនសព្វគ្រប់ ដូចយ៉ាងលោកដែលបានសម្រេចគុណធម៌ដ៏ខ្ពង់ខ្ពស់ដល់ភាវៈជាព្រះអរហន្តហើយ ក៏គង់តែលះបង់វាសនា ២ យ៉ាងពុំបាន ទាំងមានអធ្យាស្រ័យមិនធំទូលាយដូចព្រះពុទ្ធ ហេតុនោះទើបមានគុណតិចជាងព្រះពុទ្ធនឹងព្រះធម៌ ។

ប្រសិនបើមានពាក្យសួរថា បុព្វការីជនណាមួយដែលបានធ្វើឧបការគុណដល់យើងៗ ត្រូវតែតបគុណដល់លោកវិញដោយបច្ចុបការកិច្ចដែលយើងគួរធ្វើបាន ចុះព្រះរត្នត្រ័យដែលមានគុណឥតបីបើនឹងពណ៌នាថាប៉ុណ្ណេះប៉ុណ្ណោះបាន តើយើងត្រូវតបគុណលោកដោយវិធីបែបណាទើបសមនឹងមហាគុណនោះបាន?

ត្រូវឆ្លើយថា វិធីដែលត្រូវធ្វើតបគុណលោកនោះងាយទេ គឺត្រូវប្រព្រឹត្តតាមឱវាទរបស់លោក ដរាបដល់បានតាំងខ្លួននៅក្នុងគុណវិសេសដ៏ឧត្តមគឺអរហត្តផល ប៉ុណ្ណេះឯងឈ្មោះថាជាការតបគុណរបស់លោកដោយសព្វគ្រប់ ។ សមដោយបច្ឆិមភាសិតដែលទ្រង់ត្រាស់ចំពោះនឹងព្រះអានន្ទថា

**យោ កោចិ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ការោតិ គរុការោតិ មានេតិ បូជេតិ បរមាយ បូជាយ ។**

ម្នាលអានន្ទ បុគ្គលណាមួយទោះភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តីជាអ្នកប្រតិបត្តិនូវធម៌តាមធម៌ ជាអ្នកប្រតិបត្តិសមគួរដល់ធម៌ ជាអ្នកប្រព្រឹត្តតាម បុគ្គលនោះ ឈ្មោះថាធ្វើសក្ការ គោរព រាប់អាន បូជានូវតថាគតដោយគ្រឿងបូជាដ៏ក្រៃលែង ។

ព្រះរត្នត្រ័យ ទោះបីប្រកបដោយគុណដ៏ច្រើនអធិក ពន្ទឹកក្រៃលែងយ៉ាងណាក៏ដោយ ព្រះគុណនោះក៏ពុំអាចហូរហៀរសាធារណ៍ទូទៅដល់ពួកសត្វដែលជាអ្នកមិនត្រូវការ មិនប្រតិបត្តិតាមផងទេ ដូច្នេះនឹងថាព្រះរត្នត្រ័យមានអធ្យាស្រ័យ មិនស្មើទូទៅដល់សព្វសត្វទាំងអស់ក៏ពុំមែន គឺមោះដោយហេតុដែលសត្វព្រងើយកន្តើយពុំព្រមទទួលត្រងរងយកទើបវត្ថុវិសេសនោះ ត្រឡប់ជាឥតប្រយោជន៍ចំពោះសត្វអភព្វទាំងនោះទៅវិញ ប្រៀបដូចជាដើមឈើធំមានមែកត្រសុំត្រសាយម្លប់សាខាដុះប្របមាគ៌ានៅកណ្តាលវាលធំ តែត្រឡប់ទៅជាមិនមែនម្លប់សម្រាប់អ្នកដំណើរដែលមិនព្រមដើរចូលទៅជ្រកក្នុងគិម្ហសម័យដូច្នោះ ។

សមដោយពុទ្ធភាសិតដែលទ្រង់ត្រាស់ទុកថា **អក្ខាតារោ តថាគតា** "ព្រះតថាគតទាំងឡាយ ទ្រង់គ្រាន់តែជាអ្នកប្រាប់" បានសេចក្តីថា ព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់មិនមែនជាមេតែងបុណ្យបាបចែកសត្វទេ បុណ្យបាបនៅមានជានិច្ចជាធម្មតា ទ្រង់គ្រាន់តែជាអ្នកបង្ហាញផ្លូវសុខទុក្ខដល់សត្វប៉ុណ្ណោះ ត្រង់ការប្រព្រឹត្តល្អ ឬអាក្រក់នោះស្រេចលើរូបសត្វប្រៀបដូចបុគ្គលដែលប្រាប់ផ្លូវដល់អ្នកដំណើរដែលវង្វេង ដើម្បីឲ្យដឹងថាត្រូវដើរទៅតាមផ្លូវស្តាំឬឆ្វេងប៉ុណ្ណោះ ត្រង់ការដែលព្រមទៅឬមិនព្រមទៅនោះជាភារៈលើអ្នកដំណើរ ឯអ្នកបង្ហាញផ្លូវនឹងដើរទៅជួសគេក៏ពុំបាន ។ ហេតុនោះការកាន់យកព្រះរត្នត្រ័យជាទីពឹងទីរឭក ត្រូវយើង

ខំនឹករំពឹង ខំប្រឹងប្រព្រឹត្តតាមដោយខ្លួនឯងផង ទើបឈ្មោះថាយកព្រះរត្នត្រ័យជាទីពឹងពំនាក់ ឈ្មោះថាប្រព្រឹត្តខ្លួនគួរ ព្រះរត្នត្រ័យប្រោសប្រាណបាន ។

ប្រសិនបើមានពាក្យសួរជ្រែកចូលមកថា ជនានុជនរាល់គ្នាដែលខំស្វាធ្យាយមន្តវិជ្ជាអ្វីមួយ គេមានសង្ឃឹមផលប្រយោជន៍នៅខាងមុខទើបគេអាចស្វាធ្យាយបាន ចំណែកយើងជាពុទ្ធសាសនិកជនដែលខំអង្គុយភាវនារឭកគុណ ព្រះរត្នត្រ័យមាន អរហំ ជាដើមហាក់ដូចជាគ្រាន់តែអង្គុយនឹកសរសើរគុណព្រះរត្នត្រ័យទទេ ៗ ចុះចំណែកយើងតើត្រូវបានទទួលគុណ ឬ អានិសង្សអំពីការធ្វើដូច្នោះចំពោះខ្លួនដូចម្ដេចខ្លះ?

ត្រូវឆ្លើយថា បានទទួលអានិសង្សចំពោះខ្លួនយ៉ាងសង្ខេប គឺនាំខ្លួនឲ្យមានចិត្តបរិសុទ្ធ ធម្មតាចិត្តរបស់យើង កាលណាបើបណ្ដោយឲ្យនៅទំនេរ រមែងលង់ទៅក្នុងនីវរណធម៌[១] ទាំង ៥ ណាមួយពុំខាន ចុះបើយើងបានធ្វើចិត្តឲ្យអប់រំដោយភាវនារឭកគុណព្រះរត្នត្រ័យវិញ ចិត្តនោះឯងគង់ឃ្លាតចេញចាកនីវរណធម៌ពុំខាន លុះចិត្តឃ្លាតចាកនីវរណធម៌ហើយចិត្តនោះឯងលោកឲ្យឈ្មោះថា ចិត្តបរិសុទ្ធ ។

---

១- នីវរណធម៌ ៥ យ៉ាងគឺៈ កាមច្ឆន្ទៈ សេចក្ដីពេញចិត្តក្នុងកាម ១ ព្យាបាទៈ សេចក្ដីគំនុំគុំក្ហួន១ ថីនមិទ្ធៈ សេចក្ដីងងុយងោកងក់១ ឧទ្ធច្ចកុក្កុច្ចៈ សេចក្ដីរាយមាយបិត្ត ១ វិចិកិច្ឆា សេចក្ដីងឿងឆ្ងល់ ១ ។

នេះឯងជាគុណ ឬអានិសង្សរបស់អ្នកដែលបានភាវនារឭកគុណព្រះរត្នត្រ័យ ។

## សរណគមន៍

វិធីដែលកាន់យកព្រះរត្នត្រ័យជាទីពឹងទីរឭកនៃបុគ្គលអ្នកចុះកាន់ពុទ្ធ-សាសនាដំបូង ហៅថា សរណគមន៍ ។

## ឧបត្តិហេតុនៃសរណគមន៍

**សរណគមន៍** បើសម្តែងតាមដំណើរនៃឧបត្តិហេតុដែលកើតឡើងមាន ២ យ៉ាងគឺៈ ទ្វេវាចិកសរណគមន៍(១) ១ តេវាចិកសរណគមន៍(២) ១ ។

**ទ្វេវាចិកសរណគមន៍** ដំណើរដើម កាលព្រះបរមពិជិតមារទើបនឹងបានត្រាស់បរមាភិសម្ពោធិញាណ កន្លងទៅបាន ៧ សប្តាហ៍ ទ្រង់គង់នៅក្រោមដើមរាជាយតនព្រឹក្ស (ឈើកេស) ក្នុងតំបន់ឧរុវេលប្រទេស កាលនោះមានពាណិជបងប្អូន ២ នាក់បានមកជួបនឹងព្រះអង្គ ហើយថ្វាយខ្លួនជា ឧបាសក អ្នកដល់នូវទ្វេវាចិកសរណគមន៍ និងព្រះបរមលោកនាថដោយពាក្យថា

**ឯតេ មយំ ភន្តេ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច**

---

(១) ទ្វេវាចិកសរណគមន៍ បានដល់សរណគមន៍ ២ គឺព្រះពុទ្ធ និងព្រះធម៌ ។

(២) តេវាចិកសរណគមន៍ បានដល់សរណគមន៍ ៣ គឺ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។

**ឧបាសកេ នោ ភគវា ធារេតុ អជ្ជតគ្គេ សរណំ គតេ ។**

*ប្រែថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនេះ សូមដល់នូវព្រះដ៏មានជោគផង ព្រះធម៌ផង ជាទីពឹងទីរឭក សូមព្រះដ៏មានជោគទ្រង់ចាំទុកនូវយើងខ្ញុំ ថាជាឧបាសកអ្នកដល់ (នូវព្រះពុទ្ធ ព្រះធម៌) ជាទីពឹងទីរឭក តាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។*

**តេវាចិកាសរណាគមន៍** *ដំណើរដើម សេដ្ឋីជាបិតានៃយសកុលបុត្របានជួបនឹងព្រះសម្ពុទ្ធបរមគ្រូទ្រង់គង់ ក្នុងព្រៃឥសិបតនមិគទាយវ័ន នាតំបន់ក្រុងពារាណសី កើតសេចក្តីជ្រះថ្លា ទើបបង្អោនអាត្មាជាឧបាសក តេវាចិកសរណាគមន៍ ដំបូងក្នុងព្រះពុទ្ធសាសនា ចំពោះនឹងព្រះឈ្នះមារ ដោយវិធីភេទថា*

**ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។**

*ប្រែថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ សូមដល់នូវព្រះដ៏មានជោគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះដ៏មានជោគទ្រង់ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់ (នូវព្រះរត្នត្រ័យ) ជាទីពឹងទីរឭក ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។*

*តេវាចិកសរណគមន៍នេះ ជាន់បឋមពោធិកាល[១] ព្រះសព្វញ្ញុពុទ្ធ ទ្រង់ត្រាស់អនុញ្ញាត ជាកិច្ចឧបសម្បទា[២] សម្រាប់កុលបុត្រនានា ចំពោះនឹងព្រះអរហន្ត ៦០ អង្គមានព្រះកោណ្ឌញ្ញត្ថេរជាប្រធានឲ្យសញ្ចារទៅកាន់ស្រុកតូចធំនិគមជនបទរាជធានី ដោយមាគ៌ាផ្សេងៗ គ្នា ដើម្បីផ្សាយព្រះពុទ្ធសាសនា កាលបើប្រទះកុលបុត្រមានសទ្ធាជ្រះថ្លាប្រាថ្នាបព្វជ្ជាទ្រង់អនុញ្ញាតឲ្យសម្រេចឧបសម្បទា ដោយកិច្ចត្រឹមតែទទួលយកព្រះត្រៃ-សរណគមន៍ថា* **ពុទ្ធំ សរណំ គច្ឆាមិ, ធម្មំ សរណំ គច្ឆាមិ,**

(១) រវាងកាល ៤៥ វស្សា ចាប់ដើមអំពីកាលដែលព្រះពុទ្ធត្រាស់ដឹង ទៅទល់នឹងកាលដែលទ្រង់បរិនិព្វាន ហៅថា ពោធិកាល, បែកចេញជា ៣ គឺ រាប់ពីវស្សាទី ១ ដល់ទី ១៥ ហៅថា បឋមពោធិកាល ពីវស្សាទី ១៦ ដល់ទី ៣០ ហៅថា មជ្ឈិមពោធិកាល, ពីវស្សាទី ៣១ ដល់ទី ៤៥ ហៅថា បច្ឆិមពោធិកាល ។

(២) វិធីឧបសម្បទាក្នុងពុទ្ធសម័យមាន ៨ យ៉ាងគឺ: ឯហិភិក្ខុឧបសម្បទា ឧបសម្បទាដោយពុទ្ធតម្រាស់ថា ឯហិភិក្ខុ ២- សរណគមនូបសម្បទា ឧបសម្បទាដោយទទួលត្រៃសរណគមន៍, ៣- ឱវាទប្បដិគ្គហណូបសម្បទា ឧបសម្បទាដោយអាចទទួលពុទ្ធោវាទ(បំពោះព្រះមហាកស្សបត្ថេរ), ៤- បញ្ហាព្យាករណូបសម្បទា ឧបសម្បទាដោយការដោះស្រាយពុទ្ធ-បញ្ហាបាន (បំពោះសោបាកសាមណេរ), ៥- អដ្ឋគរុធម្មប្បដិគ្គហណូបសម្បទា ឧបសម្បទាដោយទទួលប្រតិបត្តិតាមគរុធម៌ប្រាំបី (បំពោះព្រះនាងបជាបតិ), ៦- ទូតេនឧបសម្បទា ឧបសម្បទាដោយបញ្ជូនទូតទៅ (បំពោះនាងអឌ្ឍកាសីគណិកា), ៧- អដ្ឋវាចិកឧបសម្បទា ឧបសម្បទា ដោយកម្មវាចាប្រាំបី អំពីសម្នាក់ឧភតោសង្ឃគឺឧបសម្បទាសម្រាប់ពួកភិក្ខុនី, ៨- ញត្តិចតុត្ថកម្មឧបសម្បទា ឧបសម្បទាដោយញត្តិចតុត្ថកម្មវាចា គឺឧបសម្បទាសម្រាប់ពួកភិក្ខុ ។

**សង្ឃំ សរណំ គច្ឆាមិ** ប៉ុណ្ណោះឯង ទុកជាសម្រេចកិច្ចឧបសម្បទា ហៅថា សរណគមនូបសម្បទា ។

លុះតមក ព្រះពុទ្ធសាសនាកាន់តែផ្សាយទូលាយឡើងច្រើនតំបន់ មានភិក្ខុសង្ឃសម្បូណ៌កុះករឡើងហើយ ទើបទ្រង់លើកវិធីឧបសម្បទាបែបនេះ ដាក់ទុកជាវិធីសម្រាប់បព្វជ្ជាជាសាមណេរទៅវិញ ហើយទ្រង់បញ្ញត្តវិធីឧបសម្បទាថ្មី ដោយញត្តិចតុត្ថកម្មវាចាជាលំដាប់រៀងរាបមក ។

**ឥមានិ តីណិ សរណគមនានិ** ព្រះត្រៃសរណគមន៍នេះ ទោះបីព្រះដ៏មានជោគទ្រង់ត្រាស់អនុញ្ញាតជាវិនយកម្មចំពោះបព្វជ្ជា និងឧបសម្បទាក៏ពិតមែន, តែជាគន់មានអានុភាពអាចឲ្យសម្រេចឱតារណ-កិច្ចចុះកាន់ព្រះពុទ្ធសាសនាដោយប្រការ ២ គឺញុំាងបុគ្គលឲ្យកើតបាននាមថា ឧបាសក ឧបាសិកា ដោយអត្ថ និងញុំាងបុគ្គលឲ្យកើតជាសាមណេរ សាមណេរី ដោយបាលី ។

សេចក្តីថា មនុស្ស ឬទេវតា ដែលមានសទ្ធាជឿជាក់ក្នុងគុណព្រះរត្នត្រ័យនឹងចុះកាន់ព្រះពុទ្ធសាសនាដំបូងត្រឹមភូមិជាឧបាសក ឧបា-សិកា តោងយល់អត្ថ (សេចក្តី) នៃព្រះត្រៃសរណគមន៍ដោយជាក់លាក់កាលបើដឹងហើយ ទោះបីទទួលសរណគមន៍ដោយវចីភេទជាភាសាបាលីក្តី ភាសារបស់ខ្លួនក្តី ឈ្មោះថាបានតាំងនៅក្នុងភូមិជាឧបាសក ឧបាសិកាដោយស៊ប់សួនដូចគ្នា ព្រោះសរណគមន៍របស់ឧបាសក ជាចេតនាកម្ម លើក

យកចេតនាដែលដឹងសេចក្តីជាប្រមាណ ។

ចំណែកខាងបព្វជ្ជាកិច្ចនៃសាមណេរវិញ ទោះបីបព្វជ្ជាបេក្ខបុគ្គលនោះយល់អត្ថ (សេចក្តី) នៃសរណគមន៍ជាក់លាក់ហើយក្តី ក៏ត្រូវបញ្ចេញវចីភេទទទួលយកសរណគមន៍ដោយភាសាបាលីជាថ្មីទៀត តាមសមគួរដល់អក្ខរសម្បត្តិ ទើបអាចញ៉ាំងបព្វជ្ជាកិច្ចនោះឲ្យសម្រេចបាន ព្រោះបព្វជ្ជាកម្មនេះជាបញ្ញត្តិកម្ម ទ្រង់បញ្ញត្តលើកយកកាយដែលកោរសក់ពុកមាត់ ពុកចង្កា កាត់ក្រចក ស្លៀកដណ្តប់សំពត់កាសាវៈ និងវាចាដែលអាចទទួលសរណគមន៍ត្រឹមត្រូវតាមលក្ខណៈនៃអក្ខរវិធីជាប្រមាណ ។

ប្រភេទនៃសរណគមន៍

**ទុវិធំ សរណាគមនំ លោកិយំ លោកុត្តរញ្ចាតិ** សរណគមន៍បើពោលដោយប្រភេទមាន ២ យ៉ាងគឺ លោកិយសរណគមន៍ ១ លោកុត្តរសរណគមន៍ ១ ។

លោកុត្តរសរណគមន៍ បានដល់សរណគមន៍នៃព្រះអរិយបុគ្គលមានសោតាបន្នបុគ្គលជាដើម ដែលលោកមានសេចក្តីសង្ស័យក្នុងព្រះរត្នត្រ័យជាមន្ទិលនៃសរណគមន៍ផ្តាច់បង់ហើយ ដោយអរិយមគ្គញ្ញាណជាសមុច្ឆេទប្បហាន មានសទ្ធាលែងរំភើបញាប់ញ័រហើយ ព្រោះមានព្រះនិព្វានជាអារម្មណ៍, សរណគមន៍នេះ ទោះបីមានហេតុជាទំនាស់យ៉ាងណា ក៏ឥតមានកិរិយាដាច់ធ្លុះធ្លាយទៅវិញបានឡើយ ។

**លោកិយសរណគមន៍** *បានដល់សរណគមន៍នៃបុថុជ្ជនជាតិ ដែលនៅមានអធ្យាស្រ័យទោរទន់ទៅតាមលោកធម៌ទាំង ៨ ប្រការ តែមានសទ្ធាជឿជាក់ក្នុងគុណព្រះរតនត្រ័យ អាចបញ្ចេញវចីភេទសមាទានប្រារព្ធយកពុទ្ធាទិគុណជាអារម្មណ៍ថា ពុទ្ធំ សរណំ គច្ឆាមិ ជាដើម ។*

**លោកិយំ បន** *ឯលោកិយសរណគមន៍នេះ បើសម្តែងដោយលំនាំនៃវចីភេទប្តេជ្ញាខ្លួនជា ឧបាសក ឧបាសិកា ប្រកបដោយអាការ ៤ យ៉ាងគឺៈ អត្តសន្និយ្យាតន ១ តប្បរាយនតា ១ សស្សភាវូបគមន ១ បាណិបាត ១ ។*

**អត្តសន្និយ្យាតន** *គឺប្រគល់កាយថ្វាយជីវិតដល់ព្រះរតនត្រ័យទុកព្រះរតនត្រ័យស្មើដោយជីវិត ទោះបីខ្លួនមានទុក្ខភ័យប្រល័យជន្មយ៉ាងណាក៏សុខចិត្តតែលះអាត្មា ពុំអាចលាកលាលះបង់ចោលព្រះរតនត្រ័យឡើយ ដូចមានបាលីសម្រាប់សូត្រប្រកាសប្តេជ្ជាខ្លួនថា*

**អជ្ជ អាទឹ កត្វា អហំ អត្តានំ ជីវិតំ ពុទ្ធស្ស និយ្យាទេមិ**
**អជ្ជ អាទឹ កត្វា អហំ អត្តានំ ជីវិតំ ធម្មស្ស និយ្យាទេមិ**
**អជ្ជ អាទឹ កត្វា អហំ អត្តានំ ជីវិតំ សង្ឃស្ស និយ្យាទេមិ ។**

*ប្រែថា ខ្ញុំព្រះករុណា សូមថ្វាយខ្លួនគឺជីវិត ដល់ព្រះពុទ្ធ ចាប់តាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។ (ព្រះធម៌ ព្រះសង្ឃមានន័យប្រែដូចគ្នា ប្លែកតែពាក្យថា ដល់ព្រះធម៌ ដល់ព្រះសង្ឃប៉ុណ្ណោះ) ។*

**តប្បរាយនតា** *គឺអធិដ្ឋានឬប្ដេជ្ញាទុកនូវព្រះរត្នត្រ័យជាប្រធាន ជាទីពឹង ប្រព្រឹត្តទៅក្នុងខាងមុខ ទោះបីខ្លួនមានហេតុអាសន្នអន្តរាយយ៉ាងណា ក៏ពុំព្រមយកសរណវត្ថុដទៃក្រៅចាកព្រះរត្នត្រ័យជាទីពឹងឡើយដូចមានបាលីសម្រាប់សូត្រប្រកាសប្ដេជ្ញាខ្លួនថាៈ*

**អជ្ជ អាទឹ កត្វា អហំ ពុទ្ធប្បរាយនោ ឥតិ មំ ធារេថ, អជ្ជ អាទឹ កត្វា អហំ ធម្មប្បរាយនោ ឥតិ មំ ធារេថ, អជ្ជ អាទឹ កត្វា អហំ សង្ឃប្បរាយនោ ឥតិ មំ ធារេថ,**

*ប្រែថា ខ្ញុំព្រះករុណា សូមយកព្រះពុទ្ធជាទីពឹងប្រព្រឹត្តទៅក្នុងខាងមុខ ចាប់តាំងអំពីថ្ងៃនេះជាដើមរៀងទៅ សូមព្រះករុណាទាំងឡាយចាំទុកនូវខ្ញុំព្រះករុណា ថាជាឧបាសក ដោយអាការៈដូច្នេះ ។ (ព្រះធម៌ ព្រះសង្ឃមានន័យប្រែដូចគ្នា ប្លែកតែត្រង់ពាក្យថា(មានព្រះធម៌ មានព្រះសង្ឃ" ប៉ុណ្ណោះ) ។*

**សស្សភាវូបគមន** *គឺបង្អោននូវភាពនៃខ្លួនជាសិស្សអ្នកស្ដាប់ឱវាទព្រះរត្នត្រ័យ ឥតសរណវត្ថុដទៃជាទីពឹងពំនាក់របស់ខ្លួនឡើយ ដូចមានបាលីសម្រាប់សូត្រប្រកាសប្ដេជ្ញាខ្លួនថា*

**អជ្ជ អាទឹ កត្វា អហំ ពុទ្ធស្ស អន្តេវាសិកោ ឥតិ មំ ធារេថ, អជ្ជ អាទឹ កត្វា អហំ ធម្មស្ស អន្តេវាសិកោ ឥតិ មំ ធារេថ, អជ្ជ អាទឹ កត្វា អហំ សង្ឃស្ស អន្តេវាសិកោ ឥតិ មំ ធារេថ ។**

ប្រែថា ខ្ញុំព្រះករុណា សូមជាសិស្សរបស់ព្រះពុទ្ធ ចាប់តាំងអំពីថ្ងៃនេះជាដើមរៀងទៅ សូមព្រះករុណាទាំងឡាយ ចាំទុកនូវខ្ញុំព្រះករុណាថាជាឧបាសក ដោយអាការដូច្នេះ (ព្រះធម៌ ព្រះសង្ឃមានន័យប្រែដូចគ្នា ប្លែកតែត្រង់ពាក្យថា (របស់ព្រះធម៌ របស់ព្រះសង្ឃតែប៉ុណ្ណោះ) ។

**បាណិបាត** គឺដាក់ចុះនូវដៃដោយអំណាចសទ្ធាជ្រះថ្លាពន់ពេក អាចសម្ដែងអាការគោរពដល់ព្រះរត្នត្រ័យ ដោយកិច្ចដែលគួរធ្វើក្នុងព្រះ-ពុទ្ធសាសនា មានលើកហត្ថាប្រណម្យនមស្ការចំពោះព្រះរត្នត្រ័យជាដើម ដូចមានបាលីសម្រាប់សូត្រប្រកាសប្ដេជ្ញាខ្លួនថា

**អជ្ជ អាទឹ កត្វា អហំ អភិវាទនប្បច្ចុបដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ពុទ្ធាទីនំយេវ តិណ្ណំ វត្ថូនំ ករោមិ ឥតិ មំ ធារេថ ។**

ប្រែថា ខ្ញុំព្រះករុណា សូមធ្វើនូវអភិវាទនកម្ម បច្ចុបដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ដល់ត្រៃរតនវត្ថុ មានពុទ្ធាទិរតនៈជាដើម ចាប់តាំងអំពីថ្ងៃនេះជាដើមរៀងទៅ សូមព្រះករុណាទាំងឡាយ ចាំទុកនូវខ្ញុំព្រះករុណាថា (ជាឧបាសក) ដោយអាការដូច្នេះ ។

**បាណិបាតោ បន** ឯបាណិបាតសរណគមន៍នេះ លោកចែកចេញទៅទៀតជា ៤ យ៉ាងគឺ ញាតិបាណិបាត ១ ភយបាណិបាត ១ អាចរិយបាណិបាត ១ ទក្ខិណេយ្យបាណិបាត ១ ។

**ញាតិចាណិចាត** គោរពដោយសារញាតិ បានដល់យកវាសណាមួយដែលយល់ឃើញថាព្រះពុទ្ធ ឬព្រះសង្ឃត្រូវជាញាតិរបស់ខ្លួន ទើបធ្វើអញ្ជលិកម្មប្រណម្យគោរពរាប់អានព្រះរត្នត្រ័យ ។

**ភយចាណិចាត** គោរពព្រោះខ្លាច បានដល់ឧបាសក ឧបាសិកាណាមួយ ដែលយល់ឃើញថា ព្រះពុទ្ធប្រកបដោយជាតិពូជពង្សវង្សត្រកូលខ្ពង់ខ្ពស់ជាងខ្លួន មានបុទ្ធានុភាពច្រើន ទាំងឥស្សរជនក៏បានចូលគោរពកោតខ្លាចច្រើន បើខ្លួនមិនគោរពទៅ ក្រែងគេតិះដៀល ឬធ្វើទោសទុក្ខផ្សេងៗ ម៉្លោះហើយ ទើបគោរពថ្វាយបង្គំព្រះរត្នត្រ័យ ។

**អាចរិយចាណិចាត** គោរពដោយយល់ថាជាគ្រូអាចារ្យបានដល់ឧបាសក ឧបាសិកាណាមួយ យល់ឃើញថាព្រះពុទ្ធ ឬព្រះសង្ឃធ្លាប់ធ្វើជាគ្រូអាចារ្យបង្ហាត់បង្រៀនលោកិយវិជ្ជា យ៉ាងលេខនព្វន្តគុណហាជាដើមដល់ខ្លួន កាលនៅជាយកវាសនៅឡើយ ហើយជាប់សេចក្តីគោរពនោះតមក លុះដល់លោកទ្រង់កេទបព្វជ្ជាហើយ ក៏នៅតែគោរពដោយយល់ថាជាគ្រូអាចារ្យរបស់ខ្លួន ទើបគោរពរាប់អានថ្វាយបង្គំចំពោះព្រះរត្នត្រ័យ ។

**ទក្ខិណេយ្យចាណិចាត** គោរពព្រោះជាទក្ខិណេយ្យបុគ្គលបានដល់ឧបាសកឧបាសិកាណាមួយ យល់ឃើញថាព្រះពុទ្ធជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរលើសលែងទក្ខិណេយ្យបុគ្គលដទៃៗក្នុងលោក ហើយទើបមានសេចក្តីជ្រះថ្លាជឿជាក់ក្នុងគុណព្រះរត្នត្រ័យ ទើបគោរពរាប់អានថ្វាយបង្គំចំពោះព្រះរត្នត្រ័យ ។

ឯបាណាតិបាតសរណគមន៍ ៣ ខាងដើមក៏ឈ្មោះថាជាកុសល ព្រោះបុគ្គលដែលធ្វើដូច្នោះបាន សុទ្ធតែអាស្រ័យហិរិឱត្តប្បនិងមេត្តាចិត្ត តែបើទុកជាដូច្នេះ ក៏គ្រាន់តែជាវដ្តគាមិនីកុសល ញ៉ាំងសត្វឲ្យវិលវល់ក្នុងវដ្តសង្សារប៉ុណ្ណោះ បើទុក្ខិណេយ្យបាណាតិបាតសរណគមន៍ទើបជាវិវដ្តគាមិនីកុសល លែងញ៉ាំងសត្វឲ្យវិលវល់ក្នុងវដ្តសង្សារទៀត ព្រោះហេតុសរណគមន៍នេះជាគន្លងនៃព្រះនិព្វាន ។

វិធីដាច់សរណគមន៍

**លោកិយស្ស សរណគមនស្ស ទុវេ្ភទោ សាវជ្ជោ អនាវជ្ជោ ច ។** លោកិយសរណគមន៍ ដែលបានសម្តែងមកហើយនេះ រមែងដាច់ធ្លុះធ្លាយទៅវិញដោយប្រភេទ ២ ប្រការគឺ ដាច់មានទោស ១ ដាច់ឥតទោស ១ ។

ដាច់មានទោស ដូចយ៉ាងបុគ្គលដែលប្រកាសប្តេជ្ញាខ្លួនជាឧបាសកឧបាសិកា ក្នុងព្រះពុទ្ធសាសនារួចហើយ ថ្ងៃក្រោយបែរត្រឡប់ជាលះបោលព្រះរត្នត្រ័យ បែរទៅជឿគោរពកោតខ្លាចសរណវត្ថុដទៃក្រៅពុទ្ធសាសនាថាប្រសើរជាងព្រះរត្នត្រ័យវិញ ។

ដាច់ឥតទោស ដូចយ៉ាងបុគ្គលដែលប្រកាសប្តេជ្ញាខ្លួនជាឧបាសកឧបាសិកា ក្នុងព្រះពុទ្ធសាសនារួចហើយ ថ្ងៃក្រោយធ្វើកាលកិរិយាទៅកាន់បរលោកនាយ បើជាភិក្ខុក៏ដាច់ចាកភិក្ខុភាព បើជាសាមណេរ

*ក៏ដាច់ចាកសាមណេរភាព បើជាឧបាសក ឧបាសិកាក៏ដាច់ចាកព្រះត្រៃសរណគមន៍ ព្រោះមិនអាចនឹងទាញយកសរណគមន៍ឆ្លងជាតិទៅផងបាន ។*

**សេដ្ឋសេដ្ឋេ ហិ សរណគមនំ កុប្បតិ** *តែបើបុគ្គលនៅប្រកាន់យកព្រះត្រៃសរណគមន៍ ថាប្រសើរវិសេសនៅឡើយដរាបណា សរណគមន៍ក៏ពុំទាន់ដាច់ធ្លាយទៅបាន ដរាបនោះ ។*

**សេដ្ឋសេដ្ឋេ ភិជ្ជតិ** *លុះតែបុគ្គលប្រកាន់យកនូវសរណវត្ថុដទៃថាប្រសើរជាងព្រះរត្នត្រ័យ ទើបសរណគមន៍ធ្លាយទៅក្នុងខណៈនោះដែរ ប៉ុន្តែលោកិយសរណគមន៍ បើទុកណាជាមិនមានដាច់ធ្លុះធ្លាយទេ ក៏គង់មានហេតុសៅហ្មងខ្លះៗពុំខាន ដូចមានសេចក្ដីតទៅ ។*

## ហេតុដែលសៅហ្មងសរណគមន៍

*សរណគមន៍ដែលសៅហ្មងបាន អាស្រ័យបុគ្គលមានមន្ទិលសង្ស័យក្នុងគុណព្រះរត្នត្រ័យដោយចិត្ត ឬសម្ដែងអាការមិនសមគួរចំពោះព្រះរត្នត្រ័យដោយកាយនិងវាចា ដែលជាអំពើទុច្ចរិតផ្សេងៗដែលកើតអំពីអកុសលចិត្ត ដូចយ៉ាងពាក់មួក ស្បែកជើង បាំងឆត្រ លាងជើងខ្ពុរមាត់ខាកស្ដោះ បន្ទោរបង់ឧច្ចារបស្សាវៈខាងមុខព្រះភក្ត្រព្រះពុទ្ធរូប ឬក្នុងទីបរិវេណដ្ឋានតម្កល់ព្រះពុទ្ធរូបក្បែរខាងព្រះលានព្រះចេតិយ ដែលតម្កល់ព្រះសារីរិកធាតុព្រះពុទ្ធ ក្បួនខ្នាតព្រះពុទ្ធសាសនា ឬព្រះភិក្ខុសង្ឃអង្គ*

ណាមួយ ឬពុំនោះសោត សម្ដែងអាការមិនគប្បីផ្សេងៗ ដូចយ៉ាងទ្រង់ត្រាស់ហាមមិនឲ្យភិក្ខុសម្ដែងធម៌ដល់អគារវបុគ្គល[១] ១៦ ពួកជាដើម ឬក៏បុគ្គលប្រកបដោយទោសចិត្ត ពោលប្រទុស្តចំពោះព្រះរត្នត្រ័យឬនិយាយប្រារព្ធព្រះរត្នត្រ័យដំបូចសើចលេងជាការល្បែងផ្សេងៗ តាមទំនើងចិត្ត ។ អាការទាំងអស់នេះឯងសុទ្ធតែជាគ្រឿងសៅហ្មងសរណគមន៍ ។

ហេតុនោះ សាធុជនកាលបើដឹងថាមានឧបក្កិលេសចូលមកលុកលុយសរណគមន៍យ៉ាងនេះហើយ ៗ ប្រាថ្នាសេចក្ដីបរិសុទ្ធ គប្បីសូមខមាទោសនឹងព្រះរត្នត្រ័យ ទើបបរិសុទ្ធបាន នេះជាសេចក្ដីល្មើសផ្លូវកាយវាចា ។ បើល្មើសដោយចិត្តទុច្ចរិតវិញ ដូចយ៉ាងមានសេចក្ដីវង្វៀសនឹងព្រះរត្នត្រ័យ នោះគប្បីរិះរកធម៌ណាមួយដែលខ្លួនធ្លាប់ជ្រះថ្លាយកមកពិចារណាដរាបដល់អស់សង្ស័យ នោះសេចក្ដីបរិសុទ្ធនឹងកើតឡើងឯង ក្នុងខណៈដែលបាត់ងឿងឆ្ងល់ភ្លាម ។

## ធម៌ជាហេតុឲ្យសរណគមន៍ខ្ជាប់ខ្ជួន

បុគ្គលជាឧបាសក ឧបាសិកា ដែលនឹងរក្សាព្រះត្រៃសរណគមន៍ឲ្យខ្ជាប់ខ្ជួនបាន មិនដាច់មិនសៅហ្មងទៅវិញ អាស្រ័យធម៌ ២ ប្រការគឺ សទ្ធា ១ បញ្ញា ១ ។

---

១- អគារវបុគ្គល បុគ្គលមិនគោរព ១៦ ពួកនេះ មានមកក្នុងបាតិមោក្ខ ត្រង់សេក្ខិយវត្តធម្មទេសនាបដិសំយុត្ត ។

*សេចក្ដីថា បើបុគ្គលមានសទ្ធាជាមូល ជឿស៊ប់ក្នុងគុណព្រះរត្នត្រ័យ ព្រមទាំងមានបញ្ញាជាសម្មាទិដ្ឋិ ពិចារណាឃើញគុណព្រះរត្នត្រ័យ ដោយជាក់លាក់ មានដើមថា ព្រះពុទ្ធទ្រង់ឆ្ងាយចាកសឹកសត្រូវពិតមែន ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្ដែងហើយដោយល្អពិតមែន ព្រះ-សង្ឃសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិត្រឹមត្រូវប្រាកដមែន យ៉ាងនេះឯងទើបសរណគមន៍ ឋិតនៅខ្ជាប់ខ្ជួនបាន បើប្រាសចាកសទ្ធានិងបញ្ញាហើយ សរណគមន៍មិនអាចនឹងតាំងនៅឋិតថេរបានឡើយ ។*

អានិសង្សនៃសរណគមន៍

**ឯវំ ហិ សរណាគមនោ** *កាលបើបុគ្គលរក្សាសរណគមន៍ខ្ជាប់ខ្ជួនប្រកបដោយអង្គ ៣ ប្រការគឺ សទ្ធា ជឿជាក់ក្នុងគុណព្រះរត្នត្រ័យ ១ សម្មាទិដ្ឋិ មានប្រាជ្ញាយល់ត្រូវ គឺមានព្រះរត្នត្រ័យជាអារម្មណ៍ ១ ជីវិត-បរិច្ចាគ ថ្វាយជីវិតដល់ព្រះរត្នត្រ័យ អាចសម្ដែងកាយវាចាឲ្យប្រព្រឹត្តទៅដោយអាការ ៤ មានអត្តសន្និយ្យាតនៈជាដើម ១ នោះនឹងបានទៅកើតក្នុងសុគតិភពជាអានិសង្ស សមដូចពុទ្ធភាសិតទ្រង់ត្រាស់សម្ដែងទុកថា*

**យេកេចិ ពុទ្ធំ សរណំ គតា សេ**
**ន តេ គមិស្សន្តិ អបាយភូមឹ**
**បហាយ មានុសំ ទេហំ**
**ទេវកាយំ បរិបូរេស្សន្តិ ។**

សេចក្ដីថា សត្វពួកណាមួយ ដល់នូវព្រះពុទ្ធជាទីពឹង សត្វនោះរមែងមិនទៅកាន់អបាយភូមិ កាលបើលះបង់រាងកាយរបស់មនុស្សចោលហើយ នឹងបានទៅកើតជាទេវបុត្រ ទេពធីតានាឋានសួគ៌ អាចញុំាំងទេពនិករ ឲ្យពេញបរិបូណ៌បាន ។

ម្យ៉ាងទៀត សមដូចពាក្យព្រះមោគ្គល្លានត្ថេរទេសនាចំពោះសម្ដេចអមរិន្ទ្រាធិរាជព្រមដោយទេពបរិស័ទ ៨ ម៉ឺនអង្គថា

**សាធុ ខោ ទេវានមិន្ទ ពុទ្ធសរណាគមនំ ហោតិ**

សេចក្ដីថា បពិត្រទេវរាជជាកំពូលនៃទេវតា ការដែលដល់នូវព្រះពុទ្ធជាទីពឹងទីរឭកជាការប្រពៃពេកណាស់ សត្វណាមួយដែលយកព្រះពុទ្ធជាទីពឹងទីរឭកហើយ លុះរលាងខន្ធទៅកាន់បរលោកនាយនឹងបានទៅកើតក្នុងសុគតិភព ហើយបានបរិបូណ៌ដោយសក្ដានុភាពលើសលប់ជាងទេវតាដទៃ ១០ យ៉ាងគឺ

១- **ទិព្វេន អាយុនា** មានអាយុទិព្វយឺនយូរជាងទេវតាដទៃ,

២- **ទិព្វេន វណ្ណេន** មានសម្បុរទិព្វឱភាសជាងទេវតាដទៃ,

៣- **ទិព្វេន សុខេន** មានសេចក្ដីសុខទិព្វជាងទេវតាដទៃ,

៤- **ទិព្វេន យសេន** មានយសបរិវារទិព្វជាងទេវតាដទៃ,

៥- **ទិព្វេន អធិបតេយ្យេន** នឹងបានជាឥស្សរាធិបតីលើទេវតាដទៃ

៦- **និព្វុតិ រូបេហិ** *បរិបូណ៌ដោយរូបលើសលែងទេវតាដទៃ,*

៧- **និព្វុតិ សទ្ទេហិ** *បរិបូណ៌ដោយសំឡេងលើសលែងទេ-វតាដទៃ,*

៨- **និព្វុតិ គន្ធេហិ** *បរិបូណ៌ដោយវត្ថុមានក្លិនទិព្វលើសលែងទេវតាដទៃ,*

៩- **និព្វុតិ រសេហិ** *បរិបូណ៌ដោយវត្ថុមានរសទិព្វលើសលែងទេវតាដទៃ,*

១០- **និព្វុតិ ផោដ្ឋព្វេហិ** *បរិបូណ៌ដោយសម្ផស្សទិព្វលើសលែងទេវតាដទៃ ។*

*លោកិយសរណគមន៍ អាចបង្ហូរមកនូវអានិសង្សម៉្លេះទៅហើយ ចំណែកលោកុត្តរសរណគមន៍ រឹងរឹតតែមានអានិសង្សក្រៃលែងជាងនេះទៅទៀត គឺអាចឲ្យសម្រេចសាមញ្ញផល ៤ ប្រការគឺ សោតាបត្តិផល ១ សក-ទាគាមិផល ១ អនាគាមិផល ១ អរហត្តផល ១ ព្រោះថាលោកុត្តរសរណ-គមន៍ កើតព្រមក្នុងខណៈនៃអរិយមគ្គទាំង ៤ ។*

**សព្វទុក្ខក្ខយោ** *រួមសេចក្តីថា លោកុត្តរសរណគមន៍អាចឲ្យផលដ៏ឧត្តមគឺ ក្ស័យទុក្ខសព្វយ៉ាង ។*

# ពុទ្ធរតនវិនិច្ឆ័យ

## ពាក្យថា "ពុទ្ធ"

ពាក្យថា "ពុទ្ធ" ប្រែថា អ្នកត្រាស់ដឹង មាន ៣ ពួកគឺ សព្វញ្ញូពុទ្ធ ពួក ១ បច្ចេកពុទ្ធ ពួក ១ អនុពុទ្ធ ពួក ១ ។

សព្វញ្ញូពុទ្ធ គឺលោកអ្នកត្រាស់ដឹងដោយព្រះអង្គឯង ហើយញ៉ាំង អ្នកដទៃឲ្យត្រាស់ដឹងផង បច្ចេកពុទ្ធ គឺលោកអ្នកត្រាស់ដឹងចំពោះតែ អង្គលោក អនុពុទ្ធ គឺលោកអ្នកត្រាស់ដឹងតាមព្រះសព្វញ្ញូពុទ្ធ បាន ដល់ពួកព្រះអរិយសាវក ។ តែពាក្យថា "ពុទ្ធ" ក្នុងពុទ្ធរតនៈនេះ សំដៅ យកតែសព្វញ្ញូពុទ្ធមួយប៉ុណ្ណោះ ។

ប្រសិនបើមានពាក្យសួរជ្រៀតចូលមកថា សព្ទថា "ពុទ្ធ" ប្រែថា "អ្នកត្រាស់ដឹង" យ៉ាងនេះ ឃើញថាព្រះពុទ្ធទ្រង់ប្រកបដោយបញ្ញាគុណ តែមួយប៉ុណ្ណោះ ចុះន័យដែលថាព្រះពុទ្ធលុះតែប្រកបដោយគុណ ៣ យ៉ាង គឺបញ្ញាគុណ វិសុទ្ធិគុណ និងករុណាគុណ ទើបបាននាមថាព្រះពុទ្ធ បើខ្វះគុណណាមួយមិនបាននាមថាព្រះពុទ្ធឡើយ ទំនងសេចក្តីនេះយ៉ាង ណាទៅ? ត្រូវឆ្លើយថា ពាក្យថា "ពុទ្ធ" នេះក៏ដូចនឹងពាក្យថា "អ្នកប្រាជ្ញ អ្នកមានប្រាជ្ញ" បើតាមពាក្យនេះឃើញថា ហៅសំដៅត្រង់ការចេះ ដឹងប៉ុណ្ណោះ មិនសំដៅត្រង់ការប្រព្រឹត្តផងឡើយ តែដែលពិតនោះ

គឺលោកសំដៅយកការប្រព្រឹត្តសុចរិតផង ទើបហៅថាអ្នកប្រាជ្ញបាន ។

សម្បទារបស់ព្រះពុទ្ធ

គុណជាតិជាគ្រឿងសម្រេចពោធិញ្ញាណ ហៅថាសម្បទា មាន ៣ ប្រការគឺ ហេតុសម្បទា ១ ផលសម្បទា ១ សត្តូបការសម្បទា ១ ។

១- ហេតុសម្បទា គុណជាតិជាគ្រឿងសម្រេចដោយហេតុ ឬសម្បទាដែលជាហេតុ គឺជាប្រធាននៃសម្បទាទាំង ២ ខាងចុង លោកចែកចេញជា ២ យ៉ាងទៀតគឺ មហាករុណាសមាយោគ ១ ពោធិសម្ភារ-សម្ភរណៈ ១ ។

ក) ដែលទ្រង់មានព្រះទ័យប្រកបដោយសេចក្តីករុណាអាណិតអាសូរយ៉ាងធ្ងន់ជានិច្ច ចំពោះសព្វសត្តនិករឥតរើសមុខ ដោយទ្រង់មានបំណងតែនឹងអនុគ្រោះសត្វទាំងនោះ ឲ្យរួចចាកទុក្ខសព្វប្រការ យ៉ាងនេះឯងហៅថា មហាករុណាសមាយោគ ។

ខ) លុះទ្រង់ប្រកបដោយអធ្យាស្រ័យដ៏ធំទូលាយដូច្នេះ ហើយក៏ខំប្រឹងប្រែងខ្វល់ខ្វាយបំពេញពុទ្ធការកធម៌ជាអនេកប្បការ ដែលព្រះអង្គនឹងគប្បីបានដោយការសន្សំដ៏យូរអង្វែង ស៊ូអត់ធ្មត់សេចក្តីទុក្ខលំបាកជាពន្លឹករាប់អសង្ខេយ្យកប្ប ដើម្បីប្តូរយកនូវសម្មាសម្ពោធិញ្ញាណ យ៉ាងនេះឯងហៅថា ពោធិសម្ភារសម្ភរណៈ ។

២- ផលសម្បទា គុណជាតិជាគ្រឿងសម្រេចដោយផល គឺកម្រៃ

ដែលសម្រេចមកអំពីហេតុសម្បទា លោកចែកចេញជា ៤ យ៉ាងទៀត គឺ ញាណសម្បទា ១ បហានសម្បទា ១ អានុភាវសម្បទា ១ រូបកាយសម្បទា ១ ។

ក) ប្រាជ្ញាញាណដែលត្រាស់ដឹងនូវមគ្គ ៤ ដែលជាទីតាំងនៅនៃសព្វញ្ញុតញ្ញាណ និងញាណដទៃឯទៀត មានទសពលញ្ញាណជាដើម (ដែលកើតមកអំពីមគ្គញ្ញាណនោះដែរ) ជាញាណអាចឆ្ពុះយល់នូវញេយ្យធម៌សព្វប្រការ ឥតមានធម៌អ្វីមួយអាចជាមន្ទិលនាំឲ្យបាំងព្រះញាណ របស់ព្រះអង្គបាន យ៉ាងនេះឯងហៅថា ញាណសម្បទា ។

ខ) បហាតព្វធម៌ គឺធម៌ដែលព្រះអង្គគួរលះបង់គ្រប់ប្រការមានកិលេសនិងវាសនាជាដើម ទ្រង់លះបង់ចោលអស់រលីងពីខន្ធសន្តាន ឥតមានសេសសល់ឡើយ យ៉ាងនេះឯងហៅថា បហានសម្បទា ។

គ) ព្រះអង្គអាចស្ទាត់ជំនាញក្នុងការថ្វៃងឫទ្ធិបានផ្សេងៗ ទោះបីចង់និមិត្តព្រះកាយតែមួយ ឲ្យក្លាយទៅជាព្រះកាយច្រើនរាប់សែនកោដិកប្ប ឬក៏និមិត្តបង្រួមព្រះកាយច្រើនឲ្យរួមតិចមកនៅតែព្រះកាយមួយឲ្យធំឲ្យតូចវិញយ៉ាងណាក៏ទ្រង់និមិត្តបានដូចបំណងឥតមានទើសទាល់ ព្រោះព្រះអង្គជាឥស្សរៈលើចិត្ត យ៉ាងនេះឯងហៅថា អានុភាវសម្បទា ។

ឃ) ការបរិបូណ៌នៃអត្តភាព ដែលទ្រង់ប្រកបដោយមហាបុរិសលក្ខណៈ ព្រមទាំងអសីត្យានុព្យញ្ជនៈ ដែលជានយនាភិសេករបស់សកល-

លោកដែលបានក្រឡេកឃើញហើយ ចង់ក្រឡេកមើលទៀត មិនចង់ដាក់ភ្នែក ដោយហេតុដែលឃើញព្រះកាយនោះល្អឡើងៗ សមរម្យគ្រប់ឥរិយាបថទាំង៤, ដូចមានដំណាលក្នុងរឿងវក្កលិកព្រាហ្មណ៍ដែលបួសដោយសេចក្ដីជ្រះថ្លាក្នុងព្រះរូបរបស់ព្រះអង្គជាដើម យ៉ាងនេះឯង ហៅថា រូប-កាយសម្បទា ។

៣- សត្តូបការសម្បទា ទ្រង់បរិបូណ៌ដោយឧបការគុណចំពោះសត្វលោកចែកចេញជា ២ យ៉ាងទៀតគឺ អាសយសម្បទា ១ បយោគសម្ប-ទា ១ ។

ក) ទ្រង់មានព្រះទ័យដោតដោរដោយមហាករុណាគុណគឺទ្រង់ប្រា-ថ្នាប្រយោជន៍ឲ្យសត្វជានិច្ច កុំថាតែពួកសត្វដែលស្លូតសុភាពស្រាប់សូម្បីតែសត្វរឹងរូសខូចកាចហ៊ានចងពៀរព្យាបាទប្រទុស្ត ចំពោះព្រះអង្គដូចយ៉ាងភិក្ខុទេវទត្តជាដើមក៏ដោយ ទ្រង់នៅតែមានព្រះទ័យប្រណីអាសូរចំពោះសត្វទាំងនោះដូចគ្នា ឥតមានទោមនស្សអាក់អន់សោះឡើយសមដោយពាក្យដែលព្រះអដ្ឋកថាចារ្យសរសើរទុកថា ទ្រង់តាំងព្រះទ័យស្មើៗចំពោះសព្វសត្វទាំងអស់ ទោះខ្មាន់ធ្នូក្ដី ទេវទត្តក្ដី ចោរអង្គុលិមាលក្ដីដំរីធនបាលក្ដី ក៏ប្រហែលៗ គ្នានឹងរាហុលរាជឱរសដែរ យ៉ាងនេះឯងហៅថា អាសយសម្បទា ។

ខ) ទ្រង់ឥតមានព្រះទ័យបំណងចំពោះអាមិសវត្ថុ ហើយសម្ដែង

ធម៌ប្រៀនប្រដៅសត្វ ដោយសីល សមាធិ បញ្ញា ដែលជាបដិបទានៃព្រះនិព្វាន ទ្រង់ញែកធម៌ទាំងនោះ ឲ្យមានសេចក្ដីពាក់ឆាយយល់ឡើង ដើម្បីឲ្យសត្វ ដែលមានឧបនិស្ស័យចូលចិត្តស្ដាប់បាន ប្រតិបត្តិតាម ហើយនឹងបាននូវលោកុត្តរារិយសម្បត្តិគឺ មគ្គ ផល និព្វាន យ៉ាងនេះឯង ហៅថាបយោគសម្បទា ។

## ពុទ្ធការកធម៌

ធម៌ដែលអាចធ្វើមនុស្ស សាមញ្ញឲ្យបាននាមថាព្រះពុទ្ធ ហៅថា ពុទ្ធការកធម៌ ។ ពុទ្ធការកធម៌នោះ មានច្រើនជាអនេក ពុំអាចគណនាឲ្យសព្វគ្រប់ក្នុងទីនេះបាន តែគង់មានគោល ឬប្រធាននៃធម៌ទាំងនោះ ល្មមជ្រើសរើសស្រង់យកមកពណ៌នាបានខ្លះដោយអន្លើៗ ដូចសេចក្ដីរៀបរាប់តាមលំដាប់តទៅនេះ ៖

ពុទ្ធការកបុគ្គល អ្នកប្រាថ្នាជាពុទ្ធភូមិជាដំបូងតោងប្រកបដោយពុទ្ធភូមិកធម៌ (ធម៌ជាភូមិនៃព្រះពុទ្ធ) ៤ យ៉ាងគឺ **ឧស្សាហោ** សេចក្ដីព្យាយាមអាចចាត់បានថាជា វីរិយបារមី ១ **ឧម្មង្គោ** សេចក្ដីឈ្លាសវៃអង់អាចដែលចាត់បានថាជាបញ្ញាបារមី ១ **អវត្ថានំ** ការតាំងចិត្តទទួលកិច្ចដែលខ្លួនគួរធ្វើមិនរួញរា ដែលចាត់បានថាជាអធិដ្ឋានបារមី ១ **ហិតចរិយា** ការប្រព្រឹត្តប្រយោជន៍ដើម្បីបុគ្គលដទៃដោយចិត្តមេត្តាអាចចាត់បានថាជា មេត្តាបារមី ១ ។

# បារមីធម៌ ១០

ពុទ្ធការកបុគ្គលដែលតាំងនៅក្នុងពុទ្ធភូមិកធម៌ទាំង ៤ យ៉ាងនេះហើយ ក៏ពុំទាន់អស់ហើយត្រឹមប៉ុណ្ណេះទេ នៅមានធម៌ដែលត្រូវប្រព្រឹត្តតទៅទៀតជាអនេក ព្រោះថាពុទ្ធភូមិកធម៌ ៤ យ៉ាងនេះគ្រាន់តែជាភូមិជាហេតុដើមចមដំបូងប៉ុណ្ណោះទេ ។

ឯធម៌ដែលត្រូវប្រព្រឹត្តតទៅទៀតនោះបានដល់បារមីធម៌ទាំង ១០ គឺ

**១- ទាន** ការឲ្យនូវវត្ថុដែលគួរឲ្យ

**២- សីល** ការរក្សាកាយវាចាឲ្យរៀបរយ

**៣- នេក្ខម** ការចេញស្វែងរកគុណធម៌ដ៏ធំ ឬចេញបព្វជ្ជា

**៤- បញ្ញា** ការយល់ច្បាស់នូវអំពើជាប្រយោជន៍និងមិនមែនប្រយោជន៍

**៥- វិរិយ** សេចក្តីព្យាយាម

**៦- ខន្តី** សេចក្តីអត់ធ្មត់

**៧- សច្ច** សេចក្តីទៀងត្រង់

**៨- អធិដ្ឋាន** ការតាំងចិត្តទទួលកិច្ចដែលគួរធ្វើ

**៩- មេត្តា** សេចក្តីអាណិតអាសូរ

**១០- ឧបេក្ខា** ការដាក់ចិត្តជាកណ្តាល ។

ក្នុងធម៌ទាំង១០យ៉ាងនេះ ធម៌មួយៗ លោកចែកចេញជាបីៗ តទៅទៀត គឺ បារមី ១ ឧបបារមី ១ បរមត្ថបារមី ១ រួមត្រូវជា ៣០ ។

ដែលលោកចែកដូច្នេះ គឺចែកតាមទំនងនៃសេចក្តីប្រព្រឹត្តដែលប្រវត្តទៅលើវត្ថុទាបខ្ពស់ជាងគ្នាគឺ កិច្ចណាដែលប្រារព្ធទៅលើវត្ថុខាងក្រៅខ្លួន យ៉ាងទ្រព្យសម្បត្តិបុត្រភរិយា លោកចាត់ថាជាបារមី កិច្ចណាដែលប្រារព្ធចំពោះវត្ថុផ្ទាល់ខ្លួន យ៉ាងអវយវៈរូបរាងកាយ លោកចាត់ថាជាឧបបារមី កិច្ចណាដែលប្រារព្ធចំពោះវត្ថុក្នុងខ្លួន យ៉ាងអាយុជីវិត លោកចាត់ថាជាបរមត្ថបារមី ។

ឯបារមីទាំង ៣០ ប្រការនោះគឺៈ

១- **ទានបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយគឺព្រះនិព្វានគឺទាន បានដល់កិរិយាបរិច្ចាគនូវគ្រឿងប្រើប្រាស់របស់ខ្លួន យ៉ាងទ្រព្យសម្បត្តិ បុត្រភរិយា ឲ្យទៅជាទាន ។

២- **ទានឧបបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយខាងលើគឺព្រះនិព្វានគឺទាន បានដល់កិរិយាលះបង់នូវអវយវៈរបស់ខ្លួនឲ្យទៅជាទាន ។

៣- **ទានបរមត្ថបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយដ៏ឧត្តមគឺព្រះនិព្វានគឺទាន បានដល់កិរិយាលះបង់នូវជីវិតរបស់ខ្លួនឲ្យទៅជាទាន ។

៤- **សីលបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយគឺព្រះនិព្វានគឺសីល បានដល់កិរិយារក្សាសីលមិនឲ្យធ្លុះធ្លាយ ទោះបីវិបត្តិកូនប្រពន្ធឬទ្រព្យសម្បត្តិជាដើមក៏ដោយ ។

៥- **សីលឧបបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយខាងលើគឺព្រះនិព្វានគឺសីល បានដល់កិរិយារក្សាសីលមិនឲ្យដាច់ធ្លុះធ្លាយបាន ទោះបីអវយវៈតូចធំក្នុងរាងកាយមានវិបត្តិយ៉ាងណាក៏ដោយ ។

៦- **សីលបរមត្ថបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយដ៏ឧត្តមគឺព្រះនិព្វានគឺសីល បានដល់កិរិយារក្សាសីលមិនឲ្យដាច់ធ្លុះធ្លាយបាន ទោះបីមានហេតុគួរដល់ជីវិតរបស់ខ្លួនក៏ដោយ ។

៧- **នេក្ខម្មបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយ គឺព្រះនិព្វានគឺបព្វជ្ជា បានដល់កិរិយាលះសេចក្តីអាល័យបុត្រករិយាហើយចេញកសាងផ្នួស ។

៨- **នេក្ខម្មឧបបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយខាងលើគឺព្រះនិព្វានគឺបព្វជ្ជា បានដល់កិរិយាលះសេចក្តីអាល័យអវយវៈតូច-ធំក្នុងរាងកាយហើយចេញកសាងផ្នួស ។

៩- **នេក្ខម្មបរមត្ថបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយដ៏ឧត្តមគឺព្រះនិព្វានគឺបព្វជ្ជា បានដល់កិរិយាលះសេចក្តីអាល័យជីវិតហើយចេញកសាងផ្នួស ។

១០- **បញ្ញាបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយគឺព្រះ-និព្វានគឺបញ្ញា បានដល់សេចក្តីមិនទាក់ទាមដោយទ្រព្យសម្បត្តិបុត្រករិយាហើយវិនិច្ឆ័យសម្រេចកិច្ចដល់អ្នកដទៃ ។

១១- **បញ្ញាឧបចារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយខាងលើគឺព្រះនិព្វានគឺបញ្ញា បានដល់កិរិយាលះកាត់សេចក្ដីអាល័យអំពីអវយវៈតូចធំហើយវិនិច្ឆ័យសម្រេចកិច្ចដល់អ្នកដទៃ ។

១២- **បញ្ញាបរមត្ថចារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយដ៏ឧត្តមគឺព្រះនិព្វានគឺបញ្ញា បានដល់កិរិយាមិនអើពើនឹងជីវិតរបស់ខ្លួនហើយស៊ូវិនិច្ឆ័យសម្រេចកិច្ចដល់អ្នកដទៃ ។

១៣- **វិរិយចារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយគឺព្រះនិព្វាន គឺព្យាយាម បានដល់កិរិយាលះនូវទ្រព្យសម្បត្តិបុត្រភរិយាហើយសង្វាតធ្វើនូវអំពើជាកុសល ។

១៤- **វិរិយឧបចារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយខាងលើគឺព្រះនិព្វាន គឺព្យាយាម បានដល់កិរិយាលះបង់នូវអវយវៈតូចធំហើយសង្វាតចម្រើនធម៌ជាកុសល ។

១៥- **វិរិយបរមត្ថចារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយដ៏ឧត្តមគឺព្រះនិព្វាន គឺព្យាយាម បានដល់កិរិយាលះបង់ជីវិតហើយសង្វាតធ្វើកុសល ។

១៦- **ខន្តិចារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយគឺព្រះនិព្វាន គឺខន្តី បានដល់សេចក្ដីអត់ធ្មត់មិនខឹងតនឹងកំហុសរបស់ជនដទៃដែលធ្វើរំលោភលើខ្លួនព្រោះទ្រព្យសម្បត្តិឬបុត្រភរិយា ។

១៧- **ខន្តិឧបចារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយខាងលើគឺព្រះនិញ្វានគឺខន្តី បានដល់សេចក្តីអត់ធ្មត់មិនខឹងតនឹងកំហុសរបស់ជនដទៃដែលធ្វើរំលោភមកលើរាងកាយរបស់ខ្លួន ។

១៨- **ខន្តិបរមត្ថចារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយដ៏ឧត្តម គឺព្រះនិញ្វាន គឺខន្តី បានដល់សេចក្តីអត់ធ្មត់មិនខឹងតនឹងកំហុសរបស់សត្វដទៃដែលប្រព្រឹត្តរំលោភដល់អាយុជីវិតរបស់ខ្លួន ។

១៩- **សច្ចចារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយគឺព្រះនិញ្វានគឺសេចក្តីទៀងត្រង់ បានដល់កិរិយាមិនហ៊ានពោលពាក្យឲ្យឃ្លាតចាកសេចក្តីពិត ព្រោះហេតុនៃទ្រព្យសម្បត្តិកូនប្រពន្ធរបស់ខ្លួន ។

២០- **សច្ចឧបចារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយខាងលើគឺព្រះនិញ្វានគឺពាក្យសត្យ បានដល់កិរិយាមិនហ៊ានពោលពាក្យឲ្យឃ្លាតចាកសេចក្តីពិត ព្រោះហេតុនៃអវយវៈតូចធំរបស់ខ្លួន ។

២១- **សច្ចបរមត្ថចារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយដ៏ឧត្តមគឺព្រះនិញ្វានគឺពាក្យសត្យ បានដល់កិរិយាមិនហ៊ានពោលពាក្យឲ្យឃ្លៀងឃ្លាតរំលងសេចក្តីពិត ព្រោះហេតុនៃជីវិតរបស់ខ្លួន ។

២២- **អធិដ្ឋានចារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយគឺព្រះនិញ្វានគឺអធិដ្ឋាន បានដល់កិរិយាតាំងចិត្តទទួលកាន់យកកុសលធម៌មិនរើរុះព្រោះហេតុនៃទ្រព្យសម្បត្តិ កូនប្រពន្ធរបស់ខ្លួន ។

**២៣- អធិដ្ឋានឧបបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយខាងលើគឺព្រះនិញ្វាន គឺអធិដ្ឋាន បានដល់កិរិយាតាំងចិត្តទទួលកាន់យកកុសលធម៌មិនរើរុះព្រោះហេតុនៃអវយវៈតូចធំរបស់ខ្លួន ។

**២៤- អធិដ្ឋានបរមត្ថបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយដ៏ឧត្តមគឺព្រះនិញ្វានគឺអធិដ្ឋាន បានដល់កិរិយាតាំងចិត្តទទួលកាន់យកនូវកុសលធម៌មិនរើរុះព្រោះហេតុនៃជីវិតរបស់ខ្លួន ។

**២៥- មេត្តាបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយគឺព្រះនិញ្វានគឺមេត្តា បានដល់សេចក្តីអាណិតរាប់រកចំពោះសត្វទូទៅ ទោះបីទ្រព្យសម្បត្តិឬបុត្រភរិយារបស់ខ្លួន មានវិបត្តិក៏ដោយ ។

**២៦- មេត្តាឧបបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយខាងលើគឺព្រះនិញ្វានគឺមេត្តា បានដល់សេចក្តីអាណិតរាប់រកចំពោះសត្វទូទៅ ទោះបីរាងកាយរបស់ខ្លួន មានវិបត្តិក៏ដោយ ។

**២៧- មេត្តាបរមត្ថបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយដ៏ឧត្តមគឺព្រះនិញ្វានគឺមេត្តា បានដល់សេចក្តីអាណិតរាប់រកចំពោះសត្វទូទៅ ទោះបីមានហេតុគួរដល់វិនាសជីវិតរបស់ខ្លួនក៏ដោយ ។

**២៨- ឧបេក្ខាបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយគឺព្រះនិញ្វានគឺចិត្តមធ្យមឬចិត្តស្មើៗ បានដល់សេចក្តីតាំងចិត្តជាកណ្តាលចំពោះសត្វនិងសង្ខារ ទោះបីមានសេចក្តីវិនាសដល់ទ្រព្យសម្បត្តិឬបុត្រភរិយាក៏ដោយ ។

២៩- **ឧបេក្ខាឧបចារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយខាងលើគឺព្រះនិព្វានគឺចិត្តមធ្យម បានដល់សេចក្តីតាំងចិត្តស្មើៗ ចំពោះសត្វនិងសង្ខារ ទោះបីកំពុងមានវិបត្តិដល់រាងកាយក៏ដោយ ។

៣០- **ឧបេក្ខាបរមត្ថបារមី** គុណសម្បត្តិជាហេតុដល់នូវត្រើយដ៏ឧត្តមគឺព្រះនិព្វានគឺចិត្តមធ្យម បានដល់សេចក្តីតាំងចិត្តស្មើៗ ចំពោះសត្វនិងសង្ខារ ទោះបីកំពុងមានហេតុគួរដល់វិនាសជីវិតរបស់ខ្លួនក៏ដោយ ។

បារមីធម៌ទាំង ៣០ នេះ មិនមែនសម្រាប់ឲ្យតែពួកពុទ្ធការកបុគ្គលប្រព្រឹត្តទេ សូម្បីបុគ្គលអ្នកកសាងជាបច្ចេកពុទ្ធ និងអនុពុទ្ធ ឬសាវកពុទ្ធ ក៏ត្រូវតែប្រព្រឹត្តធម៌នេះដែរ ប្លែកគ្នាតែត្រង់កាលត្រាស់ដឹងយូរឆាប់ជាងគ្នាប៉ុណ្ណោះ ។

ធម្មសមោធាន

ពុទ្ធការកបុគ្គលទាំងឡាយ ទោះបីមានបារមីធម៌សន្សំមកយូរយារក្រាស់ក្រែលដល់ឋានៈជាសាវកបារមីញាណដែរហើយ តែពុំទាន់បានព្យាករណ៍អំពីសំណាក់ព្រះពុទ្ធអង្គណាមួយនៅឡើយ ក៏ពុំអាចនឹងនឹកសង្ឃឹមបានថា ខ្លួនមុខជានឹងបានសម្រេចសម្មាសម្ពោធិញ្ញាណទៅខាងអនាគតពិតប្រាកដ លុះណាតែបានពុទ្ធព្យាករណ៍អំពីសំណាក់ព្រះពុទ្ធអង្គណាមួយរួចហើយ ទើបអាចនឹកសង្ឃឹមបាន ក៏ការដែលព្រះពុទ្ធនីមួយៗ

ទ្រង់ហ៊ានព្យាករឲ្យ ដោយហេតុទ្រង់ឈ្វេងយល់ឃើញពុទ្ធការកបុគ្គលនោះ បរិបូណ៌ដោយធម្មសមោធាន ៨ ប្រការ ល្មមគួរទ្រង់បរិហារព្យាករ បាន ។

ឯធម្មសមោធានទាំង ៨ ប្រការនោះគឺ:

១- **មនុស្សត្តំ** មានជាតិជាមនុស្ស,

២- **លិង្គសម្បត្តិ** មានភេទជាបុរស,

៣- **ហេតុសម្បទា** មានឧបនិស្ស័យជាសាវកបារមីញាណគួរបានសម្រេចអរហត្តផលក្នុងជាតិនោះ,

៤- **សត្ថារទស្សនំ** បានជួបនឹងព្រះពុទ្ធហើយបានធ្វើបណិធានក្នុងកាលនោះ,

៥- **បព្វជ្ជា** បានទ្រង់ភេទជាបព្វជិតគឺជាភិក្ខុ-សាមណេរក្នុងព្រះពុទ្ធសាសនា ឬក៏ជាតាបសឫសី[១] ដែលជាកម្មវាទី ឬកិរិយវាទី ។

៦- **គុណសម្បត្តិ** បរិបូណ៌ដោយគុណសម្បត្តិគឺឈាន សមាបត្តិ អភិញ្ញា, ។

៧- **អធិការោ** បានបំពេញបរិច្ចាគទាំង ៥ មានបុត្តបរិច្ចាគជាដើម ។

---

១- តាបសឫសី ដែលប្រកាន់ថាមានកុសលកម្ម អកុសលកម្ម មានបុណ្យ មានបាប ហៅថា កម្មវាទី, ដែលប្រកាន់ថាផលកើតអំពីកម្ម អំពើល្អឲ្យផលល្អ អំពើអាក្រក់ឲ្យផលអាក្រក់ ហៅថា កិរិយវាទី ។

៨- **ឆន្ទតា** មានសេចក្ដីស្ម័គ្រស្រឡាញ់ពោធិញ្ញាណយ៉ាងខ្លាំង ប្រៀបដោយបុគ្គលដែលហ៊ានចុះលុយងើកភ្លើងពេញផ្ទៃចក្រវាឡ ឬហ៊ានចុះទៅនៅក្នុងអវិចិមហានរកអស់កាល៤ អសង្ខេយ្យកប្បនិង ១សែនកប្ប ។

លុះបរិបូណ៌ដោយអដ្ឋសមោធាន ព្រមទាំងបានទទួលពុទ្ធព្យាករណ៍យ៉ាងនេះហើយ ពុទ្ធការកបុគ្គលនោះទើបបាននាមថា ពោធិសត្វ ប្រែថា អ្នកជាប់ចំពាក់ក្នុងការត្រាស់ដឹង ឬថា មហាសត្វ ប្រែថា អ្នកជាប់ចិត្តក្នុងពោធិញ្ញាណដ៏ប្រសើរ ។

លំដាប់អំពីជាតិនោះមក ដរាបដល់បច្ឆិមជាតិ នឹងបានផុតស្រឡះចាកអភព្វដ្ឋាន ១៨ ប្រការ ជាអានិសង្សគឺ: មិនមានភ្នែកខ្វាក់ពីកំណើត ១, មិនគថ្លង់ពីកំណើត ១, មិនជាមនុស្សឆ្កួត ១, មិនជាមនុស្សនិយាយជាប់ ១, មិនជាមនុស្សលើលា ១, មិនកើតក្នុងប្រទេសទមិឡ ១, មិនកើតក្នុងផ្ទៃស្ត្រីទាសី ១, មិនក្លាយខ្លួនជានិយតមិច្ឆាទិដ្ឋិ ១, មិនត្រឡប់ភេទជាស្រី ១, មិនធ្វើអនន្តរិយកម្មប្រាំប្រការ ១, មិនកើតរោគឃ្លង់ ១, មិនកើតជាសត្វតិរច្ឆានមានកាយតូចជាងចាប ឬធំជាងដំរី ១, មិនកើតជាខុប្បិបាសិកប្រេត និជ្ឈាមតណ្ហិកប្រេត និងកាឡកញ្ចិកាសុរប្រេត ១, មិនកើតក្នុងអវិចិនរក និងលោកន្តរនរក ១, មិនកើតជាមារាធិរាជ ១, មិនកើតក្នុងសុទ្ធាវាសព្រហ្ម ១, មិនកើតក្នុងអរូបភព ១, មិនកើតក្នុងចក្រវាឡដទៃ ១, ។

កាលបើបាននាមជាពោធិសត្វឬមហាសត្វហើយ ទើបអាចកំណត់

*កាលនឹងត្រាស់ដឹង ជានៅប៉ុណ្ណេះប៉ុណ្ណោះកប្បទៀតបាន តាមដំណើរនៃពោធិសត្វជាបញ្ញាធិក, សទ្ធាធិក និងវីរិយាធិក ។*

**បញ្ញាធិកោ ពោធិសត្តោ** *ពោធិសត្វដែលមានឧបនិស្ស័យជាបញ្ញាធិក (ក្រាស់ដោយបញ្ញា) ចាប់ដើមអំពីចេញវាចាតាំងប្រណិធានជាពុទ្ធភូមិ នឹងបានទទួលពុទ្ធព្យាករណ៍ក្នុងសម្នាក់ព្រះពុទ្ធជាបឋម រៀងមកទល់នឹងបច្ឆិមជាតិកំណត់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ។*

**សទ្ធាធិកោ ពោធិសត្តោ** *ពោធិសត្វដែលមានឧបនិស្ស័យជាសទ្ធាធិក (ក្រាស់ដោយសទ្ធា).... កំណត់ ៨ អសង្ខេយ្យ និង ១ សែនកប្ប ។*

**វីរិយាធិកោ ពោធិសត្តោ** *ពោធិសត្វដែលមានឧបនិស្ស័យជាវីរិយាធិក (ក្រាស់ដោយព្យាយាម) ...... កំណត់ ១៦ អសង្ខេយ្យ និង ១ សែនកប្ប ។*

### បរិយារបស់ពោធិសត្វ

*បារមីធម៌ទាំងអម្បាលនោះ ដែលព្រះពោធិសត្វទ្រង់បំពេញ បើសម្ដែងរួបរួមតាមដំណើរនៃចរិយា (សេចក្ដីប្រព្រឹត្ត) វិញមាន ៣ យ៉ាងគឺ:*

១- **ពុទ្ធត្ថចរិយា** *ទ្រង់ប្រព្រឹត្តដើម្បីប្រយោជន៍នឹងបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ។*

២- **ញាតត្ថចរិយា** *ទ្រង់ប្រព្រឹត្តដើម្បីប្រយោជន៍នឹងស្រោចស្រង់ញាតិ ។*

៣- **លោកត្ថចរិយា** ទ្រង់ប្រព្រឹត្តដើម្បីប្រយោជន៍នឹងស្រោចស្រង់សត្វលោក ។

អធ្យាស្រ័យរបស់ពោធិសត្វ

ធម្មតាវត្ថុគ្រឿងប្រើប្រាស់ជាវិការនៃលោហធាតុ និងរុក្ខជាតិនានា តោងអាស្រ័យការដុសខាត់សម្អាតសព្វកាលវេលា ទើបមានសម្បុរភ្លឺថ្លារលើបរលង់ឡើងបាន ចំណែកពោធិញ្ញាណរបស់ពោធិសត្វ ក៏គង់មានធមិសម្រាប់ដុសខាត់ដូចគ្នា ទើបអាចភ្លឺថ្លាផូរផង់ឡើងបានដែរ ។

ឯធមិសម្រាប់ដុសខាត់ពោធិញ្ញាណនោះបានដល់អធ្យាស្រ័យ ៦ ប្រការគឺ:

១- **នេក្ខមជ្ឈាសយ** ពេញព្រះទ័យក្នុងភេទបព្វជិត,

២- **បវិវេកជ្ឈាសយ** ពេញព្រះទ័យក្នុងទីស្ងាត់,

៣- **អលោភជ្ឈាសយ** ពេញព្រះទ័យក្នុងដំណើរសេចក្ដីមិនលោភ,

៤- **អទោសជ្ឈាសយ** ពេញព្រះទ័យក្នុងដំណើរសេចក្ដីមិនក្រោធ,

៥- **អមោហជ្ឈាសយ** ពេញព្រះទ័យក្នុងដំណើរសេចក្ដីមិនវង្វេង,

៦- **និស្សរណជ្ឈាសយ** ពេញព្រះទ័យក្នុងការរលាស់ខ្លួនចេញចាកភព ។

កាលបើពុទ្ធការកធម៌ ដែលព្រះមហាសត្វទ្រង់ខំសាងសន្សំទុកមក ច្រើនអស់កាលដ៏យូរលង់ គ្រប់ចំនួនធួនបរិបូណ៌ហើយ ដល់ក្នុងបច្ឆិមជាតិ គឺជាតិជាទីបំផុត ទើបព្រះបរមពោធិសត្វទ្រង់យាងចេញទៅរកទីស្ថាន ដើម្បីសាងអភិនេស្ក្រមបន្ទំបារមី ដោយទុក្ករកិរិយាតាមបែបព្រះ ពោធិសត្វពីបូរាណនាយរៀងមក ។

ព្រះពោធិសត្វទាំងឡាយរាល់ព្រះអង្គ ទោះបីមានពុទ្ធការកធម៌គ្រប់ គ្រាន់ហើយ ដល់មកក្នុងជាតិជាទីបំផុតក៏ត្រូវតែប្រកបសេចក្តីព្យាយាមធ្វើ ទុក្ករកិរិយាទៀតទើបអាចត្រាស់ដឹងបាន ប្រៀបដូចបុគ្គលដែលមានភត្តា-ហារស្រាប់ តែបើមិនលូកដៃចាប់យកមកបរិភោគ ក៏ពុំអាចនឹងញ៉ាំងផ្ទៃឲ្យ ឆ្អែតបាន ប៉ុន្តែការបំពេញទុក្ករកិរិយានោះផ្សេងគ្នាតែយូរ និងឆាប់ប៉ុណ្ណោះ ចំណែកព្រះសាក្យមុនីគោតមបរមគ្រូរបស់យើង ទ្រង់ប្រកបព្យាយាមធ្វើ ទុក្ករកិរិយាអស់ ៦ វស្សាទើបបានត្រាស់ដឹង ។ ដំណើរទុក្ករកិរិយាដែល ព្រះបរមគ្រូរបស់យើងទ្រង់ធ្វើនោះ ដូចពណ៌នាដោយសង្ខេបតទៅនេះ៖

លើកដំបូង ទ្រង់ខាំសង្កត់ព្រះទន្តទល់ព្រះជិវ្ហាញាត់ផ្ទប់នឹងព្រះតាលុ (ក្រអូមមាត់) រងទុក្ខលំបាកជាពន្ទឹកដរាបដល់ព្រះសេទោហូររហាមតាម ព្រះកច្ឆ (ក្លៀក) ក៏ឥតមានសម្រេចគុណវិសេសអ្វីមួយ ហើយទ្រង់ផ្លាស់ វិធីហាត់តទៅទៀត ។

លើកទី ២ ទ្រង់បិទខ្យល់ដង្ហើមចេញចូល ដរាបដល់ប្រាលខ្យល់លាន់ឮខ្ទរខ្ទារតាមព្រះកាណ៌ ឈឺចុកសៀតទៅក្នុងព្រះឧទរនិងព្រះសិរ ប្រកបដោយទុក្ខវេទនាដ៏ពន្លឹក ដោយហេតុដែលខ្យល់ស្ទុះស្ទាសចុះឡើងខុសប្រក្រតី, យ៉ាងនេះក៏ឥតបានសម្រេចគុណវិសេសណាមួយ ហើយទ្រង់ផ្លាស់វិធីហាត់ទៅទៀត ។

លើកទី ៣ ទ្រង់បន្ថយព្រះស្ងោយបន្តិចម្តងៗដរាបដល់លែងសោយសោះ ទាល់តែព្រះកាយស្គាំងស្គមស្លេកស្លាំងព្រះឆវីឡើងសរសៃរវើមរវាមពាសសរីរាវយវៈ ព្រះកក្ដ្រក្រៀមក្រំស្ទុលស្ទប់សញ្ជប់នៅ ទ្រាំយាងទៅពុំបាន ក៏ប្រាសប្រាណដួលក្រាបស្រពាបលើប្រថពីរងទុក្ខវេទនាហួសប្រមាណ ។ តែទុកណាជាប្រកបដោយ សេចក្ដីលំបាក លើសលន់ពន់ប្រមាណយ៉ាងនេះក៏ដោយ ទុក្ខវេទនានោះក៏ពុំអាចគ្របសង្កត់ព្រះអង្គឲ្យទ្រង់មានព្រះទ័យណាមួយ នឹកធុញថប់ត្រឡប់ទម្លាក់ចាកវីរិយភាពនោះបានឡើយ ។

ហេតុដែលនាំឲ្យទ្រង់ប្រព្រឹត្តអត្តកិលមថានុយោគបែបនេះ ព្រោះក្នុងសម័យនោះពួកព្រាហ្មណសាសនិកជន អ្នករាប់អានសាសនាព្រាហ្មណ៍ គេតែងនាំគ្នារាប់អាន ការប្រព្រឹត្តទូន្មានកាយដោយវិធីបែបនេះថាជាគ្រឿងចម្រាញ់កិលេស បានជាទ្រង់ប្រព្រឹត្តល្បងមើល ។

លុះទ្រង់ប្រព្រឹត្តល្បងមើល ឃើញថាមិនមែនជាផ្លូវត្រាស់ដឹងហើយ

ទ្រង់មិនសម្ងំទម្រន់នៅព្រងើយ ខំរិះរកព្រះទ័យរេរកសេចក្ដីប្រតិបត្តិជាថ្មីទៀត តាមឧបាយដែលទ្រង់យល់ថាជាផ្លូវត្រាស់ដឹងដូចទ្រង់ត្រិះរិះឃើញតទៅនេះ ៖

សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ មានកាយពុំទាន់ឃ្លាតចេញចាកកាមនៅឡើយ ទាំងចិត្តក៏នៅត្រាំជោកជាំដោយកាមដែរ សមណ-ព្រាហ្មណ៍ពួកនោះ ទោះបីរងទុក្ខវេទនាឬមិនបានរងទុក្ខវេទនា ព្រោះសេចក្ដីព្យាយាមខុសក៏ដោយ ក៏គង់មិនអាចនឹងត្រាស់ដឹងបាន ប្រៀបដូចជាឈើស្រស់ហើយត្រាំនៅក្នុងទឹកថែមទៀត បុរសអ្នកត្រូវការភ្លើងស្រង់យកឈើនោះមកពួតគ្នាដើម្បីឲ្យចេញភ្លើង ទោះបីបានសេចក្ដីនឿយព្រួយឬមិនសូវនឿយព្រួយ ព្រោះសេចក្ដីព្យាយាមខុសនោះក៏ដោយ ក៏ពុំអាចបង្កាត់ភ្លើងឲ្យឆេះបាន ។

សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ មានកាយឃ្លាតចេញចាកកាមដែរហើយ តែចិត្តនៅអាឡោះអាល័យកាមនៅឡើយ សមណព្រាហ្មណ៍ពួកនោះទោះបីរងទុក្ខវេទនាឬមិនបានរងទុក្ខវេទនា ព្រោះសេចក្ដីព្យា-យាមខុសក៏ដោយ ក៏គង់មិនអាចត្រាស់ដឹងបាន ។ ប្រៀបដូចឈើស្រស់តែនៅលើគោក បុរសអ្នកត្រូវការភ្លើងរើសយកឈើនោះ មកពួតគ្នាដើម្បីឲ្យចេញភ្លើង ទោះបីបានសេចក្ដីនឿយហត់ឬមិនសូវនឿយហត់ក៏ដោយ ក៏ពុំអាចបង្កាត់ភ្លើងឲ្យឆេះបាន ។

សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ មានកាយឃ្លាតចេញចាកកាមហើយ ទាំងចិត្តក៏លែងអាឡោះអាល័យកាមស្រឡះហើយ សមណព្រាហ្មណ៍ពួកនោះទោះបីរងទុក្ខវេទនាឬមិនបានរងទុក្ខវេទនា ព្រោះសេចក្តីព្យាយាមក៏ដោយ ក៏គង់តែអាចត្រាស់ដឹងបាន ។ ប្រៀបដូចឈើដែលស្ងួតស្រាប់ ហើយស្ថិតនៅលើគោកថែមទៀត បុរសអ្នកត្រូវការរើសយកឈើនោះមកពួតគ្នា ដើម្បីឲ្យចេញភ្លើង ទោះបីបានសេចក្តីនឿយហត់ឬមិនសូវនឿយហត់ ព្រោះសេចក្តីព្យាយាមក៏ដោយ ក៏គង់តែបង្កាត់ភ្លើងឲ្យឆេះបាន ។ បើតាមទំនងនេះ អាត្មាអញមិនអាចនឹងត្រាស់ដឹងបានដោយទុក្ករកិរិយាដែលតឹងហួសប្រមាណ គ្រាន់តែជាអត្តកិលមថានុយោគបែបនេះទេ ។

លុះទ្រង់ពិចារណាឃើញ ការហាត់កាយឲ្យលំបាកហួសប្រមាណឥតមានផលប្រយោជន៍ដូច្នេះហើយ ទើបទ្រង់រំពឹងការហាត់ខាងផ្លូវចិត្តវិញ ទ្រង់សន្និដ្ឋានថាល្មមត្រាស់ដឹងបាន តែទ្រង់នឹកឃើញថាបុគ្គលទុព្វលភាពបែបអាត្មាអញនេះ មិនងាយនឹងចាប់យកវិធីហាត់ចិត្តដូច្នោះបានទេ ដូច្នេះគួរអាត្មាអញត្រឡប់បរិភោគអាហារ ឲ្យមានកម្លាំងពលំឡើងវិញសិនទើបអាចធ្វើបាន ។ លុះត្រិះរិះឃើញដូច្នេះហើយ ក៏ត្រឡប់សោយព្រះស្ងោយឡើងវិញ ដរាបដល់មានព្រះកាយពលល្មមសមគួរហើយ ទ្រង់ផ្តើមធ្វើសេចក្តីព្យាយាមហាត់ផ្លូវចិត្ត គឺទ្រង់ផ្គងចិត្តឲ្យឋិតនៅ

ក្នុងសមាធិធម៌សព្វៗថ្ងៃ ត្រាតែចិត្តប្រព្រឹត្តទៅបានបទអស់កាលកំណត់ អឌ្ឍមាស (កន្លះខែ) ដល់ថ្ងៃពេញបូណ៌មីខែពិសាខជាឱកាសគួរត្រាស់ដឹង ទ្រង់យាងទៅប្រថាប់នាគល់ពោធិព្រឹក្សភាគទិសបូព៌ា និសជ្ជ-នាការពែនព្រះបាទស្តាំតម្រួតលើព្រះបាទឆ្វេង ដាក់ព្រះហស្តស្តាំ-ឆ្វេងតម្រួតលើព្រះភ្នែន សង្រួមព្រះកាយត្រង់ឆ្ពោះទៅខាងបុព្វទិស ទ្រង់រំពឹងអានា-បានស្សតិកម្មដ្ឋាន គឺប្រុងស្មារតីផ្ទៀងខ្យល់ដង្ហើមចេញចូល ដើម្បីប្រមូលអារម្មណ៍ឲ្យមូលល្អដរាបដល់ចិត្តឋិតនៅនឹងថ្កល់ ឥតមានចលាចលដោយនីវរណធម៌ណាមួយបាន លុះមកំណត់នាមថាជាសមាធិចិត្ត ទ្រង់ប្រព្រឹត្តព្យាយាមផ្លូវចិត្តយ៉ាងនេះ ដរាបដល់បានត្រៃវិជ្ជាក្នុងរាត្រីនោះឈ្មោះថាសម្រេចសម្មាសម្ពោធិញ្ញាណមាននាមថា **អរហំ សម្មាសម្ពុទ្ធ** ប្រាកដក្នុងលោក ហេតុនេះហើយបានជាមានបទបណាមគាថា ដែលលោកចង់ទុកសម្រាប់ឲ្យនមស្សការដូចតទៅនេះ ៖

*វិនិច្ឆ័យបទនមស្ការព្រះពុទ្ធ*

**យោ សិទ្ធិសិន្ធោ វរពោធិមូលេ**

**មារំ សសេនំ មហតឹ វិជេយ្យោ**

**សម្ពោធិមាគច្ឆិ អនន្តញ្ញាណោ**

**លោកុត្តមោ តំ បណមាមិ ពុទ្ធំ ។**

*ប្រែថា ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរបាន ផ្ចាញ់នូវមារាធិរាជព្រមទាំងសេនា[១]ដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។*

សេចក្តីសួរដែលគួរចាំ

*១- បុ. បុគ្គលដូចម្តេច ទើបហៅថា សម្មាសម្ពុទ្ធ?*

*២- បុ. កម្មដ្ឋានដូចម្តេច ទើបហៅថា អានាបានស្សតិកម្មដ្ឋាន*

---

១- មារសេនា ១០ យ៉ាងគឺ ១- កាម វត្ថុកាមកិលេសកាម, ២- អរតិ សេចក្តីមិនត្រេកអរក្នុងទីសេនាសនៈស្ងាត់ ឬក្នុងអធិកុសលណាមួយ, ៣- ខុប្បិបាស សេចក្តីស្រេកឃ្លាន, ៤- តណ្ហា បំណង់, ៥- ថីនមិទ្ធ សេចក្តីងោកងក់, ៦- ភិរុ សេចក្តីខ្លាចក្នុងសេនាសនៈក្នុងព្រៃតូច ធំ, ៧- វិចិកិច្ឆា សេចក្តីស្ទាក់ស្ទើរចិត្ត, ៨- មាន សេចក្តីប្រកាន់, មក្ខ សេចក្តីលុបគុណ, ថម្ភ សេចក្តីបបេសរឹងត្អឹង, ៩- យសសក្តិ លាភ សក្ការ សេចក្តីរាប់អាន, ១០- អត្តុក្កំសន សេចក្តីលើកខ្លួន, បរវម្ភន សេចក្តីមើលងាយអ្នកដទៃ ។ មហានិទ្ទេស ។

៣- បុ. ញាណដូចម្តេច ទើបហៅថា សម្មសម្ពោធិញ្ញាណ?

៤- បុ. អ្វីហៅថា មារ?

៥- បុ. ថ្វាយបង្គំដូចម្តេចឈ្មោះថាថ្វាយបង្គំដោយគោរព?

សេចក្តីឆ្លើយ

១- បុគ្គលដែលត្រាស់ដឹងឯងដោយប្រពៃនូវអរិយសច្ច ៤ ហៅថា សម្មាសម្ពុទ្ធ ។

២- កម្មដ្ឋានដែលរលឹកប្រារព្ធយកខ្យល់ដង្ហើមចេញចូលជាអារម្មណ៍ ហៅថា អានាបានស្សតិកម្មដ្ឋាន ។

៣- ប្រាជ្ញាជាគ្រឿងត្រាស់ដឹងដោយប្រពៃនូវអរិយសច្ច ៤ នៃព្រះពុទ្ធហៅថា សម្មាសម្ពោធិញ្ញាណ ។

៤- ពួកសត្រូវដែលតែងបំផ្លិចបំផ្លាញសម្លាប់បង់នូវកុសលធម៌របស់អ្នកដែលកសាង បំផ្លាញសេចក្តីសុខរបស់សត្វឲ្យវិនាស ហៅថាមារ។

៥- ថ្វាយបង្គំដោយអាការលម្អុតលំឱនដោយកាយ ដែលលោកហៅថា បញ្ចង្គប្រតិស្ឋាន (តាំងចុះនូវអវយវៈទាំង ៥ គឺដៃ ២ ជើង ២ ក្បាល ១) ទើបឈ្មោះថាថ្វាយបង្គំដោយគោរព ។

សេចក្តីអធិប្បាយអំពីរមារ ៥ យ៉ាង

មារ ពាក្យថា "មារ" នេះ ជាឈ្មោះបុគ្គលដែលមានចិត្តបាបក៏មាន, ជាឈ្មោះធម៌បាបក៏មាន ហេតុនេះហើយទើបលោកចែកចេញ

ជា ៥ ដូចតទៅនេះ គឺ ៖

**១- ខន្ធមារ** មារគឺខន្ធ

**២- កិលេសមារ** មារគឺកិលេស

**៣- អភិសង្ខារមារ** មារគឺអភិសង្ខារ

**៤- ទេវបុត្តមារ** មារគឺទេវបុត្រ

**៥- មច្ចុមារ** មារគឺសេចក្ដីស្លាប់ ។

**ខន្ធ** ៥ គឺ រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ដែលនៅប្រកបដោយឧបាទានមានសេចក្ដីប្រកាន់ថាយើង, ថារបស់យើង, ថាគេ, ថារបស់គេជាដើមហៅថា ឧបាទានក្ខន្ធ, បុគ្គលដែលនៅមានសេចក្ដីប្រកាន់យ៉ាងនេះឯង មិនងាយឡើយនឹងដោះខ្លួនឲ្យរួចចេញចាកសេចក្ដីទុក្ខបាន ហេតុនោះហើយទើបលោកចាត់ខន្ធ ៥ ដែលនៅប្រកបដោយឧបាទានយ៉ាងនេះហៅថា មារ ព្រោះតែងបំផ្លិចបំផ្លាញអ្នកដែលយល់ដូច្នោះ ។

**កិលេស** អារម្មណ៍ដែលធ្វើចិត្តឲ្យសៅហ្មង ឲ្យកើតសេចក្ដីតម្រេកឲ្យអាក់អន់ ឲ្យមួម៉ៅ ធ្វើចិត្តឲ្យល្អក់ ឲ្យអាប់ពន្លឺរស្មី ឈ្មោះថាកិលេស ។ នេះឯង ហៅថា មារ ព្រោះតែងបំផ្លិចបំផ្លាញអ្នកដែលមានចិត្តដូច្នោះឲ្យបានរងទុក្ខទោសផ្សេងៗ ប្រៀបដូចច្រែះដែលកើតពីដែកហើយត្រឡប់ធ្វើដែកនោះឲ្យពុកផុយខូច ទៅជារបស់ប្រើការមិនកើត ។

**អភិសង្ខារ** សភាពដែលតាក់តែងសត្វ ឲ្យប្រវត្តទៅក្នុងភពបី

ហៅថាអភិសង្ខារមាន ៣ យ៉ាងគឺ បុញ្ញាភិសង្ខារ សភាពតាក់តែងសត្វឲ្យកើតក្នុងកាមភពប៉ែកខាងសុគតិ និងរូបភព ១, អបុញ្ញាភិសង្ខារ សភាពតាក់តែសត្វឲ្យកើតក្នុងកាមភពប៉ែកខាងទុគ្គតិ ១, អនេញ្ជាភិសង្ខារ សភាពតាក់តែងសត្វឲ្យកើតក្នុងអរូបភព ១, សភាពទាំង ៣ នេះ ឈ្មោះថាមារ ព្រោះតាក់តែងសត្វឲ្យវិលស្លាប់វិលកើត រងទុក្ខវេទនាជាអនេក ក្នុងភពទាំង ៣ ។

ទេវបុត្ត ដែលជាអធិរាជ ស្តេចធំបំផុតនៅក្នុងឋានសួគ៌ជាន់ទី ៦ ឈ្មោះបរនិម្មិតវសវត្តី លោកឲ្យឈ្មោះថាមារ, ព្រោះមានចិត្តបាប តែងមានសេចក្តីគំនុំគំកួន ព្យាបាទ អាឃាដ ចងពៀរពារាំង ឃាត់ខាំងហួងហែងសត្វ ដែលកសាងបម្រុងនឹងកន្លងវិស័យរបស់ខ្លួន ឲ្យអាក់ខានស្ទាក់ស្ទើរដំណើរវិលវល់នៅក្នុងភពទាំងបី មិនឲ្យឆ្លងត្រៃភពទៅបានឡើយ ។

មច្ចុរាជ ស្តេចធំបណ្តាច់ក្នុងត្រៃលោក គឺសេចក្តីស្លាប់ លោកឲ្យឈ្មោះថាមារ ព្រោះតែងរឹបជាន់ផ្តាច់ផ្តិលជីវិតសង្ខារ របស់សត្វសព្វឋានឲ្យក្សិណក្ស័យប្រល័យជន្មព្រាត់ប្រាសនិរាសចាកគ្នានិងគ្នា ជាហេតុនាំឲ្យសត្វកើតចំបែងចិត្តហួសពណ៌នា ។

## វិធិប្ចុ័យបទនមស្សការព្រះពុទ្ធ គ្រប់ត្រៃកាល

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា**
**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ។**

*ប្រែថា ព្រះសម្មាសម្ពុទ្ធទាំងឡាយ អង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី, ព្រះសម្មាសម្ពុទ្ធទាំងឡាយ អង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយ អង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រកល្បនេះក្តី, ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះគ្រប់កាលទាំងពួង ។*

*សេចក្តីសួរដែលគួរចាំ*

*១- ព្រះពុទ្ធដែលបានត្រាស់ហើយបរិនិព្វានកន្លងទៅមានប៉ុន្មានអង្គ? គឺអង្គណាខ្លះ?*

*២- ព្រះពុទ្ធដែលនឹងបានត្រាស់ក្នុងកាលខាងមុខទៀតប៉ុន្មានអង្គ? គឺអង្គណាខ្លះ?*

*៣- ព្រះពុទ្ធដែលបានត្រាស់ក្នុងភទ្រកល្បនេះ មានប៉ុន្មានអង្គ? គឺអង្គណាខ្លះ?*

*៤- ពាក្យថាកល្បនេះជាឈ្មោះអ្វី? លោកកំណត់ដូចម្តេច? កល្បសព្វថ្ងៃនេះ ឈ្មោះអ្វី?*

# សេចក្តីឆ្លើយ

១- ព្រះពុទ្ធដែលបានត្រាស់ហើយបរិនិព្វានកន្លងទៅហើយនោះមានច្រើនជាអនេក ផុតវិស័យនឹងគណនារាប់ថាប៉ុណ្ណេះប៉ុណ្ណោះអង្គបាន តែដែលលោកកំណត់ទុកខ្លះនោះ ឃើញមានត្រឹម ២៨ ព្រះអង្គ បើមិនរាប់ព្រះពុទ្ធក្នុងភទ្រកល្បនេះផងទេ មាន ២៤ ព្រះអង្គគឺៈ ១- ព្រះពុទ្ធតណ្ហង្ករ, ២- ព្រះពុទ្ធមេធង្ករ, ៣- ព្រះពុទ្ធសរណង្ករ, ៤- ព្រះពុទ្ធទីបង្ករ, ៥- ព្រះពុទ្ធកោណ្ឌញ្ញ, ៦- ព្រះពុទ្ធសុមង្គល, ៧- ព្រះពុទ្ធសុមន, ៨- ព្រះពុទ្ធរេវត, ៩- ព្រះពុទ្ធសោភិត, ១០- ព្រះពុទ្ធអនោមទស្សី, ១១- ព្រះពុទ្ធបទុម, ១២- ព្រះពុទ្ធនារទ, ១៣- ព្រះពុទ្ធបទុមុត្តរ, ១៤- ព្រះពុទ្ធសុមេធ, ១៥- ព្រះពុទ្ធសុជាត, ១៦- ព្រះពុទ្ធបិយទស្សី, ១៧- ព្រះពុទ្ធអត្ថទស្សី, ១៨- ព្រះពុទ្ធធម្មទស្សី, ១៩- ព្រះពុទ្ធសិទ្ធត្ថ, ២០- ព្រះពុទ្ធតិស្ស, ២១- ព្រះពុទ្ធបុស្ស, ២២- ព្រះពុទ្ធវិបស្សី, ២៣- ព្រះពុទ្ធសិខី, ២៤- ព្រះពុទ្ធវេស្សភូ, បើរាប់យកព្រះពុទ្ធដែលបានត្រាស់ហើយក្នុងភទ្រកល្បនេះ ៤ ព្រះអង្គផ្សំមកទៀតត្រូវជា ២៨ ព្រះអង្គ ។

២- ព្រះពុទ្ធដែលមិនទាន់បានត្រាស់នៅឡើយ ក៏នៅមានច្រើនជាអនេកពុំអាចនឹងគណនាបានឡើយ តែដែលលោកកំណត់ព្រះនាមព្រះពុទ្ធដែលបម្រុងនឹងបានត្រាស់ក្នុងភទ្រកល្បនេះ ជាដំណអំពីព្រះសាក្យមុនីសមណគោតមនេះទៅ មាន ១ ព្រះអង្គទៀតគឺៈ ព្រះអរិយមេត្តយ្យពោធិ-

សត្វ ។ ក្នុងកល្បឯទៀតៗ តពីភទ្រកល្បនេះទៅនឹងមានព្រះពុទ្ធច្រើន ព្រះអង្គត្រាស់តាមសមគួរដល់កាល ។

៣- ព្រះពុទ្ធដែលត្រូវបានត្រាស់ ក្នុងភទ្រកល្បនេះមាន ៥ ព្រះអង្គ គឺ: ១- ព្រះពុទ្ធកកុសន្ធៈ, ២- ព្រះពុទ្ធកោនាគមនៈ, ៣- ព្រះពុទ្ធកស្សបៈ, ៤- ព្រះពុទ្ធសមណគោតម, ៥- ព្រះពុទ្ធអរិយមេត្តេយ្យ ។ តែព្រះពុទ្ធ ៤ ព្រះអង្គខាងដើមបានត្រាស់រួចហើយ ១ ព្រះអង្គខាងចុងពុំទាន់បានត្រាស់នៅឡើយ ។

៤- ពាក្យថា "កល្ប" នេះជាឈ្មោះកាលដែលយូរអង្វែងឆ្នាំអង្វែងជាតិ លោកកំណត់កាលដែលយូរអង្វែងនោះប្រៀបដោយភ្នំពេជ្រ មានទំហំ ១០០ យោជន៍ ៤ ជ្រុងស្មើ ក្នុងមួយឆ្នាំមានទេព្តាអាយុទិព្វ ១ អង្គ យកសំពត់ដែលមានសាច់ម៉ដ្ឋមកជូតភ្នំនោះម្តង រៀងរាល់ឆ្នាំ ដរាបដល់សឹកភ្នំអស់រលីងរាបស្មើត្រឹមផែនដី លោកកំណត់ដោយសេចក្តីប្រៀបដូច្នេះឲ្យឈ្មោះថា កល្ប ១, កល្បសព្វថ្ងៃនេះ ឈ្មោះថា ភទ្រកល្ប ។

## សេចក្តីអធិប្បាយអំពីកល្ប ឬ កប្ប

កាលវេលាដែលយូរអង្វែងនេះឯង លោកចែកជាច្រើនផ្នែកដូច្នេះ មហាកប្ប (កល្បធំ) ចែកចេញជា ២ គឺ សំវដ្តកប្ប ១, វិវដ្តកប្ប ១

**សំវដ្តកប្ប** (កល្បវិនាស) លោករាប់ពីត្រឹមរលាយផែនដី មកទល់ត្រឹមកកើតផែនដីវិញ **វិវដ្តកប្ប** (កល្បចម្រើន) លោករាប់ពីត្រឹម

កកើតផែនដីមានមនុស្សសត្វ មកទល់ត្រឹមរលាយផែនដីទៅវិញ រូបរួមកប្បទាំង ២ នេះហៅថាមហាកប្ប ១ ។

**វិវដ្តកប្ប**, បែកចេញជា ២ គឺ សុញ្ញកប្ប ១, អសុញ្ញកប្ប ១ ។ កប្បណាដែលមានផែនដីដុះកើតឡើងហើយ តែឥតមានព្រះពុទ្ធត្រាស់ ហៅថា សុញ្ញកប្ប (កល្បសូន្យ) កប្បណាដែលមានផែនដីដុះ កើតឡើងហើយ មានព្រះពុទ្ធត្រាស់ហៅថា អសុញ្ញកប្ប (កល្បមិនសូន្យ) ។

**អសុញ្ញកប្ប** មាន ៥ គឺ សារកប្ប ១ មណ្ឌកប្ប ១ វរកប្ប ១, សារមណ្ឌកប្ប ១ ភទ្រកប្ប ១ ។ កប្បទាំង ៥ នេះ ក្នុងកប្បទី ១ មានព្រះពុទ្ធត្រាស់ ១ ព្រះអង្គ, កប្បទី ២ មានព្រះពុទ្ធត្រាស់ ២ ព្រះអង្គ, កប្បទី ៣ មានព្រះពុទ្ធត្រាស់ ៣ ព្រះអង្គ, កប្បទី ៤ មានព្រះពុទ្ធត្រាស់ ៤ ព្រះអង្គ, កប្បទី ៥ មានព្រះពុទ្ធត្រាស់ ៥ ព្រះអង្គ ។

## ពុទ្ធគុណ ១០ ព្រះនាម

១- **ឥតិបិ សោ ភគវា អរហំ** ព្រះមានព្រះភាគអង្គនោះទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេសព្រមទាំងវាសនាគឺកាយប្បយោគនិងវចីបយោគ,

២- **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា "សម្មាសម្ពុទ្ធោ" ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

៣- **វិជ្ជាចរណសម្បន្នោ** *ទ្រង់ព្រះនាមថា "វិជ្ជាចរណសម្បន្នោ" ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និង វិជ្ជា ៨ និងចរណៈ ១៥*

៤- **សុគតោ** *ទ្រង់ព្រះនាមថា "សុគតោ" ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន,*

៥- **លោកវិទូ** *ទ្រង់ព្រះនាមថា "លោកវិទូ" ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក,*

៦- **អនុត្តរោ** *ទ្រង់ព្រះនាមថា "អនុត្តរោ" ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន,*

៧- **បុរិសទម្មសារថិ** *ទ្រង់ព្រះនាមថា "បុរិសទម្មសារថិ" ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន,*

៨- **សត្ថាទេវមនុស្សានំ** *ទ្រង់ព្រះនាមថា "សត្ថា ទេវមនុស្សានំ" ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ*

៩- **ពុទ្ធោ** *ទ្រង់ព្រះនាមថា "ពុទ្ធោ" ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង,*

១០-**ភគវា** *ទ្រង់ព្រះនាមថា "ភគវា" ព្រោះព្រះអង្គមានដំណើរយាងទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ*

# វិគិប្ប័យបទថា "អរហំ"

## សេចក្ដីសួរដែលគួរចាំ

១- **អរហំ** ប្រែបានប៉ុន្មានន័យ យ៉ាងណាខ្លះ? នាមថា "អរហំ" នេះ ចំពោះតែព្រះពុទ្ធប៉ុណ្ណោះឬ ឬក៏ជានាមសាធារណៈដល់សាវកដទៃទៀតដែរ? បើដូច្នោះមិនប្រឡំគ្នាហើយឬ?

២- កិលេស ដូចម្ដេចទើបលោកឲ្យឈ្មោះថាសឹកសត្រូវ?

៣- អ្វីហៅថាវាសនា? វាសនាដូចម្ដេចហៅថាកាយប្បយោគ? ដូចម្ដេចហៅថា វចីបយោគ?

## សេចក្ដីឆ្លើយ

១- អរហំ ប្រែបាន ៤ ន័យដូច្នេះគឺ

ក) ព្រោះទ្រង់ឆ្ងាយចាកសឹកសត្រូវគឺកិលេសព្រមទាំងវាសនា,

ខ) ព្រោះទ្រង់បំបាក់បង់នូវសំសារចក្រ,

គ) ព្រោះទ្រង់គួរដល់គ្រឿងបូជាវិសេស,

ឃ) ព្រោះទ្រង់មិនសម្ងំធ្វើបាបក្នុងទីកំបាំង ។

ព្រះនាមថា "អរហំ" នេះ ជានាមសាធារណៈទូទៅដល់ព្រះអរហន្តគ្រប់រូប ព្រោះឆ្ងាយចាកកិលេសដូចគ្នា មិនប្រឡំទេ, ព្រះនាមព្រះពុទ្ធលោកតែងបញ្ចូលពាក្យថា "សម្មាសម្ពុទ្ធ" មកទៀត រួមថា អរហំសម្មាសម្ពុទ្ធ "ព្រះអរហន្តត្រាស់ដឹងឯង" ដូច្នេះវិញ ។

២- កិលេសបានឈ្មោះថាសឹកសត្រូវ ព្រោះធ្វើអ្នកដែលមានសន្តានចិត្តសៅហ្មងឲ្យបានសេចក្តីវិនាសផ្សេងៗ ។

៣- ដំណើរទំនងអាកប្បកិរិយា ពាក្យសម្តីដែលធ្លាប់មានក្នុងអតីតជាតិ ហើយជាប់រហូតមកដល់ជាតិជាបច្ចុប្បន្ន ហៅថាវាសនា, វាសនាដែលជាប់ដោយកាយ ហៅថា កាយប្បយោគ, ជាប់ដោយសម្តី ហៅថា វចីបយោគ ។

សេចក្តីអធិប្បាយ

ព្រះមានព្រះភាគទ្រង់ឆ្ងាយចាកសឹកសត្រូវ ទ្រង់លះបង់ ទ្រង់កម្ចាត់បង់ ទ្រង់បដិសេធចោលនូវសឹកសត្រូវគឺកិលេសបានស្រឡះដោយអរិយ-មគ្គញ្ញាណឥតមានសេសសល់នៅក្នុងខន្ធសន្តានរបស់ព្រះអង្គឡើយ ។

កិលេសនោះមាន ៣ យ៉ាងក៏មាន ១៦ យ៉ាងក៏មាន ។

កិលេស ៣ យ៉ាង

១- រាគៈ សភាពជាប់ចិត្ត ត្រេកត្រអាល រីករាយ ក្នុងវត្ថុកាម គឺ រូប សំឡេង ក្លិន រស សម្ផស្ស ធម្មារម្មណ៍ដែលជាទីគាប់ចិត្ត, បុគ្គលដែលត្រូវរាគៈឲ្យជាប់ចិត្តហើយ ដែលត្រូវរាគៈគ្របសង្កត់ហើយ មានចិត្តត្រូវរាគៈញាំញីបានហើយ តែងគិតដើម្បីបៀតបៀនខ្លួនខ្លះ ដើម្បីបៀត-បៀនបុគ្គលដទៃខ្លះ ដើម្បីបៀតបៀនខ្លួនឯងនិងបុគ្គលដទៃទាំងពីរខ្លះ បុគ្គលដែលត្រូវរាគៈឲ្យជាប់ចិត្តហើយ រាគៈគ្របសង្កត់ហើយ មានចិត្តដែល

រាគៈញាំញីហើយ រមែងសម្លាប់សត្វខ្លះ កាន់យករបស់ដែលគេមិនឲ្យខ្លះ គប់រកប្រពន្ធកូនរបស់បុគ្គលដទៃខ្លះ ពោលពាក្យមុសាវាទខ្លះ ។

២- **ទោសៈ** សេចក្តីប្រទុស្តចំពោះសត្វនិងសង្ខារ ដែលកើតឡើងអំពីបដិឃៈ បុគ្គលដែលត្រូវទោសប្រទុស្តហើយ រមែងហ៊ានប្រទុស្តចំពោះមាតាបិតារបស់ខ្លួនក៏មាន ចំពោះញាតិសាលោហិតមានបងប្អូនប្រុសស្រីជាដើមក៏មាន ចំពោះបព្វជិតក៏មាន ។ ទោសៈ តែងញុាំងសេចក្តីវិនាសឲ្យកើតឡើងដល់ខ្លួននិងបុគ្គលដទៃ ទោសៈ រមែងបំភ្លក់ចិត្តរបស់បុគ្គលពាល មិនឲ្យស្គាល់នូវភ័យដែលកើតឡើងក្នុងសន្តានរបស់ខ្លួន, បុគ្គលដែលត្រូវទោសៈប្រទុស្តហើយ រមែងមិនស្គាល់នូវប្រយោជន៍របស់ខ្លួនជាដើម, បុគ្គលដែលទោសៈគ្របសង្កត់ហើយរមែងមិនយល់ច្បាស់នូវធម៌ សូម្បីត្រឹមកម្មបថ ១០ កាលណា នរជនដែលទោសៈគ្របសង្កត់បានហើយ សេចក្តីងងឹតងងល់នឹងកើតមានក្នុងកាលនោះឯង ។

៣- **មោហៈ** សេចក្តីវង្វេង ភ័ន្តច្រឡំ ងងឹតងងល់មិនស្គាល់សេចក្តីពិតគឺ មិនស្គាល់អរិយសច្ច ៤, បុគ្គលដែលមោហៈឲ្យវង្វេងហើយ រមែងប្រទុស្តចំពោះមាតាបិតាក៏មាន ចំពោះចេតិយ ចំពោះពោធិព្រឹក្សក៏មាន ចំពោះបព្វជិតក៏មាន រមែងបាននូវពាក្យនិន្ទាក្នុងទីផ្សេងៗ ដែលខ្លួនទៅហើយ។ មោហៈ តែងញុាំងសេចក្តីវិនាសឲ្យកើតឡើងដល់ខ្លួននិងបុគ្គល

ដទៃ, មោហៈ រមែងបំភ្លេចចិត្តរបស់បុគ្គលពាលមិនឲ្យស្គាល់ភ័យដែលកើតឡើងក្នុងសន្ដានរបស់ខ្លួន បុគ្គលដែលត្រូវមោហៈឲ្យវង្វេងហើយរមែងមិនយល់នូវប្រយោជន៍របស់ខ្លួនជាដើម បុគ្គលដែលមោហៈគ្របសង្កត់ហើយ រមែងមិនយល់ច្បាស់នូវធម៌សូម្បីត្រឹមតែកម្មបថ ១០, កាលណានរជនដែលមោហៈគ្របសង្កត់បានហើយ សេចក្ដីងងឹតងងល់នឹងកើតមានឡើងក្នុងកាលនោះ ។

## កិលេស ១៦

១- **អភិជ្ឈាវិសមលោភៈ** សេចក្ដីលោភមិនស្មើ គឺអភិជ្ឈា បានសេចក្ដីថាការលោភចង់បានឥតមានរើសឥតមានចំពោះរបស់តូច-ធំ ឬអា-ក្រក់ល្អឡើយ តាមតែប្រទះ ទោះបីបានដោយការមិនសមគួរមានការលួចលាក់ឆក់ដណ្ដើម បំបាត់ប្រវញ្ចន៍ជាដើមក្ដី ក៏ទទួចធ្វើអំពើនោះទាល់តែសម្រេចបានមកតាមបំណងដែលខ្លួនត្រូវការ គឺជាមនុស្សឃើញតែពីខាងបានប៉ុណ្ណោះ សេចក្ដីលោភនេះអាក្រក់ក្រៃលែង កាលបើមានក្នុងសន្ដានរបស់ជនណា អាចនាំជននោះឲ្យហ៊ានធ្វើអំពើលាមកបានជាលំដាប់តាំងអំពីបាបតូចៗ រហូតដល់បាបធំៗ ដែលជាហេតុនៃសេចក្ដីទុក្ខទោសយ៉ាងក្លាខ្លាំងបំផុត ។

២- **ទោសៈ** (ចូរមើលក្នុងពួកកិលេស ៣ យ៉ាង) ។

៣- **កោធៈ** សេចក្ដីក្រោធ បានដល់កំហឹងដែលកើតឡើងក្នុងចិត្តហើយបញ្ចេញចំហាយមកខាងក្រៅ សេចក្ដីក្រោធនេះកើតឡើង

ដោយហេតុដែលបានប្រទះអនិដ្ឋារម្មណ៍ គឺអារម្មណ៍ដែលមិនគាប់ចិត្ត, កាលបើកើតឡើងហើយ អាចនាំបណ្ដាលឲ្យក្ដៅរោលរាលមិនមានយោគយល់អ្នកណាមួយឡើយ ហើយជាហេតុនាំឲ្យប្រព្រឹត្តធ្វើអំពើលាមកផ្សេងៗទៀត មានជេរប្រទេចផ្ដាសាដាល់តប់អ្នកដទៃជាដើម ។

៤- **ឧបនាហៈ** ការចងសេចក្ដីក្រោធទុក គឺប្រកាន់ទុកនូវកំហឹងដែលខ្លួនខឹងនោះមិនរសាយរសាយ ដោយហេតុចេះតែនឹករកនូវអំពើអាក្រក់ដែលធ្វើរួចហើយនោះឲ្យនៅឃើញថ្មីៗ ហាក់ដូចជាអំពើដែលទើបនឹងធ្វើហើយក្ដាមៗ កិលេសធម៌នេះឲ្យទោសផ្សេងគ្នាអំពីកោធៈ គឺមានទោសធ្ងន់ជាងកោធៈទៅទៀត ព្រោះតាំងនៅអង្វែងយូរក្នុងសន្ដាន ជាឱកាសនឹងឲ្យផលអាក្រក់ចម្រើនច្រើនឡើងៗឥតស្រាក ជាគ្រឿងកាត់សេចក្ដីសាមគ្គីអំពីគ្នា ។

៥- **មក្ខៈ** ការលុបលាងគុណអ្នកដទៃ បានដល់សេចក្ដីមើលងាយចំពោះឧបការគុណដែលអ្នកដទៃបានធ្វើហើយដល់ខ្លួនថា ឥតផលប្រយោជន៍ មិនគិតសងគុណដល់អ្នកដទៃវិញ កិលេសធម៌នេះរមែងឲ្យទោសក្នុងបច្ចុប្បន្ន ជាផ្លូវអាចនាំឲ្យផ្ដាច់បង់នូវសេចក្ដីមេត្តាករុណាអំពីអ្នកដទៃដែលបម្រុងនឹងមានដល់ខ្លួនតទៅមុខទៀត ។

៦- **បលាសៈ** ការវាយឫកស្មើ បានដល់សេចក្ដីលើកខ្លួនផ្ទឹមនឹងលោកអ្នកមានសំណាងវាសនា ដោយហេតុដែលយល់ឃើញថា

មិនខ្វីពឹងរកអ្នកណា គេយ៉ាងណាអញក៏យ៉ាងនោះដែរ មិនព្រមឱនលំ-ទោនចំពោះអ្នកណាឡើយ ស្មានថាខ្លួនប្រហែលគ្នានឹងលោកអ្នកមានសំណាងវាសនាដែរ កិលេសធម៌នោះរមែងឲ្យទោសទាន់ហន់ក្នុងបច្ចុប្បន្នច្រើនយ៉ាង មាននាំឲ្យគេស្អប់ខ្ពើមមិនចង់និយាយតបតរកជាដើម ។

**៧- ឥស្សា** សេចក្ដីឫស្យា បានដល់សេចក្ដីច្រណែនឈ្នានិះគេ បើឃើញគេបានល្អ បានសេចក្ដីសុខ សេចក្ដីចម្រើន មានទ្រព្យសម្បត្តិ មានចំណេះវិជ្ជាច្រើនជាងខ្លួន ក៏មានសេចក្ដីក្ដៅក្រហាយមិនសប្បាយចិត្ត ចង់រករឿងរកហេតុមិនចង់ឲ្យគេលើសខ្លួន កិលេសធម៌នេះជាហេតុជាឧបាយនាំឲ្យកើតធម៌ព្យាបាទផង នាំឲ្យខ្លួនរឹងរឹតតែអប្បអន់ទន់ថយទៅតាមលំដាប់ផង ព្រោះរវល់តែរករឿងរកហេតុមិនខំធ្វើសេចក្ដីល្អដូចគេ ។

**៨- មច្ឆរិយៈ** សេចក្ដីកំណាញ់ បានដល់សេចក្ដីហួងហែងទ្រព្យសម្បត្តិដែលបានមកហើយ ទុកឲ្យគង់នៅមិនឲ្យរបេះចេញទៅដោយការកុសលណាមួយ មិនចាយវាយចំពោះខ្លួនឯងផង មិនមានសង្គ្រោះដល់អ្នកកំសត់ ទុគ៌ត កំព្រា ក្រីក្រលំបាកផង បានប៉ុន្មានលាក់លៀមទុកប៉ុណ្ណោះ, កិលេសធម៌នេះ ជាហេតុនាំឲ្យខាតសេចក្ដីមេត្រីស្នេហាអំពីអ្នកផង គឺឥតមានអ្នកណាសេពគប់ជាមួយ នឹងត្រឡប់ទៅជាមនុស្សទោលតែឯង ឥតមានមិត្តសំឡាញ់ជួយជ្រោមជ្រែង ក្នុងពេលដែលខ្លួនមានវិបត្តិណាមួយ ។

៩- **មាយា** សេចក្ដីលាក់ពុតរបស់ខ្លួន, បានដល់ការដែលធ្វើអាការកិរិយាឲ្យគេដឹងថា ខ្លួនជាមនុស្សល្អ កាយកប់ត្រឡប់ជានបំបាត់ទោសរបស់ខ្លួន ច្រើនតែឃើញទោសរបស់គេ កិលេសធម៌នេះ ដែលឲ្យទោសក្នុងបច្ចុប្បន្នជាហេតុនាំឲ្យគេលែងទុកចិត្តថាជាមនុស្សទៀងត្រង់ ។

១០- **សាថេយ្យៈ** អំនួត បានដល់សេចក្ដីអួតអាងថាខ្លួនល្អគ្រាន់បើជាងគេ ចេះដឹងជាងគេ ទោះបីខ្លួនអាក្រក់ ឬល្ងង់យ៉ាងណាក៏ដោយ បើពួកគេផ្ដើមនិយាយរឿងអ្វីមួយ ធ្វើយកាត់គេឯង មិនក្រែងអ្នកដទៃ មាននិយាយថាមិនបាច់ទេ រឿងនេះខ្ញុំចេះដែរ ដឹងដែរ កាលបើគេឲ្យនិយាយ ឬឲ្យធ្វើអ្វីៗ ត្រឡប់ជានិយាយមិនកើត ធ្វើមិនបាន កិលេសធម៌នេះច្រើននាំឲ្យអាម៉ាស់មុខកណ្ដាលទីប្រជុំ នឹងជាហេតុនាំឲ្យគេលែងទុកចិត្តតទៅទៀត ទោះបីពេលក្រោយនិយាយពិតមែន ក៏នៅតែគេមិនជឿ នឹងជាហេតុនាំឲ្យខូចប្រយោជន៍ដែលខ្លួនបំណង ឬជាហេតុកាត់ផ្លូវចេះដឹងនិងសេចក្ដីល្អដែលបម្រុងនឹងមានតទៅខាងមុខទៀត ។

១១- **ថម្ភៈ** សេចក្ដីចចេស មុខរឹង ម្នះ បានដល់ភាពជាអ្នកចចេសរឹងត្អឹង មិនព្រមស្ដាប់អ្នកណាមួយដែលគេដាស់តឿនណែនាំប្រាប់ពន្យល់សេចក្ដីខុសត្រូវរកប្រយោជន៍ឲ្យ គឺជាមនុស្សប្រដៅក្រ កិលេស-ធម៌នេះបើមាននៅក្នុងសន្ដានអ្នកណា អាចធ្វើអ្នកនោះឲ្យខានទទួលសេចក្ដីល្អដែលត្រូវមានដល់ខ្លួនតទៅទៀត ។

១២- **សារម្ភៈ** *ប្រណាំងវាសនា គឺបើឃើញគេមានសំណាងវាសនាមានជាតិត្រកូលទ្រព្យសម្បត្តិឧត្តុង្គឧត្តមជាងខ្លួន កំខំប្រឹងរកឧបាយរកផ្លូវប្រណាំងប្រជែងមិនឲ្យខ្លួនអន់ថយជាងគេ ចង់ឲ្យតែបានគ្រាន់បើជាងគេ មានខំប្រឹងតាក់តែងរាងកាយដោយគ្រឿងសម្លៀកបំពាក់និងខំប្រឹងសម្ដែងអាការកិរិយាឲ្យលើសលុបហួសមាឌជាដើម, កិលេសធម៌នេះតែមានក្នុងសន្ដានអ្នកណាហើយ អ្នកនោះឯងនឹងដល់នូវសេចក្ដីវិនាសទាន់ហន់ផង នឹងនាំឲ្យអ្នកឯទៀតគេមើលងាយផង ។*

១៣- **មានៈ** *សេចក្ដីប្រកាន់ខ្លួន គឺប្រកាន់ថាខ្លួនជាអ្នកខ្ពង់ខ្ពស់គ្រាន់បើជាងគេដោយជាតិ ដោយយសសក្ដិ ដោយទ្រព្យសម្បត្តិ ដោយចំណេះវិជ្ជា, ប្រកាន់ថាខ្លួនស្មើនឹងគេរាល់គ្នាទាំងអស់ ឥតមានអ្នកណាហួសខ្លួនទេ, ប្រកាន់ថាខ្លួនជាមនុស្សអន់ថយជាងគេទាំងអស់, សេចក្ដីប្រកាន់នេះអាចធ្វើចិត្តឲ្យរឹងរូសម្នោម្នះរបឹងរឹងមិនព្រមស្ដាប់អ្នកណា ប្រកាន់ថាស្រេចនៅលើខ្លួន, កិលេសធម៌នេះតែមានក្នុងសន្ដានអ្នកណាហើយ អ្នកនោះឯងនឹងត្រឡប់ទៅជាមនុស្សត្រូវគេស្អប់រាល់គ្នា ឥតមានអ្នកណាពេញចិត្តស្រឡាញ់រាប់អានឡើយ ជាមនុស្សឥតមិត្តសំឡាញ់ ឬនឹងដល់នូវសេចក្ដីវិនាសទាន់ហន់ក៏មាន ។*

១៤- **អតិមានៈ** *សេចក្ដីមើលងាយគេ, បានដល់សេចក្ដីរិះគន់អ្នកដទៃ, មើលទៅគេសុទ្ធតែអន់ទន់ថយជាងខ្លួនទាំងអស់ ស្រេចហើយ*

តែត្រឹមខ្លួនគ្មានអ្នកណាដល់, ទោះបីខ្លួនគ្មានគុណធម៌ណាមួយក្នុងខ្លួនក៏ដោយ បើឃើញអ្នកខ្សត់ខ្សោយក្រីក្រទ្រព្យសម្បត្តិ តែគេមានគុណធម៌ណាមួយមានទានសីលជាដើម ក៏នៅតែហ៊ានរំលោភប្រមាថមើលងាយដោយអាងថាខ្លួនមានបុណ្យស័ក្តិទ្រព្យសម្បត្តិ អ្នកណានឹងធ្វើអ្វីខ្លួនកើត, សេចក្តីយល់យ៉ាងនេះហាក់ដូចជាខ្លួនផុតសេចក្តីវិនាសហើយ, ឃើញបន្ទាតូច ឃើញរងើកភ្លើងតូច ហ៊ានយកជើងជាន់លេង មើលងាយថាបន្ទាតូចរងើកភ្លើងតូច មិនចេះមុតមិនចេះក្តៅ, មិនប្រព្រឹត្តខ្លួនឲ្យសមរម្យតាមជាន់តាមថ្នាក់របស់ខ្លួននឹងអ្នកដទៃ កិលេសធម៌នេះគង់តែធ្វើអ្នកប្រព្រឹត្តបែបនោះ ឲ្យប្រទះសេចក្តីវិនាសថ្ងៃណាមួយមិនខាន បើមិនធំក៏តូច ឲ្យឈ្មោះថាយកខ្លួនទៅរងទទួលនូវគ្រោះថ្នាក់និងសេចក្តីអន្តរាយណាមួយ នឹងជាគ្រឿងផ្តាច់បង់នូវសេចក្តីរាប់អានអំពីអ្នកដទៃ ។

១៥- **មទៈ** សេចក្តីស្រវឹង បានដល់ការដែលបណ្តោយចិត្តឲ្យវីលវល់ភ្វាត់ភ្វាំងឃ្លាតចាកសេចក្តីពិត, ភ្លេចខ្លួន គឺអ្នកមានយសស័ក្តិស្រវឹងក្នុងយសស័ក្តិ អ្នកមានទ្រព្យសម្បត្តិស្រវឹងក្នុងទ្រព្យសម្បត្តិ ភ្លេចសេចក្តីវិនាសអន្តរាយ អ្នកមានវ័យក្មេងស្រវឹងក្នុងវ័យក្មេងភ្លេចសេចក្តីស្លាប់, កិលេសធម៌នេះ អាចធ្វើមនុស្សទាំងនោះឲ្យបែរមុខទៅរកសេចក្តីវិនាសតែម្យ៉ាង ព្រោះសេចក្តីស្រវឹងរមែងបំបែរចិត្តមនុស្សទាំងនោះ ឲ្យខុសភ្វាត់ចាកហេតុដែលគួរធ្វើ ។

**១៦- បមាទះ** សេចក្តីប្រហែសធ្វេស បានដល់ការបណ្តែតបណ្តោយការងារដែលត្រូវធ្វើ, វិជ្ជាដែលត្រូវរៀនសូត្រ ឲ្យហួសពេលវេលា កាលសម័យ ដោយសេចក្តីអាងផ្សេងៗ មានអាងថានៅក្មេងនៅឡើយ ឬអាងពេលវេលាថានៅព្រឹកណាស់ ល្ងាចណាស់ជាដើម, កិលេសធម៌នេះជាហេតុនាំខ្លួនឲ្យខាតខានបានប្រយោជន៍ ដែលគួរបានឈ្មោះថាធ្វើខ្លួនឲ្យជាចំណីរបស់ថ្ងៃនិងយប់ទទេៗ ដូចជារបស់ដែលគេដាក់ចោលហាលភ្លៀងហាលថ្ងៃ នឹងទៅជារបស់ពុកផុយរលួយអសារឥតការ ។

## វាសនា ២ យ៉ាង

វាសនា ២ យ៉ាងនោះគឺកាយប្បយោគ ១ វចីបយោគ ១ ។

ដំណើរទំនងអាកប្បកិរិយាដែលធ្លាប់ប្រព្រឹត្ត ធ្លាប់សន្សំមកដោយកាយ ដូចយ៉ាងជាតិមុនធ្លាប់កើតជាសត្វស្វា ដែលជាសត្វរពឹសធ្លាប់លោតចុះឡើងលើមែកឈើ លុះរំលោងជាតិពីស្វានោះទៅ បានមកកើតជាមនុស្សដោយកុសលធម៌ណាមួយ ក៏ទម្លាប់អាកប្បកិរិយារបស់ស្វានោះជាប់មកផង, កាលបើដើរទៅប្រទះទឹកដែលដក់នៅទីណាមួយ ក៏លោតរំលងទីនោះ សេចក្តីធ្លាប់ជាប់ដោយកាយយ៉ាងនេះហៅថាកាយប្បយោគ ។

អាកប្បកិរិយាខាងពាក្យសម្តីដែលប្រព្រឹត្តជាប់មកដោយវាចាដូចជាតិមុនធ្លាប់កើតជាមនុស្សជាតិថោកទាប ហើយធ្លាប់ប្រព្រឹត្តនិយាយពាក្យ

អាក្រក់ត្រគោះបោះបោកណាមួយដែលជាពាក្យមិនពិរោះស្តាប់ លុះវិលាង ជាតិអំពីនោះមក ទោះបីបានមកកើតជាមនុស្សមានជាតិត្រកូលខ្ពង់ខ្ពស់ មានយសសក្តិធំដោយកុសលធម៌ណាមួយហើយ ក៏នៅតែប្រព្រឹត្តនិយាយ ពាក្យសម្តីអាក្រក់ដូចមុនទៀត សេចក្តីជាប់ជាប់ដោយសម្តីយ៉ាងនេះហៅ ថា វចីបយោគ ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយ គឺទ្រង់ដកព្រះទ័យឲ្យនៅ ឆ្ងាយអំពីកិលេសសព្វយ៉ាង ព្រោះទ្រង់កម្ចាត់បង់បាននូវកិលេស ព្រម ទាំងវាសនាដូចបានសម្តែងមកហើយដោយព្រះអរិយមគ្គញ្ញាណ ហេតុ នោះហើយទើបទ្រង់ព្រះនាមថា "ព្រះអរហំ" ។

១) អំពីទ្រង់បំបាក់បង់នូវសំសារចក្រ

"សំសារចក្រ" នេះកាត់ជាពីរបទគឺ "សំសារ" បទ ១ "ចក្រ" បទ ១ ។

សំសារ ប្រែថាកន្លែងដែលសត្វតែងស្លាប់កើតអន្ទោលចុះឡើង, ចក្រ ប្រែថាកង់ រួមជាប់ចូលគ្នាជាសំសារចក្រ ប្រែថាសំសារដូចជាកង់ ឬថាកង់គឺសំសារ, បានសេចក្តីថា កង់គឺសំសារនេះ មានអវិជ្ជា និងភវតណ្ហាជាដុំ, មានអភិសង្ខារបីយ៉ាងជាកាំ មានជរាទិងមរណៈជា ខ្នងកង់, មានសមុទ័យដែលប្រកបដោយអាសវក្កិលេសជាភ្លៅ, ប្រកប ចូលក្នុងរាងរថគឺភព ៣ ហើយវិលលឿនទៅឥតមានកាលវេលាឈប់ឈរ ឥតមានទីបំផុត ។

ក៏សំសារចក្រនេះឯង ដែលព្រះមានព្រះភាគ ទ្រង់សណ្ឋិតលើផែនដី គឺសីល ដោយព្រះបាទទាំងគូគឺព្យាយាម យកព្រះហស្តគឺសទ្ធា ទ្រង់ចាប់នូវព្រះខ័នគឺព្រះញាណ, កាប់ក្របែលនូវកាំកង់រថនោះឲ្យបាក់ខ្ទេចខ្ទីនៅនាពោធិមណ្ឌល, ព្រោះហេតុនោះ ទើបទ្រង់ព្រះនាម "ថាព្រះអរហំ" ព្រោះទ្រង់បំបាក់បង់នូវសំសារចក្រ ។

ន័យមួយទៀតថា សំសារវដ្ត ដែលវិលទៅក្នុងភពទាំង ៣ ហៅថា សំសារចក្រ, ក៏សំសារចក្រនេះឯង មានអវិជ្ជាទុកជាដុំ ព្រោះជាមូលហេតុ, មានសេចក្តីចាស់និងសេចក្តីស្លាប់ទុកជាខ្នងកង់ ព្រោះជាទីបំផុត មានធម៌ទាំង ១០ យ៉ាង មានសង្ខារជាដើមមានជាតិជាទីបំផុតទុកជាកាំ ព្រោះមានអវិជ្ជាជាមូលហេតុ និងព្រោះមានសេចក្តីចាស់សេចក្តីស្លាប់ជាទីបំផុត, ព្រះមានព្រះភាគអង្គនោះទ្រង់ជ្រាបនូវធម៌ទាំងអស់នេះជាក់លាក់ដោយធម្មដ្ឋិតិញ្ញាណ ហើយទ្រង់ណាយធុញទ្រាន់ក្នុងធម៌ទាំងឡាយនោះ ទើបទ្រង់កម្ចាត់បង់ ទ្រង់បំបាក់ទម្លាយបង់នូវកាំទាំងឡាយនៃសំសារចក្រនេះ មិនឲ្យមានសេសសល់, ហេតុនោះ ទើបទ្រង់ព្រះនាមថា "ព្រះអរហំ" ព្រោះទ្រង់បំបាក់បង់នូវសំសារចក្រ ។

## គ) អំពីទ្រង់គួរដល់គ្រឿងបូជាដ៏វិសេស

ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាបុគ្គលគួរទទួលនូវបច្ច័យ ព្រមទាំងគ្រឿងបូជាយ៉ាងវិសេសថ្លៃថ្លា របស់ទេវតានិងមនុស្សទាំងឡាយ ។

ពិតដូច្នោះមែន, កាលដែលព្រះពុទ្ធកើតម្តងៗ មនុស្សទេព្តាដែលមានសក្តិធំៗ មិនដែលយកគ្រឿងបូជាដ៏វិសេសទៅបូជាគ្រូដទៃៗឡើយ, តែងតែយកមកថ្វាយព្រះអង្គពុំខាន ដូចមានដំណាលរឿងស្តេចសហម្បតិព្រហ្មយកកម្រងផ្កាកែវមានសំណុំប៉ុនភ្នំសិនេរុមកថ្វាយព្រះអង្គ, ពពួកទេព្តាឯទៀតជាអនេកក៏តែងបូជាព្រះអង្គតាមកម្លាំងរបស់ខ្លួនៗ ដែរ ។ មនុស្សដែលមានសក្តិធំៗ មានស្តេចពិម្ពិសារជាដើម សុទ្ធសឹងតែបានថ្វាយគ្រឿងបូជាតម្លៃរាប់សែនកោដិ ឥតមានសេចក្តីស្តាយស្រណោះ, មិនតែប៉ុណ្ណោះ ទោះកាលព្រះអង្គបរិនិព្វានទៅហើយក្តី ក៏គង់នៅមានគេជ្រះ-ថ្លាថ្វាយគ្រឿងសក្ការបូជាទៀត, ដូចមានដំណាលរឿងស្តេចធម្មាសោកថាបានចំណាយព្រះរាជទ្រព្យ ៩៦ កោដិសាងវត្ត ៨ ម៉ឺន ៤ ពាន់ ក្នុងជម្ពូទ្វីបទាំងមូលឧទ្ទិសចំពោះព្រះអង្គ ។ ទេព្តានិងមនុស្សទាំងអស់នេះបានជាមានសេចក្តីជ្រះថ្លាលះបង់ទ្រព្យថ្លៃថ្លាទាំងអម្បាលនេះ ដោយយល់ឃើញថា ព្រះអង្គជាអគ្គទក្ខិណេយ្យបុគ្គលធ្វើមបណ្តាច់ជាងបដិគ្គាហកៈអ្នកទទួលទានទាំងអស់, ព្រោះទ្រង់អាចធ្វើទានដែលគេបូជាហើយនោះ ឲ្យមានអានិសង្សថ្លៃថ្លាឲ្យផលជាទិដ្ឋធម្មវេទនី ទាន់ភ្នែកភ្លាមៗ ក៏មាន ឲ្យផលទៅក្នុងអនាគតក៏មាន ឥតមានបដិគ្គាហកបុគ្គលណាមួយក្នុងលោកស្មើនឹងព្រះអង្គបាន, ទ្រង់គួរដល់គ្រឿងបូជាវិសេសមានបច្ច័យ ៤ ជាដើមយ៉ាងនេះទើបទ្រង់ព្រះនាមថា "ព្រះអរហំ" ព្រោះទ្រង់គួរដល់គ្រឿងបូជាដ៏វិសេស ។

## ឃ) អំពីទ្រង់មិនសម្ងំធ្វើបាបក្នុងទីកំបាំង

ព្រះមានជោគអង្គនោះ កុំថាតែទ្រង់គង់នៅក្នុងទីជួបជុំដោយពួកគណៈ សូម្បីទ្រង់គង់នៅក្នុងទីស្ងាត់តែមួយព្រះអង្គឯងក៏មិនដែលមានព្រះទ័យនឹកប្រារព្ធអំពីបាបណាមួយឡើយ, ទោះណាជាប្រទះហេតុអាក្រក់យ៉ាងល្មម ដែលបុថុជ្ជនយល់ថាគួរធ្វើ ក៏ព្រះអង្គមិនដែលធ្វើ, ពួកបុថុជ្ជនខ្លះក្នុងលោកនេះដែលសម្គាល់ខ្លួនថាជាបណ្ឌិត ទុកជាមិនហ៊ានធ្វើអំពើបាបចំពោះមុខគេឯង ក៏គង់លបលាក់លួចធ្វើក្នុងទីស្ងាត់កំបាំងពេលណាមួយពុំលែង, ដោយហេតុដែលពុំទាន់បានវៀរខ្លួនឲ្យរួចពីកណ្តាប់ដៃនៃកិលេសធម៌នៅឡើយ ឬក៏ដោយហេតុដែលលុះទៅក្នុងអំណាចនៃលោកធម៌ទាំង ៨ មានខ្លាចសាបសូន្យលាភសក្ការៈជាដើម ។ ចំណែកព្រះបរមគ្រូព្រះអង្គមិនដូច្នោះឡើយ, ហេតុនោះហើយ ទើបទ្រង់ព្រះនាមថា "ព្រះអរហំ" ព្រោះព្រះអង្គមិនសម្ងំធ្វើបាបក្នុងទីកំបាំង ។

## (២) វិនិច្ឆ័យបទថា "សម្មាសម្ពុទ្ធោ"

### សេចក្ដីសួរដែលគួរចាំ

*១- អ្វីហៅថា ញេយ្យធម៌? មានប៉ុន្មាន? គឺធម៌អ្វីខ្លះ?*

### សេចក្ដីឆ្លើយ

*១- ធម៌ដែលព្រះអង្គគប្បីត្រាស់ដឹងបាន ហៅថាញេយ្យធម៌ មាន ៤ យ៉ាងគឺ បរិញ្ញេយ្យធម៌ ១, បហាតព្វធម៌ ១, សច្ឆិកាតព្វធម៌ ១, ភាវេតព្វធម៌ ១ ។*

### សេចក្ដីអធិប្បាយ

*គ្រឿងព្រួយ គ្រឿងលំបាកដែលសត្វទាំងឡាយតែងជួបប្រទះហៅថាទុក្ខ, មាន ១៣គឺ* **ជាតិទុក្ខ** *គ្រឿងទុក្ខគឺជាតិកំណើត ១,* **ជរាទុក្ខ** *គ្រឿងទុក្ខគឺការគ្រាំគ្រាទ្រុឌទ្រោមរាងកាយ ១,* **ព្យាធិទុក្ខ** *គ្រឿងទុក្ខគឺជំងឺឈឺចាប់ ១,* **មរណទុក្ខ** *គ្រឿងទុក្ខគឺសេចក្ដីស្លាប់ ១,* **សោកទុក្ខ** *គ្រឿងទុក្ខគឺសេចក្ដីក្រៀមក្រំ ១,* **បរិទេវទុក្ខ** *គ្រឿងទុក្ខគឺសេចក្ដីខ្សឹកខ្សួល ១,* **ទុក្ខទុក្ខ** *គ្រឿងទុក្ខគឺសេចក្ដីលំបាកកាយ ១,* **ទោមនស្សទុក្ខ** *គ្រឿងទុក្ខគឺសេចក្ដីអាក់អន់តូចចិត្ត ឬសេចក្ដីលំបាកចិត្ត ១,* **ឧបាយាសទុក្ខ** *គ្រឿងទុក្ខគឺសេចក្ដីស្ដាយស្រណោះ ១,* **អប្បិយេហិ សម្បយោគទុក្ខ** *គ្រឿងទុក្ខគឺការជួបប្រទះរបស់*

ដែលមិនគាប់ចិត្ត ១, **បិយេហិ វិប្បយោគទុក្ខ** គ្រឿងទុក្ខគឺការប្រាសនិរាសចាករបស់ដែលគាប់ចិត្ត ១, **យម្បិច្ឆំ ន លភតិ តម្បិទុក្ខ** គ្រឿងទុក្ខគឺសេចក្ដីមិនសមតាមប្រាថ្នា គឺថារបស់អ្វីដែលខ្លួនប្រាថ្នា មិនបានទូវរបស់នោះ ១, **បញ្ចុប្បាទានក្ខន្ធទុក្ខ** គ្រឿងទុក្ខគឺឧបាទានក្ខន្ធទាំងប្រាំ ១ ។ រួមគ្រឿងទុក្ខទាំងអស់នេះឈ្មោះថា បរិញ្ញេយ្យធម៌ ព្រោះជាធម៌ដែលព្រះអង្គគប្បីកំណត់ដឹងបាន ។

ហេតុដែលនាំឲ្យកើតទុក្ខទាំងនេះ ហៅថាសមុទ័យ បានដល់តណ្ហា គឺសេចក្ដីប្រាថ្នាស្រេកឃ្លានដែលប្រវត្តទៅក្នុងភពទាំងបី, មាន ១០៨ គឺកាមតណ្ហា ៣៦, ភវតណ្ហា ៣៦, វិភវតណ្ហា ៣៦ ។

សេចក្ដីប្រាថ្នាដែលប្រព្រឹត្តទៅក្នុងកាមភព ហៅថា កាមតណ្ហា, សេចក្ដីប្រាថ្នាដែលប្រព្រឹត្តទៅក្នុងរូបភព ហៅថា ភវតណ្ហា, សេចក្ដីប្រាថ្នាដែលប្រព្រឹត្តទៅក្នុងអរូបភព ហៅថា វិភវតណ្ហា ។

កាមតណ្ហា ចែកចេញជា ៦ គឺ **រូបតណ្ហា** សេចក្ដីប្រាថ្នារូប ១, **សទ្ទតណ្ហា** សេចក្ដីប្រាថ្នាសំឡេង ១, **គន្ធតណ្ហា** សេចក្ដីប្រាថ្នាវត្ថុមានក្លិនក្រអូប ១, **រសតណ្ហា** សេចក្ដីប្រាថ្នារស ១, **ផោដ្ឋព្វតណ្ហា** សេចក្ដីប្រាថ្នាវត្ថុដែលប៉ះពាល់ដោយកាយ ១, **ធម្មតណ្ហា** សេចក្ដីប្រាថ្នាអារម្មណ៍ដែលប៉ះពាល់ដោយចិត្ត ១ ។ តណ្ហាទាំងនេះ ចែកចេញ

ជាខាងក្នុង ៦ ខាងក្រៅ[១] ៦ រួមជា ១២, តណ្ហាទាំង ១២ នេះចែកចេញជា អតីតតណ្ហា ១២ អនាគតតណ្ហា ១២ បច្ចុប្បន្នតណ្ហា[២] ១២ រួមគ្រប់កាល ទាំង ៣ ជា ៣៦ ។ ភវតណ្ហា និងវិភវតណ្ហា ក៏ចែកចេញជា ៣៦ ។ ដូចន័យនេះដែរ, រួបរួមប្រភេទនៃតណ្ហាទាំង ៣ ត្រូវជាតណ្ហា ១០៨ ។

តណ្ហាទាំងអស់ដែលមានឈ្មោះថា "សមុទ័យ"នេះ លោកឲ្យឈ្មោះថា **បហាតព្វធម៌** ព្រោះជាធម៌ដែលត្រូវលះបង់ ។

ធម៌ជាគ្រឿងខ្ចាស់រាំងមិនឲ្យធម៌ទាំងពីរខាងដើមនេះ វិលបានតទៅទៀត ឬជាជាគ្រឿងធ្វើឲ្យធម៌ទាំងពីរខាងដើមនេះរលត់បាត់ទៅ ហៅថា និរោធ បានដល់ព្រះនិព្វានដែលមាននាម ៣២ ដូច្នេះគឺ **អជាតិ** ព្រះនិព្វានមិនមានកំណើត ១, **អជរំ** ព្រះនិព្វានឥតមានចាស់គ្រាំគ្រា ១, **អព្យាធិ** ព្រះនិព្វានឥតមានការឈឺចាប់ ១, **និព្ភយំ** ព្រះនិព្វានឥតមានភ័យ ១, **អសំខតំ** ព្រះនិព្វានឥតមានបច្ច័យតាំងតែងបាន ១, **ភវភិង្គនំ** ព្រះនិព្វានទម្លាយចោលនូវភពបី ១, **សុខំ** ព្រះនិព្វានមានតែសេចក្តីសុខ ១, **សីតំ** ព្រះនិព្វានជាទីត្រជាក់ ១, **ខេមំ** ព្រះនិព្វានជាស្ថានក្សេមក្សាន្ត ១, **តាណំ** ព្រះនិព្វានជាទីពឹងពួន ១, **លេណំ** ព្រះ

---

១- តណ្ហាខាងក្នុងប្រារព្ធយករូបរបស់ខ្លួន តណ្ហាខាងក្រៅប្រារព្ធយករូបរបស់បុគ្គលដទៃ ។

២ សេចក្តីប្រាថ្នាដែលកន្លងហួសទៅហើយ ហៅថា អតីតតណ្ហា, ដែលមិនទាន់មានមកដល់ហៅថា អនាគតតណ្ហា ដែលមាននៅក្នុងជាតិជាបច្ចុប្បន្ន ហៅថា បច្ចុប្បន្នតណ្ហា

និព្វានជាទីជ្រកកោន ១, **និច្ចំ** ព្រះនិព្វានទៀងទាត់ឥតប្រែប្រួល ១, **អចលំ** ព្រះនិព្វានឥតមានកម្រើកញាប់ញ័រ ១, **ធុវសស្សតំ** ព្រះនិព្វាននឹងនួនប្រាកដ ១, **អវជ្ជសារំ** ព្រះនិព្វានមានខ្លឹមសារឥតវិលវល់ ១, **សុខមគ្គនំ** ព្រះនិព្វានអាចបន្ទោរបង់នូវសេចក្តីសុខជារបស់មនុស្សទេព្តាមារព្រហ្ម ១, **ខុគ្គមគ្គនំ** ព្រះនិព្វានអាចកម្ចាត់បង់នូវសេចក្តីឃ្លាន ១, **បិចាសវិជយំ** ព្រះនិព្វានអាចកម្ចាត់បង់នូវសេចក្តីស្រេក ១, **អជាលយំ** ព្រះនិព្វានឥតមានសេចក្តីអាល័យ ១, **សមុគ្ឃាដវជ្ជំជង្ខេសំ** ព្រះនិព្វានមានទោសគឺកិលេសដែលនៅជាប់ក្នុងសន្តានរបស់សត្វ ដូចជាពិសរបស់ពស់ដកផុតស្រឡះចេញហើយ ១, **វិសំខារំ** ព្រះនិព្វានប្រាស់ចាកសង្ខារគឺនាមនិងរូប ១, **តណ្ហាក្ខយំ** ព្រះនិព្វានជាទីក្ស័យនៃតណ្ហា ១, **វិភវំ** ព្រះនិព្វានប្រាសចាកភពទាំងបី ១, **វិវជ្ជំ** ព្រះនិព្វានផុតចាកទោសគ្រប់យ៉ាង ១, **វិរាគំ** ព្រះនិព្វានផុតចាករាគៈ ១, **វីតមោហំ** ព្រះនិព្វានប្រាសចាកមោហៈ ១, **និរោធំ** ព្រះនិព្វានជាទីរំលត់ទុក្ខសព្វយ៉ាង ១, **អនិមិត្តំ** ព្រះនិព្វានមិនមាននិមិត្ត ១, **សន្តិការំ** ព្រះនិព្វានមានភាពរម្ងាប់កិលេស ១, **អរសាគារំ** ព្រះនិព្វាន ឥតមានរសនៃតណ្ហា ១, **អប្បស្សាបស្សំ** ព្រះនិព្វានឥតមានខ្យល់ដង្ហើមចេញចូល ១, **អមតំ** ព្រះនិព្វានមិនចេះស្លាប់ ១ ។ ធម៌ដែលមានឈ្មោះថានិរោធបានដល់ព្រះនិព្វានដែលមានឈ្មោះ ៣២ នេះលោក

ឲ្យឈ្មោះថាសច្ចិកាតព្វធម៌ ព្រោះជាធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ។

ឧបាយឬផ្លូវដែលជាហេតុឲ្យបាននូវនិរោធនេះ ហៅថា មគ្គ មាន៨គឺ

១- **សម្មាទិដ្ឋិ** សេចក្តីយល់ត្រូវ, ពោលដោយឧក្រិដ្ឋបានដល់បញ្ញាដែលក្លៀវក្លា មានព្រះនិព្វានជាអារម្មណ៍ អាចឃើញច្បាស់នូវអរិយ-សច្ច ៤, ពោលដោយថយចុះមក បានដល់បញ្ញាដែលឈ្វេងយល់ក្នុងគុណព្រះរត្នត្រ័យនិងកម្មឬផលនៃកម្មជាដើម ។

២- **សម្មាសង្កប្បោ** សេចក្តីត្រិះរិះត្រូវ, បាលដល់សេចក្តីត្រិះរិះ ៣ យ៉ាងគឺ ត្រិះរិះដើម្បីមិនព្យាបាទអ្នកដទៃ ១, ត្រិះរិះដើម្បីមិនបៀត-បៀនអ្នកដទៃ ១, ត្រិះរិះដើម្បីចេញចាកកាម ១, ឬពុំនោះសោតសេចក្តីត្រិះរិះដទៃទៀត មានត្រិះរិះដើម្បីធ្វើទានរក្សាសីលជាដើម ។

៣- **សម្មាវាចា** សម្តីត្រូវ, បានដល់ការនិយាយវៀរចាកសម្តីខុស ៤ យ៉ាងគឺ សម្តីកុហក ១, សម្តីញុះញង់ស៊កសៀត ១, សម្តីត្រគោះបោះបោក ១, សម្តីប្រឌិតឥតហេតុផល ១ ។

៤- **សម្មាកម្មន្តោ** ការងារត្រូវ, បានដល់ការងារដែលឥតមានទោស វៀរចាកការងារខុស ៣ យ៉ាងគឺសម្លាប់សត្វ ១, លួចទ្រព្យគេ ១ ប្រព្រឹត្តសេវនកម្មដោយបុត្រកិរិយារបស់អ្នកដទៃ ១ ។

៥- **សម្មាអាជីវោ** ការចិញ្ចឹមជីវិតត្រូវ, បានដល់ការចិញ្ចឹមជី-វិតឥតទោស, ចំពោះបព្វជិត ត្រូវវៀរចាកបាបធម៌ ៥, អនេសនៈ (ការ

ស្វែងរកមិនគួរ) ២១, ចំណែកគ្រហស្ថត្រូវវៀរចាកជំនួញខុស ៥ ប្រការ គឺ លក់មនុស្ស ១, លក់គ្រឿងសស្ត្រាវុធ ១, លក់សត្វឬសម្លាប់សត្វយកសាច់លក់ ១, លក់ទឹកស្រវឹង ១, លក់ថ្នាំពិសថ្នាំពុល ១ ។

កិច្ចការឯទៀតដែលពុំសមគួរតាមធម៌ មានបំបាត់បំភាន់គេដោយជញ្ជីងកោងជាដើម ក៏គ្រហស្ថទាំងឡាយត្រូវវៀរឲ្យស្រឡះដែរ ទើបហៅថា សម្មាអាជីវៈបាន ។

៦- **សម្មាវាយាមោ** សេចក្ដីព្យាយាមត្រូវ, បានដល់សេចក្ដីព្យាយាម ៤ យ៉ាងគឺ ព្យាយាមដើម្បីញុំាងបាបដែលបម្រុងនឹងកើតឡើងមិនឲ្យកើតឡើង ១, ព្យាយាមដើម្បីលះបាបដែលធ្លាប់កើតមកហើយឲ្យអាក់ខានទៅវិញ ១, ព្យាយាមដើម្បីញុំាងបុណ្យដែលមិនធ្លាប់កើតឲ្យកើតឡើង ១, ព្យាយាមដើម្បីញុំាងបុណ្យដែលធ្លាប់កើតមកហើយ ឲ្យបានកើនចម្រើនជាកិយ្យោភាពឡើងទៀត ១ ។

៧- **សម្មាសតិ** សេចក្ដីរឭកត្រូវ, បានដល់សេចក្ដីរឭក ៤ ប្រការ គឺ រឭករឿយៗ ចំពោះរូបកាយថាមិនទៀង, ថាជាទុក្ខ, ថាមិនមែនជារបស់ខ្លួន ១, រឭករឿយៗ ចំពោះវេទនាថាមិនទៀង, ថាជាទុក្ខ, ថាមិនមែនជារបស់ខ្លួន ១, រឭករឿយៗ ចំពោះវិញ្ញាណថាមិនទៀង, ថាជាទុក្ខ, ថាមិនមែនជារបស់ខ្លួន ១, រឭករឿយៗ ចំពោះធម៌ថាមិនទៀង, ថាជាទុក្ខ, ថាមិនមែនជារបស់ខ្លួន ១ ។

៨- **សម្មាសមាធិ** *សេចក្ដីតម្កល់ចិត្តត្រូវ, បានដល់ការតម្កល់ចិត្ត ៣ ប្រការគឺ ការតម្កល់ចិត្តឲ្យនឹងក្នុងពេលដែលធ្វើកុសលមានស្ដាប់ធម៌ទេសនាជាដើម ១,[1] ការតម្កល់ចិត្តឲ្យនឹងក្នុងពេលដែលទៀបនឹងបានឈានទាំង ៥ ឈានណាមួយ ១, ការតម្កល់ចិត្តឲ្យនឹងក្នុងពេលដែលបានឈានទាំង ៥ ឈានណាមួយស៊ប់ហើយ ១ ។*

*រួមឧបាយឬ ផ្លូវដែលជាហេតុឲ្យបាននូវនិរោធ ហៅថាមគ្គ ៧ នេះលោកឲ្យឈ្មោះថា ភាវេតព្វធម៌ ព្រោះជាធម៌ដែលចម្រើនឲ្យកើនឡើង ។*

---

១- ការតម្កល់ចិត្តរបៀបទី ១ ឈ្មោះថា ខណិកសមាធិ របៀបទី ២ ឈ្មោះថាឧបចារសមាធិ, របៀបទី ៣ ឈ្មោះថា អប្បនាសមាធិ ។

## (៣) វិនិច្ឆ័យបទថា "វិជ្ជាចរណសម្បន្នោ"

### សេចក្ដីសួរដែលគួរបាំ

១- **វិជ្ជា** *ប្រែថា ដូចម្ដេច?*

២- **ចរណៈ** *ប្រែថា ដូចម្ដេច?*

៣- **វិជ្ជា** និង **ចរណៈ** *មានគុណសម្បត្តិដូចម្ដេច?*

### សេចក្ដីឆ្លើយ

*១- **វិជ្ជា** ប្រែថា សេចក្ដីចេះដឹង ឬថាធម្មជាតិកម្ចាត់បង់នូវងងឹតគឺសេចក្ដីល្ងង់ ។*

*២- **ចរណៈ** ប្រែថា ដំណើរទៅកាន់សិវស្ថានគឺអមតមហានិព្វានរបស់ព្រះអរិយបុគ្គល ។*

*៣- មានគុណសម្បត្តិដូច្នេះ គឺ វិជ្ជាអាចឲ្យសម្រេចសម្មាសម្ពោធិញ្ញាណ, ចរណៈ អាចឲ្យសម្រេចមហាករុណាគុណចំពោះសត្វ ។*

### សេចក្ដីអធិប្បាយ

*បណ្ដាសេចក្ដីចេះដឹងទាំងអស់ ដែលឥតទោស ទោះបីទាបក្ដី, ខ្ពស់ក្ដី រួបរួមមកឲ្យឈ្មោះថា វិជ្ជា, មាន ២ យ៉ាងគឺ លោកិយវិជ្ជា ១, លោកុត្តរវិជ្ជា ១ ។*

*វិជ្ជាសម្រាប់លោក ឬវិជ្ជាប្រព្រឹត្តទៅក្នុងលោក មានវិជ្ជាអក្សរលេខនព្វន្ត គ្រឿងយន្ត, គ្រឿងចក្រជាដើម ហៅថា លោកិយវិជ្ជា, វិជ្ជាដែល*

ជាគ្រឿងធ្វើខ្លួនឲ្យឆ្លងចេញចាកត្រៃលោក ហៅថា លោកុត្តរវិជ្ជា ។

ឯវិជ្ជា ដែលមានមកក្នុងវិជ្ជាចរណកថានេះ ក៏ជាភាគមួយរបស់លោកុត្តរវិជ្ជាដែរ, វិជ្ជានេះឯង មាន ៣ យ៉ាងក៏មាន ៨ យ៉ាងក៏មាន ។

វិជ្ជា ៣ និងវិជ្ជា ៨

១- **បុព្វេនិវាសានុស្សតិញ្ញាណ** ប្រាជ្ញាដែលតាមរឭកឃើញនូវលំដាប់នៃខន្ធដែលសត្វអាស្រ័យនៅហើយក្នុងកាលមុន, បានដល់ប្រាជ្ញាដែលទ្រង់រឭកសាវទៅខាងដើម តាំងអំពីជាតិទី ១-២-៣-៤-៥-៦-៧-៨-៩-១០ រហូតដល់សែនអសង្ខេយ្យជាតិ អាចរឭកឃើញច្បាស់បានក្នុងជាតិមួយៗថា ព្រះអង្គកាលកើតឯណោះ មានឈ្មោះយ៉ាងនេះ, មានអាហារយ៉ាងនេះ, មានការសោយសុខ-ទុក្ខដូច្នេះ, មានអាយុប៉ុណ្ណោះ លុះច្យុតអំពីទីនោះ បានមកកើតក្នុងទីនេះៗ ទៀត តាមលំដាប់ជាតិហូរហែមកយ៉ាងនេះឯង ។

២- **ចុតូបបាតញ្ញាណ** ប្រាជ្ញាដែលដឹង នូវចុតិនិងបដិសន្ធិរបស់សព្វសត្វ, បានដល់ប្រាជ្ញាដែលកើតអំពីចក្ខុទិព្វ កន្លងលើសចក្ខុទេព្តាមារព្រហ្ម, ទតឃើញនូវពួកសត្វដែលច្យុតដែលកើត ជាសត្វថោកទាបខ្លះ, ខ្ពង់ខ្ពស់ខ្លះ, មានរូបល្អខ្លះ, អាក្រក់ខ្លះ, មានគតិល្អខ្លះ, អាក្រក់ខ្លះ, មួយវិញទៀតទ្រង់ជ្រាបថាសត្វដែលប្រព្រឹត្តទុច្ចរិត ដោយកាយក្តី, ដោយវាចាក្តី, ដោយចិត្តក្តី បែបនេះៗ លុះរំលាងជាតិពីនេះទៅ នឹងបានទៅ

កើតក្នុងទុគ្គតិភពយ៉ាងនេះៗ ឬក៏សត្វដែលប្រព្រឹត្តសុចរិត ដោយកាយក្តី, ដោយវាចាក្តី, ដោយចិត្តក្តី បែបនេះៗ លុះវំលោងជាតិពីនេះទៅ នឹងបានទៅកើតក្នុងសុគតិភពជាន់នោះៗ ដូច្នេះឯង ។

៣- **អាសវក្ខយញ្ញាណ** ប្រាជ្ញាដែលដឹងនូវឧបាយធ្វើឲ្យអស់ទៅនៃអាសវៈ បានដល់ប្រាជ្ញាដែលទ្រង់ជ្រាបថា នេះជាទុក្ខ, នេះហេតុឲ្យកើតទុក្ខ, នេះទីរលត់ទុក្ខ, នេះបដិបទាដែលនាំឲ្យដល់ទីរលត់ទុក្ខ និងទ្រង់ជ្រាបថា នេះអាសវៈ, នេះហេតុឲ្យកើតអាសវៈ, នេះទីរលត់អាសវៈ, នេះហេតុឲ្យរលត់អាសវៈ ដូច្នេះឯង ។

ឯវិជ្ជា ៨ ក៏លោករាប់យកវិជ្ជា ៣ ខាងដើមនេះមកផ្សំនឹងវិជ្ជា ៥ ដទៃទៀត ដូចតទៅនេះ៖

៤- **វិបស្សនាញាណ** ប្រាជ្ញាដែលដឹងច្បាស់នូវកាយនេះថាគ្រាន់តែជាធាតុ ៤, បានដល់ប្រាជ្ញាដែលពិចារណា ឃើញនូវកាយនេះថាគ្រាន់តែជាធាតុ ៤ គឺ ដី, ទឹក, ភ្លើង, ខ្យល់ ប៉ុណ្ណោះ ជាសភាពមិនទៀងទាត់ស្ថិតស្ថេរ តែងនាំមកនូវសេចក្តីទុក្ខ ព្រោះជាសភាពមិនមែនជារបស់ខ្លួន ។

៥- **មនោមយិទ្ធិញ្ញាណ** ប្រាជ្ញាដែលអាចញ៉ាំងឫទ្ធិឲ្យសម្រេចដោយចិត្តគិត, បានដល់ប្រាជ្ញាដែលអាចឲ្យសម្រេចឫទ្ធិតាមព្រះទ័យដែលបំណងបាន ទោះបីចង់និមិត្តឲ្យកើតជាវត្ថុអ្វីក៏ដោយក៏ទ្រង់និមិត្តបានទាំងអស់ ស្រេចហើយតែព្រះទ័យបំណង ។

៦- **ឥទ្ធិវិធញ្ញាណ** ប្រាជ្ញាដែលប្រកបដោយការគាក់តែងឫទ្ធិដោយកាយ, បានដល់ប្រាជ្ញាដែលទ្រង់អាចនិមិត្តកាយតែមួយឲ្យទៅជាកាយច្រើនបាន ឬក៏កាយច្រើនអាចនិមិត្តឲ្យទៅជាកាយតែមួយវិញបាន ហើយអាចយាងទៅកាន់ទិសព្វស្ថានបាន, ទោះក្នុងទឹកក្តី ក្នុងដីក្តី ក្នុងភ្នំក្តី ក្នុងអាកាសក្តី ឥតទើសទាក់បានដូចគ្នាទាំងអស់ ។

៧- **ទិព្វសោតញ្ញាណ** ប្រាជ្ញាអាស្រ័យដោយព្រះស្រោតដូចជាទិព្វ, បានដល់ប្រាជ្ញាដែលអាស្រ័យដោយព្រះស្រោតទិព្វ អាចស្តាប់សំឡេងទាំងពីរយ៉ាងបាន គឺសំឡេងទិព្វនិងសំឡេងមនុស្ស ទោះជាសំឡេងតិចក្តី ខ្លាំងក្តី ជិតក្តី ឆ្ងាយក្តី ទ្រង់ស្តាប់បានទាំងអស់ ។

៨- **ចេតោបរិយញ្ញាណ** ប្រាជ្ញាកំណត់ដឹងនូវចិត្តរបស់អ្នកដទៃបាន, បានដល់ប្រាជ្ញាដែលអាចកំណត់ដឹងចិត្តរបស់អ្នកដទៃដោយព្រះទ័យរបស់ព្រះអង្គ គឺបើសត្វដែលមានចិត្តប្រកបដោយរាគៈក្តី ប្រាសចាករាគៈក្តី, ប្រកបដោយទោសៈក្តី, ប្រាសចាកទោសៈក្តី, ប្រកបដោយមោហៈក្តី, ប្រាសចាកមោហៈក្តី, ដែលមានអារម្មណ៍មូលក្តី រាយមាយក្តី, ដែលមានមហគ្គតចិត្តក្តី មិនមែនជាមហគ្គតចិត្តក្តី, ដែលជាលោកិយចិត្តក្តី លោកុត្តរចិត្តក្តី, ដែលតម្កល់ល្អក្នុងសមាធិក្តី, មិនតម្កល់ល្អក្នុងសមាធិក្តី ដែលរួចចាកកិលេសាសវៈក្តី មិនទាន់រួចចាកកិលេសាសវៈក្តី ព្រះអង្គទ្រង់ជ្រាបប្រាកដតាមទំនងនោះៗឯង ។

ចរណៈ ១៥ គឺ

១- **សីលសំវរោ** *សេចក្ដីសង្រួមក្នុងសីល, បានដល់ការធ្វើកាយវាចាឲ្យរៀបរយ មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទដែលមានក្នុងបាតិមោក្ខសំវរសីល ព្រមទាំងបរិបូណ៌ដោយអាចារៈ*[១] *និងគោចរៈ*[២] ។

២- **ឥន្ទ្រិយេសុ គុត្តទ្វារតា** *សេចក្ដីសង្រួមទ្វារក្នុងឥន្ទ្រិយទាំង ៦ បានដល់ការរក្សាទ្វារទាំង ៦ ប្រយ័ត្នមិនឲ្យប៉ះពាល់ ដោយអារម្មណ៍ជាទំនាស់ដែលជាហេតុឲ្យកើតអកុសលធម៌មានអភិជ្ឈានិងទោមនស្សជាដើម* ។

៣- **ភោជនេ មត្តញ្ញុតា** *ការដឹងប្រមាណក្នុងភោជន, បានដល់ការដឹងប្រមាណ ៣ យ៉ាង គឺដឹងប្រមាណក្នុងការស្វែងរកនូវភោជនតាមផ្លូវដែលឥតទោស ១, ដឹងប្រមាណក្នុងការទទួលភោជនតាមផ្លូវដែលឥតទោស ១, ដឹងប្រមាណក្នុងការបរិភោគភោជនល្មមគ្រាន់ ១* ។

៤- **ជាគរិយានុយោគោ** *ប្រកបសេចក្ដីព្យាយាមរឿយៗ ក្នុងការភ្ញាក់រឭក, បានដល់ការដែលខំចង្រ្កម ខំចម្រើនឈានទាំងយប់-ថ្ងៃ ក្នុងពេលយប់ សម្រេចសីហសេយ្យាតែត្រឹមមជ្ឈិមយាមមួយប៉ុណ្ណោះ* ។

៥- **សទ្ធា** *ជឿវត្ថុដែលគួរជឿ, បានដល់ការជឿប្រាជ្ញា*

---

១- អាចារៈ ការប្រព្រឹត្តគួរសម, មានមារយាទ គួនឹងពាក្យថា អនាចារៈ ការប្រព្រឹត្តមិនសមគួរ, ឥតមារយាទ។ ២- កន្លែងមិនគួរភិក្ខុត្រេចទៅ ហៅថា អគោចរស្ថាន មាន ៦ គឺ លំនៅស្ត្រីផ្កាមាស ១, លំនៅស្ត្រីមេម៉ាយ ១, លំនៅស្ត្រីសាវក្រៃ ១, លំនៅមនុស្សខ្ទើយ ១, លំនៅនាងភិក្ខុនី ១, រោងលក់សុរា ១, កន្លែងក្រៅពីអគោចរស្ថានទាំង ៦ នេះ ហៅថា គោចរៈ ។

ជាគ្រឿងត្រាស់ដឹងរបស់ព្រះអង្គ មានជឿថា ទ្រង់ឆ្ងាយចាកសឹកសត្រូវគឺកិលេសជាដើម ។

៦- **ហិរិ** សេចក្តីខ្មាសអំពើទុច្ចរិត បានដល់ការខ្ពើមអំពើបាបមិនចង់ប៉ះពាល់អំពើបាបដោយកាយ វាចា ចិត្ត ដូចជាបុរសស្អាតដែលខ្ពើមលាមក ។

៧- **ឱត្តប្បៈ** សេចក្តីស្ញុតខ្លាចអំពើទុច្ចរិត, បានដល់ការខ្លាចមិនហ៊ានធ្វើអំពើបាប ដោយកាយ វាចា ចិត្ត ដូចជាបុរសដែលខ្លាចក្តៅមិនហ៊ានប៉ះពាល់ដងើកភ្លើង ។

៨- **ពាហុសច្ចៈ** ការចេះចាំធម៌វិន័យច្រើន, បានដល់ការដែលព្រះអង្គបានចេះដឹងច្រើន ហើយប្រព្រឹត្តតាមសេចក្តីចេះដឹងនោះ ។

៩- **វិរិយារម្ភៈ** ការប្រារព្ធសេចក្តីព្យាយាម, បានដល់ការព្យាយាមលះអកុសលធម៌និងព្យាយាមញ៉ាំងកុសលធម៌ឲ្យកើតឡើង ។

១០- **សតិ** មានស្មារតី បានដល់ការប្រុងស្មារតីរឭករកសេចក្តីត្រូវឲ្យនៅចាំជាក់ក្នុងសន្តាន ដើម្បីផ្ទៀងព្រះទ័យមិនឲ្យប្រព្រឹត្តលំអៀងទៅលើអំពើទុច្ចរិត ។

១១- **បញ្ញា** មានប្រាជ្ញា, បានដល់ប្រាជ្ញាដែលដឹងច្បាស់នូវអរិយសច្ច ៤ និងប្រាជ្ញាដែលអាចទម្លុះទម្លាយនូវអកុសលមូលបាន ។

១២- **បឋមជ្ឈាន**[១] ឈានទី ១, បានដល់រូបាវចរកុសលចិត្ត ដែលផុតស្រឡះចាកបច្ចនីកធម៌ ៥ យ៉ាង ហើយប្រកបដោយធម៌ ៥ យ៉ាងគឺ វិតក្ក ១, វិចារ ១, បីតិ ១, សុខ ១, ឯកគ្គតា ១ ។

១៣- **ទុតិយជ្ឈាន** ឈានទី ២, បានដល់រូបាវចរកុសលចិត្ត ដែលធ្វងផុតចាកធម៌ ២ យ៉ាង គឺវិតក្ក និងវិចារ ហើយប្រកបដោយធម៌ ៣ យ៉ាងគឺ បីតិ ១, សុខ ១, ឯកគ្គតា ១ ។

១៤- **តតិយជ្ឈាន** ឈានទី ៣, បានដល់រូបាវចរកុសលចិត្ត ដែលធ្វងផុតស្រឡះចាកធម៌ ៣ យ៉ាង គឺ វិតក្ក ១, វិចារ ១, បីតិ ១, ហើយប្រកបដោយធម៌ ២ យ៉ាងគឺ សុខ និងឯកគ្គតា ។

១៥- **ចតុត្ថជ្ឈាន** ឈានទី ៤, បានដល់រូបាវចរកុសលចិត្តដែលធ្វងផុតស្រឡះចាកសុខ ហើយប្រកបដោយធម៌ ២ យ៉ាងគឺ ឧបេក្ខា និងឯក-គ្គតា ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់អាស្រ័យនូវគុណសម្បត្តិគឺ វិជ្ជា និង ចរណៈ ដូច្នេះទើបអាចប្រដៅសត្វឲ្យបែរមុខចេញចាកហេតុវិនាស ហើយឈមមុខទៅរកហេតុចម្រើនបាន ហេតុនោះហើយ បានជាសាវ័កអ្នកស្តាប់ឱវាទ

---

១- ឈានតាមន័យនេះជាចតុក្កន័យ គឺមានត្រឹមចតុត្ថជ្ឈាន, មានន័យខ្លះ ជាបញ្ចកន័យមានបញ្ចមជ្ឈានផង តែគង់មានសេចក្តីប្រហែលគ្នា ព្រោះមានអង្គត្រឹម ៥ ដូចគ្នា ប្លែកតែត្រង់បែកអង្គប៉ុណ្ណោះគឺ បញ្ចកន័យ អង្គទុតិយជ្ឈាន បែកជាអង្គទុតិយជ្ឈានផងតតិយជ្ឈានផង អង្គតតិយ-ជ្ឈានបែកជាអង្គចតុត្ថជ្ឈាននិងបញ្ចមជ្ឈាន ។

របស់ព្រះអង្គសុទ្ធតែប្រតិបត្តិត្រូវ មិនដែលប្រតិបត្តិខុសដូចជាសាវ័ករបស់គ្រូដទៃដែលជាអ្នកវិបត្តិចាកវិជ្ជានិងចរណៈ មាននិគ្រណ្ឋឈ្មោះអត្តន្តបៈជាដើម ។

# (៤)- វិនិច្ឆ័យបទថា "សុគតោ"

---

សេចក្ដីសួរដែលគួរចាំ

១- **សុគតោ** *ប្រែបានដូចម្ដេចខ្លះ?*

សេចក្ដីឆ្លើយ

**សុគតោ** *ប្រែបាន ៤ ន័យដូច្នេះ ៖*

**ក**) *ព្រោះទ្រង់មានដំណើរល្អ*

**ខ**) *ព្រោះទ្រង់យាងទៅកាន់ទីដ៏ល្អ,*

**គ**) *ព្រោះទ្រង់យាងទៅដោយប្រពៃ,*

**ឃ**) *ព្រោះទ្រង់ត្រាស់តែវាចាត្រូវ។*

អធិប្បាយ

**ក**) អំពីទ្រង់មានដំណើរល្អ

*ព្រះសុគតទ្រង់មានដំណើរបរិសុទ្ធស្អាត ព្រោះឥតមានទោស, ដំណើរនោះឯងបានដល់អរិយមគ្គដែលជាផ្លូវដ៏ប្រសើរ ជាផ្លូវសម្រាប់ព្រះអរិយៈ តែងគោចរទៅកាន់ទីដែលបុថុជ្ជនមិនធ្លាប់ទៅ ជាទីក្សេមក្សាន្តបានដល់អមតមហានិព្វាន ព្រះសុគតទ្រង់យាងទៅកាន់ទីដ៏ឧត្តមនេះបានតាមផ្លូវគឺអរិយមគ្គនេះឯង ទើបទ្រង់ព្រះនាមថា "សុគតោ" ។*

## ១) អំពីទ្រង់យាងទៅកាន់ទីដ៏ល្អ

ទីដ៏ល្អនោះឯងបានដល់អមតមហានិព្វាន ដែលជាស្ថានឥតមានកើតមានស្លាប់ទៀត ទីដទៃៗ កុំថាតែទីដែលមានប្រាង្គណ៍ប្រាសាទស្អាតល្អធំទូលាយខ្ពស់ស្កឹមស្កៃ ដែលសម្រេចដោយស្នាដៃជាងជាតិមនុស្សអ្នកឈ្លាសវៃប្រសប់រចនា នៅនាលោកិយសព្វថ្ងៃនេះទោះបីស្ថានរបស់ទេពឥន្ទព្រហ្មដែលជាទិព្វសុទ្ធ សឹងសម្រេចដោយទេវឫទ្ធិនិមិត្តបានតាមសេចក្តីបំណងរបស់ខ្លួន ក៏នៅតែមិនទាន់ឲ្យឈ្មោះថា ជាស្ថានក្សេមក្សាន្តដូចស្ថានអមតមហានិព្វានឡើយ, ព្រោះស្ថានទាំងនោះសុទ្ធតែនៅមានសេចក្តីកើតស្លាប់ទៀត, ព្រះអង្គទ្រង់យាងទៅកាន់ទីក្សេមក្សាន្តនេះឯងទើបបានទ្រង់ព្រះនាមថា "សុគតោ" ។

## ក) អំពីទ្រង់យាងទៅដោយប្រពៃ

ព្រះអង្គទ្រង់យាងទៅដោយប្រពៃ ព្រោះទ្រង់យាងទៅលែងត្រឡប់មកវិញ គឺទ្រង់មិនត្រឡប់មករកកិលេសដែលលះបានហើយ, សមដូចជាពាក្យដែលលោកពោលទុកថា កិលេសណាមួយដែលព្រះអង្គទ្រង់លះបានដោយសោតាបត្តិមគ្គក្តី, ដោយសកទាគាមិមគ្គក្តី, ដោយអនាគាមិមគ្គក្តី, ដោយអរហត្តមគ្គក្តី, ទ្រង់លែងត្រឡប់ផាកមករកកិលេសទាំងនោះទៀតហើយ ។

ម៉្យាងទៀតថា ព្រះសុគតដែលទ្រង់បំពេញបារមីធម៌ទាំង ៣០ ដើម្បីប្រយោជន៍និងសេចក្តីសុខ ដល់សព្វសត្វចាប់ដើមអំពីក្រាបទៀបព្រះបាទព្រះពុទ្ធទ្រង់ព្រះនាមទីបង្ករ ដរាបដល់បានសម្រេចសម្មាសម្ពោធិញ្ញាណនៅនាពោធិមណ្ឌល ទ្រង់មិនដែលងាកព្រះទ័យមករកអន្តប្បដិបត្តិគឺ សស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិ ឬកាមសុខល្លិកានុយោគនិងអត្តកិលមថានុយោគសោះឡើយ, ហេតុនោះហើយ ទើបទ្រង់ព្រះនាមថា "សុគតោ" ។

**ឃ) អំពីទ្រង់ត្រាស់តែវាចាត្រូវ**

ព្រះសុគតទ្រង់ត្រាស់សម្តែងហើយដោយប្រពៃ គឺទ្រង់ត្រាស់ព្រះវាចាដ៏សមគួរក្នុងស្ថានដែលគួរ សមដូចសេចក្តីសរសើរថា ព្រះតថាគតទ្រង់ជ្រាបវាចាឯណាដែលមិនពិត មិនប្រាកដ មិនប្រកបដោយប្រយោជន៍ ទាំងមិនជាទីពេញចិត្តរបស់អ្នកដទៃ ព្រះអង្គក៏មិនទ្រង់ត្រាស់វាចានោះ, ពុំនោះសោត, វាចាឯណា ដែលព្រះតថាគតទ្រង់ជ្រាបថាពិតប្រាកដ តែមិនប្រកបដោយប្រយោជន៍ទាំងមិនជាទីពេញចិត្តរបស់អ្នកដទៃ ព្រះអង្គក៏មិនទ្រង់ត្រាស់នូវវាចានោះ, មួយវិញទៀត វាចាឯណាដែលទ្រង់ជ្រាបថាពិតប្រាកដទាំងប្រកបដោយប្រយោជន៍ តែមិនជាទីពេញចិត្តរបស់អ្នកដទៃ ព្រះអង្គទ្រង់ជ្រាបនូវកាលដែលគួរត្រាស់ គួរព្យាករ ទើបទ្រង់ត្រាស់ ទ្រង់ព្យាករ, វាចាឯណាដែលមិន ពិតមិនប្រាកដ មិនប្រកបដោយប្រយោជន៍ សូម្បីជាទីពេញចិត្តរបស់អ្នកដទៃក៏ព្រះអង្គមិនទ្រង់

ត្រាស់វាចានោះ, វាចាណាដែលពិតប្រាកដហើយប្រកបដោយប្រយោជន៍ទាំងជាទីពេញចិត្តដល់អ្នកដទៃផង ព្រះតថាគតក៏ទ្រង់ជ្រាបនូវវាចានោះព្រមទាំងកាលដើម្បីនឹងព្យាករនូវវាចាទាំងនោះទៀត, ព្រោះហេតុនោះៗហើយទើបទ្រង់ព្រះនាមថា "សុគតោ" ។

## (៥) វិនិច្ឆ័យបទថា "លោកវិទូ"

---

### សេចក្ដីសួរដែលគួរចាំ

*១- អ្វីហៅថាលោក?*

*២- លោកមានប៉ុន្មាន គឺអ្វីខ្លះ?*

*៣- ព្រះអង្គទ្រង់ជ្រាបនូវលោកទាំងនោះដូចម្ដេច?*

### សេចក្ដីឆ្លើយ

*១- សភាពដែលកើតឡើងហើយ ត្រូវវិនាសសាបសូន្យទៅវិញ ហៅថាលោក ។*

*២- លោកមាន ៣ គឺ សង្ខារលោក ១, សត្តលោក ១, ឱកាសលោក ១*

*៣- ព្រះអង្គទ្រង់ជ្រាបនូវលោកទាំងនោះ ដោយសភាពដែលមាននៅជាធម្មតា, ដោយហេតុដែលកើតឡើង ដោយកិរិយារលត់ទៅវិញ ដោយហេតុដែលនាំឲ្យរលត់ទៅ ។*

### សេចក្ដីអធិប្បាយ

### អំពីសង្ខារលោក

*សង្ខារទាំងអស់ដែលត្រូវវិនាសសាបសូន្យទៅ ហៅថាសង្ខារលោក មានច្រើនផ្នែកដូច្នេះ ៖*

*លោក ១ បានដល់ពពួកសត្វដែលមានអាហារជាទីតាំង គឺរស់នៅ*

ព្រោះអាស្រ័យអាហារ ។

លោក ២ បានដល់នាមនិងរូប, នាម ប្រែថាធម្មជាតដែលឱនទន់ទោរទៅរកអារម្មណ៍បានដល់ចិត្ត ៨៩ ដួង, ចេតសិក ៥២, រូប ប្រែថាធម្មជាតដែលវិនាសទៅដោយធាតុក្តៅត្រជាក់ បានដល់រូប ២៨ គឺ មហាភូតរូប[១] ៤, ឧបាទាយរូប[២] ២៤ ។

លោក ៣ បានដល់វេទនា ៣ វេទនា ប្រែថាធម្មជាតិដែលសោយឬដឹងនូវអារម្មណ៍មាន ៣ យ៉ាងគឺសុខវេទនា ១, ទុក្ខវេទនា ១, អទុក្ខមសុខវេទនា ១ ។

លោក ៤ បានដល់អាហារ ៤ គឺ សភាពដែលជាបច្ច័យនាំឲ្យរស់នៅបាន មាន ៤ យ៉ាងគឺកវឡិង្ការាហារ ១, ផស្សាហារ ១, ចេតនាហារ ១, វិញ្ញាណាហារ ១ ។

លោក ៥ បានដល់ឧបាទានក្ខន្ធ ៥, ឧបាទានក្ខន្ធប្រែថា ខន្ធ ប្រកបដោយសេចក្តីប្រកាន់ មាន ៥ យ៉ាងគឺរូបូបាទានក្ខន្ធ ១, វេទនូបាទានក្ខន្ធ ១, សញ្ញូបាទានក្ខន្ធ ១, សង្ខារូបាទានក្ខន្ធ ១, វិញ្ញូបាទានក្ខន្ធ ១ ។

---

១- រូបដែលកើតប្រាកដធំៗ ហៅថាមហាភូតរូប បានដល់ធាតុ ៤ គឺ បឋវីធាតុ, អាបោធាតុ, តេជោធាតុ, និងវាយោធាតុ ។ ២- រូបដែលអាស្រ័យនូវមហាភូតរូបទើបប្រព្រឹត្តទៅបាន ហៅថាឧបាទាយរូប មាន ២៤ គឺ ចក្ខុ, សោត, ឃាន, ជិវ្ហា, កាយ, រូប សទ្ទ, គន្ធ, រស, ឥត្ថិន្ទ្រិយ, បុរិសិន្ទ្រិយ, ជីវិតិន្ទ្រិយ, ហទយវត្ថុ, កាយវិញ្ញត្តិ, វចីវិញ្ញត្តិ, អាកាសធាតុ, រូបស្សលហុតា, រូបស្សមុទុតា, រូបស្សកម្មញ្ញតា, រូបស្សឧបចយ, រូបស្សសន្តតិ, រូបស្សជរតា, រូបស្សអនិច្ចតា, កវឡិង្ការាហារ ។

*លោក ៦ បានដល់អាយតនៈ ខាងក្នុង ៦, អាយតនៈ ប្រែថា ធម្មជាតជាទីហូរមកនៃអារម្មណ៍មាន ៦ យ៉ាងគឺ ចក្ខុ ១, សោត ១, ឃាន ១, ជិវ្ហា ១, កាយ ១, ចិត្ត ១ ។*

*លោក ៧ បានដល់វិញ្ញាណដ្ឋិតិ ៧ គឺរបៀបតាំងនៅនៃវិញ្ញាណមាន ៧ យ៉ាងគឺ នានត្តកាយា នានត្តសញ្ញី[(១)] ១, នានត្តកាយា ឯកត្តសញ្ញី[(២)] ១, ឯកត្តកាយា នានត្តសញ្ញី[(៣)] ១, ឯកត្តកាយា ឯកត្តសញ្ញី[(៤)] ១, អាកាសានញ្ចាយតនៈ ១, វិញ្ញាណញ្ចាយតនៈ ១, អាកិញ្ចញ្ញាយតនៈ ១, ។*

*លោក ៨ បានដល់លោកធម៌ ៨, លោកធម៌ប្រែថា ធម៌សម្រាប់លោក ឬធម៌ដែលសត្វលោកតែងប្រព្រឹត្តវិលតាម មាន ៨ យ៉ាងគឺ មានលាភ ១, ឥតលាភ ១, មានយសសក្តិ ១, ឥតយសសក្តិ ១, សេចក្តីនិន្ទា ១, សេចក្តីសរសើរ ១, សេចក្តីសុខ ១, សេចក្តីទុក្ខ ១ ។*

*លោក ៩ បានដល់សត្តាវាស ៩ គឺកន្លែង ឬលំនៅរបស់សត្វមាន ៩ ដូចវិញ្ញាណដ្ឋិតិទាំង ៧ ដែរ ប្លែកគ្នាតែត្រង់ទី ៥ បានដល់អសញ្ញីសត្វ, ទី ៦ បានដល់អាកាសានញ្ចាយតនៈ ទី ៧ បានដល់វិញ្ញាណញ្ចាយតនៈ ទី ៨*

---

១ ពួកសត្វមានកាយផ្សេងគ្នាមានសញ្ញាផ្សេងគ្នា បានដល់មនុស្សនិងទេវតាពួកខ្លះ និងវិនិបាតពួកខ្លះ ។ ២ ពួកសត្វមានកាយផ្សេងគ្នាមានសញ្ញាដូចគ្នា បានដល់ពួកព្រហ្មក្នុងបឋមជ្ឈានភូមិ ។ ៣ ពួកសត្វដែលមានកាយដូចគ្នាមានសញ្ញាផ្សេងគ្នា បានដល់អាភស្សរព្រហ្ម ។ ៤ ពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា បានដល់សុភកិណ្ហព្រហ្ម ។

បានដល់អាកិញ្ចញ្ញាយតនៈ, ទី ៩ បានដល់នេវសញ្ញានាសញ្ញាយតនៈ ។

លោក ១០ បានដល់អាយតនៈ[១] ១០ ។ លោក ១២ បានដល់អាយតនៈ ១២ ។ លោក ១៨ បានដល់ធាតុ ១៨ ។

អំពីសត្វលោក

ឧបាទិន្នកសង្ខារទាំងអស់ដែលមានចិត្តជាប់នៅក្នុងកាម ហៅថា សត្វ, សត្វទាំងអស់នោះសុទ្ធតែត្រូវវិនាស គឺត្រូវតែចាស់ ឈឺ ស្លាប់សព្វប្រាណដូចគ្នា បាននាមថា "សត្វលោក" ។

សត្វលោកនេះចែកចេញជា ៣ ពួកគឺ កាមលោក ១, រូបលោក ១, អរូបលោក ១ ។ កាមលោកមាន ១១ គឺ អបាយភូមិ ៤ មនុស្ស ១ ឋានសួគ៌ ៦ ជាន់ ។ រូបលោក បានដល់រូបព្រហ្ម ១៦ ជាន់មានព្រហ្មបារិសជ្ជាជាដើម ។ អរូបលោក បានដល់អរូបព្រហ្ម ៤ ជាន់មានអាកាសានញ្ចាយតនព្រហ្មជាដើម ។

ព្រះលោកនាថទ្រង់ជ្រាបនូវសត្វលោកទាំងនោះដូច្នេះថា សត្វនេះមានអធ្យាស្រ័យបែបនេះៗ, សត្វនេះមានអាសយធម៌ គឺធម៌ដែលនៅអែបផ្ចាប់ជាមួយនឹងចិត្តយ៉ាងនេះៗ, ឯអាសយធម៌នោះលោកចែកចេញជា ២ យ៉ាងកាមបុថុជ្ជននិងព្រះអរិយៈ, បើបុថុជ្ជនបានដល់បាបធម៌ ២ យ៉ាងគឺ សស្សត-

---

១ អាយតនៈ ១០ គឺរាប់យកអាយតនៈខាងក្នុង ៥ ខាងក្រៅ ៥ វៀរលែងអាយតនៈ២គឺមនាយតនៈ និងធម្មាយតនៈ ។

ទិដ្ឋិនិងឧច្ឆេទទិដ្ឋិ[១], បើព្រះអរិយៈបានដល់វិបស្សនាញាណ ១០[២] យ៉ាង ។ ទ្រង់ជ្រាបនូវអនុសយធម៌ជាគ្រឿងដេកត្រាំនៅជាមួយនឹងចិត្ត មានកាមរាគនិងព្យាបាទជាដើម, ទ្រង់ជ្រាបនូវចរិត[៣] របស់សត្វ ថាសត្វនេះរាគចរិតឬទោសចរិតជាដើម, ទ្រង់ជ្រាបនូវអធិមុត្តិ[៤] របស់ចិត្ត ថាសត្វនេះមានសន្តានចិត្តថ្លៃថ្នាឬថោកទាបបែបនេះៗ, ទ្រង់ជ្រាបនូវពួកសត្វដែលមានភ្នែកមានធូលីតិច, និងពួកសត្វដែលមានភ្នែកមានធូលីច្រើន, ទ្រង់ជ្រាបនូវពួកសត្វដែលមានឥន្ទ្រិយក្លៀវក្លាឬទន់ថយ ទ្រង់ជ្រាបនូវពួកសត្វដែលមានអាការល្អឬអាក្រក់, ទ្រង់ជ្រាបនូវពួកសត្វដែលព្រះអង្គងាយប្រោសនិងមិនងាយប្រោស, ទ្រង់ជ្រាបនូវពួកសត្វដែលមានភ័ព្វនិងឥតភ័ព្វគឺគួរបានមគ្គផលនិងមិនគួរបានមគ្គផល ។ សត្វមានភ័ព្វបានដល់សត្វដែលមិនប្រកបដោយអាវរណធម៌ គឺធម៌ជាគ្រឿងហាមរាំង ៣ យ៉ាងគឺ កាមាវរណៈ ១, កិលេសាវរណៈ ១ វិបាកាវរណៈ ។ កាមាវរណៈបានដល់តណ្ហា ៥ យ៉ាងគឺ រូបតណ្ហា ១, សទ្ទតណ្ហា ១, គន្ធតណ្ហា ១, រសតណ្ហា ១, ផោដ្ឋព្វ-តណ្ហា ១, កិលេសាវរណៈ បានដល់កិលេស ១០ យ៉ាងគឺ កាមរាគៈ ១ ភវរាគ ១, រូបរាគ ១, អរូបរាគ ១, លោភ ១, ទោស ១, មោហ ១, មាន ១, ទិដ្ឋិ១,

---

១- សស្សតទិដ្ឋិ សេចក្ដីយល់ថា សត្វទៀង លោកទៀង ធ្លាប់កើតជាអ្វីស្លាប់ហើយក៏កើតជានោះទៀត ។ ឧច្ឆេទទិដ្ឋិ សេចក្ដីយល់ថាសត្វស្លាប់ទៅសូន្យមិនកើតទៀតទេ ។ ២ វិបស្សនាញាណ ១០ ចូរមើលក្នុងធម្មវតនវិនិច្ឆ័យត្រង់វិធីចម្រើនវិបស្សនា ។ ៣ ចរិត ប្រែថា សេចក្ដីប្រព្រឹត្ត លំនាំអាការរបស់កាយ វាចា ចិត្ត មាន ៦ យ៉ាងគឺរាគចរិត, ទោសចរិត, មោហចរិត, វិតក្កចរិត, សទ្ធាចរិត, ពុទ្ធិចរិត ។ ៤ អធិមុត្តិ សេចក្ដីបុះចិត្ត សេចក្ដីធ្ងន់ចិត្ត ជំនឿស៊ប់ ។

វិចិកិច្ឆា ១, វិបាកាវរណៈ បានដល់ទិដ្ឋិ ៣ យ៉ាងគឺ អកិរិយទិដ្ឋិ ១, អហេតុកទិដ្ឋិ ១, នត្ថិកទិដ្ឋិ[១] ១ ។ ន័យ ១ ទៀតថាសត្វដែលមិនប្រកបដោយអនន្តរិយកម្មដែលជាកម្មមានទោសធ្ងន់ឥតកំណត់ទាំង ៥ យ៉ាងគឺ សម្លាប់មាតា ១ សម្លាប់បិតា ១, សម្លាប់ព្រះអរហន្ត ១, ធ្វើឲ្យរបួសជាំឈាមដល់សរីរាវយវៈរបស់ព្រះពុទ្ធ ១, បំបែកសង្ឃឲ្យបែកគ្នា ១, សត្វពួកនោះឯងឈ្មោះថាមានភព្វព្រោះគួរបានមគ្គផល ។ សត្វដែលប្រកបដោយអាវរណធម៌ ៣ យ៉ាងនោះក្តី ប្រកបដោយកម្មមានទោសធ្ងន់ឥតកំណត់ទាំង ៥ យ៉ាង ឬក៏ណាមួយក្តីឈ្មោះថាសត្វឥតភព្វព្រោះមិនគួរបានមគ្គផល ។ ព្រះមានព្រះភាគអង្គនោះទ្រង់ជ្រាបនូវសត្វលោកយ៉ាងនេះទើបទ្រង់ព្រះនាមថា "លោកវិទូ" ។

## អំពីឱកាសលោក

មហាប្រថពី មហាសមុទ្រ មហាបព៌ត ខ្យល់ អាកាស កាមាវចរសួគ៌ ហៅថា ភាជនលោក, ព្រោះទ្រតម្រួតៗលើគ្នាដូចជាភាជនៈដែលសម្រាប់ទ្រវត្ថុផ្សេងៗ គឺខ្យល់ទ្រទឹកៗ ទ្រដីៗ ទ្រភ្នំត្រីកូដៗ ទ្រភ្នំសិនេរុៗ ទ្រឆកាមាវចរសួគ៌, ពុំនោះសោតហៅថា ចក្រវាឡ ព្រោះថាផែនដីនេះមានសណ្ឋានមូលដូចជាកង់ មានចក្ររាសីទាំង ១២ ជាកាំ ។ ន័យមួយទៀត

---

១ អកិរិយទិដ្ឋិ សេចក្តីយល់ថា បុគ្គលដែលធ្វើបុណ្យបាប មិនបាច់ថាជាបុណ្យបាបទេ (ទុកដូចជាមិនធ្វើ), អហេតុកទិដ្ឋិ សេចក្តីយល់ថាហេតុបច្ច័យសម្រាប់ឲ្យសត្វសៅហ្មង ឬបរិសុទ្ធមិនមាន សត្វដែលនឹងសៅហ្មងឬបរិសុទ្ធក៏សៅហ្មងឬបរិសុទ្ធឯងៗ ។ នត្ថិកទិដ្ឋិ សេចក្តីយល់ថាទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាដែលបុគ្គលបូជាហើយមិនមានផល ។

ដែលហៅថា ចក្រវាឡ ព្រោះមានសេចក្ដីថា ជាប់ទាក់ទងគ្នាឥតមានទីបំផុត ។ ភាជនលោក ឬ ចក្រវាឡនេះ ហៅថា ឱកាសលោក ព្រោះជាសភាពត្រូវវិនាសលាញទៅតាមធម្មតា ។

ព្រះបរមលោកនាថ ទ្រង់ជ្រាបនូវឱកាសលោកនេះដូច្នេះថា ចក្រ-វាឡមួយ មានបណ្ដោយនិងទទឹង ១២ សែន ៣ ពាន់ ៤ រយ ៥០ យោជន៍ បើវាស់ដោយមូលជុំវិញប្រវែង ៣៦ សែន ១ ម៉ឺន ៣ រយ ៥០ យោជន៍ ។

ក្នុងចក្រវាឡនេះ ចំណែកផែនដីមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍, ទឹកដែលតាំងនៅលើខ្យល់សម្រាប់ទ្រផែនដីនោះ មានកម្រាស់ ៤ សែន ៨ ម៉ឺនយោជន៍, ខ្យល់សម្រាប់ទ្រទឹកនោះ បក់ឡើងទៅលើអាកាសមានកម្រាស់ ៩ សែន ៦ ម៉ឺនយោជន៍, លោកតាំងនៅមាំយ៉ាងនេះឯង ។

លោកដែលតាំងនៅមាំដូច្នេះហើយមានភ្នំសិនេរុ ដែលជាមហា-បព៌តធំខ្ពស់ចម្បងបណ្ដាច់ក្នុងលោក លិចចុះទៅក្នុងសមុទ្រ ៨ ម៉ឺន ៤ ពាន់យោជន៍, មានកម្ពស់ខ្ពស់ឡើងទៅលើក៏ប៉ុណ្ណោះដែរ, មិនតែប៉ុណ្ណោះ នៅមានបព៌តជាបន្ទាប់បន្សំ ៧ ទៀតគឺភ្នំ យុគន្ធរ ១, ភ្នំឥសិន្ធរ ១, ភ្នំករវិក ១, ភ្នំសុទស្សនៈ ១, ភ្នំនេមិន្ធរ ១, ភ្នំវិនតក ១, ភ្នំអស្សកណ្ណ ១, ភ្នំទាំង ៧ នេះដំពាសពេញទៅដោយរតនវត្ថុច្រើនប្រការសុទ្ធសឹងតែជាទិព្វ មានជម្រៅចុះទៅនិងកម្ពស់ខ្ពស់ឡើង តាមលំដាប់លំដោយប្រមាណពាក់

កណ្តាលៗពីគ្នាហើយតាំងនៅព័ទ្ធភ្នំសិនេរុនោះ និងជាទីអាស្រ័យនៅរបស់មហារាជទាំង ៤ ដែលជាទីពឹងអាស្រ័យនៃទេព្តានិងយក្ខទាំងឡាយ, មិនតែប៉ុណ្ណោះឡើយ នៅមានភ្នំហិមវន្ត មានកម្ពស់ ៥០០ យោជន៍ មានបណ្តោយនិងទទឹង ៣ ពាន់យោជន៍ ប្រដាប់ដោយកំពូល ៨ ម៉ឺន ៤ ពាន់ ហើយមានដើមព្រីងមួយដើមទៀត មានទំហំដើមវាស់ដោយជុំវិញប្រមាណ ១៥ យោជន៍ ទាំងដើមទាំងមែកប្រវែង ៥០ យោជន៍ផ្សាយចេញទៅខាង ១០០ យោជន៍ជុំវិញ កម្ពស់ខ្ពស់ឡើងក៏ប៉ុណ្ណោះដូចគ្នា, ដោយអានុភាពដើមព្រីងនោះទើបបានឈ្មោះថា ជម្ពូទ្វីបដូច្នេះ ។ ដើមជ្រនៀងសម្រាប់ពួកអសុរក្តី, ដើមរកាសម្រាប់ពួកគ្រុឌក្តី, ដើមកទម្ពព្រឹក្សនៅនាអមរគោយានទ្វីបក្តី, ដើមកល្បព្រឹក្ស នៅនាឧត្តរកុរុទ្វីបក្តី, ដើមប្រេសនៅនាបុព្វវិទេហទ្វីបក្តី, ដើមបារិច្ឆត្តកព្រឹក្សនៅនាស្ថានតាវតិង្សក្តីទាំងអស់នេះសុទ្ធតែមានប្រមាណត្រូវគ្នានឹងដើមព្រីងនៅនាជម្ពូទ្វីបនេះដែរ ។

ភ្នំចក្រវាឡមានជើងលិចចុះទៅក្នុងមហាសមុទ្រជម្រៅ ៨ ម៉ឺន ២ ពាន់យោជន៍ មានកម្ពស់ខ្ពស់ឡើងទៅក៏ដូចគ្នា ។

ក្នុងលោកនេះ មានព្រះចន្ទ្រប្រកបដោយមណ្ឌល ៤៩ យោជន៍ព្រះអាទិត្យមានមណ្ឌល ៥០ យោជន៍ ។ ភពតាវតិង្សមានទំហំប្រមាណ ១ ម៉ឺនយោជន៍, ភពអសុរនិងមហានរកឈ្មោះអវីចិក្តី, ជម្ពូទ្វីបក្តី មានប្រមាណប៉ុនគ្នា ។ អមរគោយានទ្វីបមានទំហំប្រមាណ ៧ ពាន់យោជន៍,

បុព្វវិទេហទ្វីបក៏ដូចគ្នា ។ ឧត្តរកុរុទ្វីបមានទំហំប្រមាណ ៨ ពាន់យោជន៍, ក្នុងទ្វីបអស់នេះ ទ្វីបនីមួយៗមានទ្វីបតូចៗ ៥ រយៗជាបរិវារ ។ ចក្រវាឡទាំងមូលនេះឯងឈ្មោះថាលោកធាតុ ព្រោះទ្រទ្រង់ទុកនូវលោក, ក្នុងចន្លោះៗ នៃលោកធាតុនោះៗ មាននរកឈ្មោះលោកន្តរិយៈ ឬលោកន្តរិកៈ ប្រតិស្ឋាននៅ ។

ចក្រវាឡដែលមិនមានទីបំផុត លោកធាតុដែលឥតចុងឥតដើមដូចពណ៌នាមកនេះ ព្រះបរមលោកនាថទ្រង់ជ្រាបហើយ, ទ្រង់ត្រាស់ដឹងហើយ, ទ្រង់បានចាក់ធ្លុះហើយដោយព្រះពុទ្ធញ្ញាណដែលឥតមានទីបំផុតដែរ ។

សេចក្ដីដែលអធិប្បាយមកនេះ ដើម្បីសឲ្យឃើញថាសូម្បីតែឱកាសលោក ក៏គង់ព្រះអង្គត្រាស់ដឹងបានដោយសព្វគ្រប់, ព្រោះហេតុដែលព្រះអង្គទ្រង់ជ្រាបច្បាស់នូវលោកដោយសព្វគ្រប់យ៉ាងនេះ ទើបទ្រង់ព្រះនាមថា "លោកវិទូ" ។

## (៦) វិគិច្ឆ័យបទថា "អនុត្តរោ"

---

## សេចក្ដីសួរដែលគួរបាំ

១- ព្រះមានព្រះភាគអង្គនោះទ្រង់ប្រសើរដោយគុណអ្វីខ្លះ?

២- បុគ្គលដែលបានសម្រេចអរហត្តផលហើយ ឈ្មោះថាមានគុណវិសេសស្មើគ្នា ហេតុអ្វីក៏ព្រះអង្គទើបឈ្មោះថាប្រសើរជាង?

៣- ព្រះអង្គបានសម្ដែងប្រាប់ពួកកិក្ខុថា ព្រះអង្គប្រសើរជាងគេ បើដូច្នោះមិនឈ្មោះថាព្រះអង្គមានអំនួតឬ?

## សេចក្ដីឆ្លើយ

១- ទ្រង់ប្រសើរដោយគុណជាអនេក តែពោលដោយសង្ខេបនៅត្រឹមតែ ៥ គឺទ្រង់ប្រសើរដោយសីលគុណ, សមាធិគុណ, បញ្ញាគុណ, វិមុត្តិគុណ, វិមុត្តិញាណទស្សនគុណ ។

២- បុគ្គលទាំងនោះ ឈ្មោះថាមានគុណវិសេសស្មើគ្នា ចំពោះតែត្រង់ការលះបង់កិលេសប៉ុណ្ណោះ ឯគុណដទៃៗនៅមានផ្សេងគ្នាខ្លះ ដូចយ៉ាងព្រះអរហន្តជាបដិសម្ភិទានិងជាសុក្ខវិបស្សកៈជាដើម, ឯព្រះសម្មា-សម្ពុទ្ធទ្រង់ផ្សេងដោយគុណជាអនេកអំពីពួកសាវ័ក ដូចយ៉ាងទ្រង់មាន

*អសាធារណញ្ញាណ[១] ៦ យ៉ាង ដែលជាញាណមិនទូទៅដល់សាវក ឯទៀតៗជាដើម ។*

*៣- ព្រះអង្គមិនមានអំនួតទេតែបានទ្រង់ពិនិត្យរកទៅឃើញថាឥត មានអ្នកណាមួយដែលស្មើព្រះអង្គដោយគុណវិសេសដូច្នោះពិតមែន ។*

## សេចក្ដីអធិប្បាយ

## អំពីសីលគុណ

*សេចក្ដីរៀបរយកាយវាចា ហៅថាសីល, មាន ២ យ៉ាងគឺ លោកិយ-សីល ១, លោកុត្តរសីល ១ ។ សីលដែលញុំាងសត្វឲ្យប្រវត្តទៅក្នុងលោក ទាំងបីហៅថាលោកិយសីល, បានដល់សីល ៥, សីល ៨, សីល ១០, សីល ២២៧ ដែលជាសីលបារមីខ្លះ, សីលឧបបារមីខ្លះ, សីលបរមត្ថបារមីខ្លះ ដែលទ្រង់ធ្លាប់សន្សំមកហើយ រាប់អស់អសង្ខេយ្យកប្ប ដរាបដល់បាន សម្រេចសម្មាសម្ពោធិញាណ ។ សីលដែលញុំាងសត្វឲ្យឆ្លងផុតចាកលោក*

---

១ អសាធារណញ្ញាណ ៦ គឺ អាសយានុសយញ្ញាណ ប្រាជ្ញាជ្រាបច្បាស់នូវអាសយៈនិង អនុសយៈរបស់សត្វ ១, ឥន្ទ្រិយបរោបរិយញ្ញាណ ប្រាជ្ញាជ្រាបច្បាស់នូវសត្វមានឥន្ទ្រិយក្លៀវ-ក្លានិងទន់ខ្សោយ ១, យមកប្បាដិហារិយញ្ញាណ ប្រាជ្ញាអាចធ្វើយមកប្បាដិហារ្យ ១, មហាករុណា-សមាបត្តិញ្ញាណ ប្រាជ្ញាអាចក្នុងកិរិយាចូលសមាបត្តិ ដើម្បីប្រមើលមើលឧបនិស្ស័យនៃសត្វ ដោយមហាករុណា ១, សព្វញ្ញុតញ្ញាណ ប្រាជ្ញាជ្រាបច្បាស់នូវធម៌ជាគ្រឿងត្រាស់ដឹងទាំងពួង១, អនាវរណញ្ញាណ ប្រាជ្ញាដែលទ្រង់ឈ្វេងយល់ឥតមានអ្វីទើសទាក់ ១, ញាណទាំង ៦ នេះ មិន ជាសាធារណៈទូទៅដល់សាវ័កទាំងពួងឡើយ ។

ទាំង ៣ ហៅថាលោកុត្តរសីល បានដល់វិរតិចេតនាវៀរផ្ដាច់ចាកអកុសល-ធម៌សព្វយ៉ាងដោយសមុច្ឆេទប្បហាន កើតឡើងព្រមជាមួយនឹងអរិយមគ្គមាន ៣ យ៉ាងគឺ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ ។ ព្រះអង្គទ្រង់ប្រសើរដោយគុណគឺសីល ២ យ៉ាងដូច្នេះឯង ។

## អំពីសមាធិគុណ

ចិត្តស្ងប់ស្ងៀមនៅនឹងក្នុងគុណធម៌ណាមួយហៅថាសមាធិ មាន ២ យ៉ាងគឺ ឧបចារសមាធិ ១, អប្បនាសមាធិ ១ ។ ចិត្តដែលស្ងប់ស្ងៀមខាងដើមបន្ទាប់អំពីបានឈានទាំង ៤ ណាមួយហៅថា ឧបចារសមាធិ, ចិត្តដែលនឹងនៅស្ងប់ស្ងៀមក្នុងឈានទាំង ៤ ណាមួយហៅថា អប្បនាសមាធិ, អប្បនាសមាធិនេះ លោកចែកចេញជា ២ យ៉ាងគឺ លោកិយអប្បនា-សមាធិ ១, លោកុត្តរអប្បនាសមាធិ ១ ។ ព្រះអង្គទ្រង់ប្រសើរដោយគុណគឺសមាធិ ២ យ៉ាង ដូច្នេះឯង ។

## អំពីបញ្ញាគុណ

គុណជាតិដែលដឹងច្បាស់នូវហេតុនិងផល នៃសេចក្ដីចម្រើននិងសេចក្ដីវិនាសហៅថា បញ្ញា, មាន ២ យ៉ាងគឺ លោកិយប្បញ្ញា ១, លោកុត្តរប្ប-ញ្ញា ១, បញ្ញាដែលប្រព្រឹត្តទៅក្នុងលោកហៅថា លោកិយប្បញ្ញា, បានដល់បញ្ញាដែលចេះចាំឈ្លាសវៃក្នុងត្រៃវេទ ឬចំណេះវិជ្ជាដែលឥតទោសសព្វយ៉ាងក្នុងលោកមានវិជ្ជាពេទ្យជាដើម, ចំណែកខាងផ្លូវធម៌ បាន

ដល់បញ្ញាដែលសម្បយុត្តដោយលោកិយមគ្គ, លោកិយមគ្គនោះ បានដល់វិសុទ្ធិ ៤ គឺ ទិដ្ឋិវិសុទ្ធិ ១, កង្ខាវិតរណវិសុទ្ធិ ១, មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ១, បដិបទាញាណទស្សនវិសុទ្ធិ ១ ។ បញ្ញាដែលជាគ្រឿងឆ្លងចេញចាកលោក ហៅថា លោកុត្តរបញ្ញា បានដល់បញ្ញាដែលសម្បយុត្តដោយលោកុត្តរមគ្គ ៤ យ៉ាងគឺ សោតាបត្តិមគ្គ ១, សកទាគាមិមគ្គ ១, អនាគាមិមគ្គ ១, អរហត្តមគ្គ ១ ។ បញ្ញានេះឯង ផ្តាច់ផ្តិលនូវកិលេសដែលល្អិតបានដាច់ស្រឡះ ។

## អំពីវិមុត្តិគុណ

គុណជាតិដែលរួចផុតស្រឡះចាកគ្រឿងសៅហ្មង ហៅថា វិមុត្តិ មាន ៤ យ៉ាងគឺ បញ្ញាវិមុត្តិ ១, សមុច្ឆេទវិមុត្តិ ១, វិក្ខម្ភនវិមុត្តិ ១, តទង្គវិមុត្តិ ១ ។ បញ្ញាវិមុត្តិបានដល់លោកុត្តរបញ្ញាដែលផុតស្រឡះចាកបាបធម៌គ្រប់យ៉ាង, សមុច្ឆេទវិមុត្តិ បានដល់បញ្ញាដែលផ្តាច់បង់នូវកិលេសធម៌មិនឲ្យលូតលាស់ឡើងបានទៀត ដូចដើមត្នោតដែលកំបុតចុង, វិក្ខម្ភនវិមុត្តិ បានដល់រូបាវចរចិត្តដែលសង្កត់ទុកបាននូវកិលេសមិនឲ្យកើតឡើងបានដោយកាល ដោយខណៈ តែលះបង់មិនទាន់បានដាច់ស្រឡះប្រៀបដូចថ្មដែលសង្កត់ស្មៅ, តទង្គវិមុត្តិបានដល់កាមាវចរកុសលចិត្តដែលលះកិលេសបានខ្លះៗ ដោយស្របក់ៗ ប្រៀបដូចស្មៅដែលបុគ្គលទើបនឹងជម្រះថ្មីៗ អាចនឹងលាស់ឡើងវិញបាន ។ ន័យដទៃទៀតថា តទង្គវិមុត្តិ បានដល់

*កាមាវចរកុសល, វិក្ខម្ភនវិមុត្តិ បានដល់រូបាវចរកុសល, បសុទ្ធិវិមុត្តិ បានដល់លោកុត្តរកុសល, និស្សរណវិមុត្តិ បានដល់ព្រះនិព្វាន ។*

## អំពីវិមុត្តិញ្ញាណទស្សនគុណ

*កិរិយាឃើញដោយប្រាជ្ញាដែលកើតអំពីវិមុត្តិ ហៅថា វិមុត្តិញ្ញាណ-ទស្សនៈៗ នេះជាគុណសម្បទា ១ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទើបហៅថា វិមុត្តិញ្ញាណទស្សនគុណ, ក៏វិមុត្តិញ្ញាណទស្សនៈនោះបានដល់បច្ចវេក្ខណញ្ញាណ គឺបញ្ញាសម្រាប់ពិចារណានូវមគ្គផល កិលេសនិងនិព្វាន ។ ព្រះមានព្រះភាគទ្រង់ប្រកបដោយបច្ចវេក្ខណញ្ញាណ ឥតមានបុគ្គលណាប្រៀបដូចទើបទ្រង់ព្រះនាមថា "អនុត្តរោ" ។*

(៧) វិនិច្ឆ័យបទថា "បុរិសទម្មសារថិ"

សេចក្ដីសួរដែលគួរចាំ

១- បុរសដូចម្ដេចដែលគួរទូន្មាន? -ដូចម្ដេចដែលមិនគួរទូន្មាន?

២- បុរសដែលគួរទូន្មាន មានប៉ុន្មានពួក?

៣- បើទ្រង់ទូន្មានខ្លះ មិនទូន្មានខ្លះដូច្នេះព្រះអង្គមិនជាអ្នករើសមុខហើយឬ?

៤- ព្រះអង្គទ្រង់ទូន្មានទាំងបុរសទាំងស្ត្រី ហេតុអ្វីទើបលោកដាក់តែបុរស?

សេចក្ដីឆ្លើយ

១- បុរសដែលមានឧបនិស្ស័យល្មមស្ដាប់ឱវាទព្រះអង្គបានឈ្មោះថាបុរសគួរទូន្មាន, បុរសក្រៅពីនេះមិនឈ្មោះថាគួរទូន្មានឡើយ ។

២- បុរសដែលគួរទូន្មាន មាន ៣ ពួកគឺ តិរច្ឆានបុរស ១, មនុស្សបុរស ១, អមនុស្សបុរស ១ ។

៣- មិនមែនទ្រង់រើសមុខទេ, តែទ្រង់យល់ថា បុរសដែលឥតឧបនិស្ស័យបើទុកជាទ្រង់ទូន្មានក៏ឥតអំពើ មិនសម្រេចប្រយោជន៍ដល់សត្វទាំងនោះទេ ។

៤- បានជាលោកដាក់បុរសមកជាប្រធាន ព្រោះកំណត់ដោយ

ភេទជាឧក្រិដ្ឋ គឺមានភេទថ្លៃជាងស្ត្រីប៉ុណ្ណោះទេ តែក៏គង់មានសេចក្ដីសាធារណៈដល់ស្ត្រីដែរ ។

## សេចក្ដីអធិប្បាយ

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គឈ្លាសវៃក្នុងវិធីប្រដៅសត្វ សត្វណាដែលពេញចិត្តនឹងធម៌គ្រោតគ្រាត ទ្រង់សម្ដែងធម៌គ្រោតគ្រាតប្រាប់, សត្វណាដែលពេញចិត្តនឹងធម៌ល្អិតជ្រាលជ្រៅ ទ្រង់សម្ដែងធម៌ដែលល្អិតជ្រាលជ្រៅប្រាប់, សត្វណាដែលពេញចិត្តធម៌គ្រោតគ្រាតខ្លះ ល្អិតជ្រាលជ្រៅខ្លះ ទ្រង់ក៏សម្ដែងធម៌តាមទំនងនោះប្រាប់ ត្រាតែសត្វនោះចូលចិត្តស្ដាប់បាន ប្រតិបត្តិតាម សម្រេចប្រយោជន៍តាមឧបនិស្ស័យរៀងខ្លួន, ដូចយ៉ាងទ្រង់សម្ដែងអំពីកម្មដ្ឋាន ឲ្យសត្វចម្រើនតាមចរិតរបស់ខ្លួនជាដើម សត្វដែលជារាគចរិត ឲ្យចម្រើនអសុភ ១០ និងកាយគតាសតិ ១, សត្វដែលជាទោសចរិត ឲ្យចម្រើនព្រហ្មវិហារធម៌ ៤ និងវណ្ណកសិណ ៤ គឺនីលកសិណ ១, បីតកសិណ ១, លោហិតកសិណ ១, ឱទាតកសិណ ១, សត្វដែលជាមោហចរិតនិងវិតក្កចរិត ឲ្យចម្រើនអានាបានស្សតិ, សត្វដែលជាសទ្ធាចរិត ឲ្យចម្រើន អនុស្សតិ ៦ គឺ ពុទ្ធានុស្សតិ ១, ធម្មានុស្សតិ ១, សង្ឃានុស្សតិ ១, សីលានុស្សតិ ១, ចាគានុស្សតិ ១, ទេវតានុស្សតិ ១, សត្វដែលជាពុទ្ធិចរិត ឲ្យចម្រើនកម្មដ្ឋាន ៤ គឺ មរណានុស្សតិ ១, ឧបសមានុស្សតិ ១, ធាតុវវដ្ឋាន ១, អាហារេបដិកូលសញ្ញា ១, កម្មដ្ឋានសល់ពីនេះ ១០ គឺបឋវី-

កសិណ ១, អាបោកសិណ ១, តេជោកសិណ ១, វាយោកសិណ ១, អាកាសកសិណ ១, អាលោកកសិណ ១, អរូប ៤ គួរដល់ចរិតទាំងអស់ ។

ព្រះអង្គទ្រង់សម្ដែងធម៌ដើម្បីឲ្យសត្វប្រតិបត្តិតាមទំនងបែបនេះ ព្រោះទ្រង់ស្គាល់ហេតុ ប្រៀបដូចជាគ្រូពេទ្យដែលចេះប្រាកដអាចប្រកបឱសថដាក់ជំងឺឲ្យជាសះស្បើយបានឆាយ ព្រោះស្គាល់សមុដ្ឋានរោគពិតប្រាកដ ។ ម្យ៉ាងទៀត សត្វណាដែលពេញចិត្តនឹងរូប ព្រះអង្គទ្រង់ត្រាស់សម្ដែងទោសរបស់រូបប្រាប់ ដូចវក្កលិព្រាហ្មណ៍ និងនាងរូបនន្ទាជាដើម, សត្វណាដែលគួរប្រោសដោយបាដិហារ្យ ទ្រង់ធ្វើបាដិហារ្យប្រោស ដូចពួកជដិលបងប្អូន ៣ នាក់ជាដើម ។ ព្រះអង្គទ្រង់ធ្វៀវឆ្លាសក្នុងពិធីប្រដៅសត្វយ៉ាងនេះហើយ ទើបទ្រង់ទូន្មានបុរសទាំង ៣ ក្រុមនោះបាន ។ តិរច្ឆានបុរសដែលទ្រង់ទូន្មានបានមានច្រើនជាអនេក មាននាគរាជឈ្មោះអបលាល, ចូឡោទរ, មហោទរ, អគ្គិសិខ, ធូមសិខ, អារវាឡ និងដំរីឈ្មោះធនបាលក, បាលិលេយ្យកជាដើម ។ មនុស្សបុរសដែលរបឹងដូចយ៉ាងសច្ចកនិគណ្ឋបុត្រ, អម្ពដ្ឋមាណព, បោក្ខរសាតិព្រាហ្មណ៍, សោណទណ្ឌព្រាហ្មណ៍ និងកូដទណ្ឌព្រាហ្មណ៍ជាដើម ។ អមនុស្សបុរសក៏ទ្រង់ទូន្មានបានជាអនេក ដូចយ៉ាង អាឡវកយក្ខ, សុចិលោមយក្ស ខរលោមយក្ស, និងសក្កទេវរាជជាដើម ។ ព្រះអង្គឈ្លាសវៃដោយវិធីទូន្មានសត្វបានឥតទទាក់ទទាម ហេតុនោះឯងហើយទើបទ្រង់

ព្រះនាមថា "បុរិសទម្មសារថិ" គឺប្រៀបដោយនាយសារថីរបស់មហាក្ស-ត្រិយ៍ ដែលប៉ិនប្រសប់ទូន្មានដំរី ឬសេះអាជានេយ្យដែលជាវាហនៈសម្រាប់ព្រះបរមក្សត្រិយ៍ ។ មានសេចក្ដីសរសើរថា នាយសារថីនោះអាចទាញទប់សេះដែលកំពុងអូសរាជរថលឿនជ្រុលទៅក្នុងផ្លូវរបាប់ ឲ្យទប់នៅនឹងបាន មិនឲ្យរាជយានវិលទៅបានតាមទំនើងកង់យ៉ាងណាមិញ ព្រះបរមលោក-នាថទ្រង់ព្រះនាមថាបុរិសទម្មសារថិក៏ដូច្នោះដែរ ។

មានន័យខ្លះ លោករួបរួមព្រះនាមទាំង ២ គឺអនុត្តរោនិងបុរិសទម្ម-សារថិ ជាព្រះនាមមួយថា អនុត្តរោ បុរិសទម្មសារថិ "ទ្រង់ជានាយសារថីអាចទូន្មានបាននូវបុរស ឥតមានអ្នកណាប្រសើរជាង" ។ ពិតមែន សត្វណាដែលទ្រង់ប្រដៅបានបទហើយ អាចអង្គុយក្នុងកន្លែង១ ព្លែទ១ ហើយស្ទុះទៅកាន់ទិសទាំង ៨ ដោយកម្លាំងសមាបត្តិទាំង ៨ បាន, ឯរូប-ធម៌នៅនឹងត្រង់កន្លែង ១ ដដែល តែនាមធម៌ស្ទុះចេញទៅ ។

ព្រះបរមគ្រូទ្រង់ឈ្លាសវៃក្នុងពិធីប្រដៅសត្វយ៉ាងនេះ ទើបទ្រង់ព្រះនាមថា "អនុត្តរោ បុរិសទម្មសារថិ" ។

# វិគិប្ប័យបទថា "សត្ថា ទេវមនុស្សានំ"

## ពាក្យសួរដែលគួរចាំ

*១- ព្រះបរមគ្រូទ្រង់ប្រដៅសត្តនិករដោយប្រយោជន៍ប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?*

*២- ដែលទ្រង់ប្រដៅសត្វសព្វស្ថានដរាបដល់ពេលបរិនិព្វានឥតមានធុញទ្រាន់ តើដោយទ្រង់បំណងដាច់ខាតដូចម្តេច?*

*៣- ហេតុអ្វី ទើបលោកប្រៀបព្រះអង្គដោយនាយឈ្មួញរទេះយ៉ាងធំ?*

## សេចក្តីឆ្លើយ

*១- ទ្រង់ប្រដៅប្រយោជន៍ ៣ យ៉ាងគឺ ទិដ្ឋធម្មិកប្រយោជន៍ ១, សម្បរាយិកប្រយោជន៍ ១, បរមត្ថប្រយោជន៍ ១ ។*

*២- ដើម្បីបំណងដាច់ខាតឲ្យសត្វបានវិមុត្តិសុខឬបរមត្ថសុខ[១] ប៉ុណ្ណោះ ។*

*៣- បានជាលោកប្រៀបដូច្នោះ ព្រោះនាយឈ្មួញរទេះយ៉ាងធំមានប្រាជ្ញាអាចញ៉ាំងពួកកូនឈ្មួញឲ្យឆ្លងផ្លូវកន្តារបាន មិនឲ្យស្អុនដំណើរដូចជាព្រះអង្គដែលទ្រង់ញ៉ាំងសត្តនិករឲ្យសញ្ចារកាត់សង្សារកន្តារបាន ។*

---

១- វិមុត្តិសុខ ឬ បរមត្ថសុខ បានដល់សេចក្តីសុខក្នុងព្រះនិព្វាន ។

## សេចក្តីអធិប្បាយ

*ព្រះបរមគ្រូលោកនាថសាស្តាចារ្យ ទ្រង់ប្រៀនប្រដៅសត្វអស់កាលកំណត់ ៤៥ វស្សា ដោយធម្មទេសនា រួបរួមមកនូវត្រឹមប្រយោជន៍ ៣ យ៉ាង ឬត្រឹមពាក្យ ៣ ម៉ាត់គឺ មិនឲ្យធ្វើបាប ១, ឲ្យខំធ្វើបុណ្យ ១, ឲ្យខំធ្វើចិត្តឲ្យស្អាត[១] ១ ។*

## ទិដ្ឋធម្មិកប្រយោជន៍

*ប្រយោជន៍ដែលមានក្នុងបច្ចុប្បន្ន ហៅថាទិដ្ឋធម្មិកប្រយោជន៍ មាន ៤ យ៉ាងគឺ*

១- **ឧដ្ឋានសម្បទា** *ដល់ព្រមដោយសេចក្តីប្រឹងប្រែង គឺទ្រង់ប្រដៅឲ្យខំខ្នះខ្នែងរវាសរវៃធ្វើការងារដែលឥតទោស មានរៀនជំនួញ ៥ ប្រការជាដើម មិនត្អូញត្អែរបង្អែបង្អង់ឲ្យហួសកាលវេលាខកខានការងារ ទាល់តែលែងសម្រេចសេចក្តីបំណងនោះៗ,*

២- **អារក្ខសម្បទា** *ដល់ព្រមដោយការរក្សា គឺទ្រង់ប្រដៅឲ្យខំថែរក្សាទុករបស់ដែលរកបានមក ដោយអំពើដែលមិនមានទោសនោះឲ្យគង់នៅ បានដល់ការធ្វើទីកន្លែង សម្រាប់ទុកដាក់របស់ទាំងនោះមានជួសជុលផ្ទះសម្បែងធ្វើជង្រុក, ធ្វើក្រោល ធ្វើរបងជាដើម, ម្យ៉ាងទៀត*

---

១- ពាក្យទី ១ បានដល់វិន័យបិដក, ពាក្យទី ២ បានដល់សុត្តន្តបិដក, ពាក្យទី ៣ បានដល់អភិធម្មបិដក ។

មិនត្រូវធ្វើទ្រព្យទាំងនោះឲ្យខូចខាតដោយការឥតប្រយោជន៍ ដូចយ៉ាងល្បែងស្រី, ល្បែងស្រា, ល្បែងស៊ីសងផ្សេងៗ,

៣- **សមជីវិតា** ភាពជាអ្នកចិញ្ចឹមជីវិតស្មើៗ គឺទ្រង់ប្រដៅឲ្យចិញ្ចឹមជីវិតតាមសមគួរដល់ទ្រព្យដែលខ្លួនរកបាន កុំរិះពេក, កុំកញ្ចះកញ្ចាយពេក, ត្រូវតែត្រូវរំលែកទ្រព្យដែលរកបានមកនោះជាបីចំណែក មួយចំណែកទុកចំណាយខាងគ្រឿងឧបភោគ បរិភោគធម្មតា[១] មួយចំណែកសម្រាប់ទុកការពារសេចក្ដីអន្តរាយខ្លះៗទៅខាងមុខ, មួយចំណែកទៀតសម្រាប់សាងកុសលទុកក្នុងព្រះពុទ្ធសាសនា ជាកំណាប់បុណ្យទៅអនាគត ។

៤- **កល្យាណមិត្តតា** ភាពជាអ្នកគប់រកតែកល្យាណមិត្រ គឺទ្រង់ប្រដៅឲ្យសេពគប់រាប់រកតែមិត្រដែលគួរគប់ ៤ ចំពូកគឺ មិត្រមានឧបការៈ១, មិត្ររួមសុខទុក្ខបាន ១, មិត្រចេះណែនាំពន្យល់ប្រយោជន៍ឲ្យ ១, មិត្រចេះអនុគ្រោះគ្នា ១, វៀរមិត្រអាក្រក់មិនគួរគប់ ៤ ចំពូកគឺ មិត្រគិតតែប្រយោជន៍ខ្លួន ១, មិត្រល្អតែមាត់ ១, មិត្រប្រសប់និយាយចាក់បណ្ដោយ ១, មិត្រនាំឲ្យវិនាស ១, មិត្រ ៤ ពួកនេះ ហៅថាមិត្របួម ។

## សម្បរាយិកប្រយោជន៍

ប្រយោជន៍ដែលមានខាងបរលោក ឬខាងអនាគតជាតិ ហៅថាសម្បរាយិកប្រយោជន៍ មាន ៤ យ៉ាងគឺ

---

១- គ្រឿងឧបភោគ បានដល់គ្រឿងប្រើប្រាស់, គ្រឿងបរិភោគ បានដល់គ្រឿងអាហារ ។

១- **សទ្ធាសម្បទា** ដល់ព្រមដោយសទ្ធា គឺទ្រង់ប្រដៅឲ្យជឿហេតុដែលគួរជឿបានដល់ជឿកម្មថាទោះល្អក្តី អាក្រក់ក្តី សុទ្ធតែឲ្យផល, ជឿផលថាទោះបីល្អក្តី, អាក្រក់ក្តី សុទ្ធតែមកអំពីកម្ម, ជឿថាអ្វីទាំងអស់សុទ្ធតែមានហេតុមានបច្ច័យ, ជឿប្រាជ្ញាត្រាស់ដឹងរបស់ព្រះពុទ្ធថាប្រាកដជាត្រាស់ដឹងត្រូវពិតមែន ។

២- **សីលសម្បទា** ដល់ព្រមដោយសីល គឺទ្រង់ប្រដៅឲ្យរក្សាសីលឲ្យហ្មត់ចត់តាមនាទីរបស់ខ្លួនកុំឲ្យដាច់ធ្លុះធ្លាយ ។

៣- **ចាគសម្បទា** ដល់ព្រមដោយការលះបង់ គឺទ្រង់ប្រដៅឲ្យចំណាយទ្រព្យដែលរកបានមកធ្វើបុណ្យទាន មានចែកចាយដល់ស្មូមយាចកជាដើម ។

៤- **បញ្ញាសម្បទា** ដល់ព្រមដោយបញ្ញា គឺទ្រង់ប្រដៅឲ្យមានប្រាជ្ញាចេះពិចារណា ឲ្យស្គាល់គុណ ទោស ខុស ត្រូវ, ស្គាល់ព្រះត្រៃលក្ខណ៍, ស្គាល់អរិយសច្ច ៤ ។

សម្បរាយិកប្រយោជន៍ ៥ យ៉ាងទៀតគឺ

១- **ហិតចរិយា** ប្រព្រឹត្តប្រយោជន៍ដើម្បីបុគ្គលដទៃ គឺទ្រង់ប្រដៅថាបើឃើញប្រយោជន៍យ៉ាងធំដែលជនច្រើននាក់គប្បីបាន ព្រោះលះបង់ប្រយោជន៍ល្មមប្រមាណរបស់ខ្លួន, នោះលោកថាគួរឲ្យលះបង់ប្រយោជន៍ខ្លួនដើម្បីជួយឧបត្ថម្ភដល់ជនច្រើននាក់ ល្អជាង, ដូចទ្រង់លះបង់ប្រយោជន៍

របស់ព្រះអង្គដើម្បីសត្វលោក ក្នុងកាលនៅជាសុមេធតាបសជាតួយ៉ាង ។

២- **កម្ម** អំពើ សព្វសត្វក្នុងលោកដែលនឹងបានល្អឬអាក្រក់, ក៏ព្រោះអំពើដែលខ្លួនធ្វើទុក, បើធ្វើល្អ ក៏បានល្អ, ធ្វើអាក្រក់ក៏បានអាក្រក់, ហេតុនេះហើយ ទើបទ្រង់ប្រដៅឲ្យជឿកម្ម ។

៣- **បរិសុទ្ធិ** សេចក្ដីបរិសុទ្ធ, ទ្រង់ប្រដៅឲ្យធ្វើចិត្តឲ្យបរិសុទ្ធ បើចិត្តបរិសុទ្ធហើយ អាចនាំឲ្យបានទៅកើតក្នុងសុគតិភព, បើចិត្តមិនបរិសុទ្ធទេ នឹងនាំឲ្យទៅកើតក្នុងទុគ្គតិភពវិញ, ព្រោះថា បដិសន្ធិចិត្តអាស្រ័យនឹងចិត្តចាស់ជាបច្ច័យ បើចិត្តចាស់យ៉ាងណាបដិសន្ធិក៏យ៉ាងនោះដែរ ។

៤- **ភាវនា** ការចម្រើន បានដល់ការដែលធ្វើកុសលណាមួយ ឲ្យរឿយៗ នៅក្នុងសន្ដាន, ដូចយ៉ាងសេចក្ដីស្លាប់ជាភ័យមួយយ៉ាងពន្លឹកសម្រាប់ពួកសត្វលុះណាតែបានចម្រើនសេចក្ដីស្លាប់នេះ ជាប់នៅក្នុងចិត្តរឿយៗ ទើបអាចការពារសេចក្ដីខ្លាចដ៏ពន្លឹកនេះបាន, ហេតុនោះ សាធុជនគួរចម្រើនមរណស្សតិឲ្យរឿយៗ ។

## បរមត្ថប្រយោជន៍

ប្រយោជន៍ដែលឧត្ដមបំផុតហៅថា បរមត្ថប្រយោជន៍, បានដល់ត្រៃសិក្ខាគឺ សីល, សមាធិ, បញ្ញា និងបដិបទាដទៃៗ ទៀតដែលជាគ្រឿងញ៉ាំងសត្វឲ្យដល់នូវព្រះនិព្វាន ព្រះនិព្វាននេះឯងជាមកុដរត្នរបស់ពុទ្ធសាសនា, ជាមហាសម្បត្តិរបស់ត្រៃលោក, ជាឧត្ដមប្រយោជន៍របស់ពុទ្ធ-

សាសនិកជន, ហេតុអ្វី? ព្រោះថាពាក្យប្រដៅរបស់ព្រះពុទ្ធដែលទ្រង់ប្រដៅអស់កាលកំណត់ ៤៥ ឆ្នាំ ទ្រង់មានបំណងតែម៉្យាង គឺដើម្បីឲ្យសត្វបាននូវកំពូលកែវគឺព្រះនិព្វាននេះឯង, សម្បត្តិទាំងអស់ក្នុងត្រៃភព ទោះជាសម្បត្តិមនុស្សក្តី, សម្បត្តិទេវតាក្តី, សម្បត្តិព្រហ្មក្តី ឥតមានសម្បត្តិណាមួយ ថ្លៃថ្លាដូចបរមត្ថប្រយោជន៍នេះឡើយ ព្រោះថាសម្បត្តិទាំងនោះសុទ្ធសឹងនៅប្រែប្រួលទៅតាមសាមញ្ញលក្ខណៈ, ឯបរមត្ថសម្បត្តិមិនដូច្នោះឡើយ ហើយតែងជាទីប្រាថ្នារបស់ត្រៃលោក, ប្រយោជន៍ដែលថ្លៃថ្លាបំផុត ដែលពុទ្ធសាសនិកជន គប្បីប្រាថ្នាហើយ គប្បីបានជារង្វាន់នោះឥតមានអ្វីក្រៃលែងជាងបរមត្ថប្រយោជន៍នេះឡើយ ។

មកុជរត្ន, មហាសម្បត្តិ, ឧត្តមប្រយោជន៍នោះឯង ក៏គឺសេចក្តីសុខដែលហួសប្រៀប, ព្រោះជាសុខដ៏ក្រៃលែង (បរមត្ថសុខ) ជាសុខដោយចំណែកមួយ (ឯកន្តសុខ) ព្រោះមានសុខតែម៉្យាង ឥតមានទុក្ខជាគូផង, ជាសុខឥតប្រឡំដោយទុក្ខ (និរាមិសសុខ) គឺមិនមែនសុខខ្វះ ទុក្ខខ្វះ ជាសុខលែងប្រែប្រួលទៅដោយហេតុបច្ច័យទៀតបាន ផុតអំណាចហេតុបច្ច័យត្រូវគ្រប់គ្រង ផុតបំណងរបស់បញ្ចពិធមារ, ព្រោះឥតមានជាតិជាបច្ច័យ គឺថាព្រះនិព្វានអស់ពូជ ចាស់ ឈឺ ស្លាប់ ពោលគឺជាតិទៀតហើយ។

ន័យមួយទៀតពាក្យថា សត្ថា លោកប្រៀបដោយនាយឈ្មួញរទេះ, ឯឈ្មួញរទេះ ដែលឈ្លាសវៃ ប៉ិនប្រសប់ ស្គាល់កាលវេលាត្រូវទៅឬត្រូវឈប់នៅជាដើម ទើបអាចញ៉ាំងកូនឈ្មួញ ទាំងរយនាក់មិនឲ្យស្អុនដំណើរ ឲ្យឆ្លងផ្លូវឬវាលឆ្ងាយដាច់ស្រយាល ដែលហៅថា កន្តារៈបាន ។ កន្តារៈនោះមាន ៥ គឺចោរកន្តារៈ បានដល់ផ្លូវដែលមានចោរច្រើននៅចាំពិឃាដ ឬបៀតបៀនអ្នកដំណើរដែលដើរទៅមកតាមដងផ្លូវ, ពាលកន្តារៈ បានដល់ផ្លូវដែលមានម្រឹគសាហាវច្រើនមានខ្លានិងសិង្ហតោជាដើម នៅតាមដងមាគ៌ា ចាំចាប់មនុស្សឬសត្វជាអាហារ, និរុទកកន្តារៈ បានដល់ផ្លូវឆ្ងាយដែលឥតទឹកសោះ មានសុទ្ធតែខ្សាច់ពាសពេញវាល ដែលហៅថា សមុទ្រខ្សាច់, អមនុស្សកន្តារៈ បានដល់ផ្លូវដែលមានអមនុស្សច្រើនមានយក្សជាដើមនៅតាមដងផ្លូវ ចាំបៀតបៀនអ្នកដំណើរដោយអាការផ្សេងៗ, អប្បភក្ខកន្តារៈ បានដល់ផ្លូវដែលមានស្បៀងអាហារសម្រាប់សត្វឬមនុស្សតិចពេក, នាំឲ្យអ្នកដំណើរក្សយជីវិតព្រោះសេចក្តីអត់ឃ្លាន ។ នាយឈ្មួញដែលឈ្លាសវៃអាចញ៉ាំងកូនឈ្មួញឲ្យឆ្លងសេចក្តីអន្តរាយក្នុងផ្លូវបានយ៉ាងណា ឯព្រះបរមគ្រូក៏ដូច្នោះដែរ ទ្រង់ជាមហានាយកតែងដឹកនាំសត្វឲ្យឆ្លងផ្លូវឆ្ងាយដាច់ស្រយាលវាលធំឥតជ្រុងជ្រោយពោលគឺ **ជាតិ, ជរា, ព្យាធិ, មរណៈ, សោក, បរិទេវ, ទុក្ខ, ទោមនស្ស, ឧបាយាស, ទិដ្ឋិ,**

**ឧទ្ធច្ច, វិចិកិច្ឆា, សីលព្វតបរាមាស** *ឥតមានទទាក់ទទាម, ធម៌ទាំង ១៣ នេះឯងហើយ ជាផ្លូវឆ្ងាយដាច់ស្រយាល វាលវែងរបស់សត្វ, សត្វដែលប្រតិបត្តិធ្វើតាមពុទ្ធឱវាទ ទើបអាចឆ្លងកន្តារៈបាន ឯសត្វក្រៅពីនេះ ពុំដែលឆ្លងបានឡើយ, សុទ្ធសឹងតែវិនាសក្សិណក្ស័យក្នុងផ្លូវឬវាលធំនេះឯងពុំខាន ។*

*ព្រះបរមគ្រូលោកនាថ ទ្រង់ឈ្លាសវៃក្នុងវិធីប្រដៅសត្តនិករដោយប្រយោជន៍ ៣ យ៉ាង និងចម្លងសត្វដែលប្រព្រឹត្តតាមឱវាទឲ្យឆ្លងសំសារ-កន្តារៈបានយ៉ាងនេះទើបទ្រង់ព្រះនាមថា "សត្ថាទេវមនុស្សានំ" ។*

## វិនិច្ឆ័យបទថា "ពុទ្ធោ"

### សេចក្ដីសួរដែលគួរចាំ

*១- អ្វីហៅថា អរិយសច្ច? មានប៉ុន្មាន គឺអ្វីខ្លះ?*

*២- អរិយសច្ចទាំងនោះ មួយៗ មានអត្ថប៉ុន្មានយ៉ាងៗ គឺអ្វីខ្លះ?*

### សេចក្ដីឆ្លើយ

*១- ធម៌ពិតដែលអាចធ្វើអ្នកត្រាស់ដឹងឲ្យឆ្លងផុតបុថុជ្ជនគោត្រទៅកាន់អរិយគោត្របាន ហៅថា អរិយសច្ច, មាន ៤ យ៉ាង គឺ* **ទុក្ខសច្ច ១, សមុទយសច្ច ១, និរោធសច្ច ១, មគ្គសច្ច ១ ។**

*២- អរិយសច្ចទាំង ៤ នេះ មួយៗ មានអត្ថ ៤ យ៉ាងៗរួមទាំងអស់ជា ១៦ យ៉ាង,*

*សច្ចៈទី១ មានអត្ថ ៤ យ៉ាងគឺ បីឡនត្ថៈ១, សង្ខតត្ថ ១, សន្តាបត្ថ ១, វិបរិណាមត្ថ ១ ។*

*សច្ចៈទី ២ មានអត្ថ ៤ យ៉ាងគឺ អាយុហនត្ថ ១, និទានត្ថ ១, សំយោគត្ថ ១, បលិពោធត្ថ ១ ។*

*សច្ចៈទី ៣ មានអត្ថ ៤ យ៉ាងគឺ និស្សរណត្ថ ១, អបលិពោធត្ថ ១, អសំខតត្ថ ១, អមតត្ថ ១ ។*

*សច្ចៈទី ៤ មានអត្ថ ៤ យ៉ាងគឺ និយ្យានត្ថ ១, ហេតុត្ថ ១, និទស្សនត្ថ ១, អធិបតត្ថ ១, រួមទាំងអស់ត្រូវជាអត្ថ ១៦ យ៉ាង ។*

# សេចក្តីអធិប្បាយ

សច្ចៈទី១ មានអត្ថ ៤ យ៉ាងគឺ ១- បីឡនត្ថ មានកិរិយាបៀតបៀនជាអត្ថ សេចក្តីថា ទុក្ខទាំង ១២ មានជាតិទុក្ខជាដើម តែងបៀតបៀនពាធាសត្វដែលកើតក្នុងភាជនលោក ឲ្យឈឺចាប់ចុកសៀតរាងកាយក្សយជីពជន្ម ព្រាត់ប្រាសបុត្រភរិយា សែនសោយសោកអន់ចិត្ត តូចចិត្ត ចង្អៀតទ្រូង មានសេចក្តីលំបាកលើសពណ៌នា ២- សំខតត្ថ មានកិរិយាតាក់តែងជាអត្ថ សេចក្តីថា សព្វសត្វទាំងអស់សឹងមានតណ្ហាជាបច្ច័យប្រជុំតាក់តែងលៃលកឲ្យកើតកងទុក្ខទាំងពួង, ៣- សន្តាបត្ថ មានកិរិយាដុតកម្តៅជាអត្ថ, សេចក្តីថា សព្វសត្តនិករដែលបានសេចក្តីក្តៅក្រហាយអន្ទះអន្ទែងពុំចេះបានស្រាកស្រាន្តនោះ ព្រោះមិនប្រតិបត្តិតាមអដ្ឋង្គិកមគ្គដែលប្រកបដោយអង្គ ៨ មានសម្មាទិដ្ឋិជាដើម, ៤- វិបរិណាមត្ថ មានកិរិយាប្រែប្រួលជាអត្ថ, សេចក្តីថាប្រជាសត្វដែលមានសេចក្តីវិបត្តិមករឹបជាន់ឲ្យប្រែប្រួលទៅតាមធម្មតាវិស័យ អាស្រ័យហេតុដែលពុំទាន់បាននូវនិរោធសច្ចដែលជាគ្រឿងផ្តិលផ្តាច់ សេចក្តីវិបត្តិសព្វប្រការនៅឡើយ ។

សច្ចៈទី ២ មានអត្ថ ៤ យ៉ាងគឺ ១- អាយុហនត្ថ មានកិរិយាប្រមូលនូវសេចក្តីទុក្ខជាអត្ថ, សេចក្តីថា តណ្ហាជាមេបា តែងប្រមូលជញ្ជូនមកនូវសេចក្តីទុក្ខសព្វប្រការដល់សត្វ, ពួកសត្វសព្វក្រុមពុំមានរើសថាសត្វណាឡើយ ទោះបីជាសត្វដែលតូចដែលធ្មារល្អិតមានស្រមោចស្រមើលជាដើម

ក៏សុទ្ធសឹងរងសេចក្តីទុក្ខទាំងអស់, ២- និទានត្ថ មានហេតុគឺតណ្ហាជាអត្ថ, សេចក្តីថា សត្វសព្វជាតិដែលទទួលរងសេចក្តីទុក្ខជានិច្ច និរន្ត ឥតមានចន្លោះកាលវេលាព្រោះអាស្រ័យតណ្ហាជាដើមហេតុ ដើមចម ជាអ្នកបង្កបង្កើតសេចក្តីទុក្ខឲ្យ, ៣- សំយោគត្ថ មានកិរិយាប្រកបសត្វទុកជាអត្ថ, សេចក្តីថា តណ្ហានេះឯង តែងចងត្រៀមសត្វទុកនឹងបង្គោលពោលគឺភព ឲ្យសត្វវិលកើតស្លាប់ ឥតមានល្ហែ, ព្រោះហេតុអ្វី? ព្រោះហេតុដែលសត្វទាំងនោះមិនធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន, ៤- បលិពោធត្ថ មានសេចក្តីកង្វល់ជាអត្ថ, សេចក្តីថា សព្វសត្តនិករ ដែលមានសេចក្តីវល់ជានិច្ច ដោយវត្ថុកាមនិងកិលេសកាម រកលះបង់ធុរៈនោះៗ មិនរួចព្រោះហេតុអ្វី? ព្រោះហេតុដែលសត្វមិនព្រមប្រតិបត្តិតាមមគ្គសច្ច ដែលប្រកបដោយអង្គទាំង ៨ ប្រការ ។

សច្ចៈទី ៣ មានអត្ថ ៤ យ៉ាងគឺ ១- និស្សរណត្ថ មានកិរិយាវេចេញជាអត្ថ, សេចក្តីថា បុគ្គលដែលវេខ្ជួនចេញចាកភព ៣ បាន មិនវិលស្លាប់កើតទៀតក្នុងភពទាំងនោះ ព្រោះហេតុដែលបាននូវនិរោធសច្ចពោលគឺនិព្វាន, ២- អបលិពោធត្ថ មានសេចក្តីអស់វល់ជាអត្ថ, សេចក្តីថា បុគ្គលដែលលះវល់ក្នុងវត្ថុកាមនិងកិលេសកាមបាន ព្រោះមានសន្តានប្រាសចាកតណ្ហាជាមេតាក់តែងនូវបដិសន្ធិក្នុងជាតិថ្មីទៀត, ៣- អសំខតត្ថ មានកិរិយាមិនតាក់តែងជាអត្ថ, សេចក្តីថា បុគ្គលដែលវេរុះទម្លុះទម្លាយបំបាក់

បំបែកនូវផ្ទះពោលគឺអត្តភាពដែលជាស្នាដៃរបស់មេជាង គឺតណ្ហាសង់ឲ្យបាន ព្រោះអាស្រ័យសេចក្ដីប្រតិបត្តិតាមពុទ្ធោវាទគឺ អដ្ឋង្គិកមគ្គ, ៤- អមតត្ថ មានសេចក្ដីមិនស្លាប់ជាអត្ថ, សេចក្ដីថា បុគ្គលដែលបានក្រេបផឹកនូវអម្រឹតរសបានជាសះស្បើយដាច់ស្រឡះចាករោគទាំង ១២ មុខមានជាតិរោគជាដើមបាន ព្រោះបានក្រេបផឹកនូវអម្រឹតរសដែលជាឱសថទិព្វវិសេស ។

សច្ចៈទី ៤ មានអត្ថ ៤ យ៉ាងគឺ ១- និយ្យានត្ថ មានកិរិយានាំខ្លួនជាអត្ថ សេចក្ដីថា បុគ្គលដែលអាចឆ្លងនូវមហាសមុទ្ទ គឺវដ្ដសង្សារបាន ព្រោះអាស្រ័យមហានាវា គឺអរិយមគ្គជាយាន សម្រាប់ជិះឆ្លង បើវៀរចាកនាវានេះហើយ ពុំអាចឆ្លងបានឡើយ, ២- ហេត្វត្ថ មានហេតុគឺតណ្ហាជាអត្ថ, សេចក្ដីថាបុគ្គលដែលឆ្លងលោកិយសមុទ្ទមិនរួច ព្រោះអាស្រ័យតណ្ហាជាមូលហេតុ មានតណ្ហាជាប្រធាន លុះត្រាតែជិះយានគឺ អដ្ឋង្គិក-មគ្គ ទើបអាចឆ្លងបាន, ៣- និទស្សនត្ថ មានសេចក្ដីណែនាំពន្យល់ជាអត្ថ, សេចក្ដីថាបុគ្គលដែលបាននូវនិរោធពោលគឺមហានិព្វាន ជាស្ថានក្សេមចាកទុក្ខសព្វយ៉ាង ព្រោះអាស្រ័យអរិយមគ្គជាគ្រឿងពន្យល់ ជាគ្រឿងណែនាំ, បើប្រាសចាកអរិយមគ្គនេះហើយ មិនអាចនឹងសម្រេចបានសោះឡើយ, ៤- អធិបតត្ថ មានភាពធំជាអត្ថ, សេចក្ដីថា សព្វសត្វដែលបានរម្ងាប់នូវសេចក្ដីទុក្ខជាអនេកបាន ព្រោះអាស្រ័យសច្ចៈជាធំ

មានមគ្គសច្ចជាអធិបតី បើវៀរចាកមគ្គសច្ចហើយ មិនមានអ្វីឡើយនឹងអាចរំងាប់សេចក្តីទុក្ខទាំងនោះបាន ។

ព្រះមានជោគ ទ្រង់ជ្រាបនូវអរិយសច្ចទាំង ៤ នេះ ព្រមទាំងអត្ថដោយជាក់ច្បាស់ ចំពោះព្រះអង្គឯងរួចហើយ ទ្រង់ចែករំលែកឲ្យសត្វដទៃបានត្រាស់ដឹងផង ទើបទ្រង់ព្រះនាមថា "ពុទ្ធោ" ។

## (១០) វិនិច្ឆ័យបទថា "ភគវា"

## សេចក្ដីសួរដែលគួរចាំ

*១- ដែលទ្រង់ព្រះនាមថា "ភគវា" ព្រោះទ្រង់ប្រកបដោយគុណធម៌អ្វីខ្លះ?*

*២- ព្រះនាមថា "ភគវា" នេះ អ្នកណាថ្វាយ?*

*៣- ព្រះនាមថា "ភគវា" នេះ ជាអត្តសម្បត្តិ? ឬបរហិតបដិបត្តិ?*

## សេចក្ដីឆ្លើយ

*១- ដែលទ្រង់ព្រះនាមថា "ភគវា" ព្រោះទ្រង់ប្រកបដោយគុណធម៌ដូច្នេះ៖*

*ក) ព្រោះទ្រង់មានកុសលធម៌,*

*ខ) ព្រោះទ្រង់បំបាក់បង់នូវកិលេស,*

*គ) ព្រោះទ្រង់មានភោគ,*

*ឃ) ព្រោះទ្រង់ចែកនូវធម្មរតន,*

*ង) ព្រោះទ្រង់គប់រកនូវវិហារធម៌ចំណែកខាងល្អ,*

*ច) ព្រោះទ្រង់ខ្ជាក់ចោលនូវតណ្ហាក្នុងភព,*

*២- ព្រះនាមថា "ភគវា"នេះ ឥតមានអ្នកណាថ្វាយទេ គឺកើតមានឡើងដោយគុណសម្បត្តិរបស់ព្រះអង្គ គឺតាំងឡើងដោយសំអាងហេតុ ។*

*៣- ព្រះនាមថា "ភគវា" ប្រកាសគុណទាំង ២ គឺទាំងអត្តសម្បត្តិ*

និងបរហិតបដិបត្តិ ។

# សេចក្ដីអធិប្បាយ

## ក) អំពីទ្រង់មានកុសលធម៌

បារមីធម៌ទាំងអស់ ហៅថា កុសលធម៌, មាន ១០ យ៉ាងគឺ ទាន ការឲ្យវត្ថុដែលគួរឲ្យ ១, សីល សេចក្ដីប្រព្រឹត្តកាយវាចាឲ្យល្អ ១, នេក្ខម្ម: ការចេញបួសឬចេញសាងផ្នួស ១, បញ្ញា សេចក្ដីយល់ឃើញជាក់លាក់ ១, វិរិយ សេចក្ដីប្រឹងប្រែង ១, ខន្តិ សេចក្ដីអត់ធន់ ១, សច្ច សេចក្ដីទៀងត្រង់ ១, អធិដ្ឋាន សេចក្ដីតាំងចិត្តទទួលកិច្ចដែលគួរកាន់យក ១, មេត្តា សេចក្ដីអាណិតអាសូរ ១, ឧបេក្ខា សេចក្ដីទទួលអារម្មណ៍កណ្ដាលៗ (មិនសុខមិនទុក្ខ) ១ ។

ធម៌ទាំង ១០ យ៉ាងនេះ ក្នុងធម៌មួយៗលោកចែកជា ៣ ថ្នាក់គឺ មុទុ ថ្នាក់អន់ ១, មជ្ឈិម ថ្នាក់កណ្ដាល ១, ឧក្រិដ្ឋ ថ្នាក់ខ្ពស់ ១ ។ មុទុ សំដៅយកបារមីប្រារព្ធរបស់ខាងក្រៅអំពីអវយវៈរបស់ព្រះអង្គគឺ បុត្តភរិយានិងវត្ថុផ្សេងៗ, មជ្ឈិម សំដៅយកឧបបារមីប្រារព្ធយកអវយវៈរបស់ព្រះអង្គ, ឧក្រិដ្ឋ សំដៅយកបរមត្ថបារមី ប្រារព្ធយកជីវិតរបស់ព្រះអង្គ ។ តួយ៉ាងដូចទាន មានសេចក្ដីពន្យល់ថា ទានបារមី[១] បានដល់ការឲ្យបុត្តភរិយា

---

១- បារមីដទៃទៀតបណ្ឌិតគប្បីយល់សេចក្ដីអធិប្បាយតាមន័យនេះចុះ ។ រឿងនេះមានអធិប្បាយមកហើយត្រង់ពុទ្ធការកធម៌ ។

និងទ្រព្យនានាទៅជាទាន ទានឧបបារមី បានដល់ការឲ្យអវយវៈ ឬខ្លួនរបស់ព្រះអង្គជាទាន, ទានបរមត្ថបារមី បានដល់ការឲ្យជីវិតទៅជាទាន ។

ធម៌ទាំង ១០ យ៉ាងនេះ បានឈ្មោះថា បារមី លុះត្រាតែមានករុណូបាយកោសល្យ គឺសេចក្តីឆ្លៀវឆ្លាសក្នុងឧបាយនៃសេចក្តីអាណិតអាសូរជួយឧបត្ថម្ភផងទើបបានឈ្មោះដូច្នោះ, បើកសាងចំពោះប្រយោជន៍ខ្លួនមិនបម្រុងនឹងជួយសង្គ្រោះសត្វដទៃផងទេ មិនចាត់ឲ្យឈ្មោះថា "បារមីធម៌" ឡើយ ។ បារមីធម៌នេះហើយ ដែលអាចឲ្យបានសុខទាំង ២ យ៉ាងគឺ លោកិយសុខ បានដល់សុខដែលប្រព្រឹត្តទៅក្នុងលោកគឺភពបី ១, លោកុត្តរសុខ បានដល់សុខទីបំផុតគឺព្រះនិព្វាន ១ ។

ព្រះមានព្រះភាគទ្រង់បរិបូណ៌ដោយធម៌ទាំង ១០ នេះ, ទ្រង់ដល់នូវត្រើយនៃធម៌ទាំង ១០ នេះ ទើបឈ្មោះថា "ទ្រង់មានកុសលធម៌" ។

៦) អំពីទ្រង់បំបាក់បង់នូវកិលេស

កិលេសរាប់សែនជាគ្រឿងក្រវល់ក្រវាយសព្វយ៉ាង, ជាគ្រឿងក្រហល់ក្រហាយសព្វប្រការ ទ្រង់បំបាក់បង់បាន ទ្រង់លះបង់បានឥតសំណល់, ឥតសេសសល់ក្នុងសន្តានព្រះអង្គដល់តិចតួចឡើយ ។

កិលេសទាំងនោះមានប្រភេទផ្សេងៗគ្នាដូច្នេះគឺ **លោភៈ** សេចក្តីលោភ, **ទោសៈ** សេចក្តីប្រទូស្ត, **មោហៈ** សេចក្តីវង្វេង, **វិបរីតៈ** សេចក្តីខុសចាកការធ្វើទុកក្នុងចិត្ត, **អហិរិកៈ** សេចក្តីមិនខ្មាសបាប, **អនោ-**

**ត្តប្បៈ** *សេចក្តីមិនខ្លាចបាប,* **គោ្រាធៈ** *សេចក្តីក្រោធ ។ ល ។* **បមាទៈ** *សេចក្តីធ្វេសប្រហែស,* **តណ្ហា** *សេចក្តីចំណង់អន្ទះសា,* **អវិជ្ជា** *សេចក្តីល្ងង់,* **អកុសលមូលៈ** *ឫសអកុសល,* **ទុច្ចរិតៈ** *សេចក្តីប្រព្រឹត្តអាក្រក់,* **សំកិលេសៈ** *សេចក្តីសៅហ្មង,* **មលៈ** *មន្ទិល,* **វិសមសញ្ញា** *សេចក្តីសម្គាល់ខុស,* **វិតក្កៈ** *សេចក្តីត្រិះរិះខុស,* **បបញ្ចៈ** *ធម៌ធ្វើដំណើរឲ្យយឺតយូរ,* **វិបរិយេសៈ** *សេចក្តីស្វែងរកខុស,* **អាសវៈ** *ធម៌ជាគ្រឿងត្រាំសត្វ,* **គណ្ឋៈ** *ធម៌ជាគ្រឿងចងសត្វ,* **ឱឃៈ** *ធម៌ជាគ្រឿងជ្រមុជពន្លិចសត្វ,* **យោគៈ** *ធម៌ជាគ្រឿងក្រងសត្វទុក,* **អគតិ** *សេចក្តីលម្អៀង,* **តណ្ហុប្បាទៈ** *សេចក្តីប្រកាន់ព្រោះតណ្ហា,* **ចេតោខិលៈ** *បង្គោលគ្រាកចិត្ត,* **វិនិពន្ធៈ** *ចំណងសម្រាប់រឹតសត្វ,* **នីវរណៈ** *ធម៌ជាគ្រឿងរារាំង,* **អភិជ្ឈៈ** *សេចក្តីរីករាយខ្លាំង,* **រាគមលៈ** *ហេតុនៃជម្ងោះ,* **តណ្ហាកាយៈ** *ធម៌ជាពួកនៃតណ្ហា,* **សត្តានុសយៈ** *ធម៌ជាគ្រឿងដេកនៅក្នុងសន្តានសត្វ,* **មិច្ឆត្តៈ** *សេចក្តីយល់ខុស,* **តណ្ហាមូលកៈ** *ហេតុនៃតណ្ហា,* **អកុសលកម្មបថៈ** *គន្លងនៃអកុសលកម្ម,* **ទ្វាសដ្ឋីទិដ្ឋិ** *សេចក្តីយល់ខុស ៦២,* **តណ្ហាវិបរីតៈ** *សេចក្តីខុសគឺតណ្ហា ។ បើពោលដោយសង្ខេបមានតែ ៥ គឺ កិលេសមារ ១, ខន្ធមារ ១, អភិសង្ខារមារ ១, ទេវបុត្តមារ ១, មច្ចុមារ ១ ។*

## ក) អំពីទ្រង់មានជោគ

*ព្រះមានព្រះភាគ ទ្រង់មានជោគ ព្រោះទ្រង់ប្រកបដោយធម៌ ៦ យ៉ាងគឺ ឥស្សរិយៈ ភាពជាធំ ១, ធម្មៈ លោកុត្តរធម៌ ១, យសៈ យស ១, សិរី សួស្តី ១, កាមៈ សេចក្តីសម្រេចដូចប្រាថ្នា ១, បយត្តៈ សេចក្តីអង់អាច ១ ។*

*ឥស្សរិយៈ បានដល់ភាពជាធំយ៉ាងឆ្នើមដែលមានក្នុងព្រះទ័យរបស់ព្រះអង្គ ឬឥស្សរិយយស[១] ដែលលោកសន្មតថា "អណិមា, លឃិមា" ជាដើម ក៏មានដោយប្រការសព្វគ្រប់ ។ ធម្មៈ បានដល់លោកុត្តរធម៌ ដែលបរិបូណ៌ក្នុងសន្តានរបស់ព្រះអង្គ ។ យសៈ បានដល់សេចក្តីបរិសុទ្ធវិសេស ដែលទ្រង់បានត្រាស់ដឹងតាមសមគួរដល់សេចក្តីពិត សឹងប្រាកដដល់ត្រៃ-លោក ។ សិរី បានដល់សួស្តី ដែលទ្រង់មានសរីរាវយវៈបរិបូណ៌សព្វគ្រប់ អាចឲ្យកើតសេចក្តីជ្រះថ្លាដល់ភ្នែកនិងចិត្តនៃជនអ្នកខ្មីឃ្មាតចង់មើលរូបកាយ របស់ព្រះអង្គ ។ កាមៈ បានដល់ការសម្រេចប្រយោជន៍តាមបំណងដែលទ្រង់ប្រាថ្នា ព្រោះថាកិច្ចណាៗដែលទ្រង់ប្រាថ្នាហើយ,*

---

១ ឥស្សរិយយសមាន ៨ យ៉ាងគឺ ១- អណិមា ការធ្វើកាយឲ្យតូច ២- លឃិមា ការធ្វើកាយឲ្យស្រាលរហ័ស, ៣- មហិមា ការធ្វើកាយឲ្យធំ, ៤- បត្តិ ការដល់នូវប្រទេសតាមប្រាថ្នា, ៥- បាកម្មៈ ការសម្រេចសេចក្តីប្រាថ្នាដោយអំណាចអធិដ្ឋានជាដើម, ៦- វសិតា មានឥស្សរភាព ៧- ឥសិតា សេចក្តីស្ទាត់ជំនាញក្នុងការថ្លែងឫទ្ធិ, ៨- យត្ថកាមាវសាយិតា ការបញ្ឈប់នូវដំណើរ ឬកិច្ចការក្នុងទីណាមួយតាមសេចក្តីប្រាថ្នាបាន ។

ទ្រង់បំណងហើយ ទោះជាប្រយោជន៍ផ្ទាល់ព្រះអង្គក្តី, ប្រយោជន៍ដល់បុគ្គលដទៃក្តី, កិច្ចនោះៗ សឹងសម្រេចដូចទ្រង់បំណង ។ បយត្តៈ បានដល់សេចក្តីព្យាយាមត្រូវ ដែលជាហេតុឲ្យកើតឡើងនៃភាពជាអ្នកគួរគោរពរបស់សព្វសត្វលោក ។

**ឃ**) អំពីទ្រង់បែកនូវធម្មទាន

ព្រះមានជោគ ទ្រង់បែកនូវធម៌សព្វយ៉ាង (ឲ្យសត្វប្រតិបត្តិ) តាមប្រភេទមានកុសលធម៌ជាដើមថា នេះខន្ធៈ, នេះធាតុ, នេះអាយតនៈ, នេះឥន្ទ្រិយ, នេះបដិច្ចសមុប្បាទ, នេះទុក្ខ ព្រោះមានកិរិយាបៀតបៀនជាដើមជាអត្ថ, នេះសមុទ័យ ព្រោះមានកិរិយាប្រមូលមកជាដើមជាអត្ថ, នេះនិរោធ ព្រោះមានកិរិយារំខ្ជួនចេញចាកភពជាដើមជាអត្ថ, នេះមគ្គ ព្រោះមានកិរិយានាំចេញជាដើមជាអត្ថ ។ ធម៌ទាំងនេះ ព្រះអង្គទ្រង់បែក ទ្រង់ញែក ទ្រង់បើក, ទ្រង់ពន្យល់ហើយដោយប្រភេទប្លែកៗ គ្នា ។

**ង**) អំពីទ្រង់គប់រកវិហារធម៌បំណែកល្អ

ព្រះបរមលោកនាថ ទ្រង់គប់រក, ទ្រង់សេពរក, ទ្រង់ធ្វើឲ្យកើននូវធម៌ ជាគ្រឿងនៅ ដែលឈ្មោះថា ទិព្វវិហារ, ព្រហ្មវិហារ, អរិយវិហារ, ទ្រង់គប់សេចក្តីស្ងាត់កាយ, ស្ងាត់ចិត្ត, ស្ងាត់ចាកកិលេស, ទ្រង់គប់រកនូវឧត្តមគតិ (ឧត្តរិមនុស្សធម៌) ទាំងលោកិយ-លោកុត្តរ ។

## ៥) អំពីទ្រង់ខ្ជាក់បោលនូវតណ្ហាក្នុងភព

*ក៏ដំណើរសម្រាប់ទៅមកក្នុងភពទាំង ៣ គឺតណ្ហានោះ ទ្រង់ខ្ជាក់បោលហើយ, ទ្រង់លែងវាកបែរមករកភពនេះទៀតហើយ, ទ្រង់ផ្ដាច់សេចក្ដីអាល័យក្នុងភពស្រឡះអស់ហើយ, ទ្រង់បានដល់ហើយនូវត្រើយ គឺព្រះនិព្វាន ដែលជាស្ថានឥតមានកើតស្លាប់ទៀត ព្រោះអស់ពូជគឺតណ្ហាជាមេនាំឲ្យកើត-ស្លាប់នោះហើយ ។*

*ព្រះមានព្រះភាគ ទ្រង់ប្រកបដោយគុណធម៌ផ្សេងៗ យ៉ាងនេះ ទើបទ្រង់ព្រះនាមថា "ភគវា" ។*

## រួមហេតុដែលថ្វាយព្រះនាម

*ហេតុដែលតាំងឈ្មោះមាន ៤ យ៉ាងគឺ អវត្ថិកៈ តាំងតាមហេតុ ១, លិង្គិកៈ តាំងតាមភេទ ១, នេមិត្តិកៈ តាំងតាមសំអាង ១, បដិច្ច-សមុប្បន្នៈ តាំងតាមគាប់ចិត្ត ១ ។ តាំងតាមហេតុដូចហៅថា "កូនគោ, គោថ្នឹក, គោបម្រើ" ជាដើម, តាំងតាមភេទ ដូចហៅថា "ជនមានឈើច្រត់ គឺ មនុស្សចាស់, មនុស្សមានឆត្រ គឺមនុស្សប្រាំងឆត្រ, សត្វកំប៉ោយ (ក្ងោក), សត្វមានប្រមោយ (ដំរី)" ជាដើម តាំងតាមគាប់ចិត្តដូចហៅថា "នាយចម្រើនសិរី, នាយចម្រើនទ្រព្យ" ជាដើម ។*

*ក៏ព្រះនាមទាំង ១០ យ៉ាងតាំងអំពី "អរហំ" ដរាបដល់ "ភគវា" សុទ្ធតែជានេមិត្តិកនាម គឺតាំងតាមសំអាងហេតុ ព្រោះជាព្រះនាមទាំងនោះ*

ព្រះបាទសិរីសុទ្ធោទន ឬព្រះនាងសិរីមហាមាយាថ្វាយក៏ទេ ឬក៏ព្រះបរម-ញាតិវង្សានុវង្សទាំង ១៦ ហ្មឺន ថ្វាយក៏មិនមែន ឬនឹងថា ទេវតាពិសេសណាមួយ មានព្រះឥន្ទ្រជាដើម ថ្វាយក៏មិនមែន, ព្រះនាមទាំងនេះឯងកើតឡើងអាស្រ័យសំអាងគុណវិសេសដែលកើតមានក្នុងព្រះអង្គឯង ។

## វិធិប្ប័យបទប្បេជ្ញា

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ**

*ប្រែថា វត្ថុដទៃជាទីពឹងទីរឭក នៃខ្ញុំព្រះករុណាមិនមានឡើយ មានតែព្រះពុទ្ធជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា, សូមសិរីសួស្តីជយមង្គល ចូលមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

## សេចក្តីសួរដែលគួរចាំ

*១- វត្ថុជាទីពឹងដទៃបានដល់អ្វី?*

*២- បុគ្គលដែលបានប្តេជ្ញាខ្លួនដូច្នេះហើយ ត្រឡប់លះបង់ព្រះរត្នត្រ័យហើយងាករកទីពឹងដទៃវិញដាច់សរណគមន៍ឬទេ?*

*៣- ហេតុដែលសៅហ្មងសរណគមន៍ដូចម្តេចខ្លះ?*

## សេចក្តីឆ្លើយ

*១- បានដល់វត្ថុដទៃក្រៅចាកព្រះរត្នត្រ័យមានទេព្តាវិសេសដូចយ៉ាងព្រះឥសូរ-នារាយណ៍ ឬអារក្សទេព្រក្សអ្នកតាជាដើម ។*

*២- បុគ្គលបែបនេះឯង ឈ្មោះថាដាច់សរណគមន៍។*

*៣- ហេតុដែលសៅហ្មងសរណគមន៍មាន ៣ យ៉ាងគឺ ១- អញ្ញាណៈ*

មិនដឹងមិនស្គាល់គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ថាជាដូចម្តេចឡើយ ឮគេថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃក៏ថាតាមគេទៅ, ២- សំសយ រង្កៀសសង្ស័យក្នុងគុណព្រះរត្នត្រ័យមិនជាក់ច្បាស់ក្នុងចិត្ត, ៣- មិច្ឆា-ញាណៈ យល់ខុស ដឹងខុសក្នុងគុណព្រះរត្នត្រ័យថា ព្រះរត្នត្រ័យមាន គុណយ៉ាងនេះៗ យល់មិនត្រូវតាមសេចក្តីពិត ។

## សេចក្តីអធិប្បាយ

បុគ្គលដែលបានថ្វាយខ្លួនជាឧបាសក ឧបាសិកាចំពោះព្រះរត្នត្រ័យ ហើយ ឈ្មោះថាមានសរណគមន៍, បុគ្គលដែលមានសរណគមន៍ ដូច្នេះ ហើយ ដល់ពេលក្រោយមានទុក្ខធុរៈផ្សេងៗ ត្រឡប់លះបង់ព្រះរត្នត្រ័យ ចោល ហើយយកវត្ថុដទៃជាទីពឹង មានថ្វាយអាយុជីវិតចំពោះ អារក្សទេ-ព្រក្សអ្នកតាជាដើម ឬក៏រត់ទៅចូលកាន់សាសនាដទៃៗ ទៅ, បុគ្គលបែប នេះឯង ឈ្មោះថាដាច់សរណគមន៍ ព្រោះហេតុសរណគមន៍ដាច់មាន ២ យ៉ាងគឺ ដាច់មានទោស ១, ឥតទោស ១, ដាច់មានទោសដូចសេចក្តីខាង លើនេះ, ដាច់ឥតទោសដូចយ៉ាងបុគ្គលដែលបានប្តេជ្ញាខ្លួនថាយកព្រះរត្ន-ត្រ័យ ជាសរណគមន៍ហើយ លុះទម្លាយសង្ខារចាកលោកនេះទៅនឹងទាញ យកសរណគមន៍ក្នុងជាតិនេះទៅជាតិខាងមុខទៀតពុំបាន កើតឡើងត្រូវ សូមសរណគមន៍ជាថ្មីទៀត, ដាច់យ៉ាងនេះឈ្មោះថាដាច់ឥតទោស ។ ដាច់ ដោយហេតុផ្សេងៗ មានចូលកាន់សាសនាគ្រូដទៃជាដើម បើប្រាថ្នាចង់

ត្រឡប់មកកាន់ព្រះពុទ្ធសាសនាវិញនោះ    លុះត្រាតែសូមសរណគមន៍ជាថ្មីទៀត  ទើបឈ្មោះថាមានសរណគមន៍ពេញលេញឡើងវិញ ។

## វិនិច្ឆ័យបទ "ខមាទោស"

**ឧត្តមង្គេន វន្ទេហំ ចាទបំសុំ វរុត្តមំ**

**ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ**

*ប្រែថា ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទ នៃព្រះសម្មា-សម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តមគឺត្បូង, ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់, សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។*

### សេចក្តីសួរដែលគួរបាំ

១- *ភ្លាំងភ្លាត់បែបណា ទើបរួចរដោះទៅបានដោយវិធីសូមខមា-ទោស?*

២- *មនុស្សពាលមិនស្គាល់បុណ្យបាប ធ្វើពានពារទៅលើទោសធ្ងន់មានលោហិតុប្បាទកម្មជាដើម តើសូមខមាទោសរួចឬទេ?*

៣- *ព្រះពុទ្ធបរិនិព្វានហួសទៅហើយ បើយើងប្រព្រឹត្តល្មើសលើព្រះអង្គ តើត្រូវខមាទោសនឹងអ្នកណា?*

### សេចក្តីឆ្លើយ

១- *ទោសស្រាលៗ ដែលកើតអំពីការល្មើសមិនគោរព ដូចយ៉ាងពាក់មួក, ពាក់ស្បែកជើង, ទទូរក្បាល, ផ្លូតទឹក, លាងជើង, ស្តោះទឹកមាត់, បន្ទោរបង់ឧច្ចារៈបស្សាវៈជាដើមចំពោះព្រះភក្ត្រព្រះពុទ្ធរូបលើ*

វិហារ ឬលើទីលានចេតិយ, បែបនេះទើបរួចរដោះទៅបានដោយវិធីខមាទោស ។

២- ទោសដទៃក្រៅអំពីទោសល្មើសចំពោះព្រះពុទ្ធទៅក្តីឬទោសឯ-ទៀតមានសម្លាប់សត្វជាដើមក្តីមិនរួចទៅបានដោយវិធីខមាទោសឡើយ ។

៣- ព្រះពុទ្ធបរិនិព្វានទៅក៏ពិតមែន តែទ្រង់អនុញ្ញាតឲ្យសត្វដែលប្រព្រឹត្តល្មើសសូមខមាទោសនឹងព្រះពុទ្ធរូប, ព្រះចេតិយដែលតម្កល់ព្រះ-សារីរិកធាតុឬចំពោះព្រះភិក្ខុសង្ឃក៏គង់រួចទោសបាន ដូចកាលព្រះអង្គទ្រង់ធរមាននៅដែរ ។

## សេចក្តីអធិប្បាយ

ពាក្យថា "សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទដោយអវយវៈដ៏ឧត្តមគឺត្បូង (ក្បាល)" នេះឯង ជាពាក្យប្រកាសនូវសេចក្តីគោរពដ៏ឧត្តមបំផុតរបស់ពុទ្ធសាសនិកជន, ពាក្យនេះបានសេចក្តីថា ដែលខ្ញុំព្រះអង្គគោរពនោះ កុំថាតែអវយវៈដ៏សេសមានព្រះហស្ត ឬព្រះបាទជាដើមនោះទេ ត្រឹមតែធូលីដែលជាប់នៅព្រះបាទរបស់ព្រះអង្គ ក៏គួរជាទីគោរពរបស់ខ្ញុំព្រះអង្គណាស់ទៅហើយ, ពាក្យនេះលោកពោលទុកដើម្បីប្រកាសសរណគមន៍ឲ្យឃើញជាក់លាក់ថាខ្ជាប់ខ្ជួនប្រាកដមែន ។

ពាក្យខាងក្រោមជាពាក្យប្រកាសសូមទោស ក្រែងជួនជាខ្ញុំបានធ្វើជ្រលួសភ្លាំងភ្លាត់ខុសដោយអាការមិនសមគួរត្រង់កន្លែងណាមួយ

ចំពោះព្រះពុទ្ធដោយសេចក្ដីមិនដឹង ហើយសូមឲ្យព្រះពុទ្ធអត់ទោសប្រោសប្រាណដល់ខ្លួន ។ ក៏ការដែលល្មើសដោយបទណានីមួយនោះលុះត្រាតែអាស្រ័យចេតនាក្លែងព្រោះខឹងជ្រុលទប់មិនទាន់ជាដើម, បើប្រសិនជាមិនមានចេតនាក្លែង ឥតមានសេចក្ដីប្រមាថ ក៏មិនរាប់បញ្ចូលទៅក្នុងការមិនគោរពឡើយ ។

## អានិសង្សនៃការបម្រើនពុទ្ធានុស្សតិ

កាលបើព្រះយោគីបុគ្គលរំពឹងនឹកដល់ព្រះពុទ្ធគុណណាមួយ ដោយបានធ្វើទុកក្នុងចិត្តថា ព្រះអង្គទ្រង់ព្រះនាមយ៉ាងនេះៗ ព្រោះហេតុដូច្នេះផងៗ នឹងអាចធ្វើចិត្តឲ្យស្ងប់រម្ងាប់ចាក រាគៈ ទោសៈ មោហៈបានក្នុងសម័យនោះៗ ត្រឡប់ជាចិត្តប្រកបដោយបីតិ អាចឲ្យបានសម្រេចតែត្រឹមឧបចារជ្ឈានប៉ុណ្ណោះ មិនអាចឲ្យសម្រេចអប្បនាឈានបានឡើយព្រោះថាគុណរបស់ព្រះពុទ្ធ ជាគុណគម្ភីរភាពជ្រាលជ្រៅ មានប្រការផ្សេងៗ ជាអនេកមិនអាចនឹងតម្កល់ចិត្តឲ្យនឹងនៅតែក្នុងគុណមួយៗបាន។

ព្រះយោគីអ្នកប្រកបរឿយៗ ក្នុងពុទ្ធានុស្សតិនឹងបានជាអ្នកមានសេចក្ដីកោតក្រែងចំពោះព្រះសាស្ដា នឹងជាអ្នកមានសទ្ធាស៊ប់, មានសតិមាំមួន, មានបញ្ញាច្រើន, មានបុណ្យច្រើន, មានបីតិនិងប្រាមោជ្យច្រើន អាចអត់ធន់នូវសេចក្ដីខ្លាចនិងភ័យបាន, អត់ទ្រាំនូវសេចក្ដីទុក្ខលំបាកគ្រប់យ៉ាងក៏បាន, រមែងបាននូវសំវាសសញ្ញា គឺសេចក្ដីសម្គាល់ថាបាននៅរួមជាមួយ

នឹងព្រះសាស្តា សូម្បីរាងកាយរបស់លោកដែលជាទីអប់រំនៃពុទ្ធានុស្សតិ ក៏ជាវត្ថុគួរបូជាបីដូចជាចេតិយ, ចិត្តរបស់លោករមែងបង្អោនទន់ទៅរកពុទ្ធភូមិ ។ កាលណា បើជួបប្រទះនឹងវត្ថុគួរប្រព្រឹត្តកន្លងនឹងត្រឡប់ជាមានហិរិឱត្តប្បៈកើតឡើងប្រាកដ ហាក់ដូចជាបានឃើញព្រះពុទ្ធប្រថាប់នៅក្នុងទីចំពោះមុខ មិនអាចនឹងហ៊ានប្រព្រឹត្តកន្លងបាន, បើព្រះយោគីមិនទាន់បានលុះនូវផលខ្ពង់ខ្ពស់ទេ ក៏គង់មានសុគតិប្រព្រឹត្តទៅខាងមុខពុំខានឡើយ ។

ព្រោះហេតុនោះឯង បុគ្គលអ្នកមានប្រាជ្ញាល្អ
គួរធ្វើនូវសេចក្តីមិនធ្វេសប្រហែសក្នុងការ
រឭកនូវពុទ្ធគុណដែលមានមហានុភាព
យ៉ាងនេះ សព្វៗ កាលទៅហោង ។

ពុទ្ធរតនវិនិច្ឆ័យ ចប់

# ធម្មរតនវិនិច្ឆ័យ

## ពាក្យថា "ធម៌"

ព្រះធម៌ជាភាគមួយនៃរតនវត្ថុ ហើយជាវត្ថុប្រសើរជាងរតនវត្ថុដទៃនានាក្នុងលោក ដូចពណ៌នាសេចក្ដីតទៅនេះ៖

ពុទ្ធសាសនា ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធទាំងអស់រួមមកហៅថាធម៌, មាន ៣ យ៉ាងគឺ បរិយត្តិធម៌ ១, បដិបត្តិធម៌ ១, បដិវេធធម៌ ១ ។

## បរិយត្តិធម៌

ព្រះត្រៃបិដកទាំងមូល ដែលប្រកាសពន្យល់សេចក្ដីនៃបដិបត្តិធម៌ និងបដិវេធធម៌ សម្រាប់រៀនសូត្រស្វាធ្យាយ ដើម្បីឲ្យដឹងថាត្រូវប្រដិបត្តិយ៉ាងនេះ ទើបនឹងបានសម្រេចផលដូច្នេះ ឬក៏ការដែលបានលុះគុណវិសេសយ៉ាងនេះៗ ព្រោះប្រតិបត្តិដូច្នេះៗ ហៅថាបរិយត្តិធម៌, ព្រះបរិយត្តិធម៌នេះចែកដោយសង្ខេបមាន ៣ យ៉ាងគឺ ព្រះវិន័យ ១, ព្រះសូត្រ ១, ព្រះអភិធម្ម១, បើចែកចេញដោយពិស្ដារមាន ៨ ហ្មឺន ៤ ពាន់ព្រះធម្មក្ខន្ធគឺ ព្រះវិន័យមាន ២ ហ្មឺន ១ ពាន់, ព្រះសូត្រមាន ២ ហ្មឺន ១ ពាន់, ព្រះអភិធម្មមាន ៤ ហ្មឺន ២ ពាន់ ។

បរិយត្តិធម៌នេះ មានអវយវៈ ៩ គឺ សុត្តៈ ១, គេយ្យៈ ១, វេយ្យាករណៈ ១, គាថា ១, ឧទានៈ ១, ឥតិវុត្តកៈ ១, ជាតកៈ ១, អព្ភូតធម្មៈ ១, វេទល្លៈ ១ ។

ភាសិតដែលសម្ដែង បានសេចក្ដីជារឿងមួយៗ ឲ្យឃើញជាសេចក្ដីល្មមស្ដាប់បាន ហៅថា សុត្តៈ (ព្រះសូត្រ) ។ ភាសិតជាចុណ្ណិយបទគឺជាបាឡីរាយមិនចងជាគាថាខ្លះ គាថាខ្លះលាយគ្នាទាំង ២ យ៉ាង ហៅថា

គេយ្យៈ (របៀបពាក្យដូចចម្រៀង)។ ភាសិតដែលជាចុណ្ណិយបទសុទ្ធ ឥត លាយច្រឡំដោយគាថា ហៅថា វេយ្យាករណៈ ។ ភាសិតដែលជាគាថា សុទ្ធ ឥតមានពាក្យរាយ ហៅថា គាថា ។ ភាសិតដែលព្រះមានជោគ ទ្រង់អាស្រ័យសោមនស្សញ្ញាណ ហើយទ្រង់បន្លឺឡើងដោយព្រះអង្គឯង ឥតបាច់មានគេអារាធនា ហៅថា ឧទានៈ ។ ភាសិតដែលទ្រង់សម្តែង ជាឧទ្ទេសវារៈតាមទំនងហូរហែ លុះចប់សេចក្តីហើយទ្រង់ត្រាស់សម្តែងជា និគមវចនៈ បញ្ជាក់សេចក្តីថែមទៀត ហៅថា ឥតិវុត្តកៈ ។ ភាសិតដែល ទ្រង់សម្តែងរំលើកយកបុព្វចរិត សេចក្តីប្រព្រឹត្តក្នុងជាតិមុនៗ មក បង្ហាញជាឧទាហរណ៍ ដើម្បីបានជាតឹកតាង ហៅថា ជាតកៈ ។ ភាសិត ដែលទ្រង់សម្តែងដោយសេចក្តីស្ងើចសរសើរថា អស្ចារ្យ មិនដែលកើត មាន ហៅថា អព្ភូតធម្មៈ ។ ភាសិតដែលសាកច្ឆាសាកសួរសេចក្តីនារឿង នីមួយៗ ដរាបដល់បានសេចក្តីច្បាស់ កើតប្រាជ្ញា ចេះតែសួរដេញឡើងៗ តៗទៅទៀត ដូចសក្កបញ្ហាសូត្រជាដើម ហៅថា វេទល្លៈ ។

បរិយត្តិធម៌នេះ បើចែកតាមប្រភេទនៃភាសិតរបស់បុគ្គលអ្នកសម្តែង តែងតាំងទុកមកមាន ៤ គឺ ពុទ្ធភាសិត ១, សាវកភាសិត ១, ឥសីភា-សិត ១, ទេវតាភាសិត ១ ។ ពុទ្ធភាសិតបានដល់ភាសិតដែលព្រះពុទ្ធ ទ្រង់ត្រាស់សម្តែងដោយព្រះអង្គឯង, សាវកភាសិត បានដល់សុភាសិត ដែលពុទ្ធសាវកអ្នកយល់ជាក់នូវភូមិធម៌សម្តែងទុក, ឥសីភាសិត បានដល់

សុភាសិតដែលឫសីតាបសអ្នកយល់ច្បាស់នូវភូមិនៃធម៌សម្ដែងទុក, ទេវតាភាសិតបានដល់សុភាសិតដែលទេព្ដាអ្នកយល់ន័យរបស់ធម៌សម្ដែងទុក ។

បើចែកដោយសេចក្ដីប្រារព្ធមាន ២ យ៉ាងគឺ ជាធម្មាធិដ្ឋាន ១, បុគ្គលាធិដ្ឋាន ១ ។

ពុទ្ធដីកាដែលទ្រង់សម្ដែងឡើងលើកធម៌ជាប្រធាន មិនទាក់ទង ដោយរូបបុគ្គលដូចពុទ្ធភាសិតថា **អប្បមាទោ អមតំ បទំ** "សេចក្ដីមិនប្រមាទជាផ្លូវនៃព្រះនិព្វាន" ដូច្នេះជាដើម ហៅថាធម្មាធិដ្ឋាន ។ ពុទ្ធដីកាដែលសម្ដែងឡើងប្រារព្ធបុគ្គលជាប្រធានដូចពុទ្ធភាសិតថា **យេ បមត្តា យថាមតា** "បុគ្គលដែលប្រមាទទុកដូចមនុស្សស្លាប់" ដូច្នេះជាដើម ហៅថា បុគ្គលាធិដ្ឋាន ។ បរិយត្តិធម៌ដែលនឹងបរិបូណ៌បាន ព្រោះអាស្រ័យហេតុខាងក្នុង ២ យ៉ាងគឺបញ្ញានិងវីរិយៈ[១] ហេតុខាងក្រៅគឺកាលសម្បត្តិ បើមានហេតុខាងក្នុងបរិបូណ៌ហើយ តែបើហេតុខាងក្រៅជាកាលវិបត្តិក៏ពុំអាចស្ថិតនៅបាន ។

បរិយត្តិធម៌នេះ មានអានិសង្សក្នុងអវសានជាតិ អាចហុចផលឲ្យបានសម្រេចអរហត្តបដិសម្ភិទា ។

---

១ ការរៀនបរិយត្តិធម៌ ត្រូវអាស្រ័យបញ្ញាជាគ្រឿងពិចារណាឲ្យយល់ជាក់និងវីរិយៈ សេចក្ដីព្យាយាមរៀន ដរាបដល់បានចេះចាំពិតជាពហុស្សូត ទើបអាចញុំាងបរិយត្តិធម៌ឲ្យបរិសុទ្ធបរិបូណ៌បាន ។

# បដិបត្តិធម៌

ត្រៃសិក្ខា គឺគុណជាតិដែលកុលបុត្រគប្បីសិក្សា, គប្បីប្រតិបត្តិតាម, គប្បីប្រព្រឹត្តតាម ហៅថា បដិបត្តិធម៌, មាន ៣ យ៉ាងគឺ សីល ១, សមាធិ ១, បញ្ញា ១ ។

សីល បានដល់ចេតនាដែលជាហេតុវៀរចាកអកុសលកម្មមានបាណាតិបាតជាដើម ឬក៏ ចេតនាជាហេតុបំពេញនូវវត្តប្រតិបត្តិ មានធុតង្គវត្តជាដើម ។

សីល មានអត្ថ ២ យ៉ាងគឺ **សមាធានំ** កិរិយាតម្កល់ទុកនូវកាយកម្ម វចីកម្ម មនោកម្ម មិនឲ្យរាយរាយទៅបានដោយភាពទ្រុស្តសីល ១, **ឧបធារណំ** កិរិយាទ្រទ្រង់ទុក, តម្កល់ទុកនូវកុសលធម៌ ១ ។ ន័យមួយទៀតថា មានអត្ថ ៤ យ៉ាងគឺ **សិរដ្ឋោ** មានអត្ថថាឧត្តម ១, **សីសដ្ឋោ** មានអត្ថថាជាប្រធាន ១, **សីតលដ្ឋោ** មានអត្ថថាត្រជាក់ (ព្រោះរម្ងាប់បង់នូវសេចក្តីក្រវល់ក្រវាយ) ១, **សិវដ្ឋោ** មានអត្ថថាបណ្ឌិតគប្បីសេព ១ ។

សីល មានកិរិយាតម្កល់ទុកនូវកាយកម្មជាដើម និងទ្រទ្រង់ទុកនូវកុសលធម៌ជាលក្ខណៈ (គ្រឿងចំណាំ), មានកិរិយាកម្ចាត់បង់នូវភាពទ្រុស្តសីលជាកិច្ច, មានគុណដែលមិនមានទោស គួរអ្នកប្រាជ្ញតិះដៀលបានជាសម្បត្តិ, មានសេចក្តីស្អាតកាយ, វាចា, ចិត្ត ជាគ្រឿងប្រាកដ ឬថាជា

ផល (ភស្តុតាង), មានហិរិនិងឱត្តប្បៈ ជាហេតុ ព្រោះថា សីលដែលនឹងកើតឡើងហើយតាំងនៅខ្ជាប់ខ្ជួនបាន មិនដាច់ធ្លុះធ្លាយទៅវិញព្រោះអាស្រ័យ ហិរិ និង ឱត្តប្បៈ, ហេតុនោះទើប ហិរិ និង ឱត្តប្បៈនេះជាហេតុនៃសីល ។ សីលដែលបម្រុងនឹងកើត ហើយកើតឡើងមិនរួច, ដែលកើតឡើងហើយ ប្រែជាដាច់ធ្លុះធ្លាយទៅវិញ មិនតាំងនៅខ្ជាប់ខ្ជួន ព្រោះអាស្រ័យអហិរិកៈ សេចក្តីមិនខ្មាសបាប និងអនោត្តប្បៈ សេចក្តីមិនខ្លាចបាបជាហេតុ ។

សីល ពោលដោយសង្ខេបមាន ២ យ៉ាងគឺ លោកិយសីល ១, លោកុត្តរសីល ១ ។ លោកិយសីល បានដល់សីលនៃបុថុជ្ជនដែលនៅមានអាសវៈ, លោកុត្តរសីល បានដល់សីលនៃព្រះអរិយៈដែលឥតមានអាសវៈ ។ ក៏បណ្តាសីលទាំង ២ យ៉ាងនេះ លោកិយសីល អាចឲ្យបាននូវសេចក្តីវិសេសក្នុងភព និងគ្រឿងសម្ភារៈជួយឧបត្ថម្ភជ្រោមជ្រែងឲ្យលោះខ្លួនចេញចាកភពបាន, ឯលោកុត្តរសីល អាចឲ្យលោះខ្លួនចេញចាកភពបាន និងជាភូមិនៃបច្ចវេក្ខណញ្ញាណ ។

សីល មានអានិសង្សអាចឲ្យបាននូវគុណជាអនេក មានសេចក្តីមិនស្តាយក្រោយជាដើម ។ ន័យមួយទៀតថា បុគ្គលមានសីល មានអានិសង្ស ៥ យ៉ាងគឺ មានភោគច្រើន១, មានកេរ្តិ៍ឈ្មោះល្អ ១, មានសេចក្តី

ក្មៀវក្លាអង់អាចកណ្ដាលប្រជុំបរិស័ទ ១, មិនមានសេចក្ដីវង្វេងក្នុងពេលទៀបស្លាប់ ១, លុះស្លាប់ហើយនឹងបានទៅកើតក្នុងសុគតិភព ១ ។

សមាធិ បានដល់ភាពនៃចិត្តដែលនឹងនៅក្នុងកុសលធម៌, មានកិរិយាតម្កល់ទុកដោយប្រពៃ នូវចិត្តនិងចេតសិកក្នុងអារម្មណ៍តែមួយជាអត្ថ, មានសេចក្ដីមិនរាយមាយជាលក្ខណៈ, មានកិរិយាកម្ចាត់បង់នូវសេចក្ដីរាយមាយជាកិច្ច, មានសេចក្ដីមិនរំភើបញ្ញាប់ញ័រចិត្តជាគ្រឿងប្រាកដ (ផល), មានសេចក្ដីសុខជាហេតុ ។

សមាធិ ពោលដោយសង្ខេបមាន ២ យ៉ាងគឺ ឧបចារសមាធិ ១, អប្បនាសមាធិ ១ ។ ឧបចារសមាធិ បានដល់ភាពនៃកុសលចិត្តតាំងនៅក្នុងឧបចារភូមិ គឺថ្នាក់ចិត្តដែលទៀបនឹងបានអប្បនាសមាធិ ។ អប្បនាសមាធិ បានដល់ភាពនៃចិត្តដែលតាំងនៅក្នុងបដិលាភភូមិ ដោយលះបាននូវនីវរណធម៌ទាំង ៥, ចិត្តដែលតាំងនៅក្នុងបដិលាភភូមិនេះ ទើបកើតអង្គឈានប្រាកដ ។ ឧបចារសមាធិ ទុកណាជាមានអង្គកើតឡើង ក៏មិនសូវកម្លាំង ព្រោះតាំងនៅមិនបានយូរ, ឯអប្បនាសមាធិ ទើបមានកម្លាំងក្លា ព្រោះថាកាលបើកើតឡើងហើយ ចិត្តកាត់ផ្ដាច់នូវលំដាប់នៃភវង្គតែម្ដង តាំងនៅអស់កាលទាំងយប់ទាំងថ្ងៃបាន, ប្រព្រឹត្តទៅដោយអំណាចនៃជំណាកុសលជវន ។

សមាធិនេះឯង សម្រាប់ប្រាបប្រាមកិលេសយ៉ាងកណ្ដាលដែលកើត

ឡើងតាមផ្លូវចិត្ត បានដល់បច្ចនីកធម៌ទាំង ៥ គឺ កាមច្ឆន្ទៈ សេចក្ដីប្រាថ្នាក្នុងកាម ១, ព្យាបាទៈ សេចក្ដីគុំកួន ១, ថីនមិទ្ធៈ សេចក្ដីងងុយងោកងក់ ១, ឧទ្ធច្ចកុក្កុច្ចៈ សេចក្ដីរវើរវាយរាយមាយចិត្ត ១, វិចិកិច្ឆា សេចក្ដីសង្ស័យ ១ ។ ធម៌ទាំងនេះឯង ជាសភាពផ្ទុយគ្នានឹងសមាធិ, កាលសមាធិកើតឡើង បច្ចនីកធម៌ទាំងនេះរលត់ទៅ ហេតុនោះ បើបច្ចនីកធម៌ទាំងនេះកើតឡើង ហើយត្រូវយកសមាធិទៅបង្រ្កាបទើបស្ងប់រម្ងាប់ទៅបាន ។

សមាធិនេះ កាលបើព្រះយោគីបានចម្រើនស្ទាត់ជំនាញហើយអាចឲ្យបានសម្រេចនូវលោកិយអភិញ្ញា ៦[១] ជាអានិសង្ស ។

បញ្ញាបានដល់គុណជាតិដែលដឹងច្បាស់នូវសភាវធម៌ដែលពិត, មានសេចក្ដីដឹងច្បាស់ជាអត្ថ, មានកិរិយាដឹងច្បាស់នូវសភាពនៃរូបធម៌នាមធម៌ជាលក្ខណៈ, មានកិរិយាកម្ចាត់បង់នូវងងឹតគឺមោហៈដែលបិទបាំងនូវរូប-ធម៌នាមធម៌ជាកិច្ច, មានសេចក្ដីមិនវង្វេងជាគ្រឿងប្រាកដ(ផល), មានសមាធិជាហេតុ ។

បញ្ញានេះ បើចែកតាមប្រភេទយ៉ាងសង្ខេបមាន ២ យ៉ាងគឺ លោកិយ-បញ្ញា ១, លោកុត្តរបញ្ញា ១ ។ លោកិយបញ្ញា បានដល់បញ្ញាដែលសម្បយុត្តដោយលោកិយមគ្គគឺបញ្ញាដែលប្រកបក្នុងវិសុទ្ធិ ៤ ប្រការ មានទិដ្ឋិវិសុទ្ធិជាដើម មានបដិបទាញាណទស្សនវិសុទ្ធិជាបរិយោសាន ។

---

១ អភិញ្ញា ៦ ចូរមើលត្រង់ បទវិជ្ជាចរណសម្បន្នោ ។

លោកុត្តរបញ្ញា បានដល់បញ្ញាដែលសម្បយុត្តដោយលោកុត្តរមគ្គទាំង ៤ មានសោតាបត្តិមគ្គជាដើម មានអរហត្តមគ្គជាបរិយោសាន ។

បញ្ញានេះឯង មានកិច្ចសម្រាប់ប្រាបប្រាមកិលេសយ៉ាងល្អិតបំផុតគឺទិដ្ឋិសេចក្ដីយល់ខុស និងអវិជ្ជា សេចក្ដីល្ងង់ ។

សេចក្ដីថា សត្វបុថុជ្ជន ដែលយល់ឃើញខុសថាសត្វទៀង, លោកទៀង, យល់ឃើញថាខ្លួនប្រាណមានខ្លឹមសារ ព្រោះអាស្រ័យអវិជ្ជាសេចក្ដីល្ងង់បិទបាំងបញ្ញា, កាលបើបញ្ញាកើតឡើងហើយ ទើបអាចទម្លុះទម្លាយកម្ចាត់បង់នូវអវិជ្ជាបាន ត្រឡប់ជាយល់ឃើញត្រូវតាមសភាពពិតមែនថា "សត្វមិនទៀង, លោកមិនទៀង, ខ្លួនប្រាណឥតមានខ្លឹមសារ" ជាដើម ។

## វិធីបម្រើនវិបស្សនាបញ្ញា

ព្រះយោគីដែលប្រាថ្នានឹងចម្រើនបញ្ញានោះ ត្រាតែបានតាំងនៅក្នុងសីល និងសមាធិដ៏ហ្មត់ចត់ដែលលោកចាត់ថាជាសីលវិសុទ្ធិ, ចិត្តវិសុទ្ធិជាមុន ទើបគួរចម្រើនបញ្ញាតទៅទៀតបាន ។

ក៏ការដែលចម្រើនបញ្ញានោះគប្បីចម្រើនទៅតាមលំដាប់នៃវិសុទ្ធិទាំង ៥ ខាងចុង គឺ ទិដ្ឋិវិសុទ្ធិ ១, កង្ខាវិតរណវិសុទ្ធិ ១, មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ១, បដិបទាញាណទស្សនវិសុទ្ធិ ១, ញាណទស្សនវិសុទ្ធិ ១។

មុនដំបូងព្រះយោគីគប្បីរំពឹងល្បងរកនូវលក្ខណៈ, កិច្ច, ផល, ហេតុ នៃនាមធម៌រូបធម៌នីមួយៗ តាមទំនងពិតមែន ដោយន័យសង្ខេបឬពិស្ដារ ។

ន័យសង្ខេបនោះ គប្បីរំពឹងរកលក្ខណៈចំពោះពាក្យថា "នាម-រូប" ដើម្បីឲ្យដឹងថា "នមនលក្ខណំ នាមំ" ដែលហៅថា "នាមៗ" ព្រោះមានកិរិយាបង្អោនទៅកាន់អារម្មណ៍ជាលក្ខណៈ, "រុប្បនលក្ខណំ រូបំ" ហៅថា "រូបៗ" ព្រោះមានសេចក្ដីវិនាសជាលក្ខណៈ ។

ន័យពិស្ដារ គប្បីរំពឹងរកអាការមានលក្ខណៈ ជាដើមនៃធម៌នីមួយៗ ដែលបំបែកចេញទៅអំពីពាក្យថា "នាម-រូប", តួយ៉ាងដូចពាក្យមានដើមថាផស្សៈនិងបឋវី ដែលហៅថា "ផស្សៈៗ" ព្រោះមានកិរិយាប៉ះពាល់ជាលក្ខណៈ, ដែលហៅថា "បឋវីៗ" ព្រោះមានធាតុរឹងជាលក្ខណៈជាដើម ។

លុះបានរំពឹងយល់ជាក់ទាំងលក្ខណៈ, កិច្ច, ផល, ហេតុនៃនាមធម៌, រូបធម៌នីមួយៗ សព្វគ្រប់ហើយឈ្មោះថាបានរកឃើញនូវតួនាម-ធម៌ រូបធម៌ហើយអាចរំលាយបង់បាននូវមន្ទិលដែលយល់ថា "នាម-រូបជាខ្លួន" ព្រោះបានយល់ជាក់ថា ដែលហៅថា "ខ្លួនៗ" ឥតមានអ្វីដទៃក្រៅចាកនាមធម៌, រូបធម៌នេះ គឺប្រជុំរូបធម៌ នាមធម៌ហ្នឹងឯងហើយដែលលោកសន្មតហៅថាខ្លួន ។

ប្រាជ្ញាដែលយល់យ៉ាងនេះឯង ឈ្មោះថាទិដ្ឋិវិសុទ្ធិ សេចក្ដីយល់ឃើញបរិសុទ្ធិ ។

*លុះព្រះយោគីបានរកឃើញនូវតួនាមធម៌[១]រូបធម៌ យ៉ាងនេះរួចហើយ គប្បីរំពឹងរកគ្រឿងផ្សំ ឬដើមកំណើតរបស់នាមនិងរូប (ហេតុបច្ច័យ) តទៅទៀត ។*

*ឯនាមនិងរូបនេះ ក្នុងបដិសន្ធិកាល[២] មានកំណើតជាមួយគ្នា គឺកើតឡើងដោយអំណាចនៃហេតុគឺអវិជ្ជាសេចក្ដីល្ងង់, តណ្ហា សេចក្ដីប្រាថ្នា, ឧបាទាន សេចក្ដីប្រកាន់, កម្មអំពើសាងទុក ។ ក្នុងបវត្តិកាល[៣] មានកំណើតផ្សេងគ្នា គឺរូបកើតឡើងដោយបច្ច័យគឺ កម្ម, ចិត្ត, រដូវ, អាហារ, ឯនាមកើតឡើងដោយអំណាចបច្ច័យ មានអារម្មណ៍ដែលប៉ះពាល់អាស្រ័យគ្នាយ៉ាងភ្នែកអាស្រ័យរូបជាដើម ។ លុះរំពឹងដូច្នេះទៅ ព្រះយោគីនឹងបានយល់ជាក់ថា នាមនិងរូបជាបច្ចុប្បន្ន កើតឡើង ដោយអំណាចហេតុ-បច្ច័យយ៉ាងណា, នាមនិងរូប ជាអតីត អនាគត ក៏ដូច្នោះដែរ ។*

*កាលបើព្រះយោគីបានរកឃើញគ្រឿងផ្សំ ឬដើមកំណើត (ហេតុបច្ច័យ) របស់នាមនិងរូបហើយ អាចនឹងទម្លាយបង់បាននូវសេចក្ដីងឿងឆ្ងល់អំពីនាមនិងរូបជាអតីត បច្ចុប្បន្ន អនាគត ១៦ យ៉ាង និងសង្ស័យ ៨ យ៉ាងបាន ព្រោះបានកម្ចាត់បង់នូវមន្ទិលដែលយល់ថា នាមរូប ដែលកើតឡើង គឺកើតមានឯងៗ មិនបាច់មានហេតុបច្ច័យទេ ។*

---

១ នាមធម៌ រូបធម៌ ជួនកាលលោកហៅថា រូបធម៌ អរូបធម៌ ប្រែថា ធម៌មានរូប ធម៌ឥតរូប, ធម៌មានរូប បានដល់រូបក្ខន្ធ, ធម៌ឥតរូប បានដល់ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ។ ២ បដិសន្ធិកាល សំដៅយកកាលដែលសត្វមកចាប់បដិសន្ធិក្នុងរវាង ៣៥ ថ្ងៃ ។ ៣ បវត្តិកាល សំដៅយកកាលតាំងពី ថ្ងៃទី ៣៦ ឡើងមកជាលំដាប់ដរាបដល់មរណៈ ។

ប្រាជ្ញាដែលយល់ជាក់នូវគ្រឿងផ្សំ ឬដើមកំណើតនៃនាមធម៌រូបធម៌ នេះឯងឈ្មោះថា កង្ខាវិតរណវិសុទ្ធិ "ការឆ្លងផុតនូវសេចក្តីសង្ស័យ បរិសុទ្ធិ" ។

តអំពីនេះទៅ ព្រះយោគីគប្បីប្រារព្ធយកនូវទេសនាន័យ មានខន្ធជាដើម រួបរួមចូលគ្នាជាពួកជាក្រុម ហើយផ្គងឡើងកាន់ព្រះត្រៃលក្ខណ៍ ពិចារណាដោយសម្មសនញ្ញាណ ជាអទ្ធានៈ, សន្តតិ, ខណៈដើម្បីឲ្យដឹងថា សង្ខារទាំងអស់ សុទ្ធតែរំលងព្រះត្រៃលក្ខណ៍មិនរួច ជាសភាពលង់នៅក្នុងអំណាចសាមញ្ញលក្ខណៈ គ្មានសល់ ។

រួចហើយពិចារណាអំពីការកើត(ឧទយៈ) ការរលត់(វយៈ) នៃនាមនិងរូបដោយឧទយព្វយញ្ញាណ ដោយអំណាចបច្ច័យនិងខណចិត្ត ដើម្បីឲ្យឃើញថា សង្ខារដែលកើតរលត់ញឹកញាប់យ៉ាងនេះ ព្រោះតែបច្ច័យគឺ អវិជ្ជា, តណ្ហា, កម្ម, អាហារ, បើបច្ច័យនេះនៅមានដរាបណាសង្ខារក៏នៅមានកើតស្លាប់ដរាបនោះ, បើបច្ច័យទាំងនេះរលត់ហើយ សង្ខារក៏រលត់ទៅដែរ (លែងមានកើតស្លាប់ទៀត) ។

កាលបើឧទយព្វយញ្ញាណ កំពុងកកើតឡើងក្លៀវក្លា ប្រាកដជាក់ស្តែងយ៉ាងនេះ ទទួលមានគ្រឿងសៅហ្មងទាំង ១០ យ៉ាងណាមួយ ជ្រែកចូលមកបំភ័ន្តប្រាជ្ញាព្រះយោគី ដើម្បីស្ទាក់ដំណើរនៃការត្រាស់ដឹង ប្រសិនបើព្រះយោគីភ័ន្តច្រឡំយល់ឃើញថាខ្លួនបានត្រាស់ដឹងហើយ បាន

ដល់នូវថ្នាក់ជាព្រះអរហន្តហើយ ៗ លះបង់សេចក្ដីព្យាយាមត្រឹមនោះទៅ នឹងខានត្រាស់ដឹងមគ្គផលពុំខាន, បើមិនអើពើដោយគ្រឿងបំភ័ន្តដូច្នោះទេ ខំប្រារព្ធសេចក្ដីព្យាយាម ចំណាំទុកនូវផ្លូវត្រូវនិងផ្លូវខុសតទៅទៀត មុខជានឹងបានត្រាស់ដឹងពុំខាន ។

ប្រាជ្ញាដែលកើតឡើងថ្មីចំណាំបាននូវផ្លូវត្រូវនិងផ្លូវខុសនេះឯង ឈ្មោះថាមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ "កិរិយាយល់ឃើញដោយញាណថាមគ្គនិងមិនមែនមគ្គបរិសុទ្ធ" ។

កាលព្រះយោគីរួចរបូតចាកគ្រឿងអន្តរាយទាំង ១០ យ៉ាងស្រេចហើយគប្បីតាំងសមាធិសាជាថ្មីម្ដងទៀត ផ្គងឡើងនូវព្រះត្រៃលក្ខណ៍ពិចារណាទៅតាមលំដាប់នៃវិបស្សនាញាណទាំង ៩ តាំងអំពីឧទយព្វយញ្ញាណដរាបដល់អនុលោមញ្ញាណតទៅទៀត, បានជាលោកឲ្យសាពិចារណាពីឧទយព្វយញ្ញាណទៅទៀត ព្រោះថាឧទយព្វយញ្ញាណមុននោះឧបកិលេសទាំង ១០ យ៉ាងចូលទៅលុកលុយរឹកររអស់ទៅហើយ ឧទយព្វយញ្ញាណដែលឧបកិលេសលុកលុយយ៉ាងនេះ មិនអាចនឹងកំណត់នូវព្រះត្រៃលក្ខណ៍បានឡើយ ។

ហេតុនោះ ព្រះយោគីគប្បីរំពឹងជាថ្មីដូចតទៅនេះ៖ មុនដំបូង គប្បីរំពឹងរកនូវសេចក្ដីកើតរលត់នៃនាមធម៌រូបធម៌ (ឧទយព្វយញ្ញាណ) លំដាប់នោះនឹងកើតសេចក្ដីយល់យ៉ាងនេះថា ការដែលកើតហើយរលត់ៗ ហើយកើត

យ៉ាងនេះឈ្មោះថា មិនទៀង (អនិច្ចំ), កាលបើមិនទៀងហើយ រមែងបាននូវសេចក្ដីលំបាក (ទុក្ខំ), កាលបើលំបាកហើយឈ្មោះថា មិនមែនខ្លួន, មិនមែនរបស់ខ្លួន ព្រោះមិនស្ដាប់បង្គាប់ខ្លួន (អនត្តា) ។ លុះបានយល់ជាក់ដូច្នេះហើយ ដោយហេតុដែលការរលត់ប្រាកដជាង ក៏លះលែងពិចារណាអំពីការកើត (ឧទយៈ) បង្អោនចិត្តទៅរកសេចក្ដីរលត់នៃរូបធម៌នាមធម៌តែម្យ៉ាងទៅវិញ (ភង្គញ្ញាណ) ។ លំដាប់នោះនឹងអាចសន្និដ្ឋានបានថា សង្ខារទាំងអស់សុទ្ធតែត្រូវវិនាស ។ លុះបានយល់ជាក់អំពីការបែកធ្លាយដូច្នោះហើយ ក៏យល់ឃើញសង្ខារថាជាអាការគួរឲ្យខ្លាច (ភយញ្ញាណ) ព្រោះបានយល់ជាក់ថា សង្ខារដែលកើតឡើងងាយបែកធ្លាយទៅវិញដូចជាពពុះទឹកយ៉ាងនេះ មុខគួរឲ្យខ្លាចណាស់, លំដាប់នោះក៏ឃើញទោសក្នុងសង្ខារថា មិនមែនជាទីពឹងពួន ហាក់ដូចជាគេឃើញផ្ទះកំពុងភ្លើងឆេះ (អាទីនវញ្ញាណ) លុះបានយល់ជាក់ថា សង្ខារសុទ្ធតែជាទោសដូច្នោះ ក៏ចេះតែធុញទ្រាន់នឿយណាយខ្ពើមសង្ខារ (និព្វេទញ្ញាណ), លុះការធុញទ្រាន់មានកម្លាំងឡើង ក៏មានប្រាថ្នាចង់គេចចេញឲ្យផុតស្រឡះចាកធម៌ដែលនាំឲ្យកើតក្នុងត្រៃភព ដូចជាត្រីចង់រួចចាកសំណាញ់ (មុញ្ចិតុកាម្យតាញាណ), ម្ល៉ោះហើយក៏ប្រុងរកឧបាយដែលជាហេតុនាំឲ្យរួចចាកភពនោះ (បដិសង្ខាញាណ) ។ តពីនោះមកក៏ត្រឡប់ជាព្រងើយកន្តើយមិនស្រឡាញ់ មិនស្អប់សង្ខារ មានចិត្តស្មើទូទៅលើវត្ថុនានា ដូចជា

បុរសដែលមានចិត្តព្រងើយកន្តើយក្នុងកិរិយា ដែលលះលែងគ្នាស្រឡះហើយ (សង្ខារុបេក្ខាញាណ) ។ អាស្រ័យសង្ខារុបេក្ខាញាណមានកម្លាំងក្លៀវក្លា ល្មមសង្ឃឹមបានថា អប្បនាជាតួអរិយមគ្គទៀបកើតឡើងហើយខណៈនោះ មនោទ្វារាវជ្ជនចិត្តផ្តាច់ខ្សែភវង្គហើយកើតឡើង, លំដាប់នោះវិបស្សនាចិត្តជាតួអនុលោមញ្ញាណកើតរលត់ៗ ២ ខណៈ ឬ ៣ ខណៈ (តាមព្រះយោគីជាខិប្បាភិញ្ញា និងទន្ធាភិញ្ញា) មានឈ្មោះថាបរិកម្ម, ឧបចារ, អនុលោម ដើម្បីលះកិលេសគ្រោតគ្រាត, កណ្តាល និងល្អិតឲ្យដាច់ស្រឡះ ។

ញាណដែលលះកិលេសទាំង ៣ ខណៈនោះឯង រួមហៅថា អនុ-លោមញ្ញាណ ព្រោះអនុលោមតាម, យល់តាមនូវវិបស្សនាញាណទាំង ៨ ដែលបានចម្រើនរួចមកហើយ និងពោធិបក្ខិយធម៌ ៣៧ ដែលបម្រុងនឹងបានត្រាស់ដឹងខាងលើ ក្នុងខណៈនៃមគ្គតទៅខាងមុខទៀត ។

ការដែលរំពឹងទៅតាមលំដាប់នៃវិបស្សនាញាណទាំង ៩ យ៉ាងនេះឈ្មោះថាបដិបទាញាណទស្សនវិសុទ្ធិ, បន្ទាប់ខាងមុខអំពីអនុលោមញ្ញា-ណនោះទៅ មានញាណមួយកើតឡើងបន្ទាប់ខាងដើមនៃអរិយមគ្គ អង់-អាចក្លៀវក្លាស្រូបយកព្រះនិព្វានជាអារម្មណ៍បាន ផ្តាច់នូវគោត្របុថុជ្ជនស្ទុះឡើងទៅកាន់អរិយគោត្រ (ផុតកំណើតបុថុជ្ជន) ទើបអរិយមគ្គកើតឡើង កំណាត់បាននូវទុក្ខសច្ច លះផ្តាច់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់

នូវនិរោធសច្ច ធ្លាក់ប្រឡាយអប្បនាវិថីដោយការចម្រើនមគ្គសច្ច បន្ទាប់នេះ ផលចិត្តស្ទុះឡើង ២-៣ ខណៈហើយរលត់ទៅវិញ រួចហើយទើបធ្លាក់ចុះកាន់ភវង្គ ។

ប្រាជ្ញាដែលកើតឡើងក្នុងខណៈ នៃមគ្គជ្រាបជាក់លាក់នូវចតុរារិយ-សច្ចបានឈ្មោះថាញាណទស្សនវិសុទ្ធិ ។

## បដិវេធធម៌

ធម៌ដែលព្រះអរិយៈបានចាក់ធ្លុះ បានត្រាស់ដឹង ហៅថា បដិវេធធម៌ បានដល់លោកុត្តរធម៌ ៩ ប្រការ គឺ មគ្គ ៤, ផល ៤, និព្វាន ១ ។

## មគ្គ ៤

ធម៌ជាគន្លងឬជាផ្លូវនៃជនអ្នកទៅកាន់ព្រះនិព្វានហៅថា "មគ្គ" បានដល់ប្រាជ្ញាជាឧបាយសម្រាប់ផ្ដាច់បង់នូវសំយោជនកិលេស តាមថ្នាក់តាមជាន់នៃធម៌នោះៗ លោកចែកចេញជា ៤ យ៉ាង (តាមដំណើរនៃការលះកិលេស) គឺ សោតាបត្តិមគ្គ ១, សកទាគាមិមគ្គ ១, អនាគាមិមគ្គ ១, អរហត្តមគ្គ ១ ។

សោតាបត្តិមគ្គ ប្រែថា មគ្គនៃបុគ្គលអ្នកដល់នូវធម៌ជាប្រឡាយដំបូងនៃព្រះនិព្វាន, លះបានឱរម្ភាគិយសំយោជនកិលេស[១] ៣ យ៉ាង គឺ សក្កាយទិដ្ឋិ សេចក្ដីយល់ខុសអាស្រ័យខន្ធ ប្រកាន់ថាខ្លួនប្រាណមានខ្លឹមសារជាដើម ១, វិចិកិច្ឆា សេចក្ដីសង្ស័យក្នុងបដិបទាដំណើរប្រតិបត្តិរបស់ខ្លួនជាដើម ១, សីលព្វតបរាមាសៈ សេចក្ដីប្រកាន់នូវសីលនិងវត្តដែលខុស ១ ។

សកទាគាមិមគ្គ ប្រែថា មគ្គនៃបុគ្គលអ្នកមកកើតក្នុងមនុស្សលោកនេះ

---

១ សំយោជនកិលេសទាំង ៣ យ៉ាងនេះ នឹងមានសម្ដែងក្នុងសង្ខេបគន្ធវិនិច្ឆ័យដោយហ្មត់ចត់។

១ ជាតិទៀតដោយអំណាចបដិសន្ធិ, លះបានឱរម្ភាគិយសំយោជនកិលេស ៣ យ៉ាង ដូចសោតាបត្តិមគ្គដែរ ហើយអាចធ្វើឱរម្ភាគិយសំយោជនកិលេស ២ ទៀតគឺ កាមរាគៈ សេចក្តីត្រេកត្រអាលក្នុងកាម និងបដិឃៈ សេចក្តីថ្នាំងថ្នាក់អន់ចិត្ត ឲ្យខ្សោយកម្លាំងបានថែមទៀត ព្រោះថា មគ្គថ្នាក់នេះ អាចសម្រាលនូវរាគៈ ទោសៈ ឲ្យស្រាលស្តើង ។

អនាគាមិមគ្គ ប្រែថា មគ្គនៃបុគ្គលអ្នកលែងមកកើតក្នុងកាមលោកដោយអំណាចបដិសន្ធិទៀត លះបាននូវឱរម្ភាគិយសំយោជនកិលេស ៥ គឺ សក្កាយទិដ្ឋិ, វិចិកិច្ឆា, សីលព្វតបរាមាសៈ និង កាមរាគៈ បដិឃៈ យ៉ាងល្អិតដែលសល់អំពីសកទាគាមិមគ្គលះពុំទាន់បាន, អាចរួបរួមសន្និដ្ឋានបានថាមគ្គថ្នាក់នេះ លះកាមរាគៈ ទោសៈដាច់ស្រឡះ, ឯរូបរាគៈនិងអរូបរាគៈ គ្រាន់តែស្តើង ត្រាតែអរហត្តមគ្គទើបអាចលះដាច់ស្រឡះបាន ។

អរហត្តមគ្គ ប្រែថា មគ្គនៃបុគ្គលអ្នកឆ្ងាយចាកកិលេស, លះបានសំយោជនកិលេសស្រឡះទាំង ១០ គឺ ឱរម្ភាគិយសំយោជនកិលេសទាំង ៥ ហើយនិងឧទ្ធម្ភាគិយសំយោជនកិលេស ៥ ទៀតគឺ

១- **រូបរាគៈ** សេចក្តីជាប់ចិត្តក្នុងរូបភពគឺភពមានរូប ។

២- **អរូបរាគៈ** សេចក្តីជាប់ចិត្តក្នុងអរូបភពគឺភពឥតមានរូប ។

៣- **មានៈ** សេចក្តីប្រកាន់ដោយអាងថាខ្លួន គ្រាន់បើជាងគេ, ប្រហែលនឹងគេ និងថោកទាបជាងគេ ។

៤- **ឧទ្ធច្ចៈ** សេចក្តីរវើរវាយរាយមាយចិត្ត គឺបណ្តោយចិត្តឲ្យរសាត់អណ្តែតទៅតាមអារម្មណ៍ជាខ្សែនៃតណ្ហា ។

៥- **អវិជ្ជា** សេចក្តីល្ងង់, ងងឹងងោង មិនយល់ជាក់នូវរូបធម៌និងនាមធម៌តាមសភាពពិតមែន ។

រួមសេចក្តីថា អរហត្តមគ្គលះបានដាច់ទាំងរាគៈ, ទោសៈ, មោហៈ ឥតមានសេសសល់កិលេសណាមួយទៀតឡើយ ។

សំយោជនកិលេស ៥ ខាងដើមឈ្មោះថា ឱរម្ភាគិយសំយោជនកិលេស ប្រែថា សំយោជនៈប្រព្រឹត្តទៅក្នុងខាងក្រោម, ព្រោះអាចចងសត្វភ្ជាប់នឹងភពជាន់ទាបគឺ កាមភព សំយោជនកិលេស ៥ ខាងចុងឈ្មោះ ឧទ្ធម្ភាគិយសំយោជនៈ ប្រែថា សំយោជនៈប្រព្រឹត្តទៅក្នុងខាងលើ, ព្រោះអាចចងរឹតសត្វភ្ជាប់នឹងភពជាន់លើគឺ រូបភព និងអរូបភព ។

ធម្មារម្មណ៍ជាសេចក្តីសុខសម្រាន្ត ដែលបានមកអំពីការស្ងប់រម្ងាប់កិលេសដែលមគ្គនោះៗ លះបានហើយ ហៅថា ផល, មាន ៤ យ៉ាង តាមទំនងនៃមគ្គនោះៗដែរ ។

សេចក្តីសុខសម្រាន្តដែលបានមកអំពីការស្ងប់រម្ងាប់កិលេស ដែលសោតាបត្តិមគ្គលះបានឈ្មោះថា សោតាបត្តិផល ។ សេចក្តីសុខសម្រាន្តដែលបានមកអំពីការស្ងប់រម្ងាប់កិលេស ដែលសកទាគាមិមគ្គលះបានឈ្មោះថា សកទាគាមិផល ។ សេចក្តីសុខសម្រាន្តដែលបានមកអំពីការ

ស្ងប់រម្ងាប់កិលេសដែលអនាគាមិមគ្គលះបាន ឈ្មោះថា អនាគាមិផល ។ សេចក្ដីសុខសម្រាន្ដដែលបានមកអំពីការស្ងប់រម្ងាប់កិលេស ដែលអរហត្ត-មគ្គលះបាន ឈ្មោះថា អរហត្តផល ។

## អធិប្បាយអំពីមគ្គនិងផលដោយសរុប

មគ្គនិងផលនេះ ជាប្រភេទនៃលោកុត្តរធម៌ ព្រោះជាធម៌ញ៉ាំងសត្វឲ្យឆ្លងផុតស្រឡះចាកត្រៃលោក, ជាធម៌ឥតងាកត្រឡប់មករកត្រៃ-ភពទៀត, ជាធម៌តែងឈមមុខទៅរកព្រះនិព្វាន, ព្រោះព្រះនិព្វានជាមកុដរបស់ធម៌ទាំងនេះ, ជាធម៌រួចស្រឡះចាកកណ្ដាប់ដៃនៃបញ្ចពិធមារជាធម៌ផុតអំណាចសាមញ្ញលក្ខណៈ ។ មគ្គនិងផលនេះជាប្រភេទនៃឧត្តរិ-មនុស្សធម៌ ព្រោះជាធម៌ធ្នើម ធម៌ឯករបស់មនុស្ស, ព្រោះថាមនុស្សដែលកើតឡើងរាល់ៗជាតិ បើពុំទាន់បានធម៌នេះទេ នឹងសង្ឃឹមថារួចចាកទុក្ខពុំបានឡើយ ។

ម្យ៉ាងទៀត មគ្គនិងផលនេះបាននាមថា អកាលិកធម៌ ព្រោះជាធម៌ឲ្យផលភ្លាមៗ តាមលំដាប់គ្នា ឥតរារង់ចាំកាលវេលា, កាលបើមគ្គកើតឡើងហើយ ផលក៏កើតឡើងភ្លាម, មគ្គនិងផលនេះបាននាមថា អប្ប មាណធម៌ ព្រោះជាធម៌មិនមានប្រមាណ ជាធម៌ធំក្រៃលែងជាងមហ-គ្គតធម៌ ។

មគ្គនិងផលមានដំណើរផ្សេងគ្នាដូចឧបមាតទៅនេះគឺ សំយោជនកិលេសទុកស្មើរោគាពាធក្នុងកាយ, មគ្គទុកដូចឱសថទិព្វពិសេសដែលអាចរម្ងាប់បង់នូវរោគាពាធនោះបាន, ផលទុកស្មើសេចក្ដីសុខសម្រាន្តព្រោះការសះស្បើយរោគ ។

ម្យ៉ាងទៀតថា សំយោជនកិលេសទុកស្មើពួកចោរដែលតែងបៀតបៀននូវអ្នកស្រុកឲ្យបានទុក្ខវេទនា, មគ្គទុកស្មើពួកយោធាដែលអាចកម្រាបបាននូវពួកចោរ, ផលទុកស្មើសេចក្ដីសុខសាន្តត្រាណនៃអ្នកស្រុកព្រោះអស់ចោរ ។

និព្វាន ៣០

ន័យដែលនឹងពន្យល់អំពីព្រះនិព្វាននោះជាកិច្ចមួយយ៉ាងក្របំផុត រកអ្វីស្មើពុំបានឡើយ ទោះបីព្រះសម្មាសម្ពុទ្ធក៏ទ្រង់រកពិធីពន្យល់ឲ្យជាក់លាក់ដល់សន្តានបុថុជ្ជនពុំបាន, ព្រោះថាព្រះនិព្វានជាកិច្ចត្រូវដឹងជាក់ផ្ទាល់ខ្លួនចំពោះរូបអ្នកដែលបាន គឺ អ្នកណាបាន អ្នកនោះយល់ ជាតិបុថុជ្ជនទោះបីខំត្រិះរិះគ្នេរគ្នាន់យ៉ាងណា ក៏មិនប៉ះពារទៅលើសេចក្ដីពិតមែននៃព្រះនិព្វាននោះដែរ (អតក្កាវចរោ), ព្រោះប្រាជ្ញាបុថុជ្ជនមិនមែនជាភាជន៍សម្រាប់រងកែវដ៏វិសេសគឺព្រះនិព្វាននោះឡើយ ។

ពិតមែនតែព្រះនិព្វានហាក់ដូចជាស្ពាននៅក្នុងទីកំបាំងនាំឲ្យងេងងោងវិលវល់ខ្វល់ប្រាជ្ញាបុថុជ្ជន ទាយមិនបានស្មានមិនត្រូវ យ៉ាងនេះ

ក៏ដោយ តែគង់មានតម្រួយពុទ្ធភាសិតដែលព្រះសុគតទ្រង់ពន្យល់ទុកមក ជាអនេកគួរឲ្យភ្លឺព្រឹលៗបានខ្លះដែរ ទាំងផ្លូវដែលសម្រាប់ដើរទៅកាន់ព្រះនិព្វានទៀតសោតក៏នៅមានគ្រប់គ្រាន់ ។

ហេតុនោះ យើងគប្បីសន្និដ្ឋាន តាមលំអានយោបល់ដែលព្រះសិទ្ធត្ថពោធិសត្វទ្រង់ត្រិះរិះក្នុងពេលទៀបចេញសាងអភិនេស្រ្កមថា ធម៌ទាំងអស់សុទ្ធតែមានគូផ្ទុយទំនាស់គ្នាគឺ តែមានក្តៅហើយគង់មានត្រជាក់ តែមានងងឹតហើយគង់មានពន្លឺ, មានទុក្ខហើយគង់មានសុខ, មានជាតិហើយគង់មានអ្វី ដែលមិនមែនជាជាតិ, រួមសន្និដ្ឋានថា គោងតែមាននិព្វានដែលជាគូផ្ទុយទំនាស់នឹងសំសារវដ្ត ។

មួយទៀត គួរសន្និដ្ឋានថា ហេតុដែលល្អ ឲ្យផលល្អ, ផ្លូវដែលត្រង់ធ្វើអ្នកដំណើរឲ្យត្រង់តាម, ស្ទឹងទន្លេដែលត្រង់ធ្វើទឹកឲ្យហូរត្រង់តាម, អ្វីទាំងអស់សុទ្ធតែឲ្យផលទៅតាមទំនងនៃហេតុនោះៗ, ចំណែកព្រះនិព្វាន ជាធម្មជាតឥតហេតុក៏ពិតមែន តែមានអរិយមគ្គជាតួកុសលទុកដូចជាហេតុជាប្រឡាយដែរ ព្រោះថាបុគ្គលអ្នកត្រូវការទៅកាន់ព្រះនិព្វាន គោងដើរទៅតាមអរិយមគ្គជាដំបូង ទើបឈោងទៅចាប់យកព្រះនិព្វានបាន, មិនមែនធ្វើដំណើរទៅកាន់ព្រះនិព្វានបានដោយអន្តប្បដិបត្តិជាផ្លូវអកុសលនោះទេ, តែកុំគប្បីចូលចិត្តថា កុសលគឺអរិយមគ្គទាំង ៨ នេះជាហេតុពិតនៃព្រះនិព្វាន, ទោះកុសលក្តី អកុសលក្តី មិនមែន

ជាហេតុនៃព្រះនិព្វានទេ, ព្រោះព្រះនិព្វានជាធម៌ឥតហេតុ (អសង្ខតលោកុត្តរធម៌), ហេតុនេះហើយបានជាមានដំណាលថា ព្រះអរហន្តជាអ្នកមិនមានបុណ្យបាប ព្រោះលះបុណ្យបាបចោលស្រឡះ, បុណ្យនិងបាបទុកដូចជាត្រើយខាងអាយ នៃជនអ្នកត្រូវការទៅកាន់ត្រើយខាងនាយគឺព្រះនិព្វាន ឬថាបុណ្យប្រៀបដូចជានាវាដែលអរិយជនគ្រាន់តែជិះឆ្លងគង្គាទៅកាន់ត្រើយនាយហើយលះបង់ចោលក្បែរមាត់ច្រាំងប៉ុណ្ណោះ ។

ដំណើរនេះ គួររួមសន្និដ្ឋានថា អ្វីទាំងអស់ សុទ្ធតែចេញផលទៅតាមទំនងនៃហេតុនោះៗ, ក៏អរិយមគ្គឈ្មោះថាជាផ្លូវយ៉ាងវិសេសបំផុតលើសលែងផ្លូវនានា, គង់នឹងធ្វើអ្នកដំណើរដែលដើរតាមមហាមាគ៌ានេះឲ្យបានទទួលឧត្តមផលគឺព្រះនិព្វានពុំខាន ដោយទៀងទាត់ ។

ព្រះនិព្វានមានសណ្ឋានទ្រង់ទ្រាយជាស្ថាន ឬជាអ្វីទៅ?

ព្រះនិព្វានមិនមែនជា ស្ថានអណ្តែតវិលវល់ ឬនៅនឹងថ្កល់យ៉ាងស្ថានមនុស្ស ឬស្ថានសួគ៌នោះទេ ឬនឹងថា នាមធម៌-រូបធម៌ណាមួយយ៉ាងវិញ្ញាណនិងរូបនៃវត្ថុនានាក៏មិនមែន, ពុំនោះសោតនឹងថាលោកនេះឬលោកមុខក៏មិនមែន (នាយំ លោកោ, ន បរោលោកោ), ឬនឹងថាជាធាតុក៏ទេដែរ ប៉ុន្តែកុំគប្បីសន្និដ្ឋានថា និព្វានសូន្យសោះទទេយ៉ាងអាកាសនោះពុំត្រូវទេព្រោះមានន័យគប្បីនឹងការពារពាក្យថា សូន្យ, ហាមថា (**ដ ១ដ-មត្តមេវ**" និព្វានសព្ទនេះកុំគប្បីប្រែថា រលត់តែម្យ៉ាង ។ មួយទៀត

បើថានិព្វានសូន្យហើយតើឈ្មោះថាបានសុខមកពីណាកើត? ចំណែកព្រះសម្ពុទ្ធ ទៀតសោតចាំបាច់ទ្រង់ខំរើសរកន័យជាអនេកលើកមកពន្យល់ធ្វើអ្វី គ្រាន់តែសម្ដែងប្រាប់ថាសូន្យតែប៉ុណ្ណោះសត្វស្ដាប់បានងាយណាស់ហើយ ។ ហេតុនេះនឹងថាព្រះនិព្វានជាស្ថានសូន្យទទេសោះមិនត្រូវទេ ។

## ព្រះនិព្វានមានគុណគួរប្រាថ្នា

និព្វានសព្ទ ប្រែថា គុណជាតដែលរួចរបូតផុតចាកបណ្ដាញព្រៃញាតស្បាត គឺចំណង់ (តណ្ហា) សេចក្ដីថា សត្តនិករទាំងអស់ទោះជាមនុស្សក្ដី, ទេព្តាក្ដី, ព្រហ្មក្ដី, ដែលវិលវល់នៅក្នុងលោកដោះខ្លួនចេញពុំរួច ព្រោះជាប់បណ្ដាញសំណាញ់របស់លោក, ហេតុនេះហើយ សត្វទាំងនោះចេះតែវិលកើត-ស្លាប់ឥតឈប់ឈរ ឥតមានទីបំផុតកាលកំណត់ត្រូវរួចនោះឡើយ, ឯព្រះនិព្វាននេះជាគុណធម៌ដែលមានមហានុភាពដ៏លើសលប់ អាចនឹងជួយជ្រោមជ្រែងសត្វទាំងនោះឲ្យរួចផុតចាកបណ្ដាញរបស់លោកបាន ។

ម្យ៉ាងទៀត និព្វាន ប្រែថា គុណជាតដែលរលត់ភ្លើងទុក្ខ ភ្លើងកិលេស, សេចក្ដីថា ក្នុងលោកសន្និវាសទាំងមូលនេះតែងឆេះសន្ធោសន្ធៅពាសពេញទៅដោយគំនរភ្លើងទាំងនេះជានិច្ចនិរន្តរ៍ ម្ល៉ោះហើយសត្វដែលនៅក្នុងលោក តែងរលោករលួយក្រហល់ក្រហាយអន្ទះអន្ទែង

ឥតមានស្រាកស្រាន្ត, ឯព្រះនិព្វានជាឱទកធារាយ៉ាងវិសេសអាចជួយស្រោចស្រប់លត់ភ្លើងឲ្យពពួកសត្វបានត្រជាក់ត្រជុំក្សេមក្សាន្តបាន ។

ព្រះនិព្វានជាសភាពផុយគ្នានឹងសង្សារចក្រឬសង្សារវដ្ត សង្សារគឺជាកង់មួយយ៉ាងធំរបស់លោកតែងវិលទៅទាំងយប់ទាំងថ្ងៃ ពាសពេញលោកទាំង ៣ អាចបង្វិលសត្វលោកឲ្យវិលទៅជាមួយផង ជានិច្ចសព្វកាលវេលា, ជួនកាលទាបចួនកាលខ្ពស់ចុះឡើងៗ ឥតមានកាលកំណត់ត្រូវគាំង នឹងនៅបានទេ ។ ឯព្រះនិព្វានជាគន្លឹះឬជារនុកមួយយ៉ាងសំខាន់អាចខ្ទាស់កង់របស់សត្វឲ្យគាំងឲ្យទ្រឹងរកវិលទៅមិនរួចបាន ។

ម្យ៉ាងទៀតមានតម្រួយពុទ្ធភាសិត ទ្រង់ពន្យល់ទុកមកជាអនេកមានដើមថា ព្រះនិព្វានឥតមានជាតិ (អជាតិ) ឥតមានសេចក្ដីគ្រាំគ្រា (អជរា), ឥតមានសេចក្ដីឈឺចាប់ (អព្យាធិ), ឥតមានសេចក្ដីភិតភ័យ (និព្ភយំ), ផុតអំណាចហេតុបច្ច័យតាក់តែងបាន (អសង្ខតំ), ទម្លាយនូវភពបាន (ភវភិន្ទនំ), មានសុទ្ធតែសុខ (សុខំ), ត្រជាក់ត្រជុំ (សីតំ) ក្សេមក្សាន្ត (ខេមំ), ជាទីពឹងពួន (តាណំ), ជាទីជ្រកកោន (លេណំ), ជាស្ថានទៀតទាត់ (និច្ចំ), ឥតមានរំភើប (អចលំ), ទៀងទាត់ឥតប្រែប្រួល (ធុវសស្សតំ), មានខ្លឹមសារមិនវិលវល់ (អវដ្តសារំ), បន្ទោរបង់នូវសុខរបស់មនុស្សនិងសុខទិព្វ (សុខមទ្ទនំ), កម្ចាត់បង់នូវសេចក្ដីឃ្លានបាន (ខុទ្ទមទ្ទនំ), កម្ចាត់បង់នូវសេចក្ដីស្រេកបាន

(បិបាសវិនយំ), ឥតមានអាល័យ (អនាលយំ), រំលើងចោលនូវទោសគឺកិលេសដែលស្វែងរកប្រទុស្តដូចជាអសិរ្ពិសបានហើយ (សមុគ្ឃាដវដ្ដំទវដ្ដសំ), ប្រាសចាកសង្ខារគឺនាមនិងរូប (វិសំខារំ), ប្រាសចាកទោសសព្វយ៉ាង (វិវដ្ដំ), ជាទីក្ស័យនៃតណ្ហា (តណ្ហក្ខយំ), ប្រាសចាកភព (វិភវំ), ប្រាសចាកតម្រេក (វិរាគំ), កម្ចាត់បង់នូវងងឹតងងល់បានហើយ (វីតមោហំ), ជាទីរលត់បង់នៃទុក្ខ (និរោធំ), ជាធម្មជាតមិនមានគ្រឿងសម្គាល់ (អនិមិត្តំ), ជាគុណស្ងប់រម្ងាប់កិលេស (សន្តភាវំ), មិនធ្វើឲ្យមានរសគឺតណ្ហា (អរសាករំ), ឥតមានដង្ហើមចេញចូល (អបស្សាបស្សំ), ឥតមានស្លាប់ (អមតំ) ។

និព្វានបើចែកដោយប្រភេទជា ២ យ៉ាងគឺ សឧបាទិសេសនិព្វាន ១, អនុបាទិសេសនិព្វាន ១ ។

សឧបាទិសេសនិព្វាន បានដល់និព្វានរបស់ព្រះអរហន្តដែលអស់អាសវៈហើយ, មានព្រហ្មចរិយធម៌ជាគ្រឿងនៅៗរួចហើយ, មានកិច្ច[១] ត្រូវធ្វើៗរួចហើយ, មានគ្រឿងទម្ងន់[២] ទម្លាក់ចោលហើយ, បានដល់នូវប្រ-

---

១ កិច្ចដែលព្រះអរិយបុគ្គលត្រូវធ្វើមាន ៤ យ៉ាងគឺ បរិញ្ញាកិច្ច កំណត់នូវទុក្ខសច្ច១, បហានកិច្ច លះបង់នូវសមុទយសច្ច ១, សច្ឆិកិរិយាកិច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ១, ភាវនាកិច្ច បម្រើនមគ្គសច្ច ១, ក្នុងមគ្គមួយៗ មានកិច្ច ៤ គ្រប់មគ្គទាំង ៤ ត្រូវជាកិច្ច ១៦ ហៅថា សោឡសកិច្ច ។

២ ភារៈគ្រឿងទម្ងន់ ៣ យ៉ាងគឺ ខន្ធភារៈគ្រឿងទម្ងន់គឺបញ្ចក្ខន្ធ ១, កិលេសភារៈ គ្រឿងទម្ងន់ គឺកិលេស ១, អភិសង្ខារភារៈ គ្រឿងទម្ងន់គឺអភិសង្ខារ ១ ។

យោជន៍[១] របស់ខ្លួនតាមលំដាប់ហើយ, មានចំណងក្នុងភព[២] អស់រលីង ហើយ, មានចិត្តរួចស្រឡះហើយព្រោះកិរិយាត្រាស់ដឹងត្រូវ, តែនៅមាន ឥន្ទ្រិយសម្រាប់ទទួលអារម្មណ៍គាប់ចិត្តនិងមិនគាប់ចិត្ត, សុខឬទុក្ខនៅឡើយ ក៏គឺព្រះអរហត្តផលហ្នឹងឯង ។

អនុបាទិសេសនិព្វាន បានដល់និព្វានរបស់ព្រះអរហន្តដែលប្រកប ដោយធម៌ខាងលើនេះដែរ តែរលត់ទាំងឥន្ទ្រិយសម្រាប់ទទួលអារម្មណ៍គាប់ ចិត្តនិងមិនគាប់ចិត្ត, សុខឬទុក្ខថែមទៀត គឺរលត់ទាំងកិលេសរលត់ទាំងខន្ធ បានឈ្មោះថាបរិនិព្វាន ។ ន័យមួយទៀត លោកចែកនិព្វានជា ៣ យ៉ាង គឺ កិលេសនិព្វាន ១, ខន្ធនិព្វាន ១, ធាតុនិព្វាន ១ ។

កាលព្រះសព្វញ្ញុពុទ្ធទ្រង់រំលត់កិលេស បានត្រាស់ដឹងនូវសម្មាសម្ពោ-ធិញ្ញាណមាននាមប្រាកដថា "អរហំ សម្មាសម្ពុទ្ធ" លើរតនបល្ល័ង្កនាគល់ ពោធិព្រឹក្សលោកចាត់ថាជាកិលេសនិព្វាន ។ កាលដែលទ្រង់រំលត់ខន្ធចូល កាន់បរិនិព្វានលើបណ្ដូកម្ពលសិលាអាសន៍ជាអនុដ្ឋានសេយ្យាសន៍ ក្រោម ដើមសាលព្រឹក្សទាំងគូ, លោកចាត់ថាជាខន្ធនិព្វាន ។ លុះចំណេរចិរ-កាលទៅអនាគតដល់កំណត់ពុទ្ធសាសនាបាន ៥០០០ ព្រះវស្សាព្រះសារី-រិកធាតុព្រះបរមសាស្ដាដែលស្ថិតនៅក្នុងនានាប្រទេស នឹងអណ្ដែតមកផ្ដុំគ្នា

---

១ ប្រយោជន៍ក្នុងទីនេះសំដៅយកអរហត្តផល ។ ២ បំណងក្នុងភពបានដល់សំយោជន កិលេស ១០ យ៉ាង ។

សមោធានកើតបានជាអង្គព្រះពុទ្ធមួយព្រះអង្គ ហើយទេសនាប្រោសសត្វ រហូតអស់ ៧ ថ្ងៃ ហើយនឹងមានទេវតាព្រមទាំងមនុស្សបានសម្រេចមគ្គផល ជាអនេក ទើបមានតេជោធាតុឆេះរំលាយ ព្រះធាតុរូបដរាបដល់សូន្យអស់ រលីង ឥតមានសេសសល់ឡើយ នេះឯង លោកហៅថា ធាតុនិព្វាន ។

# វិធិប្ដ័យបទនមស្សការព្រះធម៌

**អដ្ឋង្គិកាវរិយបថោ ជនានំ**

**មោក្ខប្បវេសាយ ឧជូ ច មគ្គោ**

**ធម្មោ អយំ សន្តិករោ បណីតោ**

**និយ្យានិកោ តំ បណមាមិ ធម្មំ ។**

*ប្រែថា ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នោះជាធម៌ធ្វើឲ្យត្រជាក់ រម្ងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វឲ្យចេញចាកសំសារទុក្ខ, ខ្ញុំព្រះករុណា សូមក្រាប-ថ្វាយបង្គំនូវព្រះសទ្ធម្មនោះ ដោយគោរព ។*

## ពាក្យសួរដែលគួរបាំ

*១- អ្វីហៅថា ធម៌ ក្នុងធម្មរតនៈនេះ?*

*២- ធម៌ដែលប្រកបដោយអង្គ ៨ ប្រការបានដល់ធម៌ណា?*

*៣- និព្វានមានគុណវិសេសដូចម្ដេច?*

*៤- អ្វីហៅថាភ្លើងទុក្ខ? អ្វីហៅថាភ្លើងកិលេស?*

*៥- ទុក្ខដូចម្ដេចហៅថា សំសារទុក្ខ?*

## សេចក្តីឆ្លើយ

១- សភាពដែលទ្រទ្រង់សត្វអ្នកប្រតិបត្តិតាម មិនឲ្យធ្លាក់ទៅក្នុងទីទុក្ខទីទាបមានអបាយភូមិ ៤ ជាដើម ហៅថាធម៌ ក្នុងធម្មរតនៈនេះ ។

២- ធម៌ដែលប្រកបដោយអង្គ ៨ ប្រការ បានដល់ អដ្ឋង្គិកមគ្គ ។

៣- និព្វានមានគុណវិសេសអាចឲ្យរម្ងាប់នូវភ្លើងកិលេសបាន ។

៤- ទុក្ខទាំង ១២ កងមានជាតិទុក្ខជាដើម ហៅថា ភ្លើងទុក្ខ, កិលេសធម៌សព្វយ៉ាងមាន រាគៈ ទោសៈ មោហៈ ជាដើម ហៅថាភ្លើងកិលេស ។

៥- ទុក្ខសព្វមុខដែលកើតឡើង ព្រោះការបេះតែអន្ទោលចុះឡើងវិលកើតស្លាប់ឥតឈប់ឈរក្នុងភពទាំង ៣ ហៅថា សំសារទុក្ខ ។

## សេចក្តីអធិប្បាយ

ធម៌ប្រកបដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាអាទិ៍ មានសម្មាសមាធិជាបរិយោសានជាផ្លូវដ៏ប្រសើរ ព្រោះជាគន្លងដំណើរនៃព្រះអរិយបុគ្គលតែងសញ្ចារ, ជាផ្លូវដ៏ត្រង់ព្រោះវៀរចាកផ្លូវកោងផ្លូវវៀច ២ យ៉ាងគឺ អត្តកិលមថានុយោគ (ការប្រកបខ្លួនឲ្យនឿយហត់ឥតអំពើ) និងកាមសុខល្លិកានុយោគ (ការប្រកបខ្លួនឲ្យប្រឡូកប្រឡំនៅក្នុងវត្ថុកាមនិងកិលេសកាម), ជាផ្លូវត្រជាក់ត្រជុំក្សេមក្សាន្តព្រោះប្រាសចាកចំហាយភ្លើង ២ ប្រការគឺភ្លើងទុក្ខ និងភ្លើងកិលេស, ជាផ្លូវដ៏ខ្ពង់ខ្ពស់ព្រោះស្ទួយអ្នកដំណើរឲ្យផុតលំបាក

ដោយការវិលកើត-ស្លាប់ ។

ផ្លូវនេះឯងហើយ ដែលពួកអរិយជនមានព្រះពុទ្ធជាដើមតែង សញ្ចរទៅកាន់ស្រុកធំក្សេមក្សាន្តមានសេចក្ដីសុខហួសប្រៀប គឺ អមតមហានិព្វាន ។

## វិធិប្ប័យបទនមស្សការព្រះធម៌គ្រប់ត្រៃកាល

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**
**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។**

*ប្រែថា ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី, ព្រះធម៌ទាំងឡាយឯណាដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធនឹងមានមកក្នុងកាលខាងមុខក្តី, ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ថានទុក ក្នុងកាលសព្វថ្ងៃនេះក្តី, ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។*

### ពាក្យសួរដែលគួរចាំ

*១- ព្រះធម៌របស់ព្រះពុទ្ធជាអតីត, អនាគត, បច្ចុប្បន្ន ផ្សេងៗគ្នាឬ ទើបលោកញែកចេញជាត្រៃកាលដូច្នេះ?*

*២- ព្រះធម៌គ្រប់ត្រៃកាល ដែលព្រះពុទ្ធរាល់ព្រះអង្គទ្រង់សម្តែងទុកមកនោះតើទ្រង់បំណងអ្វីជាសំខាន់?*

### សេចក្តីឆ្លើយ

*១- មិនផ្សេងគ្នាទេ, ព្រះធម៌ទាំង ៣ កាលនេះ មានអត្ថរសតែមួយដូចគ្នា, ដែលលោកញែកជា ៣ កាលនោះ តាមដំណើរដែលមានព្រះពុទ្ធផ្សេងកាលគ្នាជាអតីត, អនាគត, បច្ចុប្បន្ន ប៉ុណ្ណោះ ។*

២- ព្រះធម៌ទាំង ៣ កាលដែលទ្រង់សម្តែងទុកមកនេះ ដោយបំណង នឹងញុំាងសត្វដែលបែរមុខឈមទៅរក អម្រឹតបុរីឲ្យតាំងចិត្តគោរពចំពោះ ព្រះធម៌គ្រប់កាលទាំង ៣ ប៉ុណ្ណោះឯង ។

សេចក្តីអធិប្បាយ

ព្រះធម៌របស់ព្រះពុទ្ធដែលបានត្រាស់ហើយ, បរិនិព្វានហួសទៅហើយ ហៅថាអតីតធម៌, ព្រះធម៌របស់ព្រះពុទ្ធតទៅមុខដែលមិនទាន់បានត្រាស់ នៅឡើយតែបម្រុងនឹងបានត្រាស់ជាន់ក្រោយ ហៅថា អនាគតធម៌, ព្រះ ធម៌របស់ព្រះពុទ្ធសមណគោតមបរមគ្រូរបស់យើង ដែលបានត្រាស់ហើយ ប្រតិស្ឋានទុកសព្វថ្ងៃនេះហៅថា បច្ចុប្បន្នធម៌ ។

ព្រះធម៌ទាំងឡាយគ្រប់ត្រៃកាល ទោះជាអតីតធម៌ក្តី, អនាគត ធម៌ក្តី, បច្ចុប្បន្នធម៌ក្តី សុទ្ធសឹងមានសេចក្តីដូចៗគ្នា មានចំនួនស្មើគ្នា មានអត្ថរសតែមួយដូចគ្នា ព្រោះថាព្រះពុទ្ធទាំងឡាយរាល់ៗ ព្រះអង្គ សុទ្ធតែទ្រង់ប្រដៅសត្វ (រួបរួមពុទ្ធភាសិតមកតែត្រឹម) ៣ ព្រះឱវាទគឺ មិនឲ្យធ្វើបាបសព្វយ៉ាង ១, ឲ្យខំធ្វើបុណ្យ ១, ឲ្យខំសម្អាតចិត្តខ្លួនឲ្យផូរ ផង់ ១ ដូចៗគ្នា ។

ឯឈ្មោះធម៌ក៏មាន ៣ ដូចគ្នាគឺ បរិយត្តិធម៌ ១, បដិបត្តិធម៌ ១, បដិ- វេធធម៌ ១, បរិយត្តិធម៌ទៀតសោត ក៏ចែកចេញជាព្រះវិន័យ, ព្រះសូត្រ, ព្រះអភិធម្មដូចគ្នា បដិបត្តិធម៌ក៏ចែកចេញជា សីល, សមាធិ, បញ្ញា

ដូចគ្នា, បដិវេធធម៌ ក៏ចែកជា មគ្គ, ផល, និព្វានដូចគ្នា ។ ទាំងចំនួនធម៌ក៏មាន ៨ ម៉ឺន ៤ ពាន់ព្រះធម្មក្ខន្ធដូចគ្នា គឺព្រះវិន័យ ២១០០០, ព្រះសូត្រ ២១០០០, ព្រះអភិធម្ម ៤២០០០ ដូចគ្នា ។ ចំណែកអត្ថរសនៃធម៌ទាំងនោះទៀតសោតក៏មានតែមួយគឺ វិមុត្តិរសដូចគ្នា ។

ហេតុនោះ បានជាព្រះធម៌របស់ព្រះពុទ្ធអង្គណា ក៏ដូចជាអង្គណា, ក្នុងកាលណា ក៏ដូចជាក្នុងកាលណា ។

ព្រះធម្មគុណ ៦ ព្រះនាម

យោគីបុគ្គល អ្នកត្រូវការចម្រើនធម្មានុស្សតិ គប្បីសម្ងំនៅក្នុងទីដ៏ស្ងាត់ ហើយគប្បីរំពឹងនូវគុណនៃព្រះបរិយត្តិធម៌និងព្រះនពលោកុត្តរធម៌ ចំពោះព្រះនាមណាមួយ ដោយការចូលចិត្តសេចក្ដីជាក់ក្នុងព្រះនាមនោះៗ ដូចតទៅនេះ៖

១- **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងហើយដោយល្អ, ធម្មោ ព្រះនពលោកុត្តរធម៌មាន ៩ ប្រការគឺ មគ្គ ៤, ផល ៤, និព្វាន ១ ។

២- **សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺជានឹងបានដឹងដោយស្ដាប់ដោយជឿបុគ្គលដទៃនោះៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង ។

៣- **អកាលិកោ** ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានឃឺតយូរឡើយ

៤- **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន

៥- **ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា

៦- **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

## (១) វិនិច្ឆ័យបទថា "ស្វាក្ខាតោ ភគវតា ធម្មោ"

### ពាក្យសួរដែលគួរចាំ

១- ព្រះធម៌ទាំង ៦ បទនេះ បទណាជាឈ្មោះបរិយត្តិធម៌? បទណាជាឈ្មោះលោកុត្តរធម៌?

២- ព្រះធម៌ដែលបាននាមថា "ស្វាក្ខាតោ" ប្រែថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងល្អហើយនោះ មានលម្អប៉ុន្មានយ៉ាង គឺអ្វីខ្លះ?

### សេចក្ដីឆ្លើយ

១- ព្រះធម៌ទាំង ៦ បទនេះ, បទទី ១ ជាឈ្មោះនៃបរិយត្តិធម៌ផង លោកុត្តរធម៌ផង, ឯបទទាំង ៥ ខាងចុងជាឈ្មោះនៃលោកុត្តរធម៌ ។

២- ព្រះធម៌ដែលបាននាមថា "ស្វាក្ខាតោ" ព្រោះមានលម្អ ៣ យ៉ាង គឺ លម្អបទខាងដើមដោយសីល, លម្អបទកណ្ដាលដោយសមាធិ, លម្អបទខាងចុងដោយបញ្ញា ។

### សេចក្ដីអធិប្បាយ

បទថា "ស្វាក្ខាតោ" នេះ ជាឈ្មោះធម៌ ២ យ៉ាងគឺ បរិយត្តិធម៌ ១, លោកុត្តរធម៌ ១ ។

### បរិយត្តិធម៌ឈ្មោះថា "ស្វាក្ខាតោ"

បរិយត្តិធម៌ឈ្មោះថា "ស្វាក្ខាតោ" ព្រោះព្រះមានព្រះភាគទ្រង់

ត្រាស់សម្ដែងល្អហើយ ដោយលម្អ ៣ យ៉ាងគឺ លម្អបទខាងដើម, បទកណ្ដាល, បទខាងចុង ទាំងប្រកាសនូវព្រហ្មចរិយធម៌ ប្រកបដោយអត្ថ, ដោយព្យញ្ជនៈដ៏បរិបូណ៌ បរិសុទ្ធអស់ជើង ។

ពិតដូច្នោះមែន ព្រះមានជោគសូម្បីទ្រង់ត្រាស់សម្ដែងធម៌ត្រឹម ១ គាថាក៏ដោយ, គាថានោះឯង គង់មានលម្អខាងដើមដោយបឋមបាទ, មានលម្អបទកណ្ដាលដោយបាទទី ២ ទី ៣ មានលម្អបទខាងចុងដោយបាទទីបំផុត ។

ព្រះសូត្រដែលមានអនុសន្ធិតែមួយ ឈ្មោះថាមានលម្អខាងដើមដោយពាក្យនិទាន មានលម្អក្នុងទីបំផុតដោយពាក្យនិគម មានលម្អត្រង់កណ្ដាលដោយពាក្យរវាងកណ្ដាល ។

ព្រះសូត្រដែលមានអនុសន្ធិផ្សេងៗ ឈ្មោះថាមានលម្អខាងដើមដោយអនុសន្ធិទី ១, លម្អក្នុងទីបំផុត ដោយអនុសន្ធិជាទីបំផុត, លម្អត្រង់កណ្ដាលដោយអនុសន្ធិរវាងកណ្ដាល ។

ម៉្យាងទៀត ឈ្មោះថាមានលម្អខាងដើម ព្រោះមាននិទាននិងឧបត្តិហេតុ, មានលម្អត្រង់កណ្ដាល ព្រោះសមគួរដល់វេនេយ្យសត្វនិងប្រកបដោយហេតុនិងឧទាហរណ៍ ដោយភាពដែលមិនមានអត្ថឃ្លៀងឃ្លាត មានលម្អខាងចុង ព្រោះពាក្យនិគមដែលជាហេតុញ៉ាំងអ្នកស្ដាប់ឲ្យកើតសទ្ធា ។

ឯសាសនធម៌ទាំងអស់ (ពុទ្ធសាសនាទាំងមូល) ឈ្មោះថាមានលម្អ

ខាងដើមដោយសីល, មានលម្អត្រង់កណ្តាល ដោយសមថ, វិបស្សនា មគ្គ, ផល, មានលម្អខាងចុង ដោយនិព្វាន ។

មួយវិញទៀត ឈ្មោះថាមានលម្អខាងដើម ដោយសីលនិងសមាធិ, មានលម្អត្រង់កណ្តាល ដោយវិបស្សនានិងមគ្គ, មានលម្អខាងចុងដោយផលនិងនិព្វាន ។

ម្យ៉ាងទៀតថា ឈ្មោះថាមានលម្អខាងដើម ដោយភាពនៃធម៌ដែលព្រះពុទ្ធទ្រង់ត្រាស់ល្អហើយ, មានលម្អត្រង់កណ្តាល ដោយភាពនៃធម៌ល្អពិត, មានលម្អខាងចុង ព្រោះព្រះសង្ឃប្រតិបត្តិត្រូវ ។

ម្យ៉ាងវិញទៀត ឈ្មោះថាមានលម្អខាងដើម ដោយសេចក្តីត្រាស់ដឹងដ៏ក្រៃលែង (ដែលអ្នកស្តាប់នូវសាសនធម៌នោះហើយប្រតិបត្តិតាមពិតទើបបានត្រាស់ដឹង) មានលម្អត្រង់កណ្តាល ដោយសេចក្តីត្រាស់ដឹងចំពោះខ្លួន, មានលម្អខាងចុង ព្រោះត្រាស់ដឹងត្រឹមភូមិជាសាវ័ក ។

ន័យមួយទៀត សាសនធម៌នេះឈ្មោះថាមានលម្អខាងដើម ព្រោះអាចសង្កត់សង្កិននូវនីវរណៈ សូម្បីត្រឹមការស្តាប់, ឈ្មោះថាមានលម្អត្រង់កណ្តាល ព្រោះបាននូវសុខដែលកើតអំពីសមថនិងវិបស្សនា ដោយការប្រតិបត្តិតាម, ឈ្មោះថា មានលម្អខាងចុង ព្រោះបាននូវតាទិភាព ដែលជាផលនៃសេចក្តីប្រតិបត្តិរបស់បុគ្គលដែលប្រតិបត្តិសម្រេចហើយ ។

ព្រះបរិយត្តិធម៌ឈ្មោះថា "ស្វាក្ខាតោ" ព្រោះព្រះមានជោគទ្រង់

ត្រាស់សម្ដែងល្អហើយដោយហេតុមានលម្អ ៣ យ៉ាងដូចថ្លែងមកនេះ ។

ន័យមួយវិញទៀត ព្រះបរិយត្តិធម៌ឈ្មោះថា "ស្វាក្ខាតោ" ព្រោះទ្រង់ត្រាស់សម្ដែងល្អហើយ ដោយហេតុទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ប្រកបដោយអត្ថនិងព្យញ្ជនៈ បរិសុទ្ធ បរិបូណ៌ អស់ជើង ។

សេចក្ដីថា ព្រះមានព្រះភាគ កាលបើព្រះអង្គទ្រង់ត្រាស់សម្ដែងធម៌ណា តែងទ្រង់ប្រកាសសាសនព្រហ្មចរិយៈនិងមគ្គព្រហ្មចរិយៈ, ទ្រង់ពន្យល់ដោយន័យផ្សេងៗ ធម៌នោះដែលឈ្មោះថាព្រមដោយអត្ថ ព្រោះបរិបូណ៌ដោយអត្ថដ៏សមគួរ ដែលឈ្មោះថាព្រមដោយព្យញ្ជនៈ ព្រោះបរិបូណ៌ដោយព្យញ្ជនៈ ។ ដែលឈ្មោះថាប្រកបដោយអត្ថ ព្រោះប្រកបដោយបទដែលមានប្រយោជន៍ ដែលកើតអំពីការប្រកាសដោយសង្ខេបនិងពិស្ដារ បើកពន្យល់ធ្វើសេចក្ដីឲ្យងាយយល់ (ដល់អ្នកស្ដាប់) នឹងបញ្ញត្តទុក ដែលឈ្មោះថាព្រមដោយព្យញ្ជនៈ ព្រោះដល់ព្រមដោយអក្ខរៈ បទ, ព្យញ្ជនៈ, អាការៈ, និរុត្តិនិងនិទ្ទេស ។

ម្យ៉ាងទៀត ដែលឈ្មោះថាព្រមដោយអត្ថ ព្រោះជ្រៅដោយផលនិងបដិវេធ ឬព្រោះជ្រៅដោយហេតុនិងការសម្ដែង, ពុំនោះ ព្រោះមានកិរិយាបែកធ្លាយក្នុងផលនិងបដិភាណជាវិស័យ, ដែលឈ្មោះថា ព្រមដោយព្យញ្ជនៈ ព្រោះមានកិរិយាដឹងបែកធ្លាយក្នុងហេតុនិងនិរុត្តិជាវិស័យ ។

ម្យ៉ាងវិញទៀត ដែលឈ្មោះថាព្រមដោយអត្ថ ព្រោះជាគ្រឿង

នាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ជនអ្នកស្វះស្វែងរក, ព្រោះជាធម៌ដែលបណ្ឌិតគប្បីដឹង, ដែលឈ្មោះថាព្រមដោយព្យញ្ជនៈ ព្រោះជាគ្រឿងនាំឲ្យកើតសេចក្តីជ្រះថ្លាដល់លោកិយជន ព្រោះថាជាសភាពគួរជឿបាន ។

ន័យមួយវិញទៀត ដែលឈ្មោះថាព្រមដោយអត្ថ ព្រោះមានសេចក្តីអធិប្បាយជ្រាលជ្រៅ, ដែលឈ្មោះថាព្រមដោយព្យញ្ជនៈ ព្រោះជាបទមានសេចក្តីងាយ ។

ឈ្មោះថាបរិបូណ៌ពេញលេញ ព្រោះមានសេចក្តីគ្រប់គ្រាន់ ល្មមសត្វប្រតិបត្តិបានសព្វគ្រប់ ។

ឈ្មោះថាបរិសុទ្ធ ព្រោះមិនមានទោសជាមន្ទិល, មិនមានសេចក្តីខុសដែលនឹងគប្បីដកហូតយកចេញ ។

ន័យមួយទៀត ដែលឈ្មោះថា បរិបូណ៌ពេញលេញ ព្រោះប្រកបដោយធម្មក្ខន្ធ ៥ មានសីលក្ខន្ធជាដើម, ដែលឈ្មោះថាបរិសុទ្ធ ព្រោះឥតមានធម៌ជាគ្រឿងសៅហ្មង ព្រោះថាប្រព្រឹត្តទៅដើម្បីវិវដ្តនចេញចាកភព នឹងព្រោះឥតមានសេចក្តីប្រឡូកប្រឡំក្នុងលោក ។

ព្រះបរិយត្តិធម៌ ដែលឈ្មោះថាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងល្អហើយព្រោះប្រកាសនូវព្រហ្មចរិយធម៌ ប្រកបដោយអត្ថនិងព្យញ្ជនៈ បរិបូណ៌ បរិសុទ្ធអស់ជើង ដូចសេចក្តីអធិប្បាយមកខាងលើនេះ ។

ន័យមួយវិញទៀតថា ព្រះបរិយត្តិធម៌ឈ្មោះថា "ស្វាក្ខាតោ" ទ្រង់

ត្រាស់សម្តែងល្អហើយ) ព្រោះមានសេចក្តីមិនឃៀងឃាតចាកហេតុពិត គឺថាបើធម៌ណាដែលទ្រង់ត្រាស់សម្តែងថាមានសេចក្តីអន្តរាយ ធម៌នោះ កាលបើមានសត្វហ៊ានប្រព្រឹត្តកន្លង រមែងបានទទួលផលសេចក្តីអន្តរាយ ពិតដូច្នោះមែន, ធម៌ណា ដែលព្រះអង្គទ្រង់ត្រាស់សម្តែងប្រាប់ថា ជា និយ្យានិកធម៌ អាចស្រោចស្រង់សត្វបាន, ធម៌នោះ កាលបើសត្វ ប្រព្រឹត្តតាម រមែងបានទទួលផលដូច្នោះមែន, ហេតុនោះ (ធម៌របស់ ព្រះអង្គ) ទើបឈ្មោះថា "ស្វាក្ខាតោ" ។

ឯធម៌ពួកតិរ្ថិយដទៃ ក្រៅចាកធម៌ក្នុងសាសនានេះ ពុំដូច្នោះឡើយ រមែងមានសេចក្តីឃៀងឃាត (ចាកហេតុពិត) ព្រោះធម៌ណា ដែលពួកគេពោលថា ធ្វើសេចក្តីអន្តរាយ, ធម៌នោះ បើទុកជាសត្វ ប្រព្រឹត្តកន្លង ក៏ពុំអាចធ្វើសេចក្តីអន្តរាយដូច្នោះឡើយ ។ ធម៌ណា ដែលពួកគេពោលថាជានិយ្យានិកធម៌ (ធម៌ស្រោចស្រង់សត្វឲ្យចេញចាក វដ្តសង្សារ) ធម៌នោះ បើទុកជាសត្វប្រព្រឹត្តតាមក៏ពុំអាចស្រោចស្រង់ (ឲ្យចេញចាកវដ្តសង្សារ) បានដូច្នោះ ។

ហេតុនោះហើយបានជា ធម៌ដែលពួកតិរ្ថិយពោលទុកខុសនោះ លោកឲ្យឈ្មោះថា "ទុរាក្ខាតោ" ព្រោះថាពួកតិរ្ថិយពោលខុស ។

ព្រះបរិយត្តិធម៌ឈ្មោះថា "ស្វាក្ខាតោ" ដូចសេចក្តីដែលអធិប្បាយ មកនេះឯង ។

## លោកុត្តរធម៌ឈ្មោះថា "ស្វាក្ខាតោ"

*លោកុត្តរធម៌ ក៏បាននាមថា "ស្វាក្ខាតោ" ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងល្អហើយ ព្រោះថាព្រះអង្គទ្រង់ត្រាស់សម្ដែងនូវបដិបទាសេចក្ដីប្រតិបត្តិថាជាធម្មជាតិសមគួរដល់និព្វាន, ទ្រង់ត្រាស់សម្ដែងនូវនិព្វានថាជាធម្មជាតសមគួរដល់បដិបទា ។ សមដូចជាពាក្យដែលលោកពោលទុកថា ៖ បដិបទា ជាគ្រឿងដល់នូវព្រះនិព្វានដែលព្រះមានព្រះភាគទ្រង់ត្រាស់បញ្ញត្តទុកហើយដល់សាវ័កទាំងឡាយ អាចប្រៀបធៀបគ្នាបាន (ទៅវិញទៅមក) ទាំងនិព្វាននិងបដិបទា, មានឧបមាដូចជាទឹកទន្លេគង្គាដែលហូរលាយគ្នា (ទៅវិញទៅមក) ដោយទឹកទន្លេយមុនាយ៉ាងណាមិញ, ឯបដិបទាជាគ្រឿងដល់នូវព្រះនិព្វាន ដែលព្រះដ៏មានជោគទ្រង់ត្រាស់បញ្ញត្តទុកហើយដល់សាវ័កទាំងឡាយ រមែងប្រៀបធៀបគ្នាទៅវិញទៅមកបាន ដូច្នោះដែរ ។*

*ក្នុងអធិការនេះ, ចំណែកអរិយមគ្គដែលឥតជាប់ទាក់ទងប្រឡូកប្រឡំដោយធម៌ទីបំផុត ២ យ៉ាង, ជាបដិបទាផ្លូវកណ្ដាល ក៏បានឈ្មោះថា ស្វាក្ខាតោ (ទ្រង់ត្រាស់សម្ដែងល្អហើយ) ព្រោះទ្រង់ត្រាស់ប្រាប់ថា បដិបទាផ្លូវកណ្ដាល ។*

*សាមញ្ញផលទាំងឡាយដែលមានកិលេសស្ងប់រម្ងាប់ហើយ ក៏ឈ្មោះថា "ស្វាក្ខាតោ" (ទ្រង់ត្រាស់សម្ដែងល្អហើយ) ព្រោះទ្រង់ត្រាស់ប្រាប់*

ថាមានកិលេសស្ងប់រម្ងាប់ហើយ ។

ព្រះនិព្វានដែលមានគុណមានដើមថា ទៀង, ជាធម្មជាតមិនចេះស្លាប់, ជាទីជ្រកកោន, ជាទីពឹងពួន, ក៏បានឈ្មោះថា “ស្វាក្ខាតោ” (ទ្រង់ត្រាស់សម្តែងល្អហើយ) ព្រោះទ្រង់ត្រាស់ប្រាប់ដោយអំណាចនៃសភាពមានគុណថាទៀងជាដើម ។

លោកុត្តរធម៌បាននាមថា “ស្វាក្ខាតោ” ដូចសេចក្តីដែលរៀបរាប់មកនេះឯង ។

## (២) វិគិច្ឆ័យបទថា "សន្ទិដ្ឋិកោ"

### ពាក្យសួរដែលគួរចាំ

១- ពាក្យថា "សន្ទិដ្ឋិកោ" ប្រែបានដូចម្ដេច?

២- ព្រះអរិយបុគ្គលដែលបានដល់ធម៌នេះហើយ ដូចម្ដេចក៏ត្រឡប់ជាមិនបាច់ជឿបុគ្គលដទៃ?

៣- បច្ចវេក្ខណញ្ញាណ បានដល់អ្វី?

៤- អរិយមគ្គដូចម្ដេចដែលបាននាមថា "សន្ទិដ្ឋិកោ"?

### សេចក្ដីឆ្លើយ

១- ពាក្យថា សន្ទិដ្ឋិកោ ប្រែថា ជាធម៌ដែលព្រះអរិយបុគ្គលគប្បីឃើញពិត ឬថាជាធម៌គួរដល់ការឃើញពិត ។

២- ព្រះអរិយបុគ្គលដែលបានដល់ធម៌នេះហើយ រមែងបានឃើញជាក់, បានដឹងជាក់ផ្ទាល់ខ្លួនឯង មិនបាច់ជឿដោយសារបុគ្គលដទៃ ។

៣- បច្ចវេក្ខណញ្ញាណ បានដល់ការដឹងច្បាស់ដោយប្រាជ្ញាជាគ្រឿងរំពឹងនឹក (ពិចារណា) ។

៤- អរិយមគ្គ ដែលជាហេតុនៃអរិយផល ដែលមានព្រះនិព្វានជាអារម្មណ៍ ទើបបាននាម "សន្ទិដ្ឋិកោ" (មិនមែនអរិយមគ្គមានអង្គ ៨ ជាលោកិយឡើយ) ។

# សេចក្តីអធិប្បាយ

សេចក្តីថា ព្រះអរិយមគ្គបាននាមថា "សន្ទិដ្ឋិកោ" ព្រោះថា ព្រះអរិយ-បុគ្គលដែលបានកម្ចាត់បង់នូវរាគាទិកិលេស ក្នុងសន្តានរបស់ខ្លួនដាច់ស្រឡះ ហើយរមែងបានឃើញច្បាស់នូវអរិយមគ្គជាក់ខ្លួនឯង ហេតុនោះព្រះអរិយ-មគ្គនេះក៏បាននាមថា "សន្ទិដ្ឋិកោ" (ជាធម៌គឺព្រះអរិយបុគ្គលគប្បីឃើញជាក់ខ្លួនឯង) សមដូចជាពុទ្ធភាសិតដែលទ្រង់ត្រាស់ទុកមានដើមថា ម្នាលព្រាហ្មណ៍ បុគ្គលដែលមានសេចក្តីតម្រេក, ដែលរាគៈ[១] គ្របសង្កត់ហើយ, ដែលរាគៈញាំញីហើយ រមែងគិតដើម្បីបៀតបៀនខ្លួនខ្លះ, បៀតបៀនអ្នកដទៃខ្លះ, បៀតបៀនខ្លួននិងអ្នកដទៃខ្លះ ហើយរមែងសោយទុក្ខទោមនស្សតាមផ្លូវចិត្ត ។

ឯបុគ្គលដែលលះបង់រាគៈហើយ រមែងលែងគិតដើម្បីបៀតបៀនខ្លួនខ្លះ លែងគិតដើម្បីបៀតបៀនអ្នកដទៃខ្លះ, លែងគិតដើម្បីបៀតបៀនខ្លួននិងអ្នកដទៃខ្លះ ហើយរមែងលែងសោយទុក្ខទោមនស្សតាមផ្លូវចិត្ត ។ ម្នាលព្រាហ្មណ៍ ធម៌ដែលមាននាមថា "សន្ទិដ្ឋិកោ" មានដោយប្រការដូច្នេះឯង ។ ម៉្យាងទៀត លោកុត្តរធម៌បាននាមថា "សន្ទិដ្ឋិកោ" ព្រោះថាលោកុត្តរធម៌ទាំង ៩ ប្រការដែលព្រះអរិយបុគ្គលអង្គណាបានលុះហើយ អាចលះបង់បាននូវការជឿដោយសារបុគ្គលដទៃនិងគប្បីបានឃើញ (បានដឹង) ជាក់ខ្លួនឯងដោយបច្ចវេក្ខណញ្ញាណ ។

---

១ ទោសៈ និងមោហៈក៏មានសេចក្តីអធិប្បាយដូចរាគៈនេះដែរ ។

ន័យមួយទៀតថា អរិយមគ្គដែលបាននាមថា "សន្ទិដ្ឋិកោ" ព្រោះឈ្នះកិលេសបានដោយសន្ទិដ្ឋិ គឺសេចក្ដីយល់ត្រូវ ជាទិដ្ឋិដែលបណ្ឌិតតែងសរសើរ ។

ពិតដូច្នោះមែន អរិយមគ្គរមែងឈ្នះបាននូវកិលេសទាំងឡាយដោយសន្ទិដ្ឋិ (សេចក្ដីយល់ត្រូវ) ដែលជាវិស័យនៃព្រះនិព្វាន (មានព្រះនិព្វានជាអារម្មណ៍) ដែលជាហេតុនៃអរិយផល (ទិដ្ឋិជាហេតុឲ្យកើតអរិយផល) ដែលជាទិដ្ឋិសម្បយុត្តដោយអរិយមគ្គ ហេតុនោះបានជាលោកុត្តរធម៌ទាំង ៩ ប្រការ ក៏បាននាមថា "សន្ទិដ្ឋិកោ" ព្រោះឈ្នះកិលេសបានដោយការយល់ត្រូវ (សន្ទិដ្ឋិ) ប្រៀបដូចជា នាយសារថីឈ្នះសេវ៉ប៊ុនប្រសប់ក្នុងវិធីបរ លោកហៅហារឲ្យឈ្មោះថា "រថិកោ" អ្នកឈ្នះដោយរថ ។

ន័យមួយទៀតថា អរិយមគ្គបាននាមថា "សន្ទិដ្ឋិកោ" ព្រោះគួរដល់ការឃើញ ។ សេចក្ដីថា លោកុត្តរធម៌ (ទាំង ៩ ប្រការ) កាលបើបុគ្គលបានឃើញដោយអំណាចនៃការត្រាស់ដឹងដោយភាវនា និងដោយកិរិយាធ្វើឲ្យជាក់ច្បាស់ហើយ រមែងញ៉ាំងវដ្តភ័យ ឲ្យឃ្លាតចេញបាន (អាចរួចចេញ ចាកភ័យក្នុងវដ្តបាន) ព្រោះហេតុនោះ លោកុត្តរធម៌ទើបបាននាមថា "សន្ទិដ្ឋិកោ" (គួរដល់ការឃើញ) ប្រៀបដូចជាមន្ត្រីដែលស្លៀកសំពត់សម លោកហៅហារឲ្យឈ្មោះថា "វត្ថិកោ" (អ្នកគួរដល់សំពត់) ព្រោះស្លៀកសំពត់សម ។

## ៣) វិនិច្ឆ័យបទថា "អកាលិកោ"

### ពាក្យសួរដែលគួរចាំ

*១- អកាលិកធម៌ ប្រែថា ដូចម្ដេច បានដល់អ្វី?*

*២- កាលិកធម៌ ប្រែថា ដូចម្ដេច បានដល់អ្វី?*

*៣- ធម៌ទាំង ២ យ៉ាងនេះ ហេតុអ្វីទើបឲ្យផលផ្សេងគ្នា?*

### សេចក្ដីឆ្លើយ

*១- អកាលិកធម៌ ប្រែថា ធម៌ឲ្យផលមិនមានរវេង់ចាំកាល, បានដល់លោកុត្តរធម៌ ។*

*២- កាលិកធម៌ ប្រែថា ធម៌ឲ្យផលមានរវេង់ចាំកាល បានដល់លោកិយធម៌ ។*

*៣- ធម៌ទាំង ២ យ៉ាងនេះបានជាឲ្យផលផ្សេងគ្នា ព្រោះលោកុត្តរធម៌ឲ្យផលខាងផ្លូវចិត្ត, លោកិយធម៌ឲ្យផលក្រៅអំពីផ្លូវចិត្ត ។*

### សេចក្ដីអធិប្បាយ

*ធម៌ដែលបាននាមថា "អកាលិកោ" នេះឯង ជាឈ្មោះលោកុត្តរធម៌ បានដល់មគ្គ ៤, ផល ៤, អាចឲ្យផលភ្លាមៗតាមលំដាប់នៃខណៈចិត្ត ឥតមានរវេង់ចាំកាលវេលាឡើយ គឺថា សោតាបត្តិមគ្គកើតឡើងហើយ សោតាបត្តិផលក៏កើតឡើងភ្លាម, សកទាគាមិមគ្គកើតឡើងហើយ សកទាគាមិផលក៏កើតឡើងភ្លាម, អនាគាមិមគ្គកើតឡើងហើយ អនាគាមិ-*

ផលក៏កើតឡើងភ្លាម, អរហត្តមគ្គកើតឡើងហើយ អរហត្តផលក៏កើតឡើងភ្លាម, ប្រៀបដូចជាអណ្ដាតភ្លើងនិងពន្លឺភ្លើង, ធម្មតាភ្លើងកាលបើមានអណ្ដាតឆេះឆ្វោឡើងហើយ ក៏មានពន្លឺភ្លឺឡើងភ្លាមតាមលំដាប់គ្នា, ពុំនោះសោតប្រៀបដូចជាខ្យល់ដែលបក់មកប៉ះពាល់ត្រូវរាងកាយ, ខ្យល់ដែលបក់ត្រសៀកៗរំភើយៗមកនោះ លុះប៉ះត្រូវរាងកាយកាលណាហើយក៏មានត្រជាក់កើតឡើងភ្លាមវេលានោះ, ឯមគ្គនិងផលក៏កើតឡើងភ្លាមៗតាមលំដាប់គ្នាដូចភ្លើងនិងពន្លឺឬខ្យល់និងត្រជាក់ដូច្នោះដែរ ។

ចំណែកលោកិយធម៌ បាននាមថា “កាលិកោ” ព្រោះថាជាធម៌ឥវរង់ចាំកាល ដែលត្រូវឲ្យផល ទើបឲ្យផលបាន, មិនមែនឲ្យផលភ្លាមៗតាមខណៈចិត្តឡើយ, ក៏ដូចយ៉ាងកម្មដែលឲ្យផលផ្សេងគ្នាតាមកាល ៣ យ៉ាង[១] មាន

១ កម្ម ៣ យ៉ាងគឺទិដ្ឋធម្មវេទនីយកម្ម ១, ឧបបជ្ជវេទនីយកម្ម ១, អបរាបរវេទនីយកម្ម ១ ។ កម្មទាំង ៣ យ៉ាងនេះ ដែលនឹងឲ្យផលផ្សេងគ្នា ព្រោះអាស្រ័យចេតនាដែលកើតឡើងក្នុងវេលាធ្វើកុសលរហ័សនិងយឺតយូរជាងគ្នាដូច្នេះ បើបឋមជវនចេតនា កើតឡើងហើយ ជាប់ស្រេចត្រឹមប៉ុណ្ណោះទៅបាត់ជាទិដ្ឋធម្មវេទនីយកម្ម ឲ្យផលក្នុងជាតិជាបច្ចុប្បន្ន ។ បើជវនចេតនា កើតឡើងដល់ទី ៧ ទើបជាប់ស្រេច បាត់ជាឧបបជ្ជវេទនីយកម្ម ឲ្យផលក្នុងជាតិបន្ទាប់ ។ ចំណែកជវនចេតនាទាំង ៥ គឺទី ២-៣-៤-៥-៦ ណាមួយ កើតហើយជាប់ស្រេចត្រឹមទីនោះៗទៅ បាត់ជាអបរាបរវេទនីយកម្ម ឲ្យផលមិនមានកំណត់ស្រេចតែនឹងបានឱកាសក្នុងកាលណា ក៏ឲ្យផលក្នុងកាលនោះ រាប់អំពីជាតិទី ៣ រៀងទៅ ។ កម្មទាំង ៣ យ៉ាងនេះកម្មទី ១-២ បើខានឲ្យផលតាមកំណត់កាលរបស់ខ្លួន ដោយអំណាចកម្មណាមួយចូលទៅកាត់នឹងក្លាយទៅជាអហោសិកម្មលែងឲ្យផលសោះ ។ ឯកម្មទី ៣ មិនដែលក្លាយទៅជាអហោសិកម្មឡើយ ព្រោះជាកម្មឲ្យផលគ្មានកំណត់កាល ស្រេចហើយតែឱកាសបើកឲ្យ ។ កម្មទាំង ៣ យ៉ាងនេះប្រព្រឹត្តទៅបានទាំងកុសលនិងអកុសល ។

ទិដ្ឋធម្មវេទនីយកម្មជាដើម, កម្មខ្លះឲ្យផលជាក់ស្តែងក្នុងជាតិជាបច្ចុប្បន្ន កម្មខ្លះឲ្យផលក្នុងជាតិជាលំដាប់គឺជាតិទី ២ កម្មខ្លះឲ្យផលក្នុងជាតិណាមួយជាបន្ទាប់ៗ តទៅទៀត រាប់អំពីជាតិទី ៣ រៀងទៅដល់អនេកជាតិ ។

កម្មទាំងនោះ បើមិនទាន់ដល់ពេលត្រូវឲ្យផលនៅឡើយ ទោះបីបុគ្គលបន់ស្រន់បួងសួងយ៉ាងណា ក៏ពុំសម្រេចសេចក្តីប្រាថ្នាបាន ប្រៀបដូចជាផលានុផលនៃរុក្ខជាតិនានា កាលបើពុំទាន់ដល់រដូវត្រូវចេញផ្លែផ្កា ទោះបីបុគ្គលខំនាំគ្នាដាក់ជី ស្រោចទឹកដោកដាំយ៉ាងណា ក៏ពុំអាចញ៉ាំងព្រឹក្សទាំងនោះឲ្យផ្លែផ្កាភ្លាមៗបាន យ៉ាងណាមិញ ឯលោកិយធម៌ក៏ដូច្នោះដែរ ។

ចំណែកលោកុត្តរធម៌ពុំដូច្នោះឡើយ, តែងឲ្យផលភ្លាមៗ តាមលំដាប់គ្នាអំពីមគ្គនោះៗ ហេតុនោះហើយ ទើបបាននាមថា "អកាលិកោ" ។

## (៤) វិនិច្ឆ័យបទថា "ឯហិបស្សិកោ"

## ពាក្យសួរដែលគួរបាំ

*១- ព្រះធម៌ឥតរូបរាងទេ តើគេអាចឃើញបានដោយអ្វី?*

*២- ព្រះធម៌អាស្រ័យហេតុអ្វីទើបថាគួរហៅអ្នកដទៃឲ្យចូលមកមើល?*

*៣- លោកិយធម៌ក៏ជាធម៌ល្អដែរ, ជាធម៌មាននៅពិតមែនដែរ ហេតុអ្វីក៏មិនរាប់ថាជា "ឯហិបស្សិកោ"?*

## សេចក្ដីឆ្លើយ

*១-ព្រះធម៌ឥតរូបរាងក៏ពិតមែន តែគេអាចឃើញបានដោយបញ្ញាចក្ខុ ។*

*២- ព្រះធម៌នេះអាស្រ័យហេតុដែលមានមែនពិតប្រាកដ ១, ជាសភាពបរិសុទ្ធ ១ ទើបគួរហៅអ្នកដទៃឲ្យចូលមកមើល ។*

*៣- លោកិយធម៌បានជាមិនបាននាមថា "ឯហិបស្សិកោ" ព្រោះជាសាសវធម៌[១] ។*

## សេចក្ដីអធិប្បាយ

*លោកុត្តរធម៌ដែលបាននាមថា "ឯហិបស្សិកោ" ជាធម៌គួរហៅអ្នកដទៃឲ្យចូលមកមើលនោះ ព្រោះជាធម៌មាននៅពិតប្រាកដផង, ជាធម៌បរិសុទ្ធផង, បើជាធម៌មិនមាននៅពិតប្រាកដទេ ឬមាននៅដែរ តែជាសភាពពុំល្អបរិសុទ្ធទេ ក៏ពុំគួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលដែរ ។*

---

១ ធម៌ដែលប្រកបដោយអាសវកិលេស ។

ដូចយ៉ាងបុគ្គលក្ដាប់ដៃទទេ (ឥតមានរតនវត្ថុណាមួយមានមាសប្រាក់ជាដើមនៅក្នុងក្ដាប់ដៃនោះសោះ) ក៏ពុំគួរស្រែកហៅបុគ្គលដទៃឲ្យចូលមកមើល "ថាអ្នកចូលមកមើលរតនវត្ថុក្នុងដៃនេះ" ដូច្នេះឡើយ ព្រោះហេតុអ្វី ព្រោះថាជារបស់មិនមានពិតប្រាកដ, ពុំនោះសោត ជារបស់មាននៅមែនដែរ តែជាវត្ថុពុំល្អបរិសុទ្ធ ដូចយ៉ាងទឹកមូត្របុដុំគូថ[1] ជាដើម ដែលជាវត្ថុបិទបាំងនៅក្នុងចំបើង ឬស្មៅ សំរាម ក៏ពុំគួរនឹងហៅអ្នកដទៃឲ្យចូលមកមើល, ព្រោះហេតុអ្វី? ព្រោះថាជារបស់ពុំល្អ ពុំជាទីគាប់ចិត្តនៃអ្នកដទៃ ។

ឯលោកុត្តរធម៌ទាំង ៩ ប្រការ ដែលបាននាមថា "ឯហិបស្សិកោ" នេះ ពុំដូច្នោះឡើយ ជាសភាពគួរហៅអ្នកដទៃឲ្យចូលមកមើល ព្រោះជាសភាពមាននៅពិតមែននិងជាសភាពល្អបរិសុទ្ធ (ប្រាសចាកមន្ទិលគឺកិលេស) ប្រៀបដូចជាព្រះចន្ទ្រពេញវង់អណ្ដែតត្រឡប់កណ្ដាលអាកាស ដែលស្រឡះចាកពពក គួរជាទីរីករាយនៃសត្តនិករ, ពុំនោះសោត គណនាដូចជាកែវមណីមានជាតិសុទ្ធ (ដែលជាងកែវឆ្នៃរំលេចជាជ្រុង) ហើយតម្កល់ទុកលើសំពត់កម្ពលមានពណ៌លឿង រមែងជាទីប្រាថ្នានៃជនានុជនផងទាំងឡាយ, រតនវត្ថុនេះឯង ទើបគួរដង្ហោយហៅអ្នកដទៃឲ្យចូលមកមើល ព្រោះហេតុ

---

១ ដុំគូថគឺលាមកដែលបន្ទោរបង់ចេញពីខ្លួន ។

អ្វី? ព្រោះថាជាវត្ថុមានពិតប្រាកដមែនផង, ជាវត្ថុល្អបរិសុទ្ធផង ។

ហេតុនោះហើយ លោកុត្តរធម៌ទើបបាននាមថា "ឯហិបស្សិកោ" ជាធម៌គួរហៅអ្នកដទៃឲ្យចូលមកមើល គឺថាហាក់ដូចជានឹងហៅយោគាវចរបុគ្គលដែលបម្រុងនឹងបានធម៌នោះ ថា "អ្នកចូលមកមើល" ។

## (៥) វិនិច្ឆ័យបទថា "ឱបនយិកោ"

### ពាក្យសួរដែលគួរចាំ

*១- លោកុត្តរសង្ខតធម៌ ប្រែថាដូចម្ដេច បានដល់អ្វី?*

*២- លោកុត្តរអសង្ខតធម៌ ប្រែថាដូចម្ដេច បានដល់អ្វី?*

*៣- លោកុត្តរធម៌ទាំងនេះ គួរបង្អោនចូលមកផ្សេងគ្នាយ៉ាងណា?*

### សេចក្ដីឆ្លើយ

*១- លោកុត្តរសង្ខតធម៌ ប្រែថាលោកុត្តរធម៌នៅមានបច្ច័យតាក់តែង បានដល់អរិយមគ្គ ៤, អរិយផល ៣ ខាងដើម[១] ។*

*២- លោកុត្តរអសង្ខតធម៌ ប្រែថា លោកុត្តរធម៌មិនមានបច្ច័យតាក់-តែងបានដល់អរហត្តផលនិងនិព្វាន ។*

*៣- លោកុត្តរសង្ខតធម៌ គួរបង្អោនចូលមកដោយភាវនា លោកុត្តរ-អសង្ខតធម៌ គួរបង្អោនចូលមកដោយចិត្ត ។*

### សេចក្ដីអធិប្បាយ

*លោកុត្តរធម៌ដែលបាននាមថា "ឱបនយិកោ" លោកចែកចេញ*

---

១ មានន័យខ្លះថា មគ្គ ៤ ផល ៤ ចាត់ជាសង្ខតធម៌ និព្វានទើបចាត់ជាអសង្ខតធម៌, បើរាប់គួបយកអរហត្តផល ជាសង្ខតធម៌ផង ដូច្នោះមិនទំនាស់នឹងន័យខ្លះដែលចាត់យកអរហត្ត-ផលជាគូអនុបាទិសេសនិព្វានទៅហើយ ។ បំណែកលោកិយធម៌ទាំងអស់ទោះជាកុសលក្ដី, អកុសលក្ដី រួមហៅថា សង្ខតធម៌ដូចគ្នា ព្រោះជាសភាពលុះក្នុងអំណាចហេតុបច្ច័យ ។

ជា ២ យ៉ាងគឺលោកុត្តរធម៌ដែលនៅមានហេតុបច្ច័យ ហៅថា លោកុត្តរ-សង្ខតធម៌ ១, លោកុត្តរធម៌ដែលផុតអំណាចហេតុបច្ច័យតាក់តែងបាន ហៅថា លោកុត្តរអសង្ខតធម៌ ១ ។

លោកុត្តរធម៌ដែលមានហេតុបច្ច័យ អាស្រ័យការចម្រើន (ភាវនា) ទើបបង្អោនចូលមកទុកក្នុងចិត្តបាន ដូចជាបុគ្គលដែលកំពុងស្តាប់ធម៌ទេសនា ខំប្រុងសម្រឹងផ្ចៀងផ្ចាត់បង្អោនយកធម៌ដែលលោកសម្តែងយកមកទុកក្នុងចិត្តរបស់ខ្លួន ។ ពុំនោះសោតដូចព្រះយោគាវចរចម្រើនកសិណ ខំបរិកម្មសម្លឹងយកតួកសិណបង្អោនចូលមកទុកក្នុងចិត្តរបស់ខ្លួន ។

ឯលោកុត្តរធម៌ដែលឥតបច្ច័យ ពុំបាច់ចាំអាស្រ័យការចម្រើន (ភាវនា) ទើបបង្អោនចូលមកទុកក្នុងខ្លួនបានដូច្នោះឡើយ, ព្រះធម៌នេះព្រះអរិយ-បុគ្គលអាចបង្អោនចូលមកបានផ្ទាល់ចិត្តរបស់ខ្លួនតែម្តង ព្រោះជាធម៌ឱនទន់ទោរមកឯង ជ្រួតជ្រាបប៉ះពាល់ដល់ចិត្តឯង ក្នុងទីបំផុតដែលលោកផុតកិច្ចគួរធ្វើ (កតំ ករណីយំ) ។ ប្រៀបដូចបុគ្គលដែលរៀនវិជ្ជា កាលកំពុងរៀន ខំប្រុងស្មារតីបង្អោនយកវិជ្ជាដែលមិនទាន់ចេះចាំឲ្យចូលមកក្នុងចិត្តដោយការស្វាធ្យាយ (ទន្ទេញ), លុះបានចេះដឹងស្ទាត់ជំនាញចិត្ត ឈ្មោះថាបានផ្តិតជាប់នូវវិជ្ជា, ឈ្មោះថាស្រូបយកបាននូវវិជ្ជា ឬឈ្មោះថាចិត្តជោកដោយវិជ្ជា, ឈ្មោះថាបង្អោនវិជ្ជាចូលមកផ្ទាល់ចិត្តបាន ព្រោះថាវិជ្ជា (ការចេះដឹង) ដក់ជាប់នៅបានអាស្រ័យចិត្ត, ត្រង់ដែលខំបង្អោនវិជ្ជា

ចូលមកដោយការស្វាធ្យាយ ដូចលោកុត្តរសទ្ធតធម៌ដែលបង្អោនមកបាន ដោយភាវនា, ត្រង់បានចេះដឹងហើយ ឈ្មោះថាចិត្តផ្ចិតជាប់នូវវិជ្ជា, វិជ្ជាដែលដក់ជាប់នៅបានអាស្រ័យចិត្ត ដូចលោកុត្តរអសទ្ធតធម៌ដែល បង្អោនមកបានផ្ទាល់ចិត្ត ។

## (៦) វិនិច្ឆ័យបទថា "បច្ចត្តំ វេទិតព្វោ វិញ្ញូហិ"

## ពាក្យសួរដែលគួរចាំ

១- វិញ្ញូជន មានប៉ុន្មានពួក? គឺអ្វីខ្លះ?

២- ធម៌ដែលពួកវិញ្ញូជនគប្បីត្រាស់ដឹងចំពោះខ្លួន បានដល់ធម៌អ្វី?

៣- បរិយត្តិធម៌ កាលបើអ្នកណារៀននឹងបានចេះដឹងចំពោះខ្លួនៗដែរ ហេតុអ្វីទើបលោកមិនរាប់បញ្ចូលក្នុងលោកុត្តរធម៌ពួកនេះផង?

## សេចក្តីឆ្លើយ

១- វិញ្ញូជន មាន ៣ ពួកគឺ ឧគ្ឃដិតញ្ញូ ១, វិបចិ្ចតញ្ញូ ១, នេយ្យៈ ១ ។

២- ធម៌ដែលវិញ្ញូជនគប្បីត្រាស់ដឹងចំពោះខ្លួនបានដល់លោកុត្តរធម៌ ។

៣- បរិយត្តិធម៌, គេអាចរៀនចេះដឹងបានដូច្នោះមែន តែគេអាចរំលែកចែកគ្នាដោយការបង្រៀនបានខ្លះ, ឯលោកុត្តរធម៌ពុំដូច្នោះឡើយលុះតែសាមីរូបរំពឹងរាវរកផ្ទាល់ខ្លួន ទើបអាចត្រាស់ដឹងបាន ។

## សេចក្តីអធិប្បាយ

វិញ្ញូជនទាំងឡាយគ្រប់ពួក ទោះជាឧគ្ឃដិតញ្ញូបុគ្គលក្តី, វិបចិ្ចតញ្ញូបុគ្គលក្តី, នេយ្យបុគ្គលក្តី, កាលបើបានចម្រើនមគ្គហើយ, បានលុះផលហើយ បានធ្វើឲ្យជាក់ច្បាស់នូវនិរោធ (និព្វាន) ហើយ រមែងដឹងច្បាស់ចំពោះ

តែក្នុងចិត្តរបស់ខ្លួនឯងថា "មគ្គអញបានចម្រើនហើយ ផលអញបានលុះហើយ, និរោធអញបានធ្វើឲ្យជាក់ច្បាស់ហើយ", នឹងអាចចែករំលែកនូវគុណវិសេសនោះៗដល់អ្នកដទៃផងពុំបាន, ចំណែកបរមត្ថសុខដែលកើតអំពីគុណវិសេសនោះៗ សោតទៀតក៏បានចំពោះតែខ្លួនម្នាក់ៗ នឹងចែករំលែកឲ្យអ្នកដទៃផងពុំកើត ដូចយ៉ាងមគ្គដែលឧបជ្ឈាយ៍បានចម្រើនហើយ នឹងអាចជួយលះកិលេសរបស់សទ្ធិវិហារិកផងពុំបាន, ឯសទ្ធិវិហារិកវិញ សោតនឹងបានសោយបរមត្ថសុខដោយសារផលសមាបត្តិ របស់ឧបជ្ឈាយ៍ផងក៏ទេ គឺបើលោកអង្គណាបានសម្រេចគុណវិសេសហើយ, លោកអង្គនោះនឹងបានសោយសុខចំពោះខ្លួនៗមិនសាធារណៈ ដល់អ្នកដទៃផងឡើយ ។ សមដូចន័យដែលលោកពន្យល់ទុកថា ព្រះធម៌នេះ វិញ្ញូជនមិនមែនឃើញបានសាធារណៈ ដូចជាវត្ថុសម្រាប់ឃើញបានច្រើនគ្នា យ៉ាងគ្រឿងបំពាក់សីសៈអ្នកដទៃ (មានមកុដ) ជាដើមនោះទេ, ព្រះធម៌គឺវិញ្ញូជនតែងបានឃើញ, បានសោយ តែក្នុងចិត្តរបស់ខ្លួនម្នាក់ៗ ប៉ុណ្ណោះ ហេតុនោះ ព្រះធម៌នេះឯង ទើបបាននាមថា "បច្ចត្តំ វេទិតព្វោ វិញ្ញូហិ" ។

## ព្រះធម្មគុណទាក់ទងគ្នា

ព្រះធម្មគុណនេះមិនមែនជាវិស័យនៃជនពាលឡើយ, ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើមទ្រង់ត្រាស់ដឹងល្អហើយ, ព្រោះហេតុអ្វី? ព្រោះថាជាធម៌គឺអ្នកប្រាជ្ញគប្បីឃើញ, ហេតុអ្វី ព្រះធម៌

នេះទើបឈ្មោះថា ជាធម៌គឺអ្នកប្រាជ្ញគប្បីឃើញ? ព្រោះថាឲ្យផលមិនរេរង់ចាំកាល, ហេតុអ្វីព្រះធម៌នេះទើបឲ្យផលមិនរេរង់ចាំកាល? ព្រោះជាធម៌គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន, ហេតុអ្វីព្រះធម៌នេះទើបគួរហៅអ្នកដទៃឲ្យចូលមកមើលបាន? ព្រោះជាធម៌គួរបង្អោនចូលមកទុកក្នុងខ្លួន ។

ព្រះធម្មគុណទាំង ៦ ព្រះនាមនេះ ទាក់ទងគ្នាតាមលំដាប់ហូរហែយ៉ាងនេះឯង ។

## ពាក្យប្រេដ្ឋាខ្លួន(១)

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ**

ប្រែថា វត្ថុដទៃជាទីពឹងទីរឭក នៃខ្ញុំព្រះករុណាមិនមានឡើយ មានតែព្រះធម៌ជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា, សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា, ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

---

១ ពាក្យប្រេដ្ឋាខ្លួននេះ ខ្ញុំមិនបាច់លើកគ្រោងឡើងវិនិច្ឆ័យទេ ព្រោះមានសេចក្តីប្រហែលៗគ្នានឹងពាក្យប្រេដ្ឋាខ្លួនក្នុងពុទ្ធរតនវិនិច្ឆ័យដែរ ។

## វិធិប្ប័យបទខមាទោស

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ**

**ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ**

*ប្រែថា ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរមាន ២ ប្រការគឺ ព្រះបរិយត្តិធម៌ និងព្រះនពលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តមគឺត្បូង, ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះធម៌ជាម្ចាស់, សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។*

### សេចក្ដីសួរដែលគួរចាំ

*១- ប្រព្រឹត្តដូចម្ដេច ទើបឈ្មោះថាប្រព្រឹត្តល្មើសក្នុងព្រះធម៌?*

*២- សេចក្ដីល្មើសក្នុងព្រះធម៌បែបណា ដែលរួចចាកទោសបានដោយវិធីសូមខមាទោស?*

*៣- ព្រះធម៌ជាសភាពឥតរូប បើយើងប្រព្រឹត្តល្មើសហើយ ត្រូវសូមខមាទោសនឹងអ្វី?*

### សេចក្ដីឆ្លើយ

*១- ការប្រព្រឹត្តអគារវកិរិយា ក្នុងទីសម្ដែងធម៌, ស្ដាប់ធម៌, រៀនធម៌ជាដើម ឈ្មោះថា ប្រព្រឹត្តល្មើសក្នុងព្រះធម៌ ។*

*២- សេចក្ដីល្មើសក្នុងព្រះធម៌របស់បុគ្គលដែលស្ដាប់ធម៌បាំងឆត្រនៅដៃជាដើម ទើបរួចចាកទោសបាន ដោយវិធីសូមខមាទោស ។*

៣- ត្រូវសូមខមាទោសនឹងលោកដែលជាពហុស្សុតអ្នកទ្រទ្រង់ធម៌ ឬនឹងព្រះភិក្ខុសង្ឃគង់រួចទោសបាន ។

សេចក្ដីអធិប្បាយ

អគារវកិរិយា ការសម្ដែងសេចក្ដីមិនគោរពដោយកាយ, ដោយវាចា ឬក៏ដោយចិត្ត ក្នុងកាលដែលធម្មកថិកកំពុងសម្ដែងធម៌, ក្នុងកាលដែលបរិស័ទកំពុងស្ដាប់ធម៌, សន្ទនាធម៌, ស្វាធ្យាយធម៌, ចម្រើនធម៌ហៅថា សេចក្ដីមិនគោរពក្នុងព្រះធម៌ ។ ដូចយ៉ាងអគារវបុគ្គល ដែលមានមកក្នុងបាតិមោក្ខត្រង់សេក្ខិយវត្ត ធម្មទេសនាប្បដិសំយុត្ត ១៦ ពួកគឺ បុគ្គលមានឆត្រក្នុងដៃ១, បុគ្គលមានឈើប្រត់ក្នុងដៃ១, បុគ្គលមានគ្រឿងសាស្ត្រាក្នុងដៃ១, បុគ្គលមានអាវុធក្នុងដៃ១, បុគ្គលពាក់ស្បែកជើងឈើ ស្បែកជើងស្មៅជាដើម១, បុគ្គលពាក់ស្បែកជើងស្បែក១, បុគ្គលនៅលើយានមានរថជាដើម១, បុគ្គលនៅលើដំណេកគឺបុគ្គលដេក១, បុគ្គលអង្គុយត្របោមក្បាលជង្គង់១, បុគ្គលជួតក្បាល១, បុគ្គលទទូរក្បាល១, បុគ្គលអង្គុយលើអាសនៈភិក្ខុជាធម្មកថិកអង្គុយផ្ទាល់ផែនដី១, បុគ្គលដែលអង្គុយលើអាសនៈខ្ពស់ជាងភិក្ខុអ្នកសម្ដែងធម៌១, បុគ្គលអង្គុយហើយភិក្ខុអ្នកសម្ដែងធម៌ឈរ១, បុគ្គលដើរខាងមុខភិក្ខុអ្នកសម្ដែងធម៌១, បុគ្គលដើរក្នុងផ្លូវភិក្ខុអ្នកសម្ដែងធម៌ដើរក្រៅផ្លូវ១ ។

បុគ្គលដែលមិនមានជំងឺហើយសម្ដែងអគារវៈមិនគោរព ១៦ ពួកនេះ

ឈ្មោះថាមិនគោរពក្នុងព្រះធម៌, ព្រះបរមគ្រូទ្រង់ត្រាស់បញ្ញត្តមិនឲ្យភិក្ខុសម្ដែងធម៌ឲ្យស្ដាប់ទេ ព្រោះបុគ្គលទាំងនេះមិនគួរជាភាជនៈសម្រាប់ទទួលនូវព្រះធម៌ ។

## ផលនៃការបម្រើនធម្មានុស្សតិ

កាលបើព្រះយោគីបានរំពឹងនឹកដល់គុណព្រះធម៌ទាំង ៦ ប្រការណាមួយមាន "ស្វាក្ខាតោ" ជាដើមយ៉ាងនេះហើយ, ក្នុងសម័យនោះឯងចិត្តរបស់លោកនឹងស្ងប់ស្ងៀម មិនច្របូកច្របល់ដោយរាគាទិកិលេស, ជាចិត្តស្លុងប្រាវព្ធចំពោះគុណនៃព្រះធម៌តែម្យ៉ាង ។ កាលបើចិត្តស្លុងយ៉ាងនេះហើយ អង្គឈានទាំងឡាយនឹងកើតប្រាកដដល់លោក ក្នុងកាលដែលលោកសង្កត់សង្កិននីវរណធម៌បានហើយ, តែព្រោះហេតុដែលគុណនៃព្រះធម៌ជាសភាពជ្រាលជ្រៅពេក ទើបព្រះយោគីមិនអាចបានដល់នូវអប្បនាឈាន បានត្រឹមតែឧបចារជ្ឈានប៉ុណ្ណោះ ។ ឈាននេះឯងលោកឲ្យឈ្មោះថា "ធម្មានុស្សតិជ្ឈាន" ព្រោះកើតឡើងដោយការរឭកនូវព្រះធម្មគុណ ។

ឯព្រះយោគីអ្នកប្រកបរឿយៗនូវធម្មានុស្សតិនេះ នឹងបានដល់នូវភាពជាអ្នកមានសេចក្ដីគោរពកោតក្រែងចំពោះព្រះសាស្ដា ដោយហេតុដែលរឭកឃើញនូវគុណនៃព្រះធម៌យ៉ាងនេះថា "ក្នុងកាលដែលកន្លងទៅហើយ យើងមិនធ្លាប់បានឃើញនូវព្រះសាស្ដាដែលប្រកបដោយគុណបែបនេះ ព្រះអង្គទ្រង់សម្ដែងនូវធម៌គួរបង្អោនចូលមកក្នុងខ្លួនយ៉ាងនេះ,

ឥឡូវនេះយើងបានឃើញជាក់ថា ឥតមានអ្នកណាមួយគួរជាសាស្តាដ៏ឧត្តមក្រៃលែងជាងព្រះមានព្រះភាគអង្គនេះឡើយ" ហើយរមែងបានជាអ្នកមានសេចក្តីគោរពកោតក្រែងចំពោះព្រះធម៌ រមែងបាននូវភាពជាអ្នកបរិបូណ៌ដោយគុណមានសទ្ធាជាដើម នឹងជាអ្នកបរិបូណ៌ដោយបីតិនិងប្រមោជ្យ អាចកម្ចាត់នូវភ័យគួរខ្លាចបាន, អាចអត់ធន់នូវសេចក្តីទុក្ខបាន, ហើយរមែងបាននូវសញ្ញាថាជាអ្នកបាននៅរួមដោយព្រះធម៌ ។

ឯសរីរៈរបស់លោក ដែលអប់រំជាប់ស៊ប់សួនដោយធម្មានុស្សតិយ៉ាងនេះនឹងបានជាវត្ថុគួរដល់គ្រឿងបូជា នៃជនានុជន ដូចជាគ្រោងចេតិយ៍ដែលតម្កល់ព្រះសារីរិកធាតុ ឬគម្ពីរធម៌វិន័យព្រះពុទ្ធសាសនា, រមែងគួរជាទីបូជានៃទេវតានិងមនុស្សទាំងឡាយ ហើយចិត្តរបស់លោករមែងតែទន់ទោរទៅរកការត្រាស់ដឹងនូវគុណធម៌ដ៏ខ្ពង់ខ្ពស់ជានិច្ច ។

កាលបើលោកឧស្សាហ៍នឹកដល់ព្រះធម៌ដោយភាពជាធម៌ល្អយ៉ាងនេះហើយ ហិរិនិងឱត្តប្បៈ រមែងកើតមានឡើងប្រាកដ ក្នុងខណៈដែលបានប្រទះហេតុដែលខ្លួនបម្រុងនឹងប្រព្រឹត្តកន្លង ហើយនឹងប្រែខ្វៅជាខានប្រព្រឹត្តកន្លងទៅវិញ, បើទុកជាលោកនៅមិនទាន់បានសម្រេចគុណវិសេសណាមួយនៅឡើយទេ ក៏គង់មានសុគតិប្រព្រឹត្តទៅក្នុងខាងមុខពុំខាន ។

ហេតុនេះ អ្នកមានប្រាជ្ញាទាំងឡាយ គួរកុំប្រហែសធ្វេស គួរខំចម្រើននូវគុណនៃព្រះធម៌ដែលមានមហានុភាពយ៉ាងនេះសព្វៗ កាលទៅហោង ។

# សង្ឃរតនវិនិច្ឆ័យ

## ពាក្យថា "ព្រះសង្ឃ"

*ព្រះសង្ឃជាភាគមួយនៃរតនវត្ថុហើយជាវត្ថុដ៏ប្រសើរលើសលែងរតនវត្ថុដទៃនានាក្នុងលោក ដូចមានសេចក្ដីតទៅនេះ ៖*

*ពួកជនអ្នកស្ដាប់ឱវាទានុសាសនីរបស់ព្រះមានព្រះភាគហើយ ប្រព្រឹត្តតាមពុទ្ធោវាទនោះ ហៅថា ព្រះសង្ឃ ឬព្រះសង្ឃសាវក ។*

*ពាក្យនេះមានន័យគួរញែកអធិប្បាយជា ២ បទគឺ សាវក បទ ១, សង្ឃ បទ ១ ។*

*សាវកៈ ប្រែថា ជនអ្នកស្ដាប់ពុទ្ធោវាទដោយគោរព, សំដៅយកលោកដែលប្រព្រឹត្តតាមពុទ្ធោវាទ ដរាបដល់បានតាំងខ្លួននៅក្នុងអរិយភាពថ្នាក់ណាមួយមានសោតាបន្នជាដើម ។ សាវក នេះឯងលោកចែកចេញជា ៣ ពួកគឺ អគ្គសាវក (សាវកធ្មើមឆ្វេង-ស្ដាំ) ពួក ១, មហាសាវក ឬ អសីតិសាវក (សាវកធំៗ ៨០ អង្គ មានព្រះមហាកស្សបជាដើម) ពួក ១, បកតិសាវក (សាវកប្រក្រតីគឺសាវកបន្ទាប់បន្សំរាប់តាំងអំពីព្រះសោតាបន្នបុគ្គលជាដើម) ពួក ១ ។*

*សង្ឃៈ ប្រែថា ពួក, ក្រុម, សំដៅយកលោកដែលប្រព្រឹត្តល្អត្រូវគ្នា, ចុះរបៀបគ្នា, ព្រមព្រៀងគ្នា គឺថា បុគ្គលដែលបាននាមថាសង្ឃ ទោះបីលោកនៅក្នុងទីឆ្ងាយផ្សេងៗគ្នាក្ដី កំឈ្មោះថានៅក្នុងទីជិតគ្នា,*

នៅជាមួយគ្នា, នៅរួមគ្នា ព្រោះលោកមានសីលនិងទិដ្ឋិស្មើគ្នា ។

សមដូចសារាណីយធម៌ ដែលព្រះមានជោគទ្រង់ត្រាស់សម្ដែងក្នុងសារាណីយសូត្រថា **ឆ សារាណីយា ធម្មា** ធម៌ទាំងឡាយជាទីតាំងនៃសេចក្ដីរឭកមាន ៦ ប្រការគឺ

១- ភិក្ខុក្នុងព្រះពុទ្ធសាសនានេះ ប្រកបដោយមេត្តាកាយកម្ម, តាំងទុកនូវមេត្តាកាយកម្មនោះ ចំពោះភិក្ខុជាសព្រហ្មចារីផងគ្នាទាំងចំពោះមុខទាំងកំបាំងមុខ ។

២- ភិក្ខុក្នុងព្រះពុទ្ធសាសនានេះ ប្រកបដោយមេត្តាវចីកម្ម, តាំងទុកនូវមេត្តាវចីកម្មនោះចំពោះភិក្ខុ ជាសព្រហ្មចារីផងគ្នាទាំងចំពោះមុខទាំងកំបាំងមុខ ។

៣- ភិក្ខុក្នុងព្រះពុទ្ធសាសនានេះ ប្រកបដោយមេត្តាមនោកម្ម, តាំងទុកនូវមេត្តាមនោកម្មនោះ ចំពោះភិក្ខុជាសព្រហ្មចារីផងគ្នាទាំងចំពោះមុខ, ទាំងកំបាំងមុខ ។

៤- ភិក្ខុក្នុងព្រះពុទ្ធសាសនានេះ មានលាភបានមកដោយធម៌, កើតឡើងដោយធម៌ មិនហួងហែងលាភនោះទុកដើម្បីខ្លួនម្នាក់ឯង, បែងរំលែកចែកភិក្ខុជាសព្រហ្មចារីផងគ្នា ។

៥- ភិក្ខុក្នុងព្រះពុទ្ធសាសនានេះ រក្សាសីលដោយហ្មត់ចត់មិនហ៊ានឲ្យដាច់ធ្លុះធ្លាយទាំងចំពោះមុខទាំងកំបាំងមុខ ភិក្ខុជាសព្រហ្មចារីផងគ្នា ។

៦- *ភិក្ខុតាំងនៅក្នុងអរិយទិដ្ឋិ គឺ សេចក្ដីយល់ត្រូវរបស់ព្រះអរិយៈ ទាំងចំពោះមុខ, ទាំងកំបាំងមុខភិក្ខុជាសព្រហ្មចារីផងគ្នា ។*

*ភិក្ខុដែលតាំងមាំក្នុងសារាណីយធម៌*[១] *ទាំងឡាយនេះ ឈ្មោះថា ប្រព្រឹត្ត(ខ្លួន) ឲ្យជាទីស្រឡាញ់ ជាទីគោរពនៃសព្រហ្មចារីបុគ្គលទាំងឡាយ រមែងប្រព្រឹត្តទៅដើម្បីមិនវិវាទនឹងគ្នា, ប្រព្រឹត្តទៅដើម្បីព្រមព្រៀងគ្នា, ប្រព្រឹត្តទៅដើម្បីសេចក្ដីសម្រាន្ត, ប្រព្រឹត្តទៅដើម្បីផុតចាកទុក្ខ ។*

*ន័យនេះសមដូចពាក្យដែលព្រះអនុរុទ្ធ, ព្រះនន្ទិយៈ និងព្រះកិម្ពិលៈ ក្រាបទូលព្រះមានព្រះភាគនាព្រៃបាចិនវង្សមានដើមថា, បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គព្រមព្រៀងគ្នា មូលមិត្រគ្នា, មិនវិវាទគ្នាដូចជាទឹកលាយដោយទឹកដោះ, ក្រលេកមើលគ្នានិងគ្នាដោយបិយចក្ខុ*[២] *ទៅវិញទៅមក ព្រោះខ្ញុំព្រះអង្គបានតាំងចិត្តទុកថា ការដែលខ្ញុំព្រះអង្គបាននៅរួមគ្នាប្រព្រឹត្តព្រហ្មចរិយធម៌មានសភាពដូច្នេះ ជាលាភរបស់ខ្ញុំព្រះអង្គ, ឈ្មោះថាខ្ញុំព្រះអង្គបានប្រព្រឹត្តល្អហើយ, ខ្ញុំព្រះអង្គបានតាំងកាយកម្ម, វចីកម្ម, មនោកម្មប្រកបដោយមេត្តាចំពោះលោកពីរអង្គនេះ, ទាំងចំពោះមុខទាំងកំបាំងមុខ, ខ្ញុំព្រះអង្គបានថ្នមចិត្តរបស់ខ្លួនទុកហើយប្រព្រឹត្តតាមអំណាចចិត្តរបស់លោក ២ អង្គនេះ, ពិតមែនតែកាយរបស់ខ្ញុំព្រះអង្គផ្សេងគ្នា តែចិត្តដូចគ្នា ។*

---

១- សារាណីយធម៌ ប្រែថា ធម៌ដែលបុគ្គលគប្បីរឭក ឬជាទីតាំងនៃសេចក្ដីរឭក ។

២- ការសម្លឹងមើលជាទីស្រឡាញ់, ការក្រឡេកមើលប្រកបដោយមេត្តា ។

ចំណែកព្រះនន្ទិយៈនិងព្រះកិម្ពិលៈ ក៏ក្រាបទូលដូចន័យនេះដែរ, ព្រះមានព្រះភាគទ្រង់ព្រះសណ្ដាប់ហើយទ្រង់ត្រាស់សរសើរថា ល្អហើយ! ល្អហើយ! ។

អាស្រ័យការប្រព្រឹត្តដូចខាងលើនេះឯង លោកហៅថា សង្ឃ, រួមពាក្យទាំង ២ បទនោះមកជាបទមួយហៅថា សាវកសង្ឃឬសង្ឃជាសាវ័ក ។ ក៏ព្រះសង្ឃជាសាវ័កនេះឯងលោកចែកចេញជា ២ ពួក (តាមដំណើរគុណធម៌ខ្ពស់ទាបជាងគ្នា) គឺ សម្មតិសង្ឃពួក ១, អរិយសង្ឃពួក ១ ។

## សម្មតិសង្ឃ

សម្មតិសង្ឃ ប្រែថា ព្រះសង្ឃដោយសម្មតិ, បានដល់ព្រះសង្ឃបុថុជ្ជនដែលទ្រទ្រង់នូវចតុបារិសុទ្ធិសីល ដោយបំណងនឹងរំខ្លួនចេញចាកភព តែពុំទាន់បានសម្រេចមគ្គផលណាមួយនៅឡើយ ហើយលោកកំណត់យកត្រឹម ៤ អង្គឡើងទៅសន្មតឲ្យឈ្មោះថាសង្ឃ, បើថយជាងនេះចុះមក លោកមិនហៅថាសង្ឃឡើយ ព្រោះមិនអាចនឹងសម្រេចសង្ឃកម្មណាមួយមានឧបោសថកម្មជាដើមបាន ។

## ព្រះអរិយសង្ឃ

ព្រះអរិយសង្ឃ ប្រែថា ព្រះសង្ឃដ៏ប្រសើរឬព្រះសង្ឃបរិសុទ្ធិ, បានដល់ព្រះសង្ឃដែលបានសម្រេចគុណធម៌ដ៏វិសេសគឺ មគ្គផលណាមួយ

រួចហើយលោកហៅថា អរិយសង្ឃឬសង្ឃជាអរិយបុគ្គល ព្រោះលោកទ្រទ្រង់នូវគុណធម៌ដ៏ខ្ពង់ខ្ពស់មានសោតាបត្តិមគ្គជាដើម ។ ព្រះអរិយសង្ឃនេះ លោកចែកចេញ (តាមដំណើរនៃកិច្ចដែលត្រូវលះនិងត្រូវបំពេញ[១] ជា ៤ ពួកគឺ សោតាបន្ន ១, សកទាគាមី ១, អនាគាមី ១, អរហត្ត ១ ។

## សោតាបន្ន

សោតាបន្ន[២] បុគ្គលអ្នកដល់ ឬអ្នកចូលប្រទះនូវប្រឡាយនៃព្រះនិព្វានគឺ អរិយមគ្គជាដំបូង, លោកចែកចេញជា ៣ ពួក (តាមដំណើរនៃឥន្ទ្រិយនិងវិបស្សនាបែកផ្សេងៗគ្នា) គឺសត្តក្ខត្តុំបរម ១, កោលំកោលៈ ១, ឯកពីជី ១ ។

បុគ្គលដែលមានឥន្ទ្រិយទន់ប្រកបដោយវិបស្សនាទន់ បាននាមថា សត្តក្ខត្តុំបរមៈ ព្រោះនៅអន្ទោលទៅមកក្នុងសុគតិភព ៧ ជាតិទៀតទើបបានសម្រេចអរហត្តផលហើយបរិនិព្វាន ។ បុគ្គលដែលមានឥន្ទ្រិយយ៉ាងកណ្តាលប្រកបដោយវិបស្សនាយ៉ាងកណ្តាល បាននាមថា កោលំកោលៈ នៅអន្ទោលទៅមកយោនយកកំណើតក្នុងសុគតិភព ២-៣-៤-៥ ជាតិ

---

១- ធម៌ជាកិច្ចដែលព្រះអរិយបុគ្គលត្រូវលះត្រូវបំពេញ មានក្នុងធម្មរតនវិនិច្ឆ័យជាធម្មាធិដ្ឋានរួចហើយ ក្នុងទីនេះសម្តែងប្រារព្ធជាបុគ្គលាធិដ្ឋាន អ្នកត្រូវការចង់ដឹងដំណើរព្រះអរិយបុគ្គលជាធម្មាធិដ្ឋានគប្បីមើលក្នុងទីនោះផងចុះ ។ ២ សោតាបន្ន ប្រកបដោយអង្គ ៤ គឺជឿគុណព្រះពុទ្ធ ១, ជឿគុណព្រះធម៌ ១, ជឿគុណព្រះសង្ឃ ១, ជឿព្រះអរិយសាវកឋាមានសីលបរិសុទ្ធ ១ ។

ទៀត ទើបបានសម្រេចអរហត្តផលហើយបរិនិព្វានក្នុងជាតិនោះៗ, បុគ្គលដែលមានឥន្ទ្រិយក្លៀវក្លាប្រកបដោយវិបស្សនាក្លៀវក្លាបានទាមថា ឯកពីជី នៅកើតក្នុងទេវលោក ១ ជាតិទៀត ទើបបានសម្រេចព្រះអរហត្តផលហើយបរិនិព្វានក្នុងជាតិនោះ ។

## សកទាគាមី

សកទាគាមី ប្រែថា បុគ្គលអ្នកមកកាន់មនុស្សលោកនេះ ១ ជាតិទៀត ព្រោះថា ព្រះអរិយៈថ្នាក់នេះ កាលបើរំលាយខន្ធនឹងបានទៅកើតក្នុងទេវលោក លុះច្យុតអំពីនោះមកនឹងបានមកកើតជាមនុស្ស ១ ជាតិទៀត ទើបបានសម្រេចអរហត្តផលហើយបរិនិព្វានក្នុងជាតិនោះ ។

## អនាគាមី

អនាគាមី ប្រែថា បុគ្គលអ្នកលែងមកកាន់កាមធាតុនេះ[១]ទៀត ដោយអំណាចបដិសន្ធិ ព្រោះថាព្រះអរិយៈថ្នាក់នេះ លុះរំលាយខន្ធទៅនឹងបានទៅកើតក្នុងសុទ្ធាវាស[២] ព្រហ្មជាន់ណាមួយ តាមសមគួរដល់ឋានានុរូប ទើបបានសម្រេចអរហត្តផលហើយបរិនិព្វានក្នុងភពនោះៗ ។ ព្រះអនាគាមីថ្នាក់នេះ លោកចែកចេញជា ៥ ពួក (តាមដំណើរនៃ

---

១- កាមធាតុ សំដៅយកកាមភព ១១ គឺ អបាយភូមិ ៤, ឋានមនុស្ស ១, ឋានកាមាវចរសួគ៌ ៦ ។

២- សុទ្ធាវាស ប្រែថា ភូមិជាទីនៅនៃបុគ្គលបរិសុទ្ធគឺព្រះអនាគាមីនិងព្រះអរហន្តទាំងឡាយមាន ៥ ជាន់គឺអវិហា ១, អតប្បា ១, សុទស្សា ១, សុទស្សី ១, អកនិដ្ឋ ១ ។

ឥន្ទ្រិយដែលផ្សេងគ្នា) គឺ

១- **អន្តរាបរិនិព្វាយី** អនាគាមីរលត់កិលេសត្រង់ចន្លោះ, សេចក្ដីថា អនាគាមីបុគ្គលពួកខ្លះ កាលបើបានទៅកើតក្នុងសុទ្ធាវាសព្រហ្មជាន់ណាមួយ ហើយមិនទាន់ដល់ពាក់កណ្ដាលអាយុ ក៏អាចញុំាំងអរហត្តមគ្គញ្ញាណឲ្យកើតបាន ហើយបរិនិព្វានក្នុងព្រហ្មលោកជាន់នោះទៅ ។

២- **ឧបហច្ចបរិនិព្វាយី** អនាគាមីរលត់កិលេសក្នុងកាលទៀបអស់អាយុ, សេចក្ដីថា អនាគាមីបុគ្គលពួកខ្លះកាលបើបានទៅកើតក្នុងសុទ្ធាវាសព្រហ្មជាន់ណាមួយ ហើយស្ថិតនៅក្នុងព្រហ្មលោកជាន់នោះ បានជាងពាក់កណ្ដាលអាយុ ឬទៀបអស់អាយុទើបអាចញុំាំងអរហត្តមគ្គញ្ញាណឲ្យកើតបានហើយបរិនិព្វានក្នុងព្រហ្មលោកជាន់នោះ ។

៣- **អសង្ខារបរិនិព្វាយី** អនាគាមី រលត់កិលេសបានដោយងាយ, សេចក្ដីថា អនាគាមីបុគ្គលពួកខ្លះបានទៅកើតក្នុងសុទ្ធាវាសព្រហ្មជាន់ណាមួយហើយ ទោះបីលោកប្រកបសេចក្ដីព្យាយាមខ្សោយក៏អាចញុំាំងអរហត្តមគ្គញ្ញាណឲ្យកើតបាន ហើយបរិនិព្វានក្នុងព្រហ្មលោកជាន់នោះឯង ។

៤- **សសង្ខារបរិនិព្វាយី** អនាគាមី រលត់កិលេសបានដោយលំបាក, សេចក្ដីថា អនាគាមីបុគ្គលពួកខ្លះដែលលោកបានទៅឧប្បត្តិក្នុងសុទ្ធាវាសព្រហ្មជាន់ណាមួយហើយ លុះត្រាតែប្រកបសេចក្ដីព្យាយាមតឹងទើបអាចញុំាំងអរហត្តមគ្គញ្ញាណឲ្យកើតបាន ហើយបរិនិព្វានក្នុងព្រហ្មលោកជាន់នោះឯង ។

៥- ឧទ្ធំសោតោអកនិដ្ឋគាមី[១] អនាគាមីមានខ្សែក្នុងខាងលើគឺព្រហ្មលោកជាន់អកនិដ្ឋ, សេចក្តីថាលោកដែលបានញាណថ្នាក់នេះហើយលុះរំលាងខន្ធទៅនឹងបានទៅឧប្បត្តិក្នុងសុទ្ធាវាសព្រហ្មទាំង ៤ ជាន់[២] តាមលំដាប់ស្ថានហូរហែ តែពុំអាចញ៉ាំងអរហត្តមគ្គញាណឲ្យកើតបានក្នុងស្ថាននោះៗទេ លុះត្រាតែឡើងទៅដល់ជាន់អកនិដ្ឋ ទើបបានសម្រេចអរហត្តមគ្គញាណ ហើយបរិនិព្វានក្នុងជាន់ទីបំផុតនោះឯង ។

អរហន្ត

អរហន្ត ប្រែថា បុគ្គលឆ្ងាយចាកសឹកសត្រូវគឺកិលេសឬថាគួរទទួលយកនូវគ្រឿងបូជាដ៏វិសេស, ជានាមរបស់ព្រះអរិយបុគ្គលថ្នាក់ខ្ពស់បំផុតដែលលោកបានសម្រេចអរហត្តផលហើយ, ចែកចេញជា ៤ ពួក (តាមដំណើរគុណវិសេសដែលលោកបានសម្រេច) គឺ

១- សុក្ខវិបស្សកោ បានដល់ព្រះអរហន្តដែលបានត្រឹមការស្ងប់ស្ងួតកិលេសដោយអំណាចវិបស្សនាប៉ុណ្ណោះ ឥតមានឫទ្ធិអ្វីមួយឲ្យជាទីអស្ចារ្យដល់ភ្នែកសត្វលោកឡើយ គឺព្រះអរហន្តដែលខ្វះត្រៃវិជ្ជាឆឡភិញ្ញានិងចតុប្បដិសម្ភិទា ។

---

១- ពាក្យថា ឧទ្ធំសោតោអកនិដ្ឋគាមីនេះ សំដៅយកតែព្រះអនាគាមីដែលបានទៅកើតក្នុងសុទ្ធាវាស ៤ ជាន់ខាងក្រោមប៉ុណ្ណោះទេ មិនបំណងយកអនាគាមីដែលបានទៅកើតក្នុងជាន់អកនិដ្ឋតែម្តងនោះទេ ព្រោះលោកឥតមានកិច្ចត្រូវឡើងតទៅទៀត បានសម្រេចអរហត្តផលក្នុងថ្នាក់នេះឯង ។ ២ បានដល់សុទ្ធាវាស ជាន់ខាងក្រោម ។

២- **តេវិជ្ជោ**[១] បានដល់ព្រះអរហន្តដែលបែកធ្លាយក្នុងវិជ្ជា ៣ គឺ បុព្វេនិវាសានុស្សតិវិជ្ជា ១, ចុតូបបាតវិជ្ជា ១, អាសវក្ខយវិជ្ជា ១ ។

៣- **ឆឡភិញ្ញោ**[២] បានដល់ព្រះអរហន្តដែលបែកធ្លាយក្នុងអភិញ្ញា ៦ គឺ ឥទ្ធិវិធញ្ញាណ ១, ទិព្វសោតញ្ញាណ ១, ចេតោបរិយញ្ញាណ ១, បុព្វេនិវាសានុស្សតិញ្ញាណ ១, ចុតូបបាតញ្ញាណ ១, អាសវក្ខយញ្ញាណ ១ ។

៤- **បដិសម្ភិទប្បត្តោ** បានដល់ព្រះអរហន្តដែលបែកធ្លាយក្នុងបដិសម្ភិទា ៤ គឺ

ក) **អត្ថប្បដិសម្ភិទា** ប្រាជ្ញាដែលបែកធ្លាយក្នុងអត្ថ (ផល) គឺបែកធ្លាយក្នុងផលដែលអាស្រ័យហេតុហើយកើតឡើង, អត្ថក្នុងទីនេះផ្សេងដោយប្រភេទមាន ៥ ប្រការគឺ ការប្រាកដនៃបច្ច័យឯណាមួយ ១, ព្រះនិព្វាន ១, សេចក្តីនៃភាសិត ១, វិបាក ១, កិរិយា ១ ។ ប្រាជ្ញាដែលបែកធ្លាយក្នុងធម៌ទាំងនេះលោកហៅថា អត្ថប្បដិសម្ភិទា ។

ខ) **ធម្មប្បដិសម្ភិទា** ប្រាជ្ញាបែកធ្លាយក្នុងធម៌ (បច្ច័យ) គឺប្រាជ្ញាដែលបែកធ្លាយក្នុងបច្ច័យដែលជាហេតុឲ្យប្រព្រឹត្តទៅ ឬជាហេតុឲ្យបានលុះផលនោះៗ, ធម៌(បច្ច័យ)ក្នុងទីនេះ, ផ្សេងដោយប្រភេទជា ៥ គឺហេតុ

---

១-២ វិជ្ជា ៣ និងអភិញ្ញា ៦ ចូរមើលសេចក្តីអធិប្បាយក្នុងពុទ្ធរតនវិនិច្ឆ័យត្រង់បទវិជ្ជាចរណសម្បន្នោ ។

បណ្តាលឲ្យផលកើតឯណាមួយ ១, អរិយមគ្គ ១, ភាសិត ១, កុសល ១, អកុសល ១, ញាណដែលបែកធ្លាយក្នុងធម៌ទាំងនេះឈ្មោះថាធម្មប្បដិសម្ភិទា ។

សមតាមន័យក្នុងអភិធម្ម លោកបញ្ញត្តទុកមានដើមថា សេចក្តីដឹងក្នុងទុក្ខឈ្មោះថាអត្ថប្បដិសម្ភិទា, សេចក្តីដឹងក្នុងសមុទ័យឈ្មោះថា ធម្មប្បដិសម្ភិទា, សេចក្តីដឹងក្នុងទុក្ខនិរោធ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងទុក្ខនិរោធគាមិនីបដិទា ឈ្មោះថា ធម្មប្បដិសម្ភិទា ។

សេចក្តីដឹងក្នុងហេតុឈ្មោះថាធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងផលអាស្រ័យហេតុឈ្មោះថាអត្ថប្បដិសម្ភិទា, សេចក្តីដឹងក្នុងធម៌ទាំងឡាយដែលកើតហើយ, ប្រព្រឹត្តនៅហើយ, ប្រាកដហើយ, កើតឡើងហើយ, កើតពេញទីហើយ, ច្បាស់ហើយ, ឈ្មោះថាអត្ថប្បដិសម្ភិទា, សេចក្តីដឹងច្បាស់ក្នុងធម៌ជាដែនបណ្តាលឲ្យកើត, ឲ្យប្រព្រឹត្តទៅ, ឲ្យប្រាកដ, ឲ្យបង្កើត, ឲ្យកើតពេញទី, ឲ្យច្បាស់ឈ្មោះថាធម្មប្បដិសម្ភិទា ។

**គ) និរុត្តិប្បដិសម្ភិទា** ប្រាជ្ញាបែកធ្លាយក្នុងភាសាដែលពោលអត្ថនិងធម៌គឺប្រាជ្ញាដែលបែកធ្លាយ ព្រោងព្រាតក្នុងមគធភាសា, ដែលពោលអំពីអត្ថនិងធម៌ស្ទាត់ជំនាញ, គ្រាន់តែឮពាក្យពោលឡើងភ្លាម អាចស្តាប់បានថានេះជាភាសាខុស, នេះជាភាសាត្រូវ, ដូចដឹងថា "ផស្សោ វេទនា" ជាភាសាត្រូវ,"ផស្សា វេទនោ" ជាភាសាខុសជាដើម ។

**ឃ) បដិភាណប្បដិសម្ភិទា** ប្រាជ្ញាបែកធ្លាយក្នុងបដិភាណ គឺ

ប្រាជ្ញាដែលមានញាណជាអារម្មណ៍ ឬសេចក្តីដឹងដោយពិស្តារដោយអំ-ណាចគោចរនិងកិច្ចរបស់ខ្លួនជាដើមក្នុងញាណ[១] ទាំងនោះ ដែលបានពោលរួចហើយនៃបុគ្គលអ្នកពិចារណាយកញាណជាអារម្មណ៍ (ប្រាជ្ញាយ៉ាងនេះ) ឈ្មោះថាបដិភាណប្បដិសម្ភិទា[២] ។

## គុណរបស់ព្រះអរហន្ត

ព្រះអរិយបុគ្គលដែលឈោងចាប់ថ្នាក់ឧត្តមបំផុតបានហើយ បាននាមថា "អរហន្ត" ព្រោះឆ្ងាយចាកសឹកសត្រូវពោលគឺ កិលេសហើយ, ឈ្មោះថា "ព្រះខីណាស្រព" ព្រោះមានអាសវៈអស់ហើយគឺថាអាសវៈទាំង ៤ យ៉ាងជាគ្រឿងត្រាំសត្វនៅក្នុងភព លោកលះបង់ស្រឡះហើយ, ឈ្មោះថាមានធម៌ជាគ្រឿងនៅៗរួចហើយ, ព្រោះថាធម៌ដែលត្រូវប្រព្រឹត្តលោកបានប្រព្រឹត្តរួចហើយ, ឈ្មោះថាជាអ្នកចប់កិច្ចគួរធ្វើ ព្រោះថាកិច្ចទាំង[៣] ៤ ប្រការគឺ បរិញ្ញាកិច្ច, បហានកិច្ច ភាវនាកិច្ច, និងសច្ឆិកិរិ-យាកិច្ច ដែលលោកត្រូវធ្វើដោយអរិយមគ្គទាំង ៤ លោកបានធ្វើរួចហើយ ឥតមានកិច្ចដទៃដែលគួរធ្វើតទៅទៀតឡើយ, ឈ្មោះថាមានគ្រឿងទម្ងន់

---

១- ញាណទាំងនោះគឺ បដិសម្ភិទាទាំង ៣ ខាងដើម ។ ២ បដិសម្ភិទាទាំង ៤ នេះរមែងបែកធ្លាយក្នុងភូមិ ២ គឺសេក្ខភូមិ ១, អសេក្ខភូមិ ១, បណ្តាភូមិទាំង ២ នេះអគ្គសាវកនិងមហាសាវកបែកធ្លាយក្នុងអសេក្ខភូមិ, សាវកក្រៅពីនេះបែកធ្លាយក្នុងសេក្ខភូមិ ។ ៣ កិច្ច ៤ យ៉ាងគឺ បរិញ្ញាកិច្ច កិរិយាកំណត់ដឹងនូវទុក្ខសច្ច, បហានកិច្ច កិរិយាលះបង់នូវសមុទយសច្ច, ភាវនាកិច្ច កិរិយាបម្រើននូវមគ្គសច្ច, សច្ឆិកិរិយាកិច្ច កិរិយាធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ។

ទម្លាក់ចោលហើយ ព្រោះថាគ្រឿងទម្ងន់ទាំង ៣ គឺខន្ធភារៈ (គ្រឿងទម្ងន់គឺបញ្ចក្ខន្ធ), កិលេសភារៈ (គ្រឿងទម្ងន់គឺកិលេស), អភិសង្ខារភារៈ (គ្រឿងទម្ងន់គឺអភិសង្ខារ), លោកដាក់ចុះហើយ, បោះបង់ចោលហើយ, ទម្លាក់ចោលហើយ, ឈ្មោះថាមានប្រយោជន៍របស់ខ្លួនដល់តាមលំដាប់ហើយ ព្រោះថាប្រយោជន៍បម្រុងខ្លួនគឺអរហត្តភាព លោកបានរួចហើយ, ឈ្មោះថាមានចំណងដាច់រលីងហើយ ព្រោះថាចំណងសម្រាប់ចងសត្វភ្ជាប់ក្នុងភពទាំង ១០ យ៉ាងលោកផ្តាច់ចោលហើយ, ឈ្មោះថាមានចិត្តផុតស្រឡះហើយ ព្រោះថាជាបណ្តាញសាន់វាន់ក្នុងចិត្តលោកដោះរួចហើយ, ឈ្មោះថាមានព្រះនិព្វានបានហើយ ព្រោះថាសឧបាទិសេសនិព្វាន គឺអរហត្តផល លោកបានដល់ហើយ, ឈ្មោះថាមានបុណ្យនិងបាបបន្សាត់ចោលហើយ ព្រោះថាបុណ្យនិងបាបដែលធ្លាប់ជាបច្ច័យសម្រាប់ផ្សាំពូជសង្ខារបន្តជាតិកំណើតឲ្យយឺតយូរ ទៅក្នុងភពខាងមុខទៀតលោកកាត់តម្រឹមហើយដោយកន្ត្រៃគឺអរហត្តមគ្គញ្ញាណ, បើទុកណាជាលោកភ្លាំងភ្លាត់ធ្វើបាបដោយកាយវាចាចិត្តខ្លះ ក៏អំពើនោះមិនអាចឲ្យផលបានឡើយ, ព្រះអរិយៈថ្នាក់នេះ ប្រសិនបើលោកតាំងនៅក្នុងភេទជាបព្វជិត ទើបមានជីវិតប្រព្រឹត្តទៅតាមកាលកំណត់អាយុសង្ខារបាន, បើតាំងនៅក្នុងភេទជាគ្រហស្ថវិញ មិនអាចនឹងរស់នៅហួសកំណត់សត្តាហវារៈបានទេ នឹងបរិនិព្វានក្នុងថ្ងៃ ជាគម្រប់ ៧ ពុំខាន, ព្រោះថាភេទ

គ្រហស្ថជាភេទថោកទាប មិនគួរជាភាជន៍សម្រាប់រងអរហត្តផលរំលងហួសសត្តាហព្ភន្តរទៅទៀតបាន ។

ព្រះអរិយបុគ្គលដែលសម្ដែងមកដោយប្រភេទ ៤ នេះសំដៅយកលោកដែលតាំងនៅក្នុងផលហើយ, បើសម្ដែងរាយតួតាមដំណើរមគ្គនិងផលវិញមាន ៨, តែបើរួបរួមឲ្យខ្លីតាមកិច្ចដែលត្រូវលះនិងត្រូវបំពេញមានតែ ២ គឺ សេក្ខបុគ្គល ១, អសេក្ខបុគ្គល ១, សេក្ខបុគ្គល បានដល់អរិយបុគ្គលទាំង ៧ ពួកខាងដើមតាំងពីសោតាបត្តិមគ្គដ្ឋ រៀងមកដល់អរហត្តមគ្គដ្ឋ, ព្រោះលោកនៅជាប់កិច្ចត្រូវសិក្សាដើម្បីបានលុះអរហត្តផលតទៅទៀត, អសេក្ខបុគ្គល បានដល់ព្រះអរិយបុគ្គលដែលតាំងនៅក្នុងអរហត្តផល ព្រោះលោកចប់អស់កិច្ចត្រូវសិក្សាតទៅទៀតហើយ ។

## វិនិច្ឆ័យបទនមស្សការព្រះសង្ឃ

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**
**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**
**គុណេហិនេកេហិ សមិទ្ធិបត្តោ**
**អនាសវោ តំ បណមាមិ សង្ឃំ**

*ប្រែថា ព្រះសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់បង់ហើយ មានមន្ទិលគឺរាគាទិកិលេសទាំង-ពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមានគឺថាជាព្រះខីណាស្រព, ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះដោយគោរព ។*

### ពាក្យសួរដែលគួរចាំ

*១- បុគ្គលដូចម្តេចហៅថា ទក្ខិណេយ្យបុគ្គល?*

*២- ធម៌ដូចម្តេច ហៅថា ឥន្ទ្រិយ ?*

*៣- ធម៌ដូចម្តេចហៅថា អាសវធម៌ ?*

*៤- បុគ្គលដូចម្តេច ហៅថា ព្រះខីណាស្រព? ព្រះខីណាស្រពនិងព្រះអរិយបុគ្គលផ្សេងគ្នាដូចម្តេច?*

## ពាក្យឆ្លើយ

១- បុគ្គលដែលគួរទទួលនូវទក្ខិណាទាន ហៅថាទក្ខិណេយ្យបុគ្គល ។

២- ធម៌ដែលជាធំអាចឲ្យសម្រេចកិច្ចតាមនាទីរបស់ខ្លួនបានហៅថា ឥន្ទ្រិយ ។

៣- ធម៌សម្រាប់ត្រាំសត្វឬបង្ហូរសត្វឲ្យហូរវិលវល់ក្នុងត្រៃភពហៅថា អាសវធម៌ ។

៤- បុគ្គលដែលមានចតុរាសវធម៌អស់រលីងហើយហៅថា ព្រះខីណាស្រព, បានដល់ព្រះអរហន្ត, ឯបុគ្គលដែលហៅថាព្រះអរិយបុគ្គល បានដល់បុគ្គលដែលបានសម្រេចមគ្គផលគ្រប់ទាំង ៨ ពួក ។

## សេចក្តីអធិប្បាយ

ដែលហៅថាព្រះអរិយសង្ឃ បរិសុទ្ធវិសេស ព្រោះលោកប្រកបដោយសេចក្តីស្អាត ៣ យ៉ាងគឺ កាយសោចេយ្យៈ ប្រព្រឹត្តស្អាតដោយកាយគឺវៀរចាកកាយទុច្ចរិត ៣, វចីសោចេយ្យៈ ប្រព្រឹត្តស្អាតដោយវាចា គឺវៀរចាកវចីទុច្ចរិត ៤, មនោសោចេយ្យៈ ប្រព្រឹត្តស្អាតដោយចិត្ត គឺវៀរចាកមនោទុច្ចរិត ៣, លោកជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ព្រោះលោកគួរទទួលយកនូវទក្ខិណាទានដែលសាធុជនអ្នកជឿនូវកម្មហើយនិងផលនៃកម្មនាំមកបូជា ព្រោះថាលោកអាចញ៉ាំងទានឲ្យមានផលថ្លៃថ្លាដល់ទាយកជាជាងបដិគ្គាហកៈ ដទៃ, លោកមានឥន្ទ្រិយ

ស្ងប់រម្ងាប់ហើយព្រោះថាឥន្ទ្រិយទាំង ៦ គឺ ចក្ខុន្ទ្រិយ, សោតិន្ទ្រិយ, ឃានិន្ទ្រិយ, ជិវ្ហិន្ទ្រិយ, កាយិន្ទ្រិយ, មនិន្ទ្រិយ, លោកទូន្មានបានបទហើយ, ទុកណាជាមានឥដ្ឋានិដ្ឋារម្មណ៍ខាងក្រៅមកប៉ះពាល់យ៉ាងណា ក៏ឥតមានត្រេកអរឬអាក់អន់អ្វីឡើយ បែរជាព្រងើយកន្តើយ តាំងនៅក្នុងភាពជាឧបេក្ខាទៅវិញ, លោកមានមន្ទិលគឺរាគាទិកិលេសទាំងពួងបន្សាត់បង់ហើយ ព្រោះលោកអាចផ្តាច់បង់បាននូវគ្រឿងមន្ទិលសព្វយ៉ាងមានរាគៈជាដើមដាច់ស្រឡះដោយសមុច្ឆេទប្បហាន ពុំឲ្យកើតមានក្នុងខន្ធសន្តានរបស់លោកទៀតបាន, លោកបានសម្រេចដោយគុណធម៌ដ៏ច្រើន ព្រោះថាធម៌ទាំងឡាយដែលជាចំណែកនៃគុណ អាចទ្រទ្រង់លោកឲ្យបានដល់នូវទីដ៏ខ្ពង់ខ្ពស់យ៉ាងសីល[១], សមាធិ បញ្ញា វិមុត្តិ លោកបានដល់រួចហើយ ឥតមានគុណវិសេសដទៃដែលនឹងគប្បីបានតទៅទៀតឡើយ, លោកជាព្រះខីណាស្រពមានអាសវធម៌អស់ហើយព្រោះអាសវធម៌ទាំងឡាយ ដែលជាគ្រឿងប្រស់សត្វទុកនៅក្នុងអន្ទង់ទាំង ៤ ប្រការគឺ កាម សេចក្តីប្រាថ្នា ១, ភព សេចក្តីពេញចិត្តក្នុងត្រៃភព ១, ទិដ្ឋិ សេចក្តីយល់ខុសគឺយល់ថាសត្វទៀង លោកទៀងជាដើម ១, អវិជ្ជា

---

១- សីលគ្គំ គុណដ៏ខ្ពង់ខ្ពស់គឺសីល, សមាធិគ្គំ គុណដ៏ខ្ពង់ខ្ពស់គឺសមាធិ, បញ្ញគ្គំ គុណដ៏ខ្ពង់ខ្ពស់គឺបញ្ញា, វិមុត្តិគ្គំ គុណដ៏ខ្ពង់ខ្ពស់គឺវិមុត្តិ ។

សេចក្ដីភ័ន្តច្រឡំមិនស្គាល់មាន ៨ យ៉ាង ១, ធម៌ទាំងនេះឃ្លាតផុតចេញចាក ខន្ធសន្ដានរបស់លោកហើយ ។

## វិនិច្ឆ័យបទនមស្សការព្រះសង្ឃគ្រប់ត្រៃកាល

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា**
**បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា។**

ប្រែថា ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេច មគ្គនិងផលកន្លងទៅហើយក្ដី, ព្រះសង្ឃទាំងឡាយឯណា ដែល ជាព្រះសង្ឃនឹងបានសម្រេចមគ្គនិងផលក្នុងកាលខាងមុខក្ដី, ព្រះសង្ឃ ទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនិងផលក្នុងកាលជា បច្ចុប្បន្ននេះក្ដី, ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយ នោះ គ្រប់កាលទាំងពួង ។

## ពាក្យសួរដែលគួរបាំ

១- ព្រះសង្ឃជា អតីត, អនាគត, បច្ចុប្បន្ន ប្រព្រឹត្តធម៌ខុស គ្នាឬ ទើបលោកញែកជាត្រៃកាលដូច្នេះ?

២- ព្រះសង្ឃជា អតីត, បច្ចុប្បន្ន ល្មមយើងនឹកគុណលោក ព្រោះលោកបានផ្សព្វផ្សាយធម៌វិន័យទុកចែកយើង ចុះព្រះសង្ឃខាង អនាគតនៅមិនទាន់មានគុណដល់យើងទេ ហេតុអ្វីក៏ត្រូវនឹកដែរ?

៣- ខ្លួនយើងចូនកាលនឹងបានជាសង្ឃក្នុងអនាគត, បើយើងនឹកដូច្នេះ មិនឈ្មោះថានឹកសរសើរតែគុណខ្លួនឯងទៅហើយ?

ពាក្យឆ្លើយ

១- ព្រះសង្ឃទាំង ៣ កាលនេះ មិនមែនប្រព្រឹត្តធម៌ខុសគ្នាទេ តែលោកញែកដោយអំណាចកាលមុនក្រោយប៉ុណ្ណោះ ។

២- ព្រះសង្ឃទាំងនោះ បានជាយើងគួរនឹក ព្រោះធ្វើចិត្តយើងឲ្យផូរផង់បានដូចគ្នា ។

៣- មិនឈ្មោះថានឹកសរសើរខ្លួនឯងទេ ព្រោះយើងគ្មានបំណងនឹកចំពោះខ្លួនសោះ ។

សេចក្ដីអធិប្បាយ

ព្រះសង្ឃជាសាវ័កនៃព្រះមានជោគ ទោះបីកន្លងទៅហើយក្ដី, ពុំទាន់មានមកក្ដី មាននៅសព្វថ្ងៃនេះក្ដី សុទ្ធសឹងប្រព្រឹត្តតាមចតុបារិសុទ្ធិសីល មានចតុបារិសុទ្ធិសីលជាបន្ទាត់ ជារបងដូចគ្នា, ឥតមានប្រព្រឹត្តរំលងហួសគោលនេះទៅបានឡើយ, ទាំងលោកុត្តរធម៌គឺ មគ្គ ផល និព្វានទៀតសោតក៏មានដូចគ្នា ហេតុនេះព្រះសង្ឃទើបដូចគ្នា ។

មួយទៀត ព្រះពុទ្ធអំបាលខ្សាច់ទាំងឡាយគ្រប់ព្រះអង្គ សុទ្ធសឹងទ្រង់ត្រាស់ដឹងសព្វញ្ញុតញ្ញាណដូចគ្នា ទាំងធម៌របស់ព្រះអង្គទៀតសោត

ក៏ដូចគ្នាព្រោះទ្រង់ត្រាស់ប្រដៅសត្វត្រឹមតែឱវាទ ៣ ព្រះឱស្ឋដូចគ្នា, បើព្រះពុទ្ធ ព្រះធម៌ដូចគ្នាហើយ, ចំណែកព្រះសង្ឃដែលជាសាវកអ្នកស្តាប់ឱវាទរបស់ព្រះអង្គទៀតសោតក៏ដូចគ្នា សមដូចបទនមស្ការក្នុងរតនសូត្រថា ៖

តថាគតំ ទេវមនុស្សបូជិតំ { ពុទ្ធំ / ធម្មំ / សង្ឃំ } នមស្សាម សុវត្ថិ ហោតុ

យើងសូមនមស្ការនូវ { ព្រះពុទ្ធ / ព្រះធម៌ / ព្រះសង្ឃ } ដែលមានមកហើយដូចគ្នា ដែលទេព្តានិងមនុស្សទាំងឡាយតែងបូជា, សូមសិរីសួស្តីកើតមាន ។

## ព្រះសង្ឃគុណ ៩

*យោគីបុគ្គលអ្នកត្រូវការចម្រើននូវសង្ឃានុស្សតិគប្បីសម្ងំនៅក្នុងទីស្ងាត់ ហើយរំពឹងរកនូវគុណនៃព្រះសង្ឃ ត្រង់ព្រះនាមណាមួយ ដោយការចូលចិត្តសេចក្តីច្បាស់លាស់ចំពោះព្រះនាមនោះៗ ដូចតទៅនេះ ៖*

*១-* **សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនពលោកុត្តរធម៌ ។*

*២-* **ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមាបដិបទា ។*

*៣-* **ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វានជាឋានក្សេមផុតចាកទុក្ខទាំងពួង ។*

*៤-* **សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា ។*

**យទិទំ ចត្តារិ បុរិសយុគានិ** *ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ*

*និងសោតាបត្តិផលជាគូ ១...។ ល ។ អរហត្តមគ្គ និងអរហត្តផលជាគូ ១ ។*

**អដ្ឋ បុរិសបុគ្គលា** *បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ ព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១... ។ ល ។ ...អរហត្តផល ១ ។*

**ឯស ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃទាំងនោះជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ ។*

៥- **អាហុនេយ្យោ** *លោកគួរទទួលនូវចតុប្បច្ច័យដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា ។*

៦- **បាហុនេយ្យោ** *លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្តដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា ។*

៧- **ទក្ខិណេយ្យោ** *លោកគួរទទួលនូវទក្ខិណាទាន គឺទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្ម ហើយបង្អោនចូលមកបូជា ។*

៨- **អញ្ជលិករណីយោ** *លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ។*

៩- **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** *លោកជាបុញ្ញក្ខេត្តគឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។*

## (៧) វិនិច្ឆ័យបទថា "សុប្បដិបន្នោ"

### ពាក្យសួរដែលគួរចាំ

១-ប្រតិបត្តិដូចម្តេច ទើបហៅថាប្រតិបត្តិត្រូវ ចាត់ថា "សុប្បដិបន្នោ"?

២- សេចក្តីប្រតិបត្តិនៃពួកពុទ្ធបរិស័ទជាតិបុថុជ្ជន ចាត់ថា "សុប្បដិ-បន្នោ" បានឬទេ? ព្រោះហេតុអ្វី?

៣- បុគ្គលដែលប្រតិបត្តិត្រូវចាត់ថា "សុប្បដិបន្នោ" នោះបានដល់បុគ្គលពួកណា?

### ពាក្យឆ្លើយ

១- សេចក្តីប្រតិបត្តិត្រូវត្រង់តាមគន្លងលោកុត្តរធម៌ ទើបចាត់ថា "សុប្បដិប្បន្នោ" បាន ។

២- សេចក្តីប្រតិបត្តិនៃពួកពុទ្ធបរិស័ទជាតិបុថុជ្ជន ពុំទាន់ចាត់ថា "សុប្បដិបន្នោ" បានស៊ប់សួនឡើយ ព្រោះនៅប្រែប្រួលខុសវិញបាន ។

៣- បុគ្គលដែលប្រតិបត្តិត្រូវចាត់ថា "សុប្បដិបន្នោ" បាននោះ បានដល់ព្រះអរិយបុគ្គល ។

### សេចក្តីអធិប្បាយ

ពាក្យថា "សុប្បដិបន្នោ" នេះ ជានាមវិសេសរបស់ព្រះអរិយបុគ្គល

ដែលលោកប្រតិបត្តិដោយប្រពៃគឺប្រតិបត្តិត្រូវ, ប្រតិបត្តិលែងវិលត្រឡប់វិញប្រតិបត្តិអនុលោមទៅតាមព្រះនិព្វាន, ប្រតិបត្តិមិនជាសឹកសត្រូវ, ប្រតិបត្តិនូវធម៌ សមគួរដល់ធម៌, ជាសេចក្តីប្រតិបត្តិត្រឹមត្រង់ មិនកោងវៀចវេររពើតរពើង នឹងហៅថាជាផ្លូវប្រតិបត្តិដ៏ប្រសើរសម្រាប់នាំចេញក៏បាន ឬនឹងហៅថា សាមីចិ សេចក្តីប្រតិបត្តិដ៏ឧត្តមក៏គួរ ។ ព្រោះហេតុនោះ ព្រះអរិយសង្ឃដែលលោកប្រតិបត្តិតាមផ្លូវដូច្នោះ ហៅថា, ឧជុប្បដិបន្នោ ក៏បាន, ញាយប្បដិបន្នោ ក៏បាន ឬសាមីចិប្បដិប្បន្នោ ក៏បាន (ព្រោះថាព្រះសង្ឃគុណ ទាំង ៤ បទនេះទាក់ទងគ្នា) ។

ន័យមួយទៀតថា បណ្តាព្រះអរិយសង្ឃទាំងអម្បាលនោះ លោកពួកណាតាំងនៅក្នុងមគ្គ, លោកពួកនោះបាននាមថា "សុប្បដិបន្នោ" ព្រោះលោកប្រកបដោយសេចក្តីប្រតិបត្តិត្រូវ, លោកពួកណាតាំងនៅក្នុងផល, លោកពួកនោះក៏បាននាម សុប្បដិបន្នោ ព្រោះលោកបានលុះនូវមគ្គដែលលោកគប្បីបានដោយសម្មាបដិបត្តិ ។

ន័យមួយទៀតថា ព្រះអរិយសង្ឃ បាននាមថា សុប្បដិបន្នោ (ប្រតិបត្តិល្អហើយ) ព្រោះហេតុដែលលោកប្រតិបត្តិគួរដល់ឱវាទដែលព្រះពុទ្ធទ្រង់ប្រៀនប្រដៅក្នុងធម៌វិន័យជា ស្វាក្ខាតៈ (ត្រាស់សម្តែងល្អហើយ)

ផង, ព្រោះថាសេចក្តីប្រតិបត្តិនោះ ជាសេចក្តីប្រតិបត្តិមិនខុសផង ។

ព្រះសង្ឃប្រកបដោយគុណធម៌ដូច្នេះឯង ទើបបាននាមថា “សុប្បដិបន្នោ” ។

## (២) វិនិច្ឆ័យបទថា "ឧជុប្បដិបន្នោ"

### ពាក្យសួរដែលគួរចាំ

១- ប្រតិបត្តិដូចម្តេច ទើបឈ្មោះថាប្រតិបត្តិត្រង់?

២- អ្វីហៅថា មជ្ឈិមាបដិបទា?

៣- មជ្ឈិមាបដិបទា បានដល់អ្វី?

៤- អាការប្រតិបត្តិត្រង់នោះដូចម្តេច?

### សេចក្តីឆ្លើយ

១- ប្រតិបត្តិតាមមជ្ឈិមាបដិបទា ឈ្មោះថាប្រតិបត្តិត្រង់ ។

២- បដិបទាកណ្តាលមិនពានពារទៅលើអន្តប្បដិបត្តិហៅថាមជ្ឈិមាបដិបទា ។

៣- មជ្ឈិមាបដិបទា បានដល់អដ្ឋង្គិកមគ្គ ។

៤- អាការនៃសេចក្តីប្រតិបត្តិត្រង់នោះ គឺប្រតិបត្តិដើម្បីផ្តាច់បង់នូវទោសៈ មានៈ មាយា និងសាថេយ្យៈ ជាដើម ។

### សេចក្តីអធិប្បាយ

ពាក្យថា "ឧជុប្បដិបន្នោ" នេះ ជានាមវិសេសរបស់ព្រះអរិយបុគ្គលដែលកើតឡើងដោយសេចក្តីប្រតិបត្តិត្រង់ គឺប្រតិបត្តិដើម្បីផ្តាច់បង់នូវទោសដែលកោងវៀចវេរពើតពើងដោយកាយ វាចា ចិត្ត មានមាយា

និងសាថេយ្យៈជាដើម, បានដល់មជ្ឈិមាបដិបទា ដែលជាសេចក្តីប្រតិបត្តិកណ្តាលមិនពាក់ព័ន្ធទៅលើអន្តប្បដិបត្តិ (ប្រតិបត្តិអមខាង) ទាំង ២ ប្រការគឺ កាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ ។

## កាមសុខល្លិកានុយោគ

កាមសុខល្លិកានុយោគ សេចក្តីប្រព្រឹត្តប្រឡូកប្រឡំដោយបញ្ចកាម-គុណ ដែលវិញ្ញូជនមានព្រះពុទ្ធជាប្រធាន តែងត្រាស់តិះដៀលបន្តុះបង្អាប់មានដើមថា **ហីនោ** ជាធម៌ថោកទាប, **គម្មោ** ជាធម៌របស់អ្នកស្រុក, **ចោថុជ្ជនិកោ** ជាធម៌របស់បុថុជ្ជន, **អនរិយោ** មិនមែនជាធម៌របស់ព្រះអរិយៈ, **អនត្ថសញ្ហិតោ** ជាធម៌ឥតប្រយោជន៍ ។

ចំណែកឯបុគ្គលអ្នកស្រេកកាម, អ្នកស្វះស្វែងរកកាម, អ្នកប្រាថ្នាកាមនោះ **អម្ពសញ្ញាយ វិសផលភក្ខោ វិយ** ទុកដូចជាជនអ្នកបរិភោគនូវផ្លែឈើមានពិសដោយសម្គាល់ថាផ្លែស្វាយ, ពុំនោះសោត **យក្ខិនិយា សំវាសោ វិយ** ដូចជាជនអ្នកនៅរួមដោយមេយក្ខិនី ។

មួយវិញទៀត **សុសានេ បតិតកុណរោ វិយ** កាមគុណមានគួរនោជូចជាសាកសពដែលគេចោលក្នុងព្រៃស្មសាន ដែលជាចំណីនៃសត្វតិរច្ឆាននានា, **អដ្ឋិកង្កលូបមា** បញ្ចកាមគុណមានគួរនោដូចជាឆ្អឹងទទេដែលគេចោលលើផែនដី បុគ្គលអ្នកបរិភោគកាមប្រៀបដូចសុនខដែលអង្កៀមឆ្អឹងនោះ, **សុបិនកូបមា** ការត្រេកត្រអាលក្នុងកាមគុណ

ជារបស់ទទេគួរនោដូចយល់សប្តិ ដែលគ្រាន់តែភ្ញាក់ឡើងហើយបាត់ទៅ អង្គារកាសូបមា បញ្ចកាមគុណមានគួរនោដូចជារណ្តៅរងើកភ្លើង, បុគ្គលអ្នកបរិភោគនូវកាមគុណប្រៀបដូចសត្វ ដែលធ្លាក់ទៅក្នុងរណ្តៅនោះ វិសរុក្ខផលូបមា បញ្ចកាមគុណមានគួរនោដូចផ្លែឈើមានពិស, បុគ្គលអ្នកបរិភោគបញ្ចកាមគុណ ទុកដូចអ្នកបរិភោគនូវផ្លែឈើនោះ, អសូបមា បញ្ចកាមគុណមានឧបមាដូចជាដាវលំពែង, បុគ្គលអ្នកបរិ-ភោគនូវកាមគុណ ប្រៀបដូចជនអ្នកត្រូវប្រហារដោយគ្រឿងសាស្ត្រាវុធនោះ, ទុក្ខរាសី កាមគុណជាគំនរនៃសេចក្តីទុក្ខ បុគ្គលអ្នកបរិភោគកាមគុណរមែងបានសេចក្តីទុក្ខជាអនេកប្បការ ពុំដឹងបើនឹងពណ៌នាត្រារាប់បានឡើយ ។

## អត្តកិលមថានុយោគ

អត្តកិលមថានុយោគ គឺសេចក្តីប្រតិបត្តិប្រកបខ្លួនឲ្យនឿយហត់ឥតអំពើ, ខុសបែបទាស់ទំនង, កន្ទងធម្មតាវិស័យ, រំលងសេចក្តីពិត, ឥតផលប្រយោជន៍ ជាសេចក្តីប្រតិបត្តិក្រៅព្រះពុទ្ធសាសនា យ៉ាងលទ្ធិនិ-គ្រន្ថតិរ្ថិយជាដើម ។

ឯនិគ្រន្ថតិរ្ថិយទាំងឡាយ ពួកខ្លះប្រកាន់អចេលកវត្ត ស្រាតជានិច្ច, ពួកខ្លះប្រកាន់ឯកាគារិកវត្ត ប្រព្រឹត្តទទួលភត្តតែក្នុងផ្ទះមួយ, ពួកខ្លះប្រព្រឹត្តបរិភោគអាហារតែមួយពំនូតមួយថ្ងៃ, ពួកខ្លះប្រព្រឹត្ត

ទទួលភត្តតែអំពីស្ត្រីម្នាក់, ពួកខ្លះប្រព្រឹត្តបរិភោគអាហារតែម្តងហើយឈប់ខានបរិភោគ ១០ ថ្ងៃខ្លះ កន្លះខែខ្លះ ពួកខ្លះប្រព្រឹត្តបរិភោគតែបាយស្រងែ, ពួកខ្លះបរិភោគតែកុណ្ឌក, ពួកខ្លះបរិភោគតែអង្ករ, ពួកខ្លះទៀតប្រព្រឹត្តស្លៀកសំបកក្រថៅ, ពួកខ្លះស្លៀកសំពត់ជាវិការនៃសក់មនុស្ស, ពួកខ្លះប្រព្រឹត្តដេកក្នុងបន្លា, ពួកខ្លះទៀតប្រព្រឹត្តដេកក្បែរភ្នក់ភ្លើង, ពួកខ្លះព្រលាំងខ្លួនដោយធូលី, ការដែលប្រព្រឹត្តដូច្នេះ ព្រោះយល់ឃើញថាជាគ្រឿងសម្រុតសម្រកកិលេស ។ លទ្ធិទាំងអម្បាលនេះ នរណាប្រព្រឹត្តតាម ឈ្មោះថាស្វែងរកសុខខុសទំនង រមែងនាំមកនូវសេចក្តីទុក្ខវិញ, **សវិសកុឡោ វិយ** ដូចជាបុគ្គលបរិភោគស្ករអំពៅលាយដោយថ្នាំពិស, **ខរភេសជ្ជយោជិតបូតិមុត្តំ វិយ** ពុំនោះសោតដូចបុគ្គលផឹកទឹកមូត្រស្អុយលាយដោយថ្នាំពិសដ៏ក្លាខ្លាំង, **សលភានំ វិយ អគ្គិម្ហិ បតនំ** ដូចជាសត្វមមាចហើរចូលភ្លើង, **អសិវិសគ្គហណំ វិយ** ដូចបុគ្គលប្រឡូចាប់ពស់ក្នុងទីងងឹត, **បចាតេ បតិតោ វិយ** ពុំនោះសោតដូចបុគ្គលដែលធ្លាក់ចុះក្នុងជ្រោះជ្រៅ, អ្នកដែលប្រកាន់លទ្ធិបែបនេះពុំអាចនឹងរើខ្លួនចេញចាកវដ្តទុក្ខបានឡើយ ។

សេចក្តីប្រតិបត្តិទាំង ២ យ៉ាងនេះលោកឲ្យឈ្មោះថាអន្តប្បដិបត្តិ ប្រែថាសេចក្តីប្រតិបត្តិអមខាង ព្រោះជាការឃ្លាងទំនងសេចក្តីសុខ ឬជាដំណើរឃ្លាងចាកផ្លូវទៅកាន់ព្រះនិព្វាន, ជាសេចក្តីប្រតិបត្តិនាំឲ្យផលទន្ទុកនិងសេចក្តីទុក្ខជាដរាប, សត្វណាមួយប្រាថ្នារកសន្តិសុខ គប្បីគេចវេះចាកផ្លូវ

ទាំងគូនេះ ហើយត្រាច់ទៅតាមគន្លងឧជុវិថី គឺមជ្ឈិមាបដិបទា ទើបអាចផុតចាកសេចក្ដីទុក្ខសព្វប្រការបាន ។

## មជ្ឈិមាបដិបទា

**មជ្ឈិមាបដិបទា** គឺសេចក្ដីប្រតិបត្តិកណ្ដាល ជាដំណើរឆ្ពោះទៅកាន់ឋានសិវមោក្ខ គឺ អមតមហានិព្វាន, បានដល់សេចក្ដីប្រតិបត្តិប្រកបដោយអង្គ ៨ ប្រការគឺ **សម្មាទិដ្ឋិ** សេចក្ដីយល់ត្រូវ, **សម្មាសង្កប្បោ** សេចក្ដីត្រិះរិះត្រូវ, **សម្មាវាចា** ពាក្យសម្ដីត្រូវ **សម្មាកម្មន្តោ** ការងារត្រូវ, **សម្មាអាជីវោ** ការចិញ្ចឹមជីវិតត្រូវ, **សម្មាវាយាមោ** ការព្យាយាមត្រូវ, **សម្មាសតិ** សេចក្ដីរឭកត្រូវ, **សម្មាសមាធិ** ការតម្កល់ចិត្តត្រូវ ។

**អដ្ឋង្គិកោ មគ្គោ** ព្រះអដ្ឋង្គិកមគ្គនេះ **អរិយោ** ជាធម៌ដ៏ប្រសើរ, ជាធម៌អាចកម្ចាត់បង់នូវសឹកសត្រូវទាំងឡាយ **ចក្កវត្តិ វិយ** បីដូចជាស្ដេចចក្រពត្រាធិរាជ ដែលអាចកម្ចាត់បង់នូវអរិរាជ (ស្ដេចសត្រូវ) ទាំងពួងបាន, ព្រះអដ្ឋង្គិកមគ្គនេះជាទីប្រជុំនៃពោធិបក្ខិយធម៌ទាំងពួង **សមុទ្ទោ វិយ** បីដូចជាសមុទ្រជាទីប្រជុំនៃមេទឹកដែលហូរប្រសប់មកពីទិសនានា, ជាកំពូលបំផុតនៃកុសលធម៌ទាំងពួង **មណិជុចោ វិយ** បីដូចជាកំពូលនៃវេជយន្តប្រាសាទជាវិការៈនៃកែវមណីរបស់ស្ដេច

អម្រិន្ទ្រាធិរាជ, **សព្វកាមទទោ មណិ វិយ** ជាធម៌អាចឲ្យសម្រេចនូវសេចក្តីប្រាថ្នាសព្វយ៉ាង បីដូចជាកែវមណិជោតិរបស់ស្តេចចក្រពត្រាធិរាជ, **ឯតានិសំយានំ** ព្រះអដ្ឋង្គិកមគ្គនេះទុកដូចជាយានដ៏ឧត្តម សម្រាប់ផ្ទុកសត្វទៅកាន់អម្រឹតបូរី គឺព្រះនិព្វាន ។

## (៣) វិនិច្ឆ័យបទថា "ញាយប្បដិបន្នោ"

### ពាក្យសួរដែលគួរចាំ

*១- សេចក្តីប្រតិបត្តិដូចម្តេច ហៅថា ញាយប្បដិបត្តិ?*

*២- អ្វីហៅថានិព្វាន, និព្វានមានគុណគួរប្រាថ្នាដូចម្តេច?*

*៣- បុគ្គលដែលប្រតិបត្តិគួរដល់ញាយប្បដិបត្តិហៅថាអ្វី?*

### ពាក្យឆ្លើយ

*១- សេចក្តីប្រតិបត្តិគួរដល់ព្រះនិព្វាន ហៅថា ញាយប្បដិបត្តិ។*

*២- ការក្ស័យ រាគៈ ទោសៈ មោហៈ ហៅថានិព្វានៗបានសេចក្តីសុខសុទ្ធជាគុណគួរប្រាថ្នា ។*

*៣- បុគ្គលប្រតិបត្តិគួរដល់ញាយប្បដិបត្តិហៅថា "ញាយប្បដិបន្នោ"។*

### សេចក្តីអធិប្បាយ

*ពាក្យថា "ញាយ" នេះជានាមព្រះនិព្វាន, សេចក្តីប្រតិបត្តិគួរដល់ព្រះនិព្វាន ហៅថា ញាយប្បដិបត្តិ, បុគ្គលដែលប្រតិបត្តិគួរដល់ព្រះនិព្វានហៅថា "ញាយប្បដិបន្នោ" ។*

*ពាក្យថា* **"ញាយប្បដិបន្នោ"** *នេះ ជានាមព្រះអរិយបុគ្គលមានសោតាបន្នជាដើម ព្រោះលោកប្រតិបត្តិចុះស៊ប់ក្នុងប្រឡាយនៃព្រះនិព្វានហើយ ឯបុថុជ្ជន ទោះបីប្រតិបត្តិតាមលំអាន អដ្ឋង្គិកមគ្គ ដើម្បីប្រាថ្នាយកព្រះនិព្វានក៏ដោយ ក៏ពុំទាន់ចាត់បានថា "ញាយប្បដិបន្នោ"*

នៅឡើយ ព្រោះនៅមានគតិពុំទាន់ទៀងដូចព្រះអរិយបុគ្គល, ឯព្រះអរិយបុគ្គលលោកមានគតិទៀងតែនឹងបានសម្រេចព្រះនិព្វាន បើយូរណាស់ត្រឹម ៧ ជាតិទៀតប៉ុណ្ណោះឯង ។

ញាយប្បដិបត្តិនេះ នឹងហៅថា អនុលោមប្បដិបទាក៏បាន ព្រោះជាសេចក្ដីប្រតិបត្តិទន់ទោរទៅរកព្រះនិព្វាន ឬនឹងហៅថា អបច្ចនីកប្បដិបទាវិញក៏សម ព្រោះជាសេចក្ដីប្រតិបត្តិមិនជាសឹកសត្រូវ, មិនជាទីរង្កៀសដល់ជនដទៃ ។ សមដូចពុទ្ធភាសិតថា សមណីធ អរណា លោកេ សមណៈទាំងឡាយ មិនជាសឹកសត្រូវក្នុងលោក គឺថា សមណៈទោះបីនៅក្នុងស្រុកក្ដី, ក្នុងព្រៃក្ដី រមែងមិនជាទីតក់ស្លុតភិតភ័យដល់សត្វដទៃ ព្រោះលោកមានព្រះទ័យដោកដោយព្រហ្មវិហារទាំង ៤, អាចចែករំលែកសេចក្ដីសុខដល់សត្វដទៃឥតបើប្រមាណ, សត្វណាមួយបានចួបប្រទះនឹងសមណៈដូច្នោះ ចាត់ថាជាមង្គលដ៏ឧត្ដម ។

# (៤) វិនិច្ឆ័យបទថា "សាមីចិប្បដិបន្នោ"

## ពាក្យសួរដែលគួរចាំ

*១- អ្វីហៅថា សាមីចិកម្ម?*

*២- ប្រតិបត្តិដូចម្ដេច ហៅថា សាមីចិប្បដិបន្នោ?*

*៣- បុគ្គលប្រព្រឹត្តខ្លួនគួរដល់សាមីចិកម្ម ហៅថាអ្វី?*

## ពាក្យឆ្លើយ

*១- អំពើដែលប្រព្រឹត្តគោរព កោតក្រែង, គួរសម, អើពើ ហៅថា សាមីចិកម្ម ។*

*២- សេចក្ដីប្រតិបត្តិគួរដល់សាមីចិកម្ម ហៅថា សាមីចិប្បដិបត្តិ ។*

*៣- បុគ្គលដែលប្រព្រឹត្តខ្លួនសមរម្យគួរដល់សាមីចិកម្ម ហៅថា សាមីចិប្បដិបន្នោ ។*

## សេចក្ដីអធិប្បាយ

*ពាក្យថា "សាមីចិកម្ម" បានដល់អំពើនៃបុគ្គលដែលមានចិត្តជ្រះថ្លា ប្រព្រឹត្តលំឱតលំឱន ទន់ភ្លន់ សម្ដែងអាការរាក់ទាក់ដោយកាយ ដែលប្រកបដោយមេត្តាកាយកម្ម មានប្រណម្យអញ្ជលីថ្វាយបង្គំនឹងក្រោកទទួលជាដើម ឬសម្ដែងអាការស្រាកស្រួលទទួលដោយវាចាដែលប្រកបដោយមេត្តាវចីកម្ម, ដែលពោលពាក្យជាបិយវាចាជាដើម, ពុំនោះសោត*

សម្តែងសេចក្តីស្មោះសរ ដោយចិត្តដែលប្រកបដោយមេត្តាមនោកម្មមាននឹកថា "សូមឲ្យប្រកបដោយសេចក្តីសុខ-ចម្រើនជាដើម" ។

ន័យមួយទៀតថា សាមីចិកម្ម បានដល់ សីល-សមាធិ-បញ្ញា ព្រះអរិយបុគ្គលដែលប្រព្រឹត្តត្រូវពេញតាមគន្លង សីល-សមាធិ-បញ្ញា ហៅថា "សាមីចិប្បដិបន្នោ" ។

ពិតដូច្នោះមែន, ព្រះសង្ឃជាសាវ័កនៃព្រះមានជោគ ដែលលោកបានដល់ឋានៈដ៏ខ្ពង់ខ្ពស់ជាអរិយសាវ័ក ព្រោះអាស្រ័យត្រៃសិក្ខាបរិបូណ៌គួរដល់ថ្នាក់នេះឯង ប្រសិនបើគុណជាតិទាំង ៣ នេះណាមួយទន់ខ្សោយក៏ពុំអាចនឹងសម្រេចអរិយមគ្គបាន ហេតុនេះឯងទើបបាននាមថា "សាមីចិប្បដិបន្នោ" ។

## (៥) វិនិច្ឆ័យបទថា "អាហុនេយ្យោ"

### ពាក្យសួរដែលគួរចាំ

១- អ្វីហៅថា អាហុនវត្ថុ បានដល់វត្ថុអ្វី?

២- បុគ្គលដូចម្តេចទើបហៅថា អាហុនេយ្យបុគ្គល?

៣- ហេតុអ្វីក៏ព្រះសង្ឃគួរទទួលយកនូវអាហុនវត្ថុ?

### ពាក្យឆ្លើយ

១- វត្ថុដែលគេនាំយកមកបូជា ហៅថា អាហុនវត្ថុ បានដល់ចតុប្បច្ច័យ ។

២- បុគ្គលដែលគួរទទួលយកនូវអាហុនវត្ថុ ហៅថា អាហុនេយ្យោ ។

៣- ព្រោះលោកអាចញ៉ាំងវត្ថុនោះឲ្យមានផលវិសេសដល់ទាយក ។

### សេចក្តីអធិប្បាយ

ក៏ពាក្យថា "អាហុនេយ្យោ" នេះជានាមព្រះអរិយសង្ឃដែលគួរទទួលយកនូវអាហុនវត្ថុគឺចតុប្បច្ច័យ ដែលទាយក-ទាយិកាអ្នកប្រាថ្នាបុណ្យកុសលខំខ្មីឃ្មាតសង្វាតមកអំពីឋានទានា សំដៅរកលោកអ្នកបរិបូណ៌ដោយសីលហើយបង្អោនចូលមកបូជា, ព្រោះលោកអាចញ៉ាំងសេចក្តីប្រាថ្នារបស់ទាយក-ទាយិកានោះឲ្យសម្រេចបាន ។

ន័យមួយទៀតថា "អាហុនេយ្យោ" នេះ ចួនកាលលោកហៅថា

"អាហវនីយោ" វិញ សម្គាល់សេចក្តីថា "ព្រះសង្ឃជាទីបូជា" ព្រោះថាសម្បត្តិគ្រប់យ៉ាងដែលទាយកនាំមកអំពីទីឆ្ងាយ ជាវត្ថុគួរគប្បីបូជាចំពោះព្រះសង្ឃនេះ ឬថា លោកគួរទទួលយកនូវអាហវនីយវត្ថុដែលទេពនិករទាំងឡាយមានព្រះឥន្ទ្រជាដើមនាំមកបូជា ព្រោះលោកប្រសើរវិសេសជាងទេវតាទាំងឡាយ ហេតុនោះព្រះសង្ឃទើបបាននាមថា "អាហវនីយោ" ។

ចំណែកលទ្ធិព្រាហ្មណ៍ប្រកាន់ថា ភ្លើងណាដែលគេបូជាហើយមានផលច្រើន, ភ្លើងហ្នឹងឲ្យឈ្មោះថា "អាហវនីយោ" ដូច្នោះដែរ ព្រោះវត្ថុដែលគេបូជាហើយក្នុងព្រះសង្ឃមានផលច្រើន ។ សមដូចបទដែលព្រះមានជោគទ្រង់ត្រាស់ថា

សត្វណា (មួយ) បម្រើភ្លើង (បូជាភ្លើង)
ក្នុងព្រៃរាប់រយនៃឆ្នាំ (នឹង) បុគ្គលបូជាដល់
លោកដែលមានខ្លួនចម្រើនហើយ តែមួយអន្ទ
សូម្បីមួយរំពេច, ការបូជានោះប្រសើរជាង,
ការបូជាភ្លើងរាប់រយឆ្នាំ ពុំប្រសើរដូចឡើយ ។

## (៦) វិនិច្ឆ័យបទថា “បាហុនេយ្យោ”

### ពាក្យសួរដែលគួរចាំ

*១- ទានដូចម្តេចដែលហៅថា អាគន្តុកទាន?*

*២- បុគ្គលដូចម្តេចដែលឈ្មោះថា “បាហុនេយ្យបុគ្គល”?*

*៣- ហេតុអ្វីក៏ព្រះសង្ឃគួរទទួលយកនូវអាគន្តុកទានជាងភ្ញៀវ?*

### ពាក្យឆ្លើយ

*១- ទានដែលបម្រុងទុកជូនភ្ញៀវទើបមកដល់ថ្មីហៅថាអាគន្តុកទាន ។*

*២- បុគ្គលដែលគួរទទួលយកនូវអាគន្តុកទានឈ្មោះថា “បាហុនេយ្យបុគ្គល” ។*

*៣- ព្រោះព្រះសង្ឃមានគុណធម៌ល្អជាងភ្ញៀវផង, កម្រនឹងកើតមានផង ។*

### សេចក្តីអធិប្បាយ

*ពាក្យថា “បាហុនេយ្យោ” ជានាមព្រះសង្ឃអ្នកគួរទទួលយកនូវហុនវត្ថុ, បាហុនវត្ថុ បានដល់អាគន្តុកទានដែលគេចាត់ចែងដោយផ្ចិតផ្ចង់ត្រៀមបម្រុងទុកជូនភ្ញៀវដែលជាញាតិមិត្ត ជាទីស្រឡាញ់ពេញចិត្តស្និទ្ធស្នាលទើបនឹងមកដល់អំពីទិសានុទិស, ទានយ៉ាងនេះបើមានព្រះសង្ឃមកដល់ គួរប្រគេនដល់ព្រះសង្ឃវិញ, ព្រះសង្ឃគួរទទួលយកនូវបាហុនវត្ថុ*

នោះជាងភ្ញៀវឯទៀត ព្រោះថាភ្ញៀវដែលមានគុណធម៌ជាគ្រឿងធ្វើខ្លួនឲ្យជាទីស្រឡាញ់ពេញចិត្តស្មើដោយព្រះសង្ឃមិនមានឡើយ, ព្រះសង្ឃកម្រកើតមានណាស់ មួយពុទ្ធន្តរៈទើបកើតមានម្តង ជួនកាលរហូតដល់ទៅអសង្ខេយ្យកប្បទើបជួបប្រទះនឹងព្រះសង្ឃក៏មាន, ចំណែកខាងភ្ញៀវជាញាតិមិត្តរមែងបានជួបប្រទះជានិច្ច, បើថ្ងៃនេះឃ្លាតគ្នាទៅថ្ងៃក្រោយគង់មកជួបគ្នាវិញ ។

ម្យ៉ាងទៀត ជនជាញាតិធម្មតា បើទុកណាជាបានវត្ថុអ្វីមកផ្ញើមិត្រសំឡាញ់ ក៏បានតែរបស់ដែលត្រូវបរិភោគប្រើប្រាស់បានក្នុងអត្តភាពមួយប៉ុណ្ណោះ, ចំណែកភ្ញៀវគឺព្រះសង្ឃវិញ រមែងបានវត្ថុដែលមានខ្លឹមសារ អាចបរិភោគបានតាំងអំពីជាតិជាបច្ចុប្បន្នរហូតដល់បច្ឆិមជាតិគឺជាតិដែលបានសម្រេចព្រះនិព្វានជាអវសាន, ហេតុនោះ ព្រះសង្ឃទើបបាននាមថា "បាហុនេយ្យោ" ។

ន័យមួយទៀតថា **"ចាហុនេយ្យោ"** នេះ ជួនកាលលោកហៅថា **"ចាហវនីយោ"** សម្គាល់សេចក្តីថា ព្រះសង្ឃគួរទទួលនូវបុព្វ-ការៈគឺគួរទទួលយកនូវគ្រឿងបូជាដំបូង (វត្ថុបីថ្នោង) មុនជាងជនទាំងអស់ ។

ន័យមួយទៀតថា ព្រះសង្ឃគួរដល់ការរៀបទទួលដោយបការៈ

ទាំងពួង, ហេតុនោះទើបបាននាមថា “បាហវនីយោ” ។

បទថា **“ចាហវនីយោ”** លោកហៅថា “បាហុនេយ្យោ” វិញដោយអធិប្បាយដូច្នេះឯង ។

## (៧) វិនិច្ឆ័យបទថា "ទក្ខិណេយ្យោ"

### ពាក្យសួរដែលគួរចាំ

១- ដូចម្ដេចដែលហៅថា ទក្ខិណាទាន?

២- ទក្ខិណាទានដែលមានផលច្រើនប្រកបដោយអង្គប៉ុន្មាន?

៣- ដូចម្ដេចទើបហៅថា ទក្ខិណេយ្យបុគ្គល?

### ពាក្យឆ្លើយ

១- ទានដែលបុគ្គលជឿកម្មនិងផលរបស់កម្មហើយធ្វើ ហៅថាទក្ខិណាទាន ។

២- ទក្ខិណាទានដែលមានផលច្រើនប្រកបដោយអង្គ ៦ ។

៣- បុគ្គលដែលគួរទទួលនូវទក្ខិណាទានហៅថា ទក្ខិណេយ្យបុគ្គល ។

### សេចក្ដីអធិប្បាយ

ពាក្យថា "**ទក្ខិណេយ្យោ**"នេះ ជានាម ព្រះសង្ឃដែលគួរទទួលយកនូវទក្ខិណាទាន ។ ទក្ខិណាទានប្រែថាទានដែលចម្រើនដោយសម្បត្តិសព្វយ៉ាងតាមសមគួរដល់សេចក្ដីប្រាថ្នា, បានដល់ទានដែលបុគ្គលឲ្យដោយជឿកម្មនិងផលនៃកម្មថា អំពើល្អឲ្យផលល្អ, អំពើអាក្រក់ឲ្យផលអាក្រក់, សត្វមានកម្មជារបស់ខ្លួន មានកម្មជាទ្រព្យមតិក, មានកម្មជាកំណើត, មានកម្មជាផៅពង្ស, មានកម្មជាទីពឹងអាស្រ័យ អាត្មាអញធ្វើ

*នូវអំពើណា ទោះជាអំពើល្អក្តី, អាក្រក់ក្តី, អាត្មាអញនឹងបានជាអ្នកទទួលនូវផលនៃអំពើកម្មនោះពុំខានឡើយ, ការដែលជឿដូច្នេះហើយបរិច្ចាគទានទាននោះឯងលោកហៅថា ទក្ខិណាទាន ។ ទក្ខិណាទានដែលនឹងមានផលច្រើនលុះតែប្រកបដោយអង្គ ៦ ប្រការគឺអង្គខាងទាយក ៣ ប្រការ, ខាងបដិគ្គាហកៈ ៣ ប្រការ ។*

អង្គរបស់ទាយក ៣ ប្រការគឺ

១- **បុព្វេវ ទានា សុមនោ ហោតិ**(១) *បុគ្គលមានចិត្តល្អក្នុងកាលមុនឲ្យ*

២- **ទទំ ចិត្តំ បសាទេតិ**(២) *មានចិត្តជ្រះថ្លាក្នុងកាលកំពុងឲ្យ*

៣- **ទត្វា អត្តមនោ ហោតិ**(៣)*លុះឲ្យរួចហើយមានចិត្តជ្រះថ្លា ។*

អង្គរបស់បដិគ្គាហក ៣ ប្រការគឺ

១- **វីតរាគា វា ហោន្តិ រាគវិនយាយ វា បដិបន្នា** *លោកដែលប្រាសចាករាគៈហើយ ឬដែលកំពុងប្រតិបត្តិដើម្បីកម្ចាត់រាគៈ*

---

១-២-៣ អង្គខាងទាយកទាំង ៣ នេះ អង្គទី ១ មានន័យពន្យល់ថា ទាយកត្រូវតាំងចិត្តផ្តងបុព្វចេតនាទុកមុនមួយខែឬកន្លះខែមកថា អាត្មាអញនឹងបានកប់កំណប់ទ្រព្យជាអនុគាមក ដែលជាហេតុនៃសម្បត្តិសព្វយ៉ាងទុក ។ អង្គទី ២ ថា អាត្មាអញបានដកហូតយកទ្រព្យឥតខ្លឹមសារបំណាយធ្វើទានជារបស់មានខ្លឹមសារ ។ អង្គទី ៣ ថា ត្រូវមានបីតិសោមនស្សរីករាយក្នុងចិត្តថា អាត្មាអញមិនបានរំលងបញ្ញត្តិរបស់បណ្ឌិត ។

២- **វីតទោសា វា ហោន្តិ ទោសវិនយាយ វា បដិបន្នា** *លោកដែលប្រាសចាកទោសៈហើយ ឬកំពុងប្រតិបត្តិដើម្បីកម្ចាត់ទោសៈ*

៣- **វីតមោហា វា ហោន្តិ មោហវិនយាយ វា បដិបន្នា** *លោកដែលប្រាសចាកមោហៈហើយ ឬកំពុងប្រតិបត្តិដើម្បីកម្ចាត់មោហៈ ។*

*ទក្ខិណាទានដែលប្រកបដោយអង្គ ៦ ប្រការនេះ មានគុណានិសង្ស នឹងរាប់នឹងប្រមាណពុំបាន គ្រាន់តែកំណត់បានថាជាគំនរបុណ្យធំប៉ុណ្ណោះ, ប្រៀបដូចជាទឹកមហាសមុទ្រ ដែលបុគ្គលមិនអាចនឹងរាប់ថា ប៉ុណ្ណោះប៉ុណ្ណោះអាឡ្ហក*[១] *បានដូច្នោះ, គ្រាន់តែកំណត់បានថា គំនរទឹកធំ (អន្លង់ទឹកធំ) ប៉ុណ្ណោះឯង ។*

*ប៉ុន្តែទោះបីបុគ្គលបានបដិគ្គាហកបរិបូណ៌ ដោយគុណសម្បត្តិជាព្រះអរហន្តខីណាស្រពយ៉ាងនេះក៏ដោយ, ប្រសិនបើទាយកមិនឈ្វាសធ្វើទានដោយតាំងចិត្តចំពោះរូបជាបាដិបុគ្គលិក ក៏គង់មានផលខ្សោយជាងសង្ឃគតាទក្ខិណាទាន, ព្រោះព្រះមានជោគទ្រង់ត្រាស់ថា*

**ន ត្វេវាហំ អានន្ទ កេនចិ បរិយាយេន សង្ឃគតាយ ទាដិបុគ្គលិកទានំ មហប្ផលតរំ វទាមិ** *ម្នាលអានន្ទ*

---

១- ពាក្យថា “អាឡ្ហក” ជាឈ្មោះមាត្រាសម្រាប់វាល់ក្នុងសម័យបុរាណ ក្នុង ១ អាឡ្ហកត្រូវ ១៦ នាឡិ ។

តថាគត ពុំដែលពោល (សរសើរ) បាដិបុគ្គលិកទានថាមានផលច្រើនវិសេសជាងសង្ឃគតាទក្ខិណាទាន ដោយបរិយាយណាមួយឡើយ ។

ឯសង្ឃទាន ឬសង្ឃគតាទក្ខិណាទាននោះ គឺទានដែលបុគ្គលធ្វើដោយតាំងចិត្តឧទ្ទិសចំពោះសង្ឃ, ប្រារព្ធយកសង្ឃជាធំ, ស្រេចលើសង្ឃចាត់ឲ្យ, បានលោកអង្គណា ទទួលយកលោកអង្គនោះ ទោះបីលោកដែលសង្ឃចាត់ឲ្យមកនោះ ជាសាមណេរក្តី, ភិក្ខុទើបបានឧបសម្បទក្តី ភិក្ខុក្មេងក្តី, ភិក្ខុចាស់ក្តី, ភិក្ខុល្ងង់ក្តី, ភិក្ខុប្រាជ្ញក្តីក៏ទទួលយកដោយពេញចិត្តឥតរង្កៀស, ត្រូវនឹកប្រារព្ធដល់គុណព្រះសង្ឃមាន "សុប្បដិបន្នោ" ជាប្រធាន ។ ក៏ទានដែលបុគ្គលធ្វើចំពោះសមណបុថុជ្ជនដោយសេចក្តីគោរពក្នុងសង្ឃ, ប្រារព្ធយកសង្ឃជាធំយ៉ាងនេះ មានផលដ៏វិសេសជាងបាដិបុគ្គលិទាន ដែលបុគ្គលធ្វើចំពោះព្រះអរិយសង្ឃមានសោតាបន្នជាដើម, ព្រោះប្រកបដោយហេតុ ២ ប្រការគឺ រូបសមណៈនោះទាយកនិមន្តមកដោយឧទ្ទិសអំពីសង្ឃផង, តាំងចិត្តថាបានថ្វាយទានដល់សង្ឃផង ។

ប្រសិនបើមានពាក្យសួរជ្រែកមកថា បើទានដែលទាយកធ្វើហើយចំពោះបុគ្គលទ្រុស្តសីលដែលបានឧទ្ទិសមកអំពីសង្ឃ មានផលដ៏វិសេសជាងទានថ្វាយចំពោះព្រះអរិយបុគ្គល, ចុះព្រះពុទ្ធដីកាថា "**សីល-វតោ ខោ មហារាជ ទិន្នំ មហប្ផលំ នោ តថា ទុស្សីលស្ស**

បពិត្រមហារាជ ទានដែលបុគ្គលឲ្យហើយចំពោះបុគ្គលមានសីល មានផលច្រើន, ទានដែលបុគ្គលឲ្យហើយដល់បុគ្គលទ្រុស្តសីល មិនមានផលច្រើនដូច្នោះឡើយ" តើពាក្យនេះដូចម្តេចទៅ? ត្រូវឆ្លើយថា ព្រះពុទ្ធដីកាដែលសម្តែងដូច្នោះចំពោះតែបាដិបុគ្គលិកទានដូចគ្នាទេ, មិនទាក់ទងដល់សង្ឃទានផងឡើយគឺថាបើទាយកធ្វើបាដិបុគ្គលិកទានចំពោះភិក្ខុមានសីល មានផលច្រើនជាងធ្វើទានចំពោះភិក្ខុទ្រុស្តសីល ចំណែកសង្ឃទានវិញ មិននិយមរូបបុគ្គលដូច្នោះឡើយ ទោះបីទាយកធ្វើនឹងព្រះសង្ឃបុថុជ្ជនក្តី ព្រះអរិយសង្ឃក្តី បានផលច្រើនដូចគ្នា, ព្រោះបានតាំងចិត្តចំពោះសង្ឃគុណមានសុប្បដិបន្នោ ជាអាទិ៍តែម៉្យាង ។

សង្ឃទាននេះ មានវិភាគតាមប្រភេទនៃបដិគ្គាហក (អ្នកទទួលទាន) ជា ៧ គឺ ឧភតោសង្ឃ មានព្រះពុទ្ធជាប្រធាន ១, ឧភតោសង្ឃ ១, ភិក្ខុសង្ឃ ១, ភិក្ខុនីសង្ឃ ១, បុគ្គលដែលឧភតោសង្ឃបាត់ឲ្យ ១, បុគ្គលដែលភិក្ខុសង្ឃបាត់ឲ្យ ១, បុគ្គលដែលភិក្ខុនីសង្ឃបាត់ឲ្យ ១ ។

### ទក្ខិណាវិសុទ្ធិ ៤ ប្រការ

ទក្ខិណាទាននេះ មានសេចក្តីបរិសុទ្ធប្លែកគ្នាជា ៤ ប្រការគឺ

១- បរិសុទ្ធព្រោះទាយក មិនបរិសុទ្ធព្រោះបដិគ្គាហក គឺទាយកមានសីល មានកល្យាណធម៌, បដិគ្គាហកទ្រុស្តសីល ឥតកល្យាណធម៌ ។

២- បរិសុទ្ធព្រោះបដិគ្គាហកៈ មិនបរិសុទ្ធព្រោះទាយក គឺបដិគ្គាហកៈ មានសីល មានកល្យាណធម៌, ទាយកទ្រុស្តសីល ឥតកល្យាណធម៌ ។

៣- មិនបរិសុទ្ធព្រោះទាយកផង, ព្រោះបដិគ្គាហកផង គឺទាយកទ្រុស្តសីល ឥតកល្យាណធម៌, បដិគ្គាហកក៏ទ្រុស្តសីល ឥតកល្យាណធម៌ ។

៤- បរិសុទ្ធព្រោះទាយកផង, ព្រោះបដិគ្គាហកផង គឺទាយកក៏មានសីល មានកល្យាណធម៌, បដិគ្គាហកក៏មានសីល មានកល្យាណធម៌ ។

បណ្ដាទានដែលបរិសុទ្ធប្លែកគ្នាទាំង ៤ នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរទានទី ៤ ថាមានផលវិសេសវិសាលជាងទានទាំង ៣ ខាងដើមនេះ ។

ព្រះសង្ឃគួរទទួលយកនូវទក្ខិណាទានដ៏វិសេសដូច្នេះឯង ទើបបាននាមថា "ទក្ខិណេយ្យា" ។

## (៨) វិនិច្ឆ័យបទថា "អញ្ជលិករណីយោ"

---

## ពាក្យសួរដែលគួរចាំ

*១- ដូចម្តេចហៅថា  អញ្ជលិកម្ម?*

*២- ព្រះសង្ឃ ព្រោះហេតុអ្វី  ទើបគួរដល់អញ្ជលិកម្ម?*

*៣- បើយើងមិនធ្វើអញ្ជលិកម្ម  ដល់ព្រះសង្ឃ  តើខាស់ខុសអ្វី?*

## ពាក្យឆ្លើយ

*១- ការលើកដៃប្រណម្យថ្វាយបង្គំ ហៅថា  អញ្ជលិកម្ម ។*

*២- ព្រះសង្ឃមានគុណធម៌ដ៏ខ្ពង់ខ្ពស់ទើបគួរដល់អញ្ជលិកម្ម ។*

*៣-  បើយើងមិនធ្វើអញ្ជលិកម្មដល់ព្រះសង្ឃឈ្មោះថាមិន  គោរព ដល់ព្រះរត្នត្រ័យ  ។*

## សេចក្តីអធិប្បាយ

*បុគ្គលដែលគួរសត្វលោកលើកអញ្ជលីប្រណម្យ  ដោយចិត្តជ្រះថ្លាហៅ ថា  "អញ្ជលិករណីយោ"  ពាក្យនេះជាឈ្មោះព្រះសង្ឃដែលលោកមាន ឥន្រ្ទិយស្រគត់ស្រគំ  គួរជានយនាភិសេករបស់សាកលលោកដែលក្រឡេក ឃើញហើយមើលមិនចង់ដាក់ភ្នែក,  ការបានជួបប្រទះព្រះសង្ឃយ៉ាងនេះ, ចាត់ជាបុញ្ញលាភដ៏ឧត្តមបំផុត,  កុលបុត្រណាមួយប្រាថ្នាប្រយោជន៍ដើម្បី ខ្លួន  កាលបើបានឃើញភិក្ខុសង្ឃមានសីលនិមន្តមកហើយ  បើមាន*

ទេយ្យទានគួរប្រគេនបានគប្បីប្រគេនតាមកម្លាំង, បើមិនមានទេ គប្បីថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ពុំនោះសោតគប្បីប្រណម្យអញ្ជលីសំពះ, បើធ្វើដូច្នោះមិនកើត គប្បីក្រឡេកមើលដោយបិយចក្ខុប្រកបដោយចិត្តជ្រះថ្លា, ដោយកម្លាំងបុញ្ញានុភាពមានទស្សនកិច្ចជាមូលយ៉ាងនេះ (កុលបុត្រនោះ) នឹងមានចក្ខុឥតរោគ ឥតទោសគឺឥតមានដុះកន្ទុយថ្ងៃន, ឥតមានផ្កូត ជាភ្នែកប្រកបដោយសេរីបញ្ចពណ៌ថ្លាយង់ហាក់ដូចទ្វារជាវិការនៃកែវមណីបើកចំហ នៅនារតនវិមានរាប់ពាន់ជាតិជាអនេក, មិនត្រឹមតែប៉ុណ្ណោះ នឹងបានសម្បត្តិសព្វប្រការក្នុងទេវលោកនិងមនុស្សលោក អស់កាលប្រមាណ ១ សែនកប្ប ។

ម្យ៉ាងទៀត អញ្ជលិកម្មនេះ ជាកិច្ចមួយដ៏សំខាន់ក្នុងព្រះពុទ្ធសាសនា, ជនានុជនណាមួយ ប្ដេជ្ញាខ្លួនដល់ព្រះរត្នត្រ័យហើយខានធ្វើកិច្ចនេះពុំបាន វៀរលែងតែសម័យធ្វើពុំកើត, ព្រោះថាការដែលធ្វើដូច្នោះ ដើម្បីនឹងសម្ដែងខ្លួនបញ្ជាក់ឲ្យដឹងថា ជាអ្នកទម្លាក់មានះ បោលស្រឡះហើយ, ជាអ្នកកាន់ព្រះពុទ្ធសាសនាដោយស៊ប់សួន, ជាអ្នកប្រព្រឹត្តខ្លួនគួរឲ្យព្រះរត្នត្រ័យប្រោសប្រាណបាន, ប្រសិនបើមិនធ្វើវិញ នឹងចាត់ឲ្យឈ្មោះថាជាពុទ្ធសាសនិកជនពិតប្រាកដពុំបាន ព្រោះសម្ដែងអាការឆ្មើងកន្ទ្រើងចំពោះព្រះរត្នត្រ័យឬនឹងឲ្យឈ្មោះថាជាអ្នកកាន់សាសនាស្ទើរក៏បាន ព្រោះខូះអង្គសរណគមន៍[១] ទី ៤ ។ ព្រោះហេតុនោះពុទ្ធមាមកជនអ្នករាប់អាន

១- អង្គសរណគមន៍ទី ៤ មានមកហើយក្នុងធម្មរតនវិនិច្ឆ័យ ត្រង់ប្រភេទនៃសរណគមន៍ ។

ព្រះពុទ្ធសាសនា គួរគប្បីលើកហត្ថាប្រណម្យអញ្ជលីដល់ព្រះរត្នត្រ័យកុំខាន ព្រោះជាហេតុនាំឲ្យបានសេចក្តីសុខជាអនេកទៅអនាគតដូចបានពណ៌នាមកនេះ ។

(៩) វិនិច្ឆ័យបទថា "អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស"

ពាក្យសួរដែលគួរចាំ

*១- អ្វីជាបុញ្ញក្ខេត្តរបស់សត្វលោក?*

*២- អ្វីជាពូជសម្រាប់ព្រោះក្នុងស្រែបុណ្យ?*

*៣- ស្រែបុណ្យដែលមានផលបរិបូណ៌បានព្រោះអ្វី?*

ពាក្យឆ្លើយ

*១- ព្រះសង្ឃជាបុញ្ញក្ខេត្តដ៏ឧត្តមរបស់សត្វលោក ។*

*២- ទេយ្យទានជាពូជសម្រាប់ព្រោះក្នុងស្រែបុណ្យ ។*

*៣- ស្រែបុណ្យដែលនឹងមានផលបរិបូណ៌បាន ព្រោះមិនមានស្មៅ គឺកិលេសជាគ្រឿងឲ្យទោស ។*

សេចក្តីអធិប្បាយ

*ព្រះសង្ឃជាបុញ្ញក្ខេត្តរបស់សត្វលោករកខេត្រដទៃផ្ទឹមពុំបាន ព្រោះលោកអាចញ៉ាំងទានរបស់ទាយក ឲ្យមានផលបរិបូណ៌ពេញលេញបាន ប្រៀបដូចស្រែមានដីជាតិ រមែងញ៉ាំងធញ្ញជាតិឲ្យកើតផលបរិបូណ៌ដល់ម្ចាស់ស្រែដូច្នោះ ។ ប្រសិនបើស្រែមិនសូវមានដីជាតិក៏ពុំអាចនឹងញ៉ាំងធញ្ញ-ជាតិឲ្យកើតជាផលសម្បូណ៌ដល់ម្ចាស់ស្រែបាន យ៉ាងណាមិញ, ចំណែកបដិគ្គាហកអ្នកទទួលទានក៏ដូចគ្នា បើជាមនុស្សទ្រុស្តសីល (គ្មានសីល) ឬមានសីលមិនបរិសុទ្ធ ក៏ពុំអាចញ៉ាំងទានវត្ថុឲ្យមានផលបរិបូណ៌ដល់*

*ទាយកដូច្នោះដែរ ។ សមដូចពុទ្ធភាសិតដែលទ្រង់ត្រាស់ចំពោះពុទ្ធ-បរិស័ទប្រារព្ធអង្កុរទេវបុត្រនិងឥន្ទកទេវបុត្រថា :*

ឧដ្ឋក្ខេ យថា ខេត្តេ ពីជំ ពហុំបិ រោបិតំ
ន ផលំ វិបុលំ ហោតិ នបិ តោសេតិ កស្សកំ
តថេវ ទានំ ពហុកំ ទុស្សីលេសុ បតិដ្ឋិតំ
ន ផលំ វិបុលំ ហោតិ នបិ តោសេតិ ទាយកំ

*សេចក្តីថា ពូជ (ធញ្ញជាតិ) សូម្បីមានប្រមាណច្រើន ដែលបុគ្គលព្រោះក្នុងស្រែទួល (ស្រែហែងហួត), (ពូជនោះ) ពុំអាចញ៉ាំងផលឲ្យបរិបូណ៌បាន, ពុំអាចញ៉ាំងម្ចាស់ស្រែឲ្យពេញចិត្តបានយ៉ាងណាមិញ, អំណោយទាន ទោះបីច្រើនគរគោក ដែលបុគ្គលតម្កល់ទុកហើយក្នុងជនទ្រុស្តសីល ក៏ពុំអាចញ៉ាំងផលឲ្យបរិបូណ៌បាន, ពុំអាចញ៉ាំងម្ចាស់ទានឲ្យពេញចិត្តបានដូច្នោះដែរ ។*

យថា បិ ភទ្ទកេ ខេត្តេ ពីជំ អប្បម្បិ រោបិតំ
សម្មា ធារំ បវេច្ឆន្តេ ផលំ តោសេតិ កស្សកំ
តថេវ សីលវន្តេសុ គុណវន្តេសុ តាទិសុ
អប្បកោបិ កតោ ការោ ផលំ តោសេតិ ទាយកំ

*មួយវិញទៀត, ពូជ (ធញ្ញជាតិ) សូម្បីមានប្រមាណតិចដែលបុគ្គលព្រោះហើយ ក្នុងស្រែល្អ (មានជីជាតិ) ពូជនោះ*

អាចបង្ហូរធារផលឲ្យបរិបូណ៌បាន, អាចញ៉ាំងម្ចាស់ស្រែឲ្យពេញចិត្តបាន យ៉ាងណាមិញ, អំណោយទាន សូម្បីមានប្រមាណតិចដែលបុគ្គលធ្វើហើយក្នុងបដិគ្គាហកអ្នកមានសីល, មានគុណធម៌ល្អ អាចញ៉ាំងផលឲ្យបរិបូណ៌, អាចញ៉ាំងម្ចាស់ទានឲ្យពេញចិត្តបានដូច្នោះដែរ ។

ហេតុនោះ ទាយក-ទាយិកាអ្នកប្រាថ្នាផលវិសេសវិសាល គួររិះរកបុញ្ញក្ខេត្រប្រកបដោយសីល, ដោយកល្យាណធម៌ក្នុងព្រះពុទ្ធសាសនា ហើយសឹមធ្វើទានជាការប្រពៃ ព្រោះមានពុទ្ធភាសិតថា :

**វិចេយ្យ ទានំ ទាតព្វំ យត្ថ ទិន្នំ មហប្ផលំ**
**វិចេយ្យ ទានំ សុគតប្បសត្ថំ**
**យេ ទក្ខិណេយ្យា ឥធ ជីវលោកេ**
**ឯតេសុ ទិន្នានិ មហប្ផលានិ**
**ពីជានិ វុត្តានិ យថា សុខេត្តេ ។**

សេចក្ដីថា បុគ្គលគប្បីពិចារណា ពិនិត្យពិច័យហើយសឹមឲ្យ(ទាន) ទានដែលបុគ្គលឲ្យហើយក្នុងបុញ្ញក្ខេត្រឯណាមានផលច្រើន, គប្បីឲ្យក្នុងបុញ្ញក្ខេត្រនោះ, (ព្រោះ) ព្រះតថាគតទ្រង់ត្រាស់សរសើរទាន ដែលបុគ្គលពិចារណាហើយទើបឲ្យ ។

ទក្ខិណេយ្យបុគ្គលពួកណា ដែលមាននៅក្នុងជីវលោក[១]នេះ ទាយក

១- ពាក្យថា “ជីវលោក) ប្រែថាលោកដែលសត្វកំពុងរស់នៅ សំដៅយកជាតិជាបច្ចុប្បន្ន។

ទាយិកាគប្បីថ្វាយទានក្នុងទក្ខិណេយ្យបុគ្គលពួកនោះ ទើបមានផលច្រើន, ប្រៀបដូចពូជស្រូវដែលបុគ្គលព្រោះក្នុងស្រែល្អ (រមែងញ៉ាំងផលឲ្យបរិបូណ៌ដល់ម្ចាស់ស្រែបាន) ។

ន័យមួយទៀត ស្រែដែលនឹងមានផលបរិបូណ៌បាន ព្រោះមិនមានស្មៅដុះក្នុងស្រែ យ៉ាងណាមិញ, ទានដែលនឹងមានផលបរិបូណ៌ ក៏ព្រោះបុញ្ញក្ខេត្តដែលប្រាសតិណជាតិមានរាគៈជាអាទិ៍ដូច្នោះដែរ ។ សមដូចពុទ្ធភាសិតដែលទ្រង់ត្រាស់ទុកថា :

**តិណទោសានិ ខេត្តានិ រាគទោសា អយំ បជា**
**តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ**

សេចក្ដីថា ស្រែទាំងឡាយមានស្មៅជាទោស, ពួកសត្វលោកនេះមានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់បុគ្គលដែលប្រាសចាករាគៈហើយទើបមានផលច្រើន ។

**តិណទោសានិ ខេត្តានិ ទោសទោសា អយំ បជា**
**តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ**

ស្រែទាំងឡាយមានស្មៅជាទោស, ពួកសត្វលោកនេះមានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់បុគ្គលដែលប្រាសចាកទោសៈហើយទើបមានផលច្រើន ។

**តិណទោសានិ ខេត្តានិ មោហទោសា អយំ បជា**
**តស្មា ហិ វីតមោហេសុ ទិន្នំ ហោតិ មហប្ផលំ**

*ស្រែទាំងឡាយមានស្មៅជាទោស, ពួកសត្វលោកនេះមានមោហៈជាទោស, ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់បុគ្គលដែលប្រាសចាកមោហៈហើយ ទើបមានផលច្រើន ។*

**តិណទោសានិ ខេត្តានិ ឥច្ឆាទោសា អយំ បជា**
**តស្មា ហិ វីតឥច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ**

*ស្រែទាំងឡាយមានស្មៅជាទោស, ពួកសត្វលោកនេះមានសេចក្តីឈ្នានីសជាទោស, ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់បុគ្គលដែលប្រាសចាកសេចក្តីឈ្នានីសហើយ ទើបមានផលច្រើន ។*

*ព្រះសង្ឃមានគុណវិសេសជាទីលូតលាស់ដុះដាលនៃបុណ្យដូចពណ៌នាមកនេះ ទើបឈ្មោះថាជាបុញ្ញក្ខេត្តដ៏ឧត្តមរបស់សត្វលោក ។*

## ពាក្យសូត្របេ្តជ្ញា(១) ខ្លួន

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

*ប្រែថា វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ, មានតែព្រះសង្ឃជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា, សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

---

១- ត្រង់ពាក្យសូត្របេ្តជ្ញាខ្លួននេះ អ្នកមើលគប្បីជ្រាបតាមន័យក្នុងពុទ្ធរតនវិនិច្ឆ័យផងចុះ ។

## វិនិច្ឆ័យបទខមាទោសព្រះសង្ឃ

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ**

**សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ ។**

*ប្រែថា ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការគឺ សម្មតិសង្ឃនិងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង, ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះសង្ឃជាម្ចាស់ សូមព្រះសង្ឃជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។*

### ពាក្យសួរដែលគួរចាំ

១- *ទោសបែបណា ដែលភ្លាំងភ្លាត់ក្នុងព្រះសង្ឃហើយរួចរដោះបានដោយវិធីសូមខមាទោស?*

២- *ពុទ្ធសាសនិកជនឃើញព្រះសង្ឃប្រព្រឹត្តល្មើសវិនយប្បញ្ញត្តិ ហើយស្តីរំពុកដាស់តឿនផ្ចាញ់ផ្ចាល់ដោយបំណងល្អ មានទោសឬទេ?*

៣- *វិធីសូមខមាទោសចំពោះព្រះសង្ឃត្រូវធ្វើដូចម្តេចខ្លះ?*

### ពាក្យឆ្លើយ

១- *ទោសដែលប្រព្រឹត្តល្មើសក្នុងព្រះសង្ឃដោយត្រៃទ្វារមានសម្តែងអាការមិនគោរពដោយកាយ, ពោលតិះដៀលដោយវាចាជាដើម អាច*

រួចរដោះបានដោយវិធីសូមខមាទោស ។

២- ពុទ្ធសាសនិកជនស្ដីផ្ចញ់ផ្ចាល់ដើម្បីឲ្យលោកលះគំនិតអាក្រក់ចេញមិនមានទោសទេ ព្រោះរំពុកដោយបំណងល្អ ។

៣- វិធីសូមខមាទោសនោះ ត្រូវសម្ដែងទោសដែលខ្លួនប្រព្រឹត្តកន្លងនោះ ចំពោះភិក្ខុដែលខ្លួនប្រមាថ ឬសង្ឃដទៃក៏បាន ។

## សេចក្ដីអធិប្បាយ

ការដែលប្រព្រឹត្តល្មើសក្នុងព្រះសង្ឃ កើតឡើងដោយសេចក្ដីប្រមាថនិងចេតនាក្ដៅទើបចាត់ថាជាទោសដោយពិត, បើឥតមានសេចក្ដីប្រមាថឬចេតនាក្ដៅទេ ក៏ពុំអាចចាត់ថាជាទោសបានឡើយ ។ សេចក្ដីល្មើសដែលប្រកបដោយចេតនាក្ដៅនោះ បើពានពារទៅលើព្រះអរិយបុគ្គលមានទោសធ្ងន់ជាងសេចក្ដីល្មើសក្នុងព្រះសង្ឃបុថុជ្ជន ព្រោះលោកមានគុណធម៌ខ្ពង់ខ្ពស់ជាង, ដូចយ៉ាងការពោលតិះដៀលព្រះអរិយៈដោយលក្ខណៈជេរ ២ យ៉ាងគឺ អន្តិមវត្ថុ និងកម្ចាត់គុណ[១] លោកហៅអរិយុបវាទកកម្ម

១- សម្ដីដែលជេរថា "លោកមិនមានធម៌សម្រាប់សមណៈទេ, លោកមិនមែនសមណៈទេ, ជួច្នេះឈ្មោះថា អន្តិមវត្ថុ ។ ជេរថា ឈាន វិមោក្ខ មគ្គ ផល មិនមែនមានដល់ពួកលោកនេះទេ ប៉ុណ្ណោះជាដើម ឈ្មោះថាជេរដោយកម្ចាត់គុណ ។

ចាត់ចូលក្នុងពួកអន្តរាយ[១]ទាំង ៥ ទោសនេះមានទម្ងន់ប្រហែលគ្នានឹងអនន្តរិយកម្ម ព្រោះហាមសួគ៌និព្វានដូចគ្នា, ប៉ុន្តែអរិយុបវាទកកម្មត្រឡប់រួចទោសវិញបានដោយវិធីសូមខមាទោស, ឯបញ្ចានន្តរិយកម្មមិនមានរដោះចាកទោសបានដោយវិធីណាមួយសោះឡើយ ។

ចំណែកខាងទោសល្មើសក្នុងព្រះសង្ឃបុថុជ្ជន ពុំអាចនឹងរាប់បញ្ចូលក្នុងអន្តរាយទាំង ៥ ណាមួយបានទេ ព្រោះជាទោសស្រាលបន្តិច តែរួចទោសបានដោយវិធីខមាទោសដូចគ្នា ។

ហេតុនោះ បុគ្គលអ្នកប្រព្រឹត្តល្មើសក្នុងព្រះសង្ឃហើយប្រាថ្នាសេចក្តីបរិសុទ្ធ គប្បីទៅសូមខមាទោសចំពោះមុខភិក្ខុដែលខ្លួនប្រមាថនោះដើម្បីឲ្យលោកអត់ទោសឲ្យ, ប្រសិនបើលោកនៅឆ្ងាយ ទៅមកខ្លួនឯងមិនបាន គប្បីប្រើបម្រើឲ្យទៅសូមខមាទោសជួស ឬផ្ញើសំបុត្រទៅសូមខមាទោសក៏គួរ, ប្រសិនបើលោករូបនោះនិមន្តទៅស្រុកឆ្ងាយ មិនដឹងទីកន្លែងប្រាកដ គប្បីនិមន្តព្រះសង្ឃដទៃ ឬវិញ្ញូភិក្ខុអង្គណាមួយមកសូមខមាទោស

---

១ អន្តរាយទាំង ៥ គឺ កម្មន្តរាយ ១, កិលេសន្តរាយ ១, វិបាកន្តរាយ ១, ឧបវាទន្តរាយ ១, អាណាវីតិក្កមន្តរាយ ១ ។ បណ្តាអន្តរាយទាំង ៥ នេះ អនន្តរិយកម្ម ៥ ហៅថា កម្មន្តរាយ, និយតមិច្ឆាទិដ្ឋិ ហៅថា កិលេសន្តរាយ, ធម៌ដែលឲ្យបដិសន្ធិជាមនុស្សខ្ទើយ ជាតិរច្ឆាន ជាមនុស្សមានភេទពីរ (ឧភតោព្យញ្ជនក) ហៅថា វិបាកន្តរាយ, អរិយុបវាទកកម្ម ហៅថា ឧបវាទន្តរាយ អាបត្តិដែលត្រូវដោយចេតនាក្លែងហៅថា អាណាវីតិក្កមន្តរាយ ។ ធម៌ទាំង ៥ នេះ អាចញុំាងអ្នកប្រព្រឹត្តកន្លងឲ្យវិនាសចាកមគ្គផល ឃាំងឋានសួគ៌និព្វាន ក្នុងជាតិបន្ទាប់ខាងមុខនោះ ។

ក៏បាន, ពុំនោះសោត បើភិក្ខុរូបនោះនិព្វានទៅហើយ, សុគតហើយ គប្បីទៅសូមខមាទោសនៅទីដែលបរិនិព្វាន ដែលសុគតនោះ ឬនៅកន្លែងដែលតម្កល់អដ្ឋិធាតុរបស់លោកក៏បាន គង់រួចចាកទោសដូចគ្នា កម្មនោះនឹងក្លាយទៅជាអហោសិកម្ម សាបសូន្យរលត់រលាយបាត់បង់ទៅ ។

កាលបើបុគ្គលអ្នកប្រព្រឹត្តល្មើសបានធ្វើដូច្នេះ នោះសេចក្តីចម្រើននឹងកើតមានឡើងវិញ ព្រោះព្រះបរមគ្រូទ្រង់ត្រាស់សម្តែងក្នុងអម្ពលដ្ឋិករាហុលោវាទសូត្រប្រារព្ធព្រះរាហុលថេរថា : **សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ ទេសេតព្វំ ឧត្តានី កាតព្វំ បកាសិតព្វំ ។**

សេចក្តីថា ម្នាលរាហុល អ្នកគប្បីឧស្សាហ៍ពិចារណាមើល កាយកម្ម វចីកម្ម និងមនោកម្ម ដែលអ្នកបានធ្វើហើយរឿយៗ បើឃើញថាកម្មណាជាកម្មមិនគួរ មិនត្រូវ, អ្នកបានភ្លាំងភ្លាត់ដោយសេចក្តីប្រមាទហើយ, កុំគប្បីលាក់ទោសទុក គប្បីសម្តែងបង្ហាញប្រកាសប្រាប់នូវកម្មនោះក្នុងសម្នាក់ព្រះសាស្តាក្តី, វិញ្ញូជនទាំងឡាយក្តី, សព្រហ្មចារីបុគ្គលក្តី កុំបីខាន, បើអ្នកបានធ្វើដូច្នេះហើយ សេចក្តីចម្រើននឹងកើតមានឡើងដល់អ្នក ។

ន័យមួយទៀត, ទ្រង់ត្រាស់សម្តែងចំពោះភិក្ខុទាំងឡាយថា :

**វុឌ្ឍិហេសោ ភិក្ខវេ អរិយស្ស វិនយេ អច្ចយំ អច្ចយតោ**

**ជិស្វា, យថាធម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតិ**

*សេចក្តីថា ម្នាលភិក្ខុទាំងឡាយ រីសេចក្តីចម្រើន ក្នុងអរិយវិន័យ គឺព្រះពុទ្ធសាសនានេះ បានដល់កិរិយាដែលបុគ្គលធ្វើខុសហើយ ឃើញនូវកំហុសនោះថាជាការខុសពិត, ហើយសម្តែងទោសនោះរួសរាន់ មិនរំលងសេចក្តីប្រតិបត្តិ[១] ក្នុងធម៌វិន័យ, ហើយតាំងសង្រួមជាថ្មី ដើម្បីឈប់ធ្វើ (អំពើនោះ) តទៅទៀត ។ ទើបទ្រង់ត្រាស់ប្រៀបធៀបតទៅទៀតថា ដូចជាសក់និងសំពត់ដែលឆេះភ្លើងព្រោះអាស្រ័យសេចក្តីប្រហែសធ្វេស, បើសាមីជនដឹងខ្លួនទាន់ប្រញាប់រវៀសរវៃលត់ភ្លាមៗ នឹងឆេះតែបន្តិចបន្តួច មិនយូរប៉ុន្មានសក់នោះនឹងដុះដូចដើមវិញដដែល, សំពត់នោះដុលស្រេះហើយ គង់ល្អគួរប្រើប្រាស់តទៅទៀតបានដូចមុន ។*

*ហេតុនោះ ពុទ្ធបរិស័ទណាមួយទោះជាគ្រហស្ថក្តី បព្វជិតក្តី កាលបើដឹងថាខ្លួនមានទោសហើយ គប្បីប្រតិបត្តិតាមពុទ្ធោវាទនេះ ទើបឈ្មោះថាមានខ្លួនបរិសុទ្ធ ។*

## អានិសង្សនៃការបម្រើសង្ឃានុស្សតិ

*កាលបើព្រះយោគីចម្រើននូវគុណនៃព្រះសង្ឃមានសុប្បដិបន្នោជាដើម*

---

១- ពាក្យនេះ លោកសំដៅត្រង់សម្តែងអាការលុតក្រាបចំពោះមុខភិក្ខុណាមួយ តាមវិស្សាសាចាស់ខ្ចីប៉ុណ្ណោះ ។

សម័យនោះឯង ចិត្តរបស់លោកនឹងមិនប្រឫកប្រឫល់ដោយរាគៈ ទោសៈ និង មោហៈ ចិត្តរបស់លោករមែងជាធម្មជាតត្រង់ ប្រារព្ធយកសង្ឃគុណជាអារម្មណ៍, អង្គឈានទាំងឡាយ រមែងកើតឡើងក្នុងខណៈដែលសង្កត់សង្កិននីវរណៈបានហើយ ។ តែព្រោះហេតុ ព្រះសង្ឃគុណជាគុណជាតជ្រាលជ្រៅផង, ចិត្តដែលបង្អោននឹកទៅក្នុងគុណមានប្រការផ្សេងៗ ផងទើបព្រះយោគីមិនបាននូវអប្បនា បានត្រឹមតែឧបចារជ្ឈានប៉ុណ្ណោះ ។

ឯព្រះយោគី អ្នកប្រកបសេចក្តីព្យាយាមចម្រើនសង្ឃានុស្សតិនេះ រមែងជាអ្នកមានសេចក្តីគោរពកោតក្រែង ក្នុងព្រះសង្ឃ នឹងបានពេញពោរដោយគុណ មានសទ្ធាជាដើម, ច្រើនមានសេចក្តីរីករាយក្នុងចិត្ត, ជាអ្នកអាចអត់ធន់នូវភ័យនិងពៀរ, អាចអត់ទ្រាំបាននូវសេចក្តីទុក្ខ, រមែងបាននូវសំវាសសញ្ញា គឺសេចក្តីសម្គាល់ថា បាននៅរួមជាមួយព្រះសង្ឃ, សូម្បីសរីរៈរបស់លោក ដែលជាទីអប់រំ នៃសង្ឃានុស្សតិ រមែងគួរដល់គ្រឿងបូជា, ហាក់ដូចជារោងឧបោសថ ដែលមានព្រះសង្ឃប្រជុំគ្នាហើយ, ចិត្ត (របស់លោក) រមែងបង្អោនទៅដើម្បីបានលុះនូវគុណនៃព្រះសង្ឃ, កាលបើចួបប្រទះវត្ថុជាហេតុឲ្យប្រព្រឹត្តកន្លង ក៏ ហិរិនិងឱត្តប្បៈរមែងកើតឡើងប្រាកដដល់លោក, ហាក់ដូចបានឃើញព្រះសង្ឃក្នុងទីចំពោះមុខ (មិនអាចនឹងហ៊ានប្រព្រឹត្តកន្លងបាន) ។

**ឧត្តរឹ អប្បដិវិជ្ឈន្តោ បរេ សុគតិបរាយនោ ហោតិ**

*បើទុកណាជាលោកពុំទាន់បានលុះ នូវគុណដ៏ឧត្តុង្គឧត្តម (ក្នុងជាតិនេះ) នៅឡើយទេ ក៏គង់បានសុគតិប្រព្រឹត្តទៅខាងមុខពុំខាន ។*

*ព្រោះហេតុនោះឯង អ្នកមានប្រាជ្ញាល្អ*

*គប្បីធ្វើនូវសេចក្ដីមិនប្រមាទ ក្នុងសង្ឃានុស្សតិ*

*ដែលមានមហានុភាពយ៉ាងនេះសព្វៗកាល*

*ទៅហោង!*